កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់

*Researching and Understanding on Legal Law Program*

Website: www.lorkremlaw.wordpress.com

Tel: **012855668 / 069255525**

Address: #42Eoz, St19, Chey Chumneah Commune, Doun Penh District, Phnom Penh, Cambodia


# ក្រមបទសម្ភាសន៍
# ស្តីពីការបកស្រាយច្បាប់


**ចងក្រងដោយលោក ឡោ ក្រឹម**



**រាជធានីភ្នំពេញ - ឆ្នាំ២០១៥**

## អារម្ភកថា

សៀវភៅស្តីពី "**កម្រងបទសម្ភាសន៍ស្តីពីការបកស្រាយច្បាប់**" គឺសៀវភៅមួយដែលបានចងក្រងនូវបទសម្ភាសន៍ដកស្រង់ចេញពីបណ្តាអត្ថបទ និងគេហទំព័រកាសែត វិទ្យុ ទស្សនាវដ្តី ពីសំណាក់វាគ្មិនល្បីៗសម្បូរទៅដោយចំណេះដឹង បទពិសោធន៍នៅក្នុងជំនាញវិជ្ជាជីវៈ។ ការបកស្រាយច្បាប់ពីសំណាក់វាគ្មិននេះ នឹងអាចឲ្យអ្នកសិក្សាស្រាវជ្រាវយល់ដឹងកាន់តែច្បាស់ទាក់ទងនឹងប្រធានបទដែលវាគ្មិនបានធ្វើការបកស្រាយ បន្ថែមពីលើអត្ថបទច្បាប់ដែលអ្នកធ្លាប់បានសិក្សាក្នុងរយៈពេលកន្លងមក។

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ ខ្ញុំបាទគ្មានគោលបំណងរំលោភកម្មសិទ្ធិបញ្ញារបស់អ្នកដទៃឡើយ ដោយមានគោលបំណងតែមួយគត់ គឺចង់ចែករំលែកឯកសារទាំងនេះឲ្យអ្នកសិក្សាស្រាវជ្រាវដទៃទៀតទទួលបានអត្ថប្រយោជន៍ពីអត្ថបទរបស់អ្នកដែលខ្ញុំបានដកស្រង់ ដើម្បីងាយស្រួលយកមកធ្វើការសិក្សារៀនសូត្រទទួលបាននូវពុទ្ធិចំណេះនៅក្នុងការរស់នៅជីវភាពប្រចាំថ្ងៃក្នុងសង្គម។

ខ្ញុំក៏សូមអភ័យទោសផងដែរ នូវរាល់កង្វះខាត ឬមានប្រការលើសលស់ទាំងឡាយដែលកើតមាននៅក្នុងសៀវភៅនេះ ដោយខ្ញុំរង់ចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់លោកអ្នកគ្រប់វិនាទី។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឡោ គ្រឹម** ជានិស្សិតច្បាប់ និងជាស្ថាបនិក **កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់** ដែលមានអាសយដ្ឋាន www.lorkremlaw.wordpress.com សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- លោកឪពុក **ឡោ លិញ** និង អ្នកម្តាយ **ឡាន នៅ** ដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាង ទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឲ្យកូនបានសិក្សារៀនសូត្រ
- លោកតា-លោកយាយ អ៊ំប្រុស-អ៊ំស្រី ឪពុកមា-ម្តាយមីង បងប្រុស-បងស្រី ប្អូនប្រុស-ប្អូនស្រី និងញាតិមិត្តទាំងឡាយ ដែលលោកតែងតែផ្តល់កម្លាំងចិត្ត និងផ្តល់នូវដំបូន្មានល្អៗមកដល់រូបខ្ញុំ
- លោកគ្រូ អ្នកគ្រូ ដែលបានបង្ហាត់បង្រៀនខ្ញុំបាទតាំងតូចរហូតដល់បច្ចុប្បន្ននេះ
- អ្នកនិពន្ធ និងអ្នកប្រាជ្ញ ព្រមទាំងបណ្តាម្ចាស់គេហទំព័រ កាសែត ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ នានា ដែលខ្ញុំបានធ្លាប់បានដកស្រង់អត្ថបទស្នាដៃរបស់លោកយកមកចងក្រងជាសៀវភៅ។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងអំពីខ្ញុំបាទ។

ជាទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនដល់លោកអ្នក សូមបានប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំង **បួន** ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥**

ហត្ថលេខា

**ឡោ គ្រឹម**

# មាតិកា


| ចំណងជើង | វាគ្មិន | ទំព័រ |
|---|---|---|
| អារម្ភកថា | | i |
| សេចក្តីថ្លែងអំណរគុណ | | ii |
| មាតិកា | | ii |
| ផ្នែកទី១ អ្វីជាបណ្តឹងរដ្ឋប្បវេណី និងធ្វើឡើងនៅពេលណា? | លោកមេធាវី អ៊ីវ ប៉ូលី | ១ |
| ផ្នែកទី២ នីតិវិធីបន្ទាន់នៃការធ្វើបណ្តឹងព្រហ្មទណ្ឌ | លោកមេធាវី គង់ ទីលីន | ៤ |
| ផ្នែកទី៣ អ្វីទៅជាការទទួលខុសត្រូវព្រហ្មទណ្ឌ? | លោកសាស្ត្រាចារ្យ ជួក សំនឿន | ៧ |
| ផ្នែកទី៤ ស្វែងយល់ពីទោសនិងបទល្មើសព្រហ្មទណ្ឌ | លោកសាស្ត្រាចារ្យ ឌឹម ចាន់ថន | ៩ |
| ផ្នែកទី៥ អាជ្ញាយុកាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ | លោកមេធាវី មឿន សុវណ្ណ | ១២ |
| ផ្នែកទី៦ អ្វីទៅជាបណ្តឹងអាជ្ញា ពាក់ព័ន្ធនឹងបញ្ហាអ្វី ធ្វើនៅពេលណា? | លោកមេធាវី ឡាច សំរោង | ១៥ |
| ផ្នែកទី៧ តួនាទីនិងសិទ្ធិអំណាចរបស់អយ្យការ និងមហាអយ្យការ | លោកមេធាវី គង់ ទីលីន | ១៧ |
| ផ្នែកទី៨ បណ្តឹងរដ្ឋប្បវេណី និងសាលក្រមរដ្ឋប្បវេណី | លោកមេធាវី អ៊ីវ ប៉ូលី | ១៩ |
| ផ្នែកទី៩ អ្វីទៅការជំនុំជម្រះមុនអង្គសេចក្តី | លោកមេធាវី សុក សំអឿន | ២១ |
| ផ្នែកទី១០ ស្វែងយល់ពីការស្នើសុំលើកលែងទោសរបស់ទណ្ឌិត | លោកមេធាវី ផែង ហេង | ២៣ |
| ផ្នែកទី១១ ហេតុអ្វីច្បាប់តម្រូវឲ្យមានការព្យួរទោស? | លោកមេធាវី ឡុង ដារ៉ា | ២៥ |
| ផ្នែកទី១២ អ្វីជាការស្រូបទោសដែលច្បាប់បានបញ្ញត្តិ | លោកមេធាវី ឡុង ដារ៉ា | ២៩ |
| ផ្នែកទី១៣ ចៅក្រមចេញសាលក្រមចាត់របៀបពេលណា? | លោកមេធាវី មួង សុគន្ធ | ៣១ |
| ផ្នែកទី១៤ បណ្តាំមរតកត្រូវធ្វើស្របតាមទម្រង់ច្បាប់ | លោកមេធាវី ពិន វណ្ណៈ | ៣៣ |
| ផ្នែកទី១៥ ដីការក្សាការពារនិងប្រសិទ្ធភាពក្នុងច្បាប់ | លោកបណ្ឌិត ឡុង ដារ៉ា | ៣៥ |
| ផ្នែកទី១៦ វិធានការច្បាប់សម្រាប់ការល្មើសនឹងដីការក្សាការពារ | លោកបណ្ឌិត ឡុង ដារ៉ា | ៣៧ |
| ផ្នែកទី១៧ បណ្តឹងអាជ្ញា និងកម្មវត្ថុនៃបណ្តឹងអាជ្ញា | លោកមេធាវី ឡាច សំរោង | ៤០ |
| ផ្នែកទី១៨ ការដកហូត រក្សាទុក ប្រើប្រាស់វត្ថុតាងរបស់ជនល្មើសជនជាប់ចោទ | លោកមេធាវី មួង សុគន្ធ | ៤៣ |
| ផ្នែកទី១៩ បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ និងបណ្តឹងសើរើ | លោក ឡោ គីមហ៊ុច | ៤៥ |
| ផ្នែកទី២០ ដីកា ការចេញដីកា និងអនុវត្តដីកាក្នុងផ្នែកតុលាការ | លោកមេធាវី សេង រ៉ុន | ៤៨ |
| ផ្នែកទី២១ តួនាទីសិទ្ធិអំណាចរបស់អង្គការអយ្យការ ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា(ភាគ១) | លោកមេធាវី គង់ ទីលីន | ៥១ |

| | | |
|---|---|---|
| ផ្នែកទី២២ តួនាទីសិទ្ធិអំណាចរបស់អង្គការអយ្យការ ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា(ភាគ២) | លោកមេធាវី គង់ ទីលីន | ៥៣ |
| ផ្នែកទី២៣ អ្វីទៅជាតួនាទីនិងភារកិច្ចក្រឡាបញ្ជីនៅក្នុងរឿងក្តី? | លោកមេធាវី ឡោ គីមហ៊្គិច | ៥៥ |
| ផ្នែកទី២៤ ការជំនុំជម្រះនិងការប្រកាសសាលក្រមរបស់តុលាការ | លោកមេធាវី ហ៊ាង ហុង | ៥៧ |
| ផ្នែកទី២៥ ការដាក់ជនជាប់ចោទក្រោមការត្រួតពិនិត្យរបស់តុលាការ | លោកមេធាវី សុក សំអឿន | ៥៩ |
| ផ្នែកទី២៦ ភារកិច្ចក្រឡាបញ្ជីនៅជំណាក់ថៅក្រមជំនុំជម្រះ | លោកមេធាវី ឡោ គីមហ្គេច | ៦១ |
| ផ្នែកទី២៧ បទល្មើសព្រហ្មទណ្ឌ និងការសម្រុះសម្រួលក្រៅប្រព័ន្ធច្បាប់ | លោក មេធាវី សេង រ៉ុន | ៦២ |
| ផ្នែកទី២៨ វិសមិតភាព ប្រើក្នុងតុលាការមានន័យដូចម្តេច?(ភាគ១) | លោកមេធាវី ឡុង ដារ៉ា | ៦៥ |
| ផ្នែកទី២៩ វិសមិតភាព ប្រើក្នុងតុលាការមានន័យដូចម្តេច?(ភាគ២) | លោកមេធាវី ឡុង ដារ៉ា | ៦៧ |
| ផ្នែកទី៣០ កិច្ចសន្យាការងារស្របច្បាប់របស់កម្មករនិយោជិត | លោកមេធាវី លី ច័ន្ទតុលា | ៦៨ |
| ផ្នែកទី៣១ ផ្អែកលើខ្លឹមសារច្បាប់ការងារជុំវិញការកំណត់ប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិត | លោកមេធាវី លី ច័ន្ទតុលា | ៧០ |
| ផ្នែកទី៣២ ភាពខុសគ្នានៃដីកាបង្គាប់ឲ្យចូលខ្លួននិងដីកាឲ្យនាំខ្លួន | លោកមេធាវី ផែង ហេង | ៧២ |
| ផ្នែកទី៣៣ ការដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យពីតុលាការ | លោកមេធាវី ផែង ហេង | ៧៤ |
| ផ្នែកទី៣៤ តើអ្វីទៅជាសិទ្ធិខាងរូបភាពនៃបុគ្គល? | លោក សេង ឌីណា | ៧៦ |
| ផ្នែកទី៣៥ ការទទួលខុសត្រូវចំពោះខ្លឹមសារដែលចុះផ្សាយលើប្រព័ន្ធអ៊ីនធ័រនែត | លោក សេង ឌីណា | ៧៨ |
| ផ្នែកទី៣៦ ករណីលក់អចលនវត្ថុដែលជាប់សិទ្ធិហើយប៉ុន្តែកមិនទាន់ជម្រះ | លោក សេង ឌីណា | ៨១ |
| ផ្នែកទី៣៧ ការទិញ/លក់អចលនវត្ថុ៖ តើត្រូវធ្វើយ៉ាងណា ដើម្បីជៀសវាងវិវាទ | លោកមេធាវី ប៊ុន យូឌី | ៨៣ |
| ផ្នែកទី៣៨ ស្វែងយល់អំពីកិច្ចសន្យាទិញលក់ក្នុងក្រមរដ្ឋប្បវេណីខ្មែរ | លោក សេង ឌីណា | ៨៦ |
| ផ្នែកទី៣៩ អំពីសិទ្ធិ កាតព្វកិច្ច និងទម្រង់នៃកិច្ចសន្យាជួលផ្ទះ ឬដីធ្លី | លោក សេង ឌីណា | ៨៩ |
| ផ្នែកទី៤០ ក្រមរដ្ឋប្បវេណី៖ ការដាក់ទ្រព្យជានាកាតព្វកិច្ចលើបំណុល | លោក សេង ឌីណា | ៩២ |
| ផ្នែកទី៤១ នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ | លោក សេង ឌីណា | ៩៥ |
| ផ្នែកទី៤២ នីតិវិធីក្នុងការសុំប័ណ្ណកាន់កាប់ដីធ្លី | លោក សេង ឌីណា | ៩៧ |
| ផ្នែកទី៤៣ តើម្ចាស់ដីអាចបិទផ្លូវឯកជនដែលខ្លួនធ្វើកាត់តាមដីរបស់ខ្លួនមិនឲ្យអ្នកជិតខាងឆ្លងកាត់បានដែរ ឬទេ? | លោក សេង ឌីណា | ៩៩ |
| ផ្នែកទី៤៤ សិទ្ធិ និងករណីយកិច្ចនៃម្ចាស់ដីដែលមានព្រំប្រទល់ជាប់គ្នា | លោក សេង ឌីណា | ១០១ |
| ផ្នែកទី៤៥ ឆ្លើយនឹងសំណួរអ្នកស្តាប់ជុំវិញកិច្ចសន្យាជួលអចលនវត្ថុ | លោក សេង ឌីណា | ១០៥ |
| ផ្នែកទី៤៦ ការកាន់កាប់អចលនវត្ថុដោយគ្មានប័ណ្ណកម្មសិទ្ធិ | លោកបណ្ឌិត ហ៊ែល ចំរើន | ១០៧ |
| ផ្នែកទី៤៧ សម្បទានដីសង្គមកិច្ច | លោកបណ្ឌិត ហ៊ែល ចំរើន | ១០៩ |

| | | |
|---|---|---|
| ផ្នែកទី៤៨ កិច្ចសន្យាសម្បទាន និងតំបន់សេដ្ឋកិច្ចពិសេស | ? | ១១១ |
| ផ្នែកទី៤៩ នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ | លោក ខាត់ ណារិទ្ធ | ១១២ |
| ផ្នែកទី៥០ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋបរទេស | លោក សេង ឌីណា | ១១៤ |
| ផ្នែកទី៥១ អំពីបែបបទនៃការសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត | លោក សេង ឌីណា | ១១៧ |
| ផ្នែកទី៥២ ក្នុងករណីឪពុកម្ដាយលែងលះគ្នា តើកូនត្រូវបានទៅខាងណាជាអ្នកគ្រប់គ្រង ? | លោក សេង ឌីណា | ១២០ |
| ផ្នែកទី៥៣ ឆ្លើយនឹងសំណួររបស់អ្នកស្តាប់ជុំវិញការលែងលះ | លោក សេង ឌីណា | ១២៣ |
| ផ្នែកទី៥៤ តើច្បាប់ខ្មែរចែងពីលក្ខខណ្ឌអ្វីខ្លះស្តីពីការសុំកូនទៅចិញ្ចឹមនៅបរទេស ? | លោក សេង ឌីណា | ១២៥ |
| ផ្នែកទី៥៥ ការគ្រប់គ្រង ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ | លោក សេង ឌីណា | ១២៧ |
| ផ្នែកទី៥៦ ក្រមរដ្ឋប្បវេណី ៖ អំពីរបៀបបែងចែកកេរមរតក | លោក សេង ឌីណា | ១២៩ |
| ផ្នែកទី៥៧ នីតិវិធីក្នុងការសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | លោក សេង ឌីណា | ១៣១ |
| ផ្នែកទី៥៨ អាណិកជនខ្មែរនៅបរទេសមានសិទ្ធិអ្វីខ្លះ ? | លោក សេង ឌីណា | ១៣៣ |
| ផ្នែកទី៥៩ តើសញ្ជាតិខ្មែរត្រូវផ្ដល់ឲ្យក្នុងលក្ខខណ្ឌណាខ្លះ ? | លោក សេង ឌីណា | ១៣៥ |
| ផ្នែកទី៦០ ច្បាប់ការងារ ៖ អំពីថិរវេលាការងារ និងការឈប់សម្រាក | លោក សេង ឌីណា | ១៣៨ |
| ផ្នែកទី៦១ អំពីសិទ្ធិ និងនីតិវិធីនៃការធ្វើកូដកម្មរបស់កម្មករនិយោជិត | លោក សេង ឌីណា | ១៤១ |
| ផ្នែកទី៦២ អ្វីខ្លះជាគុណសម្បត្តិ និងគុណវិបត្តិនៃការងារមាននិងគ្មានកិច្ចសន្យាត្រឹមត្រូវ ? | លោក គី សុខលីម | ១៤៣ |
| ផ្នែកទី៦៣ អំពីការបញ្ឈប់ការងារកម្មករនិយោជិត | លោក សេង ឌីណា | ១៤៥ |
| ផ្នែកទី៦៤ ការរក្សាសិទ្ធិ ៖ តើអ្នកនិពន្ធស្នាដៃទទួលបានការការពារបែបណាខ្លះ ? | លោក សេង ឌីណា | ១៤៨ |
| ផ្នែកទី៦៥ ដើម្បីទទួលបាននូវការរក្សាសិទ្ធិ តើចាំបាច់ត្រូវដាក់និមិត្តសញ្ញា "© រក្សាសិទ្ធិ" ឬទេ ? | លោក សេង ឌីណា | ១៥១ |
| ផ្នែកទី៦៦ វិសាលភាពនៃដែនអនុវត្តក្រមព្រហ្មទណ្ឌខ្មែរ | លោក សេង ឌីណា | ១៥៣ |
| ផ្នែកទី៦៧ ក្រមព្រហ្មទណ្ឌខ្មែរ ៖ ប្រភេទនៃទោសព្រហ្មទណ្ឌ និងការអនុវត្ត | លោក សេង ឌីណា | ១៥៦ |
| ផ្នែកទី៦៨ ចំណាត់ថ្នាក់បទល្មើស អាជ្ញាយុកាល និងអាជ្ញាអស់ជំនុំ នៅក្នុងច្បាប់ព្រហ្មទណ្ឌខ្មែរ | លោក សេង ឌីណា | ១៥៩ |
| ផ្នែកទី៦៩ នីតិព្រហ្មទណ្ឌ ៖ តើអ្វីទៅជាការព្យួរទោស ? អ្វីទៅជារបបពាក់កណ្ដាលសេរីភាព ? | លោក សេង ឌីណា | ១៦២ |
| ផ្នែកទី៧០ លក្ខណៈខុសគ្នារវាងបទឃាតកម្ម ឃាតកម្មគិតទុកជាមុន និងមនុស្សឃាតដោយអចេតនា | លោក សេង ឌីណា | ១៦៥ |
| ផ្នែកទី៧១ តើក្នុងករណីណាខ្លះដែលអ្នកប្រព្រឹត្តអំពើល្មើសអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ? | លោក សេង ឌីណា | ១៦៨ |
| ផ្នែកទី៧២ តើបុគ្គលឯកជនអាចប្ដឹងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិក្រុងឡាអេបានដែរឬទេ ? | លោក សេង ឌីណា | ១៧១ |

# ផ្នែកទី១

## អ្វីជាបណ្ដឹងរដ្ឋប្បវេណី និងធ្វើឡើងនៅពេលណា?

លោកមេធាវី អ៊ីវ ប៉ូលី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

បណ្ដឹងរដ្ឋប្បវេណី គឺជាការអនុវត្តសិទ្ធិតាមផ្លូវតុលាការ ចំពោះភាគីដែលមានសិទ្ធិ ឬនឹងអាចទទួលបានសិទ្ធិនេះតាមផ្លូវច្បាប់ ដោយអនុវត្តសិទ្ធិនេះតាមផ្លូវតុលាការ។ ដើម្បីយល់កាន់តែច្បាស់ពីបណ្ដឹងនេះ លោកមេធាវី អ៊ីវ ប៉ូលី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់កិច្ចសម្ភាសន៍ និងធ្វើការបកស្រាយតាមខ្លឹមសារច្បាប់អំពីបណ្ដឹងរដ្ឋប្បវេណីនេះ ដែលមានខ្លឹមសារដូចខាងក្រោម៖

**១.តើបណ្ដឹងរដ្ឋប្បវេណីមានប៉ុន្មានប្រភេទ?**

ប្រសិនបើយើងសង្កេត បណ្ដឹងរដ្ឋប្បវេណីនៅក្នុងន័យច្បាប់ យើងអាចបែងចែកជា ៣ ប្រភេទ គឺបណ្ដឹងទាមទារតាវកលិក បណ្ដឹងទាមទារបញ្ជាក់ពីអត្ថិភាព ឬអត្ថិភាពនៃសិទ្ធិ បណ្ដឹងទាមទារឲ្យបង្កើតការកែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្តិ។ ក្រៅពីបណ្ដឹងទាំង ៣ ប្រភេទនេះ យើងឃើញបណ្ដឹងមួយទៀត ដែលហៅថា បណ្ដឹងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

- បើសង្កេតឲ្យងាយយល់ពីខ្លឹមសារនេះ បណ្ដឹងទាមទារតាវកលិក គឺជាបណ្ដឹងទាមទារឲ្យធ្វើសកម្មភាពជាសម្ងាត់មួយ បណ្ដឹងទាមទារមិនឲ្យធ្វើសកម្មភាពជាសម្ងាត់មួយ និងបណ្ដឹងទាមទារឲ្យបុគ្គលដែលអាចបុគ្គលចលនវត្ថុ ឬបុគ្គលអចលនវត្ថុ។ ជាឧទាហរណ៍ៈ បណ្ដឹងទាមទារឲ្យប្រគល់ប្រាក់ និងទាមទារឲ្យប្រគល់អចលនវត្ថុ បណ្ដឹងទាមទារឲ្យប្រគល់ចលនវត្ថុ...។ បើនិយាយពីការធ្វើសកម្មភាព មានដូចជា បណ្ដឹងទាមទារឲ្យបញ្ឈប់ការរំខានរបស់អ្នកជិតខាង ជាអាទិ៍។
- បើយើងសង្កេត អំពីបណ្ដឹងទាមទារបញ្ជាក់ពីអត្ថិភាព ឬភាពមានសិទ្ធិ គឺសំដៅទៅលើការទាមទារបញ្ជាក់ពីសិទ្ធិរបស់ខ្លួនចំពោះវត្ថុមួយជាក់លាក់ ដូចជា បណ្ដឹងទាមទារបញ្ជាក់ពីវត្ថុរបស់ខ្លួន ខណៈមានការរំខានពីភាគីណាមួយដែលខ្លួនកំពុងតែកាន់កាប់ និងជានាសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ គឺបុគ្គលនោះអាចធ្វើបណ្ដឹងនេះដើម្បីបញ្ជាក់ពីកម្មសិទ្ធិ ខ្លួនតាមផ្លូវតុលាការ។
- ប្រសិនបើយើងនិយាយអំពីបណ្ដឹងទាមទារបង្កើតការកែប្រែ ឬរំលត់ ឬបង្កើតនូវទំនាក់ទំនងគតិយុត្តិ ឧទាហរណ៍ៈ បណ្ដឹងលែងលះ បណ្ដឹងលុបចោលអាពាហ៍ពិពាហ៍ និងបណ្ដឹងមោឃភាពអាពាហ៍ពិពាហ៍ជាអាទិ៍។ នេះគឺសុទ្ធតែជាបណ្ដឹងដែលកើតពីសកម្មភាពនៃបណ្ដឹងដែលកើតមានជាញឹកញាប់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។
- ក្រៅពីនេះនៅមានបណ្ដឹងមួយប្រភេទទៀតហៅថា បណ្ដឹងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង មានការដាក់ពាក្យសុំបង្កើតរបបសុំកូន ការដាក់ពាក្យសុំបង្កើតអាណាព្យាបាលទូទៅ ការដាក់ពាក្យសុំបង្កើតអាណាព្យាបាលសម្រាប់អនីតិជន និងការដាក់ពាក្យសុំប្រកាសការបាត់ខ្លួន ជាអាទិ៍ ទាំងនេះ ហៅថា បណ្ដឹងរដ្ឋប្បវេណីដែលមិនមែនជាពាក្យបណ្ដឹង។

**២.តើបណ្ដឹងរដ្ឋប្បវេណីប្រភេទណាដែលកើតមានជាញឹកញាប់នៅតុលាការ?**

បើយើងពិនិត្យមើលពីបណ្ដឹងរដ្ឋប្បវេណីដែលកើតមានជាញឹកញាប់ក្នុងសង្គមនាបច្ចុប្បន្ន គឺមានពាក់ព័ន្ធនឹងវិវាទដីធ្លី ពាក់ព័ន្ធនឹងការអះអាងពីកម្មសិទ្ធិ និងបណ្ដឹងដែលពាក់ព័ន្ធនឹងការអនុវត្តខ្លឹមសារនៃកិច្ចសន្យា ដូចជា ការខ្ចីប្រាក់ការធ្វើកិច្ចសន្យាជួលការផ្ទេរប្រាក់ និងកិច្ចសន្យាបញ្ចាំជាដើម។ មួយទៀតក៏យើងឧស្សាហ៍ឃើញដែរ ដូចជា ពាក់ព័ន្ធនឹងការលែងលះ ការគ្រប់គ្រងកូន និងការបែងចែកទ្រព្យរួម។

**៣.តើត្រូវដោះស្រាយដូចម្តេចនៅពេលដែលមានបញ្ហានេះកើតឡើង?**

នៅពេលមានបញ្ហាទាំងនេះកើតឡើង អ្វីដែលភាគីវិវាទគួរយល់ដឹង គឺសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយច្បាប់របស់ភាគី។ នៅពេលដែលភាគីយល់ដឹងពីសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ មានន័យថា ភាគីបានយល់អំពីអ្វីដែលខ្លួនឯងធ្វើបានក្នុងកម្រិតដែលច្បាប់ទទួលស្គាល់។ ការយល់ដឹងពីខ្លឹមសារនៃសិទ្ធិច្បាប់ គឺមានសារៈសំខាន់ណាស់។ ភាគីខ្លះមិនមានការយល់ច្បាស់ពីច្បាប់នេះហេតុនេះគប្បីទទួលការពិគ្រោះយោបល់ជាមួយអ្នកដែលមានជំនាញផ្នែកច្បាប់នេះ ឬអ្នកយល់ដឹងពីច្បាប់មាន មេក្រុម មេភូមិ មេឃុំ ជាដើម។ មេធាវី គណៈមេធាវី ឬសេវាកម្មច្បាប់មួយអាចជួយផ្តល់យោបល់ផ្នែកផ្លូវច្បាប់ចំពោះបុគ្គលទាំងនោះបាន។ ដូច្នេះ នៅពេលដែលគាត់យល់ពីខ្លឹមសារនៃសិទ្ធិនេះហើយ គាត់អាចអនុវត្តសិទ្ធិរបស់គាត់បានត្រឹមត្រូវ ឬគាត់អាចអនុវត្តសិទ្ធិ តាមផ្លូវតុលាការ ខណៈមានការបំពានសិទ្ធិ ឬមានការរំលោភបំពាននៅតែបន្ត។

**៤.តើមេធាវីមានតួនាទីដូចម្តេចខ្លះដែរនៅក្នុងបណ្តឹងរដ្ឋប្បវេណីនេះ?**

មេធាវីមានតួនាទីសកម្មបំផុតនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ មេធាវី ជាអ្នកធ្វើសកម្មភាពរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងបណ្តឹង។ មេធាវីអាចជាអ្នកដាក់ពាក្យបណ្តឹង អាចជាអ្នករៀបចំឯកសារមេធាវីជាអ្នកឆ្លើយដោះសារឆ្លើយការពារ ឬជាអ្នកផ្តល់យោបល់តាមផ្លូវច្បាប់ ដើម្បីឲ្យភាគីយល់ដឹងពីខ្លឹមសារច្បាប់នោះបានច្បាស់លាស់។ មេធាវីជាអ្នកបង្ហាញផ្លូវ ដើម្បីឲ្យភាគីអនុវត្តសិទ្ធិនោះពេញលេញ ត្រឹមត្រូវ មានភាពសុចរិត ចំពោះបណ្តឹងរបស់ខ្លួន។

**៥.ជាឧទាហរណ៍មួយប្រសិនអ្នកខ្ចីប្រាក់មិនព្រមសងតើម្ចាស់បំណុលគួរធ្វើដូចម្តេច?**

ប្រសិនបើមានករណីការខ្ចីបុលកើតឡើងហើយម្ចាស់បំណុលមិនសងតាមកំណត់ទេ ជំហាន ទី១ ដែលម្ចាស់បំណុលត្រូវធ្វើ គឺដាស់តឿន និងកំណត់ពេលសងជាថ្មី ដែលអាចមានមួយសប្តាហ៍ ឬ១០ថ្ងៃ ជាដើម។ បើកូនបំណុលហាក់គ្មានឆន្ទៈសងហើយមានការបំពានកាន់តែងខ្លាំងពេលនោះយើងអាចពិគ្រោះជាមួយអ្នកច្បាប់ ដើម្បីធ្វើវិធានការបន្ត។ ដូចជា ការប្តឹងទៅតុលាការជាដើម ហើយជាទូទៅអ្នកច្បាប់តែងផ្តល់យោបល់ទៅម្ចាស់បំណុល ពីចំនួនសង ឬកូនបំណុលមានទ្រព្យសម្បត្តិលក់ឡៃឡុងតាមផ្លូវតុលាការដើម្បីសម្រេចសិទ្ធិរបស់ម្ចាស់បំណុលដែរ ឬទេ? ចំណុចនេះមានសារៈសំខាន់ ប្រសិនបើប្តឹងទៅតុលាការហើយ កូនបំណុលគ្មានទ្រព្យសម្បត្តិសងទេ ទោះបីយើងឈ្នះក្តីក៏ដោយ ក៏យើងមិនដឹងថាយកសាលក្រមនោះ ឬយកសេចក្តីសម្រេចរបស់តុលាការទៅអនុវត្តដើម្បីរឹបអូសទ្រព្យសម្បត្តិកូនបំណុលដូចម្តេចដែរ។ មានន័យថា បើកូនបំណុលជំពាក់លុយ ១ម៉ឺនដុល្លារ យើងអាចយល់ដឹងពីទ្រព្យសម្បត្តិរបស់កូនបំណុលមានដូចជា ផ្ទះ ឡាន ឬលុយនៅក្នុងធនាគារជាអាទិ៍វិធានការដែលយើងត្រូវធ្វើមុនគេ គឺពាក់ព័ន្ធជាមួយនឹងប្រព័ន្ធរក្សាការពារ។ ដើម្បីរឹបអូសទ្រព្យរបស់កូនបំណុលទុកជានាសងសិទ្ធិលើបំណុលរបស់យើងនៅពេលដើមបណ្តឹងរបស់យើងបានចប់សព្វគ្រប់។

**៦.បើសិនជាគេរំលោភកាន់កាប់ដីរបស់យើងតើម្ចាស់ដីត្រូវធ្វើដូចម្តេចដើម្បីការពារ?**

បើមានការរំលោភបំពានលើដីជាកម្មសិទ្ធិស្របច្បាប់ មានរបងត្រឹមត្រូវ និងមានប្លង់កម្មសិទ្ធិជាដើម។ ក្នុងករណីនេះយើងអាចប្រើសិទ្ធិ យើងតាមប្រព័ន្ធតុលាការរដ្ឋប្បវេណី និងតាមប្រព័ន្ធតុលាការព្រហ្មទណ្ឌផងដែរ។ បើយើងសម្លឹងទៅប្រព័ន្ធតុលាការរដ្ឋប្បវេណី យើងអាចឲ្យគេបញ្ឈប់សកម្មភាពរំលោភបំពាននេះ ហើយអាចជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានដូចជាមេភូមិ មេឃុំ ជាដើម។ នៅពេលគ្មានការសម្របសម្រួល ឬមានដែរតែមិនទទួលបានលទ្ធផល វិធានការបន្ទាប់ដែលយើងអនុវត្តគឺការយល់ដឹងពីខ្លឹមសារច្បាប់ ដែលជាសិទ្ធិរបស់យើងត្រូវបានទទួលស្គាល់ ហើយអ្នកជំនាញច្បាប់គួរតែជាទីប្រឹក្សារបស់យើង។ បន្ទាប់មក យើងអនុវត្តតាមផ្លូវតុលាការ ហើយមេធាវីគឺជាទីប្រឹក្សាដ៏ល្អមួយ។ ភាពច្បាស់លាស់ចំពោះអយ្យការ ភាពច្បាស់លាស់ចំពោះការរៀបចំសិទ្ធិភាពច្បាស់លាស់ចំពោះការអះអាងសិទ្ធិ គឺជាចំណុចនៃភាពជោគជ័យ។

**៧.ក្នុងបណ្តឹងរដ្ឋប្បវេណី តើមេធាវីមានអ្វីកំពុងប្រឈមទេ?**

បញ្ហាប្រឈមជាទូទៅ គឺទី១ ពាក់ព័ន្ធនឹងការអនុវត្តខ្លឹមសារនៃមាត្រាច្បាប់ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីក៏ដូចជា ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ គឺប្រឈមនឹងការបកស្រាយផ្ទុយគ្នាពីបញ្ហាច្បាប់។ បញ្ហា ទី២ គឺការអនុវត្តមិនទាន់បានពេញលេញជាលក្ខណៈទូទៅលើខ្លឹមសារច្បាប់នីមួយៗ មួយទៀតដែលឧស្សាហ៍ជួបប្រទះ គឺពាក់ព័ន្ធនឹងឯកសារដែលជាមូលដ្ឋាននៃភស្តុតាងជាដើមនៅក្នុងការសម្រេចពីសិទ្ធិ។

# ផ្នែកទី២

# នីតិវិធីបន្ទាន់នៃការធ្វើបណ្តឹងព្រហ្មទណ្ឌ

លោក គង់ ទីលីន សមាជិកគណៈមេធាវី និងជាអនុប្រធាននៃអនុក្រុមការងារវិស័យព្រហ្មទណ្ឌ

បណ្តឹងក្នុងរឿងព្រហ្មទណ្ឌ (ឬបណ្តឹងអាជ្ញា) គឺការអនុវត្តសិទ្ធិតាមផ្លូវតុលាការ ចំពោះភាគីដែលមានសិទ្ធិ ឬនឹងអាចទទួលបានសិទ្ធិនេះ តាមផ្លូវច្បាប់ដោយអនុវត្តសិទ្ធិនេះតាមផ្លូវតុលាការ។ ដើម្បីយល់កាន់តែច្បាស់លោកមេធាវី គង់ ទីលីន អត្តលេខ៨៤៧ សមាជិកក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធាននៃអនុក្រុមការងារវិស័យព្រហ្មទណ្ឌ បានបកស្រាយតាមខ្លឹមសារច្បាប់ស្តីអំពីបណ្តឹងព្រហ្មទណ្ឌក្នុងបទសម្ភាសន៍ ដោយឡែកជាមួយ ភ្នំពេញ ប៉ុស្តិ៍ ដែលមានខ្លឹមសារដូចខាងក្រោម៖

**១. តើអ្វីទៅជាបណ្តឹងព្រហ្មទណ្ឌ? ហើយការដាក់ពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌត្រូវធ្វើឡើងយ៉ាងដូចម្តេច? បណ្តឹងមួយៗខុសគ្នាយ៉ាងម៉េចដែរ?**

អនុលោមតាមមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបែងចែកបណ្តឹងជាពីរ គឺបណ្តឹងអាជ្ញា (រឿងព្រហ្មទណ្ឌ) ជាបណ្តឹងដែលមានគោលបំណងពិនិត្យអាទិភាពនៃបទល្មើស បង្ហាញឲ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ បណ្តឹងរដ្ឋប្បវេណី ជាបណ្តឹងដែលមានគោលបំណងធ្វើឲ្យបានការជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះធ្វើឲ្យជនរងគ្រោះបានទទួលនូវសំណងជម្ងឺចិត្តធុនល្មមនឹងព្យសនកម្មដែលខ្លួនទទួល។ ឧទាហរណ៍: ឈ្មោះ «ក» បានប្រើអំពើហិង្សាវាយមកលើឈ្មោះ «ខ» តាមរយៈអំពើល្មើសនេះ ឈ្មោះ «ខ» អាចដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ «ក» លើបណ្តឹងអាជ្ញា ដើម្បីចោទប្រកាន់ពាក់ព័ន្ធបទល្មើសហិង្សាដោយចេតនា ហើយក្នុងនោះ ឈ្មោះ «ខ» អាចប្តឹងទាមទារការខូចខាត ជម្ងឺចិត្ត ដែលជាបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿងពាក់ព័ន្ធអង្គហេតុខាងលើនេះ។

**២. តើយើងត្រូវសរសេរពាក្យបណ្តឹងតាមទម្រង់យ៉ាងដូចម្តេចដើម្បីឲ្យមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់?**

ពាក្យបណ្តឹងក្នុងរឿងព្រហ្មទណ្ឌត្រូវសរសេរដោយទម្រង់មួយដែលត្រូវមាន៖

ក- ឈ្មោះ អត្តសញ្ញាណ មុខរបរ លំនៅរបស់ជនរងគ្រោះ ឬដើមបណ្តឹង

ខ- ស្ថាប័ន ឬអង្គភាព ដែលជនរងគ្រោះ ឬដើមបណ្តឹងត្រូវដាក់បណ្តឹងទៅ

គ- កម្មវត្ថុនៃបណ្តឹងដែលជនរងគ្រោះ ឬដើមបណ្តឹងស្នើសុំពីបទល្មើសដែលជនសង្ស័យប្រព្រឹត្តមកលើខ្លួន ញាតិ ឬក្រុមគ្រួសារ

ឃ- អង្គហេតុដែលកើតឡើងតាំងពីដើមរហូតដល់កើតបទល្មើស ដែលត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ ដើម្បីសមត្ថកិច្ចងាយកំណត់នូវបទល្មើសដែលបានប្រព្រឹត្ត

ង- សំណូមពរ គឺត្រូវស្នើសុំនូវចំណុចពាក់ព័ន្ធ គោលបំណងនៃការធ្វើបណ្តឹង ដែលអាចប្តឹងទាំងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីពីការទាមទារពាក់ព័ន្ធបទល្មើស

ច- ជនរងគ្រោះ ឬដើមបណ្តឹងត្រូវផ្តិតមេដៃស្តាំលើពាក្យបណ្តឹងរបស់ខ្លួន ដែលបានបំពេញតាមចំណុចដូចរៀបរាប់ខាងលើ។

បណ្តឹងក្នុងរឿងព្រហ្មទណ្ឌត្រូវអនុវត្តតាមទម្រង់ខាងលើ ដើម្បីមានលក្ខណៈពេញលេញតាមផ្លូវច្បាប់។ ក៏ប៉ុន្តែ ក្នុងករណីមានបទល្មើសណាមួយកើតឡើង ជនរងគ្រោះ ឬដើមបណ្តឹង ក៏អាចស្នើសុំឲ្យសមត្ថកិច្ចជួយសរសេរពាក្យបណ្តឹង ឬ អាចពឹងមេធាវីឲ្យរៀបចំធ្វើពាក្យបណ្តឹង ដើម្បីការពារផលប្រយោជន៍របស់ខ្លួនបានដែរ។

**២.ចំពោះបណ្តឹងក្នុងរឿងព្រហ្មទណ្ឌដែលមិនត្រឹមត្រូវតាមទម្រង់ តើសមត្ថកិច្ចទទួលចាត់ការដែរ ឬទេ?**

នេះជាសំណួរ ដែលមានសារៈសំខាន់ ដើម្បីឲ្យប្រជាពលរដ្ឋលោកបានជ្រាប ព្រោះថា ដូចដែលបានជំរាបជូនពីទម្រង់នៃការធ្វើបណ្តឹង ក៏ប៉ុន្តែ មិនមានន័យថា ពេលមានបទល្មើសណាមួយកើតឡើង ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីពុំបាន ឬពុំអាចសរសេរបណ្តឹងបាន ហើយសមត្ថកិច្ចពុំទទួលចាត់ការទេ ទោះជាពាក្យបណ្តឹងពុំពេញលេញតាមទម្រង់យ៉ាងណាក៏ដោយជាក់ស្តែងយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៧១ វាក្យខណ្ឌ ទី១ ចែងថា “មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្តឹងទាមទារ ឬបណ្តឹងបរិហារ។ មន្ត្រីនគរបាលយុត្តិធម៌ពិនិត្យបទល្មើសទាំងឡាយ។” មាត្រា ៧២ វាក្យខណ្ឌ ទី១ ចែងថា “គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌តម្រូវឲ្យធ្វើកំណត់ហេតុ” ។ មាត្រា ៧៤ វាក្យខណ្ឌ ទី១ ចែងថា “មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបណ្តឹងនោះ ត្រូវចាប់ផ្តើមភ្លាមៗ ធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ។”

តាមអត្ថន័យមាត្រាខាងលើនេះ សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ លោកត្រូវទទួលចាត់ការរាល់ពាក្យបណ្តឹងទាំងឡាយ ប៉ុន្តែ ក្នុងករណីសរសេរពុំត្រឹមត្រូវតាមទម្រង់សមត្ថកិច្ចអាចណែនាំ ក្នុងការសរសេរ ឬក៏ចង្អុលបង្ហាញឲ្យពឹងពាក់មេធាវីដើម្បីជួយរៀបចំ ក៏ប៉ុន្តែពុំអាចបដិសេធមិនទទួលពាក្យបណ្តឹងបានឡើយ។

**៣.តើអ្នកណាខ្លះដែលអាចធ្វើពាក្យបណ្តឹងបាន ក្នុងករណីមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង?**

ក្នុងករណីនេះជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវ។ ជនរងគ្រោះ គឺរាល់បុគ្គលទាំងឡាយណា ដែលទទួលរងនៅព្យសនកម្មដោយផ្ទាល់ពីបទល្មើសណាមួយមកលើខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាបុគ្គលដែលតំណាងដោយស្របច្បាប់ឲ្យជនរងគ្រោះ។

**៤.នៅពេលដែលមានបទល្មើសណាមួយកើតឡើងតើយើងអាចដាក់ពាក្យបណ្តឹងទៅកន្លែងណាខ្លះ?**

ពេលបទល្មើសកើតឡើង យើងអាចដាក់ពាក្យបណ្តឹងទៅស្ថាប័ន ឬអង្គភាពណាដែលច្បាប់ផ្តល់សម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ (មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដែលវាអាស្រ័យទៅតាមប្រភេទបទល្មើស និងសម្បទារបស់មន្ត្រីនគរបាលយុត្តិធម៌នោះ។ តែជាការងាយស្រួលយើងអាចដាក់បណ្តឹងទៅកាន់មន្ត្រីនគរបាលយុត្តិធម៌នៅមូលដ្ឋានជិតបំផុត ហើយក៏អាចដាក់បណ្តឹងទៅកាន់អយ្យការអមសាលាដំបូងដោយផ្ទាល់ផងដែរ។

**៥.ក្នុងករណីបណ្តឹងបានដាក់ហើយ ក៏ប៉ុន្តែ ពុំទាន់មានចំណាត់ការណាមួយ តើយើងត្រូវធ្វើដូចម្តេចខ្លះ?**

ក្នុងករណីនេះតាមផ្លូវច្បាប់ដូចដែលបានជម្រាបជូនខាងលើ មន្ត្រីនគរបាលយុត្តិធម៌លោកត្រូវពិនិត្យចាត់ការស៊ើបអង្កេតស្រាវជ្រាវករណីនេះ ក៏ប៉ុន្តែ ក្នុងករណីណាមួយដែលមានការយឺតយ៉ាវ ឬពុំមានការចាត់ការដោយសារមន្ត្រីនគរបាលយុត្តិធម៌ជាប់បេសកកម្មនោះ ដើម្បីចៀសវាងការបាត់បង់ផលប្រយោជន៍ ដែលទទួលបានការការពារដោយច្បាប់នោះជនរងគ្រោះ ឬដើមបណ្តឹងអាចដាក់ពាក្យបណ្តឹងជាថ្មី មកព្រះរាជអាជ្ញាអមសាលាដំបូង ដែលនឹងបង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងដែលបានស៊ើបអង្កេតមកកាន់អយ្យការអមសាលាដំបូងដើម្បីពិនិត្យចាត់ការបន្ត និងឈានទៅដល់ការសម្រេចដល់ការបើកការស៊ើបសួរ (ចោទប្រកាន់) ទៅចៅក្រមស៊ើបសួរបន្តទៀត។

**៦.ពេលបណ្តឹងកំពុងចាត់ការ តើដើមបណ្តឹងអាចដកបណ្តឹងបានទេ? ហើយតើសមត្ថកិច្ចនឹងបញ្ឈប់ចំណាត់ការ ឬយ៉ាងណា?**

ក្នុងពេលបណ្តឹងកំពុងចាត់ការដោយមន្ត្រីនគរបាលយុត្តិធម៌ ជនរងគ្រោះ ឬដើមបណ្តឹងបានទទួលសំណងណាមួយពីជនសង្ស័យ ហើយសុំដកពាក្យបណ្តឹងវិញ ក្នុងករណីនេះ ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចដកពាក្យបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងពីជនសង្ស័យតែប៉ុណ្ណោះ ចំពោះបណ្តឹងអាជ្ញា សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ត្រូវបន្តចាត់ការបញ្ជូនសំណុំរឿងទៅអយ្យការអមសាលាដំបូងមានសមត្ថកិច្ច ដោយមិនអាចតម្កល់សំណុំរឿងណាមួយទុកឥតចាត់ការបានឡើយ (មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)។

## ផ្នែកទី៣

## អ្វីទៅជាការទទួលខុសត្រូវព្រហ្មទណ្ឌ?

លោក ជួក សំនឿន គ្រូបង្រៀនផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច

លោក ជួក សំនឿន ប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ នៃវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម ជំនួយការផ្នែកច្បាប់នៅក្រុមមេធាវី អេភេខ្ស ខេមឡ្ស គ្រូបង្រៀនផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (ខេត្តបន្ទាយមានជ័យ បាត់ដំបង ព្រះសីហានុ) បានផ្តល់បទសម្ភាសន៍ជាមួយ ភ្នំពេញ ប៉ុស្តិ៍ ជុំវិញអ្វីជាបទល្មើសព្រហ្មទណ្ឌ ដែលមានខ្លឹមសារជាអាទិ៍ដូចខាងក្រោម៖

**១.អ្វីទៅដែលជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ?**

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការទទួលខុសត្រូវផ្ទាល់ខ្លួនដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌក្នុងមាត្រា ២៤ ថា៖ “បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។”

ក្នុងករណីនេះបុគ្គល អាចជា រូបវន្តបុគ្គល និងនីតិបុគ្គល ហេតុនេះការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបែងចែកជាពីរដែរ គឺ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។

ក-ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្ត បុគ្គល៖

-ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន៖

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់យកត្រឹមអាយុ ១៨ (ដប់ ប្រាំបី) ឆ្នាំ (មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ) ចំពោះការចោទប្រកាន់ពីបទព្រហ្មទណ្ឌនីមួយៗ ចាំបាច់ត្រូវផ្ទៀងផ្ទាត់តួនាទីដ៏ត្រឹមត្រូវរបស់អ្នកចូលរួមនីមួយៗ។ អាស្រ័យទៅលើជាតុទាំងឡាយនៃសំណុំរឿងអ្នកចូលរួមទាំងនោះអាចត្រូវបានកំណត់ប្រភេទគតិយុត្តជា ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត។ ម្យ៉ាងទៀត ប្រសិនបើបទល្មើស បានទៅដល់គោលបំណងហើយ គេនិយាយថា បទល្មើសនេះបានសម្រេច។ ឧទាហរណ៍៖ ចារីម្នាក់បានលើកកាំភ្លើងតម្រង់បាញ់លើបុគ្គលម្នាក់ ហើយបុគ្គលនោះស្លាប់ អំពើមនុស្សឃាតដោយចេតនា ឬអំពើមនុស្សឃាតដោយគិតទុកជាមុននេះបានសម្រេចហើយ។ ក៏ប៉ុន្តែ ប្រសិនបើបទល្មើសបែរជាបានទទួលបរាជ័យទៅវិញ ពីព្រោះថាគោលដៅពុំត្រូវបានសម្រេច តើមានការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ឬទេ? តើចាប់ពីពេលណាទៅទើបគេអាចចាត់ទុកថា បទល្មើសមួយបានចាប់ផ្តើម? ឧទាហរណ៍៖ ឃាតកដោយចេតនា បានគិតទៅដល់ការប្រព្រឹត្តបទឧក្រិដ្ឋរបស់ខ្លួនអស់រយៈពេល ៧ ថ្ងៃមុនទិញអាវុធ នៅមុនប្រព្រឹត្តបទឧក្រិដ្ឋមួយ ថ្ងៃណាត់ជួបជនរងគ្រោះនៅពេលព្រឹក ប៉ុន្តែត្រូវបាននគរបាលចាប់ខ្លួនមុនពេលជនរងគ្រោះមកដល់ តើអាចចោទប្រកាន់ជននេះពីបទព្រហ្មទណ្ឌបានដែរ ឬទេ? (ទ្រឹស្តីនៃការប៉ុនប៉ងនឹងឆ្លើយតបទៅនឹងសំណួរនេះ)។

ជាទូទៅ បទល្មើសមួយមិនអាចត្រូវបានសម្រេចឡើងក្នុងរយៈពេលតែមួយរំពេចបានឡើយ។ បទល្មើស គឺជាលទ្ធផលដែលកើតចេញពីដំណាក់កាលជាច្រើនបន្តបន្ទាប់គ្នា ចាប់ពីការគិតជម្មតាអំពីបទឧក្រិដ្ឋ រហូតដល់ការសម្រេចទាំងស្រុងនូវអំពើល្មើស។ មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌបានចែងថា៖ “ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិមអាចត្រូវផ្តន្ទាទោសបានកាលណាលក្ខខណ្ឌខាងក្រោមនេះ ត្រូវបានបំពេញ: ចារីបានចាប់ផ្តើមអនុវត្តបទល្មើស គឺមានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្ត បទល្មើស និងចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈ ក្រៅឆន្ទៈរបស់ខ្លួន។ អំពើត្រៀម

បម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្ដើមអនុវត្តទេ។ ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ។"

ខ-ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលៈ

ជាយូរលង់មកហើយការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានបង្កើតឡើងសម្រាប់តែមនុស្សប៉ុណ្ណោះ។ ក្រមព្រហ្មទណ្ឌ បានបញ្ចូលនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនៅក្នុងមាត្រា ៤២៖ "នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុង ច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតនីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដែលនោះទេ។"

**២.អ្វីទៅជាចារី សហចារី ឬជនបែបណាជាចារី សហចារី?**

- **ចារី** ៖ គឺបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលមួយណា ដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម (មាត្រា ២៥ នៃក្រមព្រហ្មទណ្ឌ)។ តាមរយៈនេះបញ្ជាក់ឲ្យឃើញពីសញ្ញាណនៃចារី គឺជាបុគ្គលដែលសម្រេចបំណងរបស់ខ្លួន ដោយការប្រព្រឹត្តបទល្មើស មួយបានសម្រេចព្រមទាំងបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទល្មើស ហើយនេះ គឺជាករណីនៃការប៉ុនប៉ង។ ចារី នៃការប៉ុនប៉ង ត្រូវបានគេប្រដូចទៅនឹងចារីនៃបទល្មើសបានសម្រេចដែរ។ ប៉ុន្តែ សម្រាប់ចារីនៃការប៉ុនប៉ងក្នុងបទមជ្ឈិម ទាល់តែមាន ច្បាប់ចែងយ៉ាងជាក់លាក់ទើបអាចផ្តន្ទាទោសដូចជា ចារី នៃបទមជ្ឈិមបានសម្រេចដែរ។
- **សហចារី** ៖ គឺបុគ្គលច្រើននាក់បានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់ បានចែងទុក (មាត្រា ២៦ នៃក្រមព្រហ្មទណ្ឌ)។ សញ្ញាណនៃសហចារីនេះ យោងទៅដល់ការចូលអន្តរាគមន៍របស់ រូបវន្តបុគ្គលជាច្រើនរូបនៅក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តបទល្មើស ដោយបុគ្គលទាំងនេះចូលអន្តរាគមន៍ជាមួយនឹងកម្រិត នៃការទទួលខុសត្រូវដូចគ្នានៅក្នុងសកម្មភាព។ ក្រៅពី ចារី និងសហចារី បុគ្គលផ្សេងទៀតអាចចូលរួមក្នុងការប្រព្រឹត្ត បទល្មើសផងដែរ។

**៣.ជនណាជាអ្នកផ្ដើមគំនិត សមគំនិត?**

- **អ្នកផ្តើមគំនិត**៖ គឺបុគ្គលជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬការបញ្ជារបស់ខ្លួន ឬបុគ្គលដែលបង្ក ឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយផ្តល់អំណោយដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ ទាល់តែបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលចារីបានប្រព្រឹត្តបានសម្រេច ឬបាន ប៉ុនប៉ងទើបអ្នកផ្តើមគំនិតត្រូវផ្តន្ទាទោសដូចគ្នានឹងចារីប្រព្រឹត្តបទល្មើស (មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ)។
- **អ្នកសមគំនិត**៖ គឺបុគ្គលដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋឬបទមជ្ឈិម ដោយផ្តល់ ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិត ក៏មានសញ្ញាណដូចគ្នានឹងអ្នកផ្តើមគំនិតដែរ ទាល់តែចារីបានប្រព្រឹត្តបទ ឧក្រិដ្ឋ ឬបទមជ្ឈិម បានសម្រេចឬបានប៉ុនប៉ង (មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ)។

# ផ្នែកទី៤

# ស្វែងយល់ពីទោសនិងបទល្មើសព្រហ្មទណ្ឌ

លោក ឌឹម ចាន់ថន សាស្ត្រាចារ្យ ផ្នែកច្បាប់នៃសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច

លោក ឌឹម ចាន់ថន មន្ត្រីនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាសាស្ត្រាចារ្យ ផ្នែកច្បាប់នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME) បានផ្តល់បទសម្ភាសន៍ជាមួយ ភ្នំពេញ ប៉ុស្តិ៍ ដោយបានលើកឡើងពីទិដ្ឋភាពច្បាប់ជុំវិញបទល្មើសព្រហ្មទណ្ឌ និងទោសព្រហ្មទណ្ឌ ដែលមានខ្លឹមសារជាអាទិ៍ដូចខាងក្រោមៈ

**១.ជាទូទៅអ្នកដែលមានទោសព្រហ្មទណ្ឌមានការកំណត់អាយុដែរ ឬទេ?**

យើងនិយាយនៅក្នុងក្របខ័ណ្ឌនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចាប់ផ្តើមអនុវត្តនៅទូទាំងប្រទេសកាលពីខែធ្នូ ឆ្នាំ២០១០ កន្លងទៅ។ ពាក្យថា ទោសព្រហ្មទណ្ឌ គឺសំដៅលើទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ បើយោងតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌចែងថា "នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។" ដូច្នេះ បានសេចក្តីថា នៅក្នុងច្បាប់ គឺមានការកំណត់អាយុជាក់លាក់ទៅលើអ្នកដែលត្រូវមានទោសព្រហ្មទណ្ឌ ហើយជាគោលការណ៍ទាល់តែជនល្មើសមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ទើបតុលាការអាចផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌបាន។ ឯជនល្មើសដែលមានអាយុក្រោម ១៨ ឆ្នាំ មិនត្រូវទទួលទោសព្រហ្មទណ្ឌទេ ប៉ុន្តែ តុលាការអាចចាត់វិធានការមួយចំនួនដើម្បីអប់រំកែប្រែជនល្មើសទាំងនោះ។

**២.ចំពោះអនីតិជនមានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬទេ ប្រសិនគេបានប្រព្រឹត្តបទល្មើស?**

ដូចបានបញ្ជាក់នៅខាងលើ ជាគោលការណ៍ទាល់តែជនល្មើសមានអាយុចាប់ពី១៨ឆ្នាំ ទៅ ទើបតុលាការអាចផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌបាន។ ពាក្យថា "អនីតិជន" គឺសំដៅទៅលើជនដែលមានអាយុមិនទាន់ដល់១៨ឆ្នាំ ហើយជាគោលការណ៍មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែ តុលាការអាចចាត់វិធានការមួយចំនួនដើម្បីអប់រំ កែប្រែពួកគេ។ វិធានការទាំងនោះអាចជាៈ ការប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ ឬអាណាព្យាបាលដើម្បីអប់រំការហាមឃាត់មិនឲ្យទៅកន្លែងណាមួយ ឬជួបបុគ្គលណាមួយដូចជា មិនឲ្យជួបជាមួយអ្នកសមគំនិត ក្នុងការប្រព្រឹត្តបទល្មើស ការបញ្ជូនអនីតិជនទៅដាក់ក្នុងមណ្ឌលកែប្រែក្តី។ ទោះជាយ៉ាងណា វិធានការទាំងនេះមិនមែនជាទណ្ឌកម្មព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែ បើយោងតាមមាត្រា ៣៩ វាក្យខណ្ឌ ទី២ នៃក្រមព្រហ្មទណ្ឌបានចែងថា "តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើសឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។"

ត្រង់នេះ គឺច្បាប់ទុក លទ្ធភាពឲ្យចៅក្រមជាអ្នកពិនិត្យ និងវាយតម្លៃ លើករណីជាក់ស្តែងថា តើបទល្មើសត្រូវបានប្រព្រឹត្តក្នុងកាលៈទេសៈបែបណា? តើជនល្មើសដែលជាអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ទៅក្រោម ១៨ ឆ្នាំនោះមានបុគ្គលិកលក្ខណៈបែបណា? ចាំបាច់ត្រូវតែប្រកាសដាក់ទោសព្រហ្មទណ្ឌដែរ ឬទេ? ក៏ប៉ុន្តែមាត្រា ១៦០ ក្នុងក្រមដដែលបានបញ្ជាក់ថា កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ គឺទោស (ដាក់ពន្ធនាគារនិងពិន័យជាប្រាក់) ត្រូវបន្ថយពាក់កណ្តាលជាងធម្មតា ហើយបើជាទោសត្រូវជាប់ពន្ធនាគារអស់មួយជីវិតគឺត្រូវកាត់បន្ថយមកនៅត្រឹម ២០ឆ្នាំ វិញ។ ឧទាហរណ៍ ក្នុងបទឃាតកម្ម ដូចមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌជាធម្មតាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ។ ប៉ុន្តែបើជនល្មើសជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ទៅក្រោម

១៨ឆ្នាំ ទោសនេះ ត្រូវកាត់បន្ថយពាក់កណ្តាល គឺមកនៅត្រឹមពី ៥ឆ្នាំ ទៅ ៧ឆ្នាំ កន្លះវិញ ហើយទោសពិន័យជាប្រាក់ក៏បន្ថយពាក់កណ្តាលដូចគ្នាដែរ។

**៣.តើការទទួលខុសត្រូវរបស់នីតិបុគ្គលច្បាប់កំណត់ដូចម្តេចខ្លះដែរ?**

ជាយូរលង់មកហើយ ការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ឡើងសម្រាប់តែរូបវន្តបុគ្គលតែប៉ុណ្ណោះ។ ប៉ុន្តែក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានបញ្ចូលនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលផងដែរ តួយ៉ាងដូចជា នៅមាត្រា ៤២ បានកំណត់ថា៖ “នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។” ចំពោះទោសដែលត្រូវរងដោយនីតិបុគ្គលវិញមានដូចជា៖ ទោសពិន័យក្នុងឋានៈជាមូលទោស។ ក្រៅពីទោសពិន័យមានទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គលដែលមានចែងក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ ២០០៩ ទោសបន្ថែមទាំងនោះអាចជាការរំលាយចោល ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។ល។ ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់។

សូមបញ្ជាក់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។ ឧទាហរណ៍: ក្នុងបទបង្កឲ្យមានរបួសស្នាមដោយអចេតនា នៅមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដោយត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ លានរៀល ទៅ ២០ លានរៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន។ ក្រៅពីនីតិបុគ្គលដែលត្រូវតុលាការប្រកាសផ្តន្ទាទោសហើយនោះ ចំពោះរូបវន្តបុគ្គលដែលជាអ្នកតំណាងឲ្យនីតិបុគ្គលវិញ ក៏មិនរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ដូចជា ត្រូវជាប់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៤ លានរៀលជាដើម។

**៤.តើមានការបែងចែកប្រភេទទោសដូចម្តេចខ្លះនៅក្នុងកម្រិតទោសព្រហ្មទណ្ឌ?**

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ឬយើងហៅថា ប្រព័ន្ធច្បាប់សរសេរដែលខ្មែរយើងអនុវត្តអំពើណាមួយដែលអាចជាបទល្មើសលុះត្រាតែអំពើនោះមានចែងក្នុងច្បាប់ជាធរមាន។ ចំពោះទោសវិញក៏ដូចគ្នាដែរ ទាល់តែមានចែងក្នុងច្បាប់ ទើបតុលាការអាចប្រកាសទោសនោះបាន។ ដូច្នេះហើយ បានជានៅក្នុងច្បាប់ខ្មែរយើងតែងតែមានចែងជាក់លាក់អំពីនិយមន័យជាតុផ្សំនៃបទល្មើស និងអំពីទោស ដែលត្រូវអនុវត្តចំពោះអំពើល្មើសណាមួយ។ ចំពោះប្រភេទនៃទោសនៅក្នុងក្រមព្រហ្មទណ្ឌ ២០០៩ ទោសព្រហ្មទណ្ឌត្រូវបានបែងចែកជាបីប្រភេទគឺ៖ មូលទោស ទោសបន្ថែម និងទោសជំនួស។

- **មូលទោស**៖ បើយោងតាមមាត្រា ៤៣ នៃក្រមមូលទោស គឺរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ។ នៅក្នុងបទល្មើសខ្លះ ដូចជា បទឧក្រិដ្ឋភាគច្រើន គឺមានតែទោសដាក់ពន្ធនាគារ ដោយមិនមានទោសពិន័យជាប្រាក់ទេ។ ឧទាហរណ៍ ដូចជា បទឃាតកម្ម បទឃាតកម្មគិតទុកជាមុន ជាដើម។ ចំពោះបទល្មើសខ្លះទៀត ដូចជា បទលហុភាគច្រើន គឺមានតែទោសពិន័យជាប្រាក់ ហើយមិនមានទោសដាក់ពន្ធនាគារទេ។ ចំណែកបទល្មើសខ្លះទៀតជាពិសេស គឺបទមជ្ឈិម គឺមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ឧទាហរណ៍៖ បទហិង្សាដោយចេតនា នៅមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ជនល្មើសអាចត្រូវទទួលទោសដាក់ពន្ធនាគារ ពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ ពី ២ លានទៅ ៦ លានរៀលនេះ គឺជាទោសព្រហ្មទណ្ឌ ដែលត្រូវបង់ទៅឲ្យរដ្ឋ។ ទោះបីមាន ឬក៏

គ្មានដើមបណ្ដឹងរដ្ឋប្បវេណី ក៏ជនល្មើសត្រូវតែបង់ដែរ។ បើសិនជាជនរងគ្រោះទាមទារសំណងជំងឺចិត្ត ចៅក្រមអាចសម្រេចឲ្យជនល្មើសបង់សំណងឲ្យទៅជនរងគ្រោះ បន្ថែមពីលើលុយពិន័យបង់ទៅឲ្យរដ្ឋ។

- **ទោសបន្ថែម៖** ទោសនេះអាចមានច្រើនប្រភេទ ដែលមានចែងក្នុងមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ។ ទោសបន្ថែម គឺអាចជា៖ ការដកសិទ្ធិខ្លះជាពលរដ្ឋ មានដូចជាសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត...ជាដើម។ ទោសបន្ថែម គឺជាទោសដែលចៅក្រមអាចប្រកាសដាក់បន្ថែមពីលើមូលទោស (ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់)។ ចៅក្រមអាចប្រកាសទោសបន្ថែមបាន លុះត្រា តែទោសនោះមានចែងច្បាស់លាស់ក្នុងច្បាប់។
- **ទោសជំនួស៖** ការប្រើទោសជំនួស ដែលជាសញ្ញាណនៃការមិនប្រកាសនូវមូលទោស ដោយសារគេយកទោសជំនួសនេះមកប្រើដើម្បីធ្វើការប្រកាសជំនួសឲ្យមូលទោសវិញ។ ទោសជំនួសនេះអាចស្ដែងឡើងតាមរយៈ ៖
  - ការងារសហគមន៍៖ ធ្វើឡើងដើម្បីបម្រើឲ្យប្រយោជន៍សាធារណៈ (រដ្ឋ សមូហភាពដែនដី នីតិបុគ្គលនៃនីតិសាធារណៈ) មិនបំពេញប្រយោជន៍ឲ្យឯកជនបុគ្គលណាទេ។ ការងារសហគមន៍អាចប្រកាសបានតែក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៣ឆ្នាំ និងត្រូវបំពេញកាតព្វកិច្ចក្នុងចន្លោះពី ៣០ ម៉ោង ទៅ ២០០ ម៉ោងដោយគ្មានកម្រៃ។
  - ការស្ដីបន្ទោស៖ ជាប្រភេទមួយនៃទោសជំនួសដែរ ហើយអាចប្រកាសបានតែក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹងបីឆ្នាំ ហើយត្រូវបំពេញលក្ខខណ្ឌទាំងអស់នេះ (១.ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើស បានបញ្ចប់ ២.ការខូចខាតត្រូវបានជួសជុលរួចហើយ ៣.ជនល្មើសមានការបង្ហាញ ឆន្ទៈក្នុងការបញ្ចូលទៅរស់នៅក្នុងសង្គមវិញ)។

គេអាចយកត្រឹមតែទោសការងារសហគមន៍ប៉ុណ្ណោះ សម្រាប់អនុវត្តចំពោះអនីតិជនដែលមានអាយុតិចជាង ១៦ឆ្នាំ ហើយការងារនេះមិនអាចមានរយៈពេលលើសពី ១០០ ម៉ោងបានទេ។ អ្វីដែលសំខាន់ គឺការងារសហគមន៍ត្រូវតែសម្របទៅនឹងចរិតលក្ខណៈរបស់អនីតិជន ហើយមានលក្ខណៈជាការបណ្ដុះបណ្ដាល និងសម្រួលទៅដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

## ផ្នែកទី៥

# អាជ្ញាយុកាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

លោកមេធាវី មឿន សុវណ្ណ សមាជិកគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា

លោក មេធាវី មឿន សុវណ្ណ អត្តលេខ ៥៦១ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់បទសម្ភាសន៍ជាមួយ ភ្នំពេញ ប៉ុស្តិ៍ ជុំវិញអាជ្ញាយុកាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលកំណត់ដោយក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលមានខ្លឹមសារជាអាទិ៍ ដូចខាងក្រោម៖

**១.តើអ្វីទៅជាអាជ្ញាយុកាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ?**

អាជ្ញាយុកាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាចិរវេលាកំណត់ដោយច្បាប់សម្រាប់អំឡុងពេលមួយដែលនៅបន្តអត្ថិភាពអានុភាពនៃសិទ្ធិ ឬកាតព្វកិច្ចរបស់បុគ្គលដែលត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

ជាទូទៅអ្នកច្បាប់លើកឡើងអំពីអាជ្ញាយុកាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺក្នុងគោលបំណងពីរយ៉ាង៖ ទី១ ដើម្បីជាប្រយោជន៍សង្គម ឬសិទ្ធិអំណាចរបស់រដ្ឋក្នុងការប្រើប្រាស់ពេលវេលាក្នុងការតបតចំពោះអំពើល្មើសច្បាប់ដែលបានបង្កព្យសនកម្មក្នុងសង្គមពីសំណាក់បុគ្គលដែលនៅក្នុងទឹកដីសមត្ថកិច្ចដែនអធិបតេយ្យរដ្ឋរបស់ខ្លួន ទី២ គឺជាផលប្រយោជន៍បុគ្គលល្មើសតាមរយៈការទទួលស្គាល់នូវសិទ្ធិជាសកលអំពីកាលវេលាដែលកន្លងហួសចំពោះអំពើល្មើសរបស់ខ្លួន ដែលត្រូវរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់។

អាជ្ញាយុកាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានបែងចែកជា ២ ប្រភេទ គឺអាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស។

**២.ដូចម្តេចដែលហៅថា អាជ្ញាយុកាលនៃបទល្មើស?**

អាជ្ញាយុកាលនៃបទល្មើស គឺរយៈពេលមួយកំណត់ដែលអាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ឬចៅក្រមអនុវត្តបណ្តឹងអាជ្ញា កិច្ចស៊ើបអង្កេត កិច្ចស៊ើបសួរ ឬការជំនុំជម្រះលើករណីរឿងក្តីព្រហ្មទណ្ឌបាន។ មានតែអង្គការអយ្យការមួយប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឲ្យឃើញពិរុទ្ធភាពនៃបុគ្គលល្មើស និងផ្តន្ទាទោសបុគ្គលនេះតាមច្បាប់កំណត់។

ចិរវេលានៃអាជ្ញាយុកាល ត្រូវបានកំណត់តាមប្រភេទនៃបទល្មើសដែលមានដូចជា៖ ទី១ រយៈពេល ១ឆ្នាំ ចំពោះបទលហុ ទី២ រយៈពេល ៥ឆ្នាំ ចំពោះបទមជ្ឈិម ទី៣ រយៈពេល ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ។

- បទល្មើសជាបទលហុ គឺជាបទល្មើសក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង ៦ ថ្ងៃ ឬបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមពិន័យជាប្រាក់ប៉ុណ្ណោះ។
- បទមជ្ឈិម គឺបទល្មើសដែលក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគាររយៈពេលលើសពី ៦ថ្ងៃ និងក្រោមឬស្មើនឹង ៥ឆ្នាំ។
- បទឧក្រិដ្ឋ គឺបទល្មើសដែលក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោមឬស្មើនឹង ៣០ឆ្នាំ ឬជាទោសដាក់ពន្ធនាគារអស់មួយជីវិត។

ដោយឡែកចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតអាជ្ញាយុកាលបានទេ។

ការចាប់ផ្ដើម និងការផ្ដាច់រយៈពេលនៃអាជ្ញាយុកាល គឺជាចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្ដើមគិតពីពេលប្រព្រឹត្តបទល្មើស។ អាជ្ញាយុកាលត្រូវផ្ដាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ។ ការបញ្ចប់នូវកិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗនាំឲ្យចាប់ផ្ដើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល។ ចិរវេលាថ្មី អាចនឹងយកទៅជំទាស់បាន ចំពោះជនគ្រប់រូបដែលបានទាក់ទិននៅក្នុងរឿងនេះ។ ឧទាហរណ៍: នៅថ្ងៃ ទី០១ តុលា ឆ្នាំ ២០១៣ ឈ្មោះ ប្រ៉ូច បានធ្វើសកម្មភាពលួចយកទូរស័ព្ទម៉ាក Iphone 5 បានសម្រេចពីឈ្មោះ មាន ពេលដែលគាត់ទុកទូរស័ព្ទរបស់គាត់នៅលើតុក្នុងការិយាល័យ។ លោក មាន បានស្គាល់លោក ប្រ៉ូច ច្បាស់ណាស់។ នៅថ្ងៃ ទី១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ លោក មាន បានដាក់ពាក្យបណ្ដឹងទៅនគរបាលប៉ុស្ដិ៍ ប៉ុន្តែ លោក ប្រ៉ូច នៅតែមិនចូល ខ្លួនទៅឆ្លើយបំភ្លឺចំពោះរឿងនេះ។ នៅថ្ងៃ ទី១២ ខែ ធ្នូ ២០១៣ ព្រះរាជអាជ្ញាបានចេញដីកាកោះហៅឈ្មោះ ប្រ៉ូច ឲ្យចូលខ្លួនទៅឆ្លើយបំភ្លឺករណីលួចទូរស័ព្ទខាងលើនេះទៀត តែលោក ប្រ៉ូច នៅតែមិនចូលខ្លួនដដែល។ ថ្ងៃ ទី៣០ ខែ ធ្នូ ឆ្នាំ ២០១៣ ព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ឈ្មោះ ប្រ៉ូច ដោយបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យចៅក្រមស៊ើបសួរ។

តាមរយៈឧទាហរណ៍នេះបើសិនលោក មាន មិនបានប្ដឹងទៅនគរបាលទេនោះ អាជ្ញាយុកាល គឺចាប់គិតពីថ្ងៃ ទី០១ ខែ តុលា ២០១៣ រហូតដល់គ្រប់ ៥ឆ្នាំ ព្រោះថា អំពើលួចជាបទល្មើសមជ្ឈិម។ ប៉ុន្តែរយៈពេល ៥ឆ្នាំ នៃអាជ្ញាយុកាលនៃអំពើរបស់ឈ្មោះ ប្រ៉ូច នេះ គឺត្រូវផ្ដាច់តាមរយៈកិច្ចស៊ើបអង្កេត និងបើកការចោទប្រកាន់ ពោលគឺត្រូវគិតរយៈពេលថ្មីចាប់ពីថ្ងៃទី ៣០ ធ្នូ ២០១៣ រហូតដល់គ្រប់ ៥ឆ្នាំ ទៅមុខទៀត។

មួយវិញទៀត នៅពេលផុតអាជ្ញាយុកាលនៃបទល្មើសខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចមិនអាចប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនក្នុងការអនុវត្តតួនាទីភារកិច្ចធ្វើការចោទប្រកាន់ការស៊ើបអង្កេត ការស៊ើបសួរ ឬការជំនុំជម្រះលើករណីរឿងក្ដីព្រហ្មទណ្ឌបានឡើយ។ ដូចគ្នាដែរ បុគ្គលល្មើសក៏មិនត្រូវបានចាប់បង្ខំឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើល្មើសរបស់ខ្លួនបានដែរ។

**៣.តើអាជ្ញាយុកាលនៃទោសមានភាពខុសគ្នានឹងអាជ្ញាយុកាលនៃបទល្មើសយ៉ាងណាដែរ?**

អាជ្ញាយុកាលនៃទោស គឺមានរយៈពេលមួយកំណត់ដែលកំណត់ដោយច្បាប់ ដែលត្រូវអនុវត្តលើទោសដែលបានប្រកាសដោយតុលាការព្រហ្មទណ្ឌ ចំពោះបុគ្គលណាមួយដែលតុលាការរកឃើញថា មានពិរុទ្ធភាព។ នៅពេលផុតអាជ្ញាយុកាលហើយទោសលែងអនុវត្តបានទៀតហើយ។

ក-ចិរវេលានៃអាជ្ញាយុកាលនៃទោសត្រូវបានកំណត់តាមប្រភេទនៃទោសដូចខាងក្រោម៖

- ទោសដែលប្រកាសពីបទឧក្រិដ្ឋ មានអាជ្ញាយុកាល ២០ឆ្នាំ
- ទោសដែលប្រកាសពីបទមជ្ឈិម មានអាជ្ញាយុកាល ៥ ឆ្នាំ
- ទោសដែលប្រកាសពីបទលហុ មានអាជ្ញាយុកាល ១ ឆ្នាំ។

ចំពោះទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតរលត់អាជ្ញាយុកាលទេ។ ក្រៅពីបទល្មើសទាំងនេះច្បាប់ពិសេស ក៏អាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន។

ខ- ការចាប់ផ្ដើមចិរវេលានៃអាជ្ញាយុកាលនៃទោសចំពោះចិរវេលានៃអាជ្ញាយុកាលនៃទោស ២០ឆ្នាំ ៥ឆ្នាំ និង ១ឆ្នាំ គឺត្រូវចាប់ផ្ដើមគិតពីថ្ងៃផ្ដន្ទាទោស (សាលក្រមឬសាលដីកា) បានក្លាយទៅជាស្ថាពរ។

ឧទាហរណ៍៖ នៅថ្ងៃ ទី០១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឈ្មោះ ច្រូច ត្រូវបានតុលាការផ្ដន្ទាទោសពីបទឆបោក និងសម្រេចដាក់ពន្ធនាគាររយៈពេលចំនួន ២ឆ្នាំ។ ប៉ុន្តែ ឈ្មោះ ច្រូច បានរត់គេចខ្លួនបាត់ចាប់តាំងពីថ្ងៃដែលប្រកាសសាលក្រមនោះមក ដោយមិនធ្វើការប្ដឹងឧទ្ធរណ៍ទេ។ ដូច្នេះសាលក្រមនឹងត្រូវចូលជាស្ថាពរចាប់ពីថ្ងៃ ទី០២ ខែ ធ្នូ ឆ្នាំ ២០១៣ ហើយអានុភាព និងចិរវេលានៃអាជ្ញាយុកាលនៃទោសនឹងចាប់ផ្ដើមគិតពីថ្ងៃទី០២ ខែធ្នូ ២០១៣ ទៅមុខរហូតដល់ផុតរយៈពេល ៥ឆ្នាំ ព្រោះថា បទឆបោក គឺជាបទមជ្ឈិម។

ការកំណត់ អំពីអាជ្ញាយុកាលនៃទោសក្នុងបទឧក្រិដ្ឋរហូតដល់រយៈពេល ២០ឆ្នាំ ច្រើនជាងអាជ្ញាយុកាលនៃបទល្មើសដែលកំណត់ត្រឹម ១៥ឆ្នាំ គឺដោយហេតុថា ការស្វែងរកការពិតក្នុងរឿងក្ដីព្រហ្មទណ្ឌពិសេសករណី បទឧក្រិដ្ឋ គឺមានស្ថានភាព និងចរិតលក្ខណៈប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម ពិសេសគឺមានភាពស្មុគស្មាញ និងចំណាយពេលវេលាយូរនិងចំណាយថវិកាច្រើនទម្រាំរកឃើញពិរុទ្ធភាពរបស់បុគ្គលល្មើស។ ពិសេសទៅទៀតនោះគឺធ្វើយ៉ាងណាឲ្យពិរុទ្ធជនដែលត្រូវតុលាការសម្រេចផ្ដន្ទាទោសពីបទឧក្រិដ្ឋ ហើយនឹងមិនងាយគេចខ្លួនពីសំណាញ់ច្បាប់ និងមិនងាយរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ពោលគឺមានគោលដៅលុបបំបាត់នូវនិទ្ទណ្ឌភាពនៅក្នុងសង្គមឲ្យបានច្រើនបំផុត។

## ផ្នែកទី៦

## អ្វីទៅជាបណ្ដឹងអាជ្ញា ពាក់ព័ន្ធនឹងបញ្ហាអ្វី ធ្វើនៅពេលណា?

លោកមេធាវី ឡាច សំរោង សមាជិកគណៈកម្មការព្រហ្មទណ្ឌ

លោក មេធាវី ឡាច សំរោង អត្តលេខ ៧៤៩ សមាជិកគណៈកម្មការព្រហ្មទណ្ឌ នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានការិយាល័យមេធាវី ឡាច សំរោង តាំងនៅភូមិ ចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុង-ខេត្ត សៀមរាប។

លោកបានផ្ដល់សម្ភាសន៍ដល់ភ្នំពេញប៉ុស្ដិ៍ ជុំវិញការធ្វើបណ្ដឹងអាជ្ញានៅពេលមានបទល្មើសកើតឡើង ដោយផ្អែកលើគោលការណ៍ច្បាប់ដែលមានខ្លឹមសារដូចខាងក្រោមៈ

**១.លោកមេធាវី អ្វីទៅជាបណ្ដឹង ហើយបណ្ដឹងគប្បីធ្វើនៅពេលណា និងដើម្បីអ្វី?**

នៅក្នុងនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា កាលណាមានបទល្មើស គឺតែងមានបណ្ដឹងពីរផ្សេងគ្នាកើតឡើង គឺបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសូមបញ្ជាក់ថា បណ្ដឹងទាមទារ និងបណ្ដឹងបរិហារ ដែលមានចែងក្នុងមាត្រា ៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនចាត់ទុកជាបណ្ដឹងដែលនាំឲ្យលំហូរនៃនីតិវិធីចាប់ដំណើរការនោះទេ ព្រោះពាក្យបណ្ដឹងទាមទារដែលធ្វើឡើងដោយជនរងគ្រោះផ្ទាល់ និងបណ្ដឹងបរិហារដែលធ្វើដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្រៅពីជនរងគ្រោះគ្រាន់តែជាព័ត៌មានដើម្បីឲ្យព្រះរាជអាជ្ញាថ្លឹងថ្លែងពីចំណាត់ការក្នុងការធ្វើការចោទប្រកាន់ទៅលើជនល្មើសតែប៉ុណ្ណោះ។

**២.បើដូច្នេះ តើអ្វីដែលជាបណ្ដឹងអាជ្ញា តើវាមានប្រយោជន៍អ្វី?**

បណ្ដឹងអាជ្ញា គឺជាបណ្ដឹងសុំឱ្យពិន័យជាប្រាក់ ឬដាក់ពន្ធនាគារមានកាលកំណត់ ឬដាក់ពន្ធនាគារអស់មួយជីវិត ឬប្រហារជីវិត (នៅកម្ពុជាបច្ចុប្បន្នគ្មានទោសប្រហារជីវិតទេ) ចំពោះជនដែលប្រព្រឹត្តអំពើដែលនាំឱ្យគ្រោះថ្នាក់ដល់សង្គម ឬប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ។ បច្ចុប្បន្ននេះបណ្ដឹងអាជ្ញាត្រូវបានមើលឃើញថា ជាបណ្ដឹងប្រឆាំងនឹងជនល្មើសដែលបានប្រព្រឹត្តបទល្មើសណាមួយ ដោយទាមទារឱ្យតុលាការផ្ដន្ទាទោសជននោះទៅតាមច្បាប់។

**៣.តើការចាប់ផ្ដើមនៃបណ្ដឹងអាជ្ញា គួរធ្វើឡើងនៅពេលណា?**

បណ្ដឹងអាជ្ញា ត្រូវបានអនុវត្តដោយអយ្យការក្នុងនាមការពារឱ្យផលប្រយោជន៍សាធារណៈការចាប់ផ្ដើមបណ្ដឹងអាជ្ញាដោយអយ្យការមានន័យថា តំណាងអយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ (អាចបទឧក្រិដ្ឋ មជ្ឈិម បទលហុ) និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ការចាប់ផ្ដើមនូវបណ្ដឹងអាជ្ញាដោយជនរងគ្រោះជាគោលការណ៍ថ្មី នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលអនុញ្ញាតឱ្យជនរគ្រោះ អាចដាក់ពាក្យបណ្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ។ ពាក្យបណ្ដឹងនេះមានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរអំពីបណ្ដឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបានបញ្ញត្តិដោយមាត្រា ១៣៩។ ការចាប់ផ្ដើមបណ្ដឹងអាជ្ញាដោយវិធីនេះមានភាពប្រថុយប្រថានខ្លាំង ព្រោះថាជនរងគ្រោះដែលបានដាក់ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានទទួលការផាកពិន័យដោយចៅក្រមស៊ើបសួរ និងសងការខូចខាត បើសិនបណ្ដឹងនោះធ្វើដោយរំលោភ ឬអូសបន្លាយពេលវេលា។

**៤.ហើយចុះ តើអ្វីទៅដែលជាកម្មវត្ថុនៃបណ្ដឹងអាជ្ញានោះ?**

បណ្ដឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ផ្អែកតាមក្រមព្រហ្មទណ្ឌថ្មី គ្រប់បុគ្គលទាំងអស់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌទោះជានីតិបុគ្គលក្ដី។ នីតិបុគ្គល ថ្វីដ្បិតតែជាបុគ្គលសិប្បនិមិត្តដែលបង្កើតឡើងដោយច្បាប់ក៏ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដែរ មានន័យថា នីតិបុគ្គលនោះអាចទទួល

រងនូវការពិន័យជាប្រាក់ ឬទទួលរងនូវទោសបន្ថែមណាមួយដូចជា ការរំលាយនីតិបុគ្គលជាដើម។ ចំណែកឯរូបវន្តបុគ្គលតំណាងឱ្យនីតិបុគ្គល ដែលបានប្រព្រឹត្តបទល្មើសនោះ ក៏មិនអាចគេចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។

**៥.តើបណ្តឹងអាជ្ញាមានគោលបំណងដើម្បីអ្វីទៅ?**

បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យទៅលើអត្ថិភាពនៃបទល្មើស និងបង្ហាញឲ្យឃើញនូវពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ ដូចនេះគោលបំណងនៃបណ្តឹងអាជ្ញា គឺកំណត់ពីអត្ថិភាពនៃបទល្មើស និងផ្តន្ទាទោសជនល្មើសតាមច្បាប់ជាធរមាន។

**៦.និយាយដល់បទល្មើស តើអ្វីទៅដែលជាបទល្មើសនោះ?**

ច្បាប់បញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម គឺជាបទល្មើស។ យោងតាមការកំណត់និយមន័យនេះ ទ្រឹស្តីព្រហ្មទណ្ឌបានកំណត់អំពីចរិតនៃបទល្មើសរួមមាន៖ អំពើដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ សង្គម អំពើដែលច្បាប់ព្រហ្មទណ្ឌកំណត់ថាជាបទល្មើស គោលការណ៍នៃកំហុសដោយចេតនាឬអចេតនា។ ជាគោលការណ៍មានតែអំពើដែលច្បាប់បានកំណត់ថា ជាបទល្មើសទើបអាចត្រូវបានផ្តន្ទាទោសដែលហៅថាគោលការណ៍ នីត្យានុកូលនៃបទល្មើស ហើយមានតែទោសដែលមានចែងដោយច្បាប់ទេ ទើបអាចសម្រេចផ្តន្ទាទោសបាន ដែលហៅថាគោលការណ៍នីត្យានុកូលនៃទោស។ ដូចនេះ ប្រសិនបើជនណាមួយបានប្រព្រឹត្តនូវអំពើណាមួយបើទោះជាអំពើនោះវានាំឲ្យមានការប៉ះពាល់ដល់សង្គមក៏ដោយ តែអំពើនេះពុំមានច្បាប់កំណត់ថា ជាបទល្មើស ជននោះមិនត្រូវបានតុលាការផ្តន្ទាទោសឡើយ។

**៧.តើបណ្តឹងអាជ្ញារលត់នៅពេលណា?**

ការរលត់បណ្តឹងអាជ្ញា មានដូចជា មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាលការលើកលែងទោសជាទូទៅ និងនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយការចោទប្រកាន់ខាងព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។ ឧទាហរណ៍ប្រសិនជនសង្ស័យទទួលមរណភាពក្នុងដំណាក់កាលតំណាងអយ្យការកំពុងធ្វើការចោទប្រកាន់នោះមានន័យថា បណ្តឹងអាជ្ញាត្រូវបានរលត់ តំណាងអយ្យការត្រូវតែតម្កល់រឿងទុកឥតចាត់ការ។

## ផ្នែកទី៧

# តួនាទីនិងសិទ្ធិអំណាចរបស់អយ្យការ និងមហាអយ្យការ

លោក គង់ ទីលីន សមាជិកក្រុមប្រឹក្សាគណៈមេធាវីកម្ពុជា

ដើម្បីស្វែងយល់ទៅលើប្រព័ន្ធតុលាការនៅកម្ពុជា និងទៅលើអំណាចស្ថាប័នពាក់ព័ន្ធដែលច្បាប់កំណត់ឲ្យលោកមេធាវី គង់ ទីលីន សមាជិកក្រុមប្រឹក្សានៃគណៈមេធាវី និងជាអនុប្រធាននៃអនុក្រុមការងារវិស័យព្រហ្មទណ្ឌបានផ្តល់បទសម្ភាសន៍ជាមួយកាសែតភ្នំពេញប៉ុស្តិ៍ តាមការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានលើកឡើងជុំវិញ តួនាទីនិងសិទ្ធិអំណាចរបស់ស្ថាប័នអយ្យការអមសាលាដំបូងខេត្ត-រាជធានី និងមហាអយ្យការអមសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារៈ

**១.តើស្ថាប័នអយ្យការនិងមហាអយ្យការមានប៉ុន្មានថ្នាក់អ្នកណាជាតំណាង?**

ស្ថាប័នអយ្យការនិងមហាអយ្យការមាន ៣ ថ្នាក់ អយ្យការអមសាលាដំបូងខេត្ត-រាជធានី ដែលតំណាងដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង មហាអយ្យការអមសាលាឧទ្ធរណ៍ តំណាងដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា។ មហាអយ្យការអមតុលាការកំពូល តំណាងដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល។

**២.តើអង្គការអយ្យការមានតួនាទីអ្វីខ្លះ?**

អង្គការអយ្យការមានតួនាទីចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យអនុវត្តច្បាប់។ អង្គការអយ្យការជានាវ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងជានាលើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចចៅក្រមអយ្យការ (ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង) មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌចៅក្រមអយ្យការត្រូវតែមានវត្តមានក្នុងពេលសវនាការចំពោះរឿងក្តីព្រហ្មទណ្ឌ។

**៣.តើសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត-រាជធានី មានអ្វីខ្លះ?**

ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត-រាជធានី មានសិទ្ធិអំណាចៈ ដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីខ្លួន។ ដំបូងប្រើប្រាស់អំណាចដែលក្រមនីតិវិធីព្រហ្មទណ្ឌទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ស៊ើបអង្កេត។ អាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើការណែនាំអ្វីដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ អាចធ្វើអធិការកិច្ចបានគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។

**៤.តើមហាអយ្យការអមសាលាឧទ្ធរណ៍មានតួនាទីធ្វើអ្វីខ្លះ?**

មហាអយ្យការអមសាលាឧទ្ធរណ៍ដឹកនាំដោយអគ្គព្រះរាជអាជ្ញា ហើយមានតួនាទីក្នុងការឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញានេះ ក៏អាចធ្វើអធិការកិច្ចនៅអង្គការអយ្យការអមសាលាដំបូងខេត្ត-រាជធានីទូទាំងប្រទេស។

**៥.តើសិទ្ធិអំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអ្វីខ្លះ?**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអំណាចៈ ធ្វើការឃ្លាំមើលនិងត្រួតពិនិត្យនគរបាលយុត្តិធម៌។ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ មកពិភាក្សាអំពីបញ្ហាដែលទាក់ទងនៃការប្រព្រឹត្តទៅរបស់

អង្គភាពនេះ។ អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ឲ្យបំពេញភារកិច្ចទាំងឡាយ ដែលខ្លួនយល់ថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការល្អនៃនគរបាលយុត្តិធម៌។ អាចធ្វើអធិការកិច្ចគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌។ អាចចូលរួមក្នុងការស្ដាប់ចម្លើយអាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ជាពិសេស ការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។ ប្រធានអង្គភាពនគរបាលយុត្តិធម៌មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូបត្រូវគោរពតាមអធិបញ្ជារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

**៦. នៅពេលមានរឿងព្រហ្មទណ្ឌ តើយើងអាចដាក់ពាក្យបណ្ដឹងទៅអង្គការអយ្យការណាមួយ ឬក៏អាចដាក់បណ្ដឹងផ្ទាល់ទៅមហាអយ្យការអមសាលាឧទ្ធរណ៍?**

ដូចបានជម្រាបជូនរួចមកហើយ នៅតាមខេត្ត-រាជធានី មានអង្គការអយ្យការអមសាលាដំបូងក្នុងករណីមានបទល្មើសព្រហ្មទណ្ឌកើតឡើងជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្ដឹងទៅអង្គការអយ្យការអមសាលាដំបូងខេត្ត-រាជធានីទាំងនោះ តែពុំអាចដាក់ពាក្យបណ្ដឹងផ្ទាល់មកមហាអយ្យការអមសាលាឧទ្ធរណ៍ទេ ព្រោះមហាអយ្យការអមសាលាឧទ្ធរណ៍ អាចទទួលសំណុំរឿងក្តីព្រហ្មទណ្ឌណាមួយមកចាត់ការ លុះត្រាតែអយ្យការអមសាលាដំបូងខេត្ត-រាជធានីសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការ ហើយមានបណ្ដឹងឧទ្ធរណ៍លើដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនោះ ទើបអយ្យការអមសាលាដំបូងខេត្ត-រាជធានី បញ្ជូនមកមហាអយ្យការអមសាលាឧទ្ធរណ៍ពិនិត្យចាត់ការ។

**៧.នៅពេលបណ្ដឹងកំពុងចាត់ការដោយព្រះរាជអាជ្ញា តើស្ថាប័នណាមានសិទ្ធិធ្វើអធិបញ្ជាមកអយ្យការអមសាលាដំបូងដែលកំពុងកាន់សំណុំរឿងនោះបាន?**

យោងមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌរដ្ឋមន្ត្រីក្រសួង យុត្តិធម៌ ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិធ្វើអធិបញ្ជាឲ្យចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណា ដែលខ្លួនយល់ថាជាការគួរមកអយ្យការអមសាលាដំបូងខេត្ត-រាជធានី។

**៨. ក្នុងករណីមានបណ្ដឹងព្រហ្មទណ្ឌណាមួយកំពុងចាត់ការដោយមន្ត្រីនគរបាលយុត្តិធម៌ តើចាំបាច់ទេ ក្នុងការសុំយោបល់ ឬសុំការអនុញ្ញាតពីព្រះរាជអាជ្ញា?**

ដូចដែរបានជម្រាបជូនមកហើយ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ហេតុនេះ ទោះជាក្នុងករណីនៃការបើកស៊ើបអង្កេតបឋម ឬស៊ើបអង្កេតជាក់ស្ដែងក៏ដោយ មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវមានការសុំយោបល់ និងការអនុញ្ញាតពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងលើកិច្ចការងាររបស់ខ្លួនជាដាច់ខាត។

**៩.តើការដាក់វិន័យទៅលើមន្ត្រីនគរបាលយុត្តិធម៌ ដែលបានប្រព្រឹត្តកំហុសមានកម្រិតណាខ្លះដែរ?**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទទួលដំណឹងពីកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ តាមរបាយការណ៍ពីព្រះរាជអាជ្ញា ឬពីចៅក្រមស៊ើបសួរ បន្ទាប់មកអគ្គព្រះរាជអាជ្ញាប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រី ក្រសួង មហាផ្ទៃ និងក្រសួងការពារជាតិដើម្បីចាប់ដំណើរការនីតិវិធីវិន័យ។ ក្នុងករណីអគ្គព្រះរាជអាជ្ញាយល់ឃើញថា កំហុសប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានសភាពធ្ងន់ធ្ងរអគ្គព្រះរាជអាជ្ញាមានសិទ្ធិប្រកាសចេញនូវវិធានការរួមមាន: ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្ដោះអាសន្នក្នុងរយៈពេល ៥ឆ្នាំ ច្រើនយូរ និងហាមមិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។

# ផ្នែកទី៨

# បណ្តឹងរដ្ឋប្បវេណី និងសាលក្រមរដ្ឋប្បវេណី

លោកមេធាវី អ៊ីវ ប៉ូលី នៃក្រុមមេធាវីកម្ពុជាអន្តរជាតិ និងជាគ្រូបង្រៀនច្បាប់

លោក អ៊ីវ ប៉ូលី មេធាវីនៃក្រុមមេធាវីកម្ពុជាអន្តរជាតិ និងជាគ្រូបង្រៀនច្បាប់នៃសាលាមេធាវី និងនៅតាមមហាវិទ្យាល័យច្បាប់មួយចំនួនបានផ្តល់បទសម្ភាសន៍ឲ្យភ្នំពេញប៉ុស្តិ៍ លើប្រធានបទស្តីពីបណ្តឹងរដ្ឋប្បវេណី និងសាលក្រមរដ្ឋប្បវេណីយោងទៅលើខ្លឹមសារច្បាប់ជាធរមានដែលមានសេចក្តីពិស្តារដូចខាងក្រោមៈ

**១.លោកមេធាវីអ្វីទៅបណ្តឹងរដ្ឋប្បវេណី?**

បណ្តឹងរដ្ឋប្បវេណី គឺជាការអនុវត្តសិទ្ធិទាមទារតាមផ្លូវតុលាការចំពោះវិវាទទាំងឡាយណា ដែលពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ ដូចជា បណ្តឹងលែងលះ បណ្តឹងទាមទារដី ឬប្រាក់ជាអាទិ៍។ បណ្តឹងរដ្ឋប្បវេណីត្រូវដាក់ទៅតុលាការរដ្ឋប្បវេណី នៃការិយាល័យទទួលពាក្យបណ្តឹង និងរដ្ឋបាលរបស់សាលាដំបូងរាជធានី-ខេត្ត ដោយភាគីនៃសំណុំរឿងហៅថា ដើមចោទ (អ្នកប្តឹងគេ) និងចុងចម្លើយ (អ្នកដែលត្រូវគេប្តឹង)។ នៅពេលដាក់ពាក្យបណ្តឹងត្រូវបង់ពន្ធ (ពន្ធដាក់ពាក្យសុំ) ដោយសមាមាត្រទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង ហើយតុលាការនឹងបោះត្រាបញ្ជាក់។

**២.ពេលដែលតុលាការទទួលបានពាក្យបណ្តឹង តើនីតិវិធីបន្តត្រូវធ្វើដូចម្តេច?**

នៅពេលតុលាការបានទទួលពាក្យបណ្តឹងរដ្ឋបាលតុលាការនឹងបញ្ជូនពាក្យបណ្តឹងនេះទៅចៅក្រមទទួលបន្ទុក ដើម្បីចាត់ការជាសមត្ថកិច្ចដោយពិនិត្យទៅលើទម្រង់នៃពាក្យបណ្តឹង ឬការបង់ពន្ធជាអាទិ៍បន្ទាប់មកនឹងចាត់បញ្ជូនពាក្យបណ្តឹងនេះទៅចុងចម្លើយ។

ចំណាត់ការបន្តទៀតតុលាការនឹងកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងអំឡុងពេលដែលច្បាប់កំណត់ និងសមរម្យ ដែលអាចឲ្យភាគីចូលរួមក្នុងនីតិវិធីត្រៀមដែលជាការអះអាងរបស់ភាគីក្នុងការឆ្លើយគាំទ្រការទាមទារ ឬបដិសេធការទាមទារ ជាអាទិ៍ ដែលជាមូលដ្ឋាននៃការសម្រេចសេចក្តីសម្រាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។

**៣.ជាបន្តតើតុលាការនឹងបើកសវនាការនៅពេលណា ហើយប្រើសិទ្ធិសម្រេចដូចម្តេចចំពោះពាក្យបណ្តឹងនោះ?**

នៅពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានបញ្ចប់តុលាការនឹងបន្តចំណាត់ការដោយកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ (សវនាការ) ដើម្បីសម្រេចសេចក្តីចំពោះពាក្យបណ្តឹងថា តើច្រានចោល ឬសម្រេចតាមការទាមទារ។ ប្រសិនបើពាក្យបណ្តឹងនោះគ្មានមូលដ្ឋានឬគ្មានភស្តុតាងគាំទ្រការទាមទារតុលាការនឹងចេញសាលក្រមច្រានចោលការទាមទារផ្ទុយទៅវិញ បើពាក្យបណ្តឹងនោះមានមូលដ្ឋាន និងភស្តុតាងគ្រប់គ្រាន់តុលាការនឹងចេញសាលក្រមសម្រេចតាមការទាមទារ។

**៤.ចុះបើមានភាគីណាមួយមិនសុខចិត្តនឹងសាលក្រមរបស់តុលាការតើច្បាប់ផ្តល់សិទ្ធិអ្វីខ្លះឲ្យទៅភាគីនោះ?**

ការសម្រេចសេចក្តីរបស់តុលាការចំពោះពាក្យបណ្តឹងត្រូវធ្វើឡើងតាមរយៈសាលក្រម ដែលជាសេចក្តីសម្រេចរបស់សាលាដំបូងរាជធានី-ខេត្ត (តុលាការជាន់ ទី១)។ ប្រសិនបើភាគីដែលចាញ់ក្តី មិនសុខចិត្តភាគីចាញ់ក្តីអាចប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចនោះទៅសាលាឧទ្ធរណ៍ (តុលាការជាន់ ទី២) ដោយការប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងតាមរយៈពាក្យបណ្តឹងឧទ្ធរណ៍នៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងដែលបានចេញសាលក្រមដោយត្រូវបង់ពន្ធស្មើនឹង ១,៥ ដង (មួយដងកន្លះ) នៃពន្ធដាក់ពាក្យសុំ។ បន្ទាប់ពីទទួលពាក្យបណ្តឹងឧទ្ធរណ៍ និងបានបង់ពន្ធគ្រប់ចំនួនសាលាដំបូងរាជធានី-ខេត្ត នឹងបញ្ជូនបណ្តឹង

នោះទៅសាលាឧទ្ធរណ៍ក្នុងពេលសមរម្យ ដែលអាចគោរពបាននូវគោលការណ៍ស្តីពីតុលាការត្រូវរ៉ាប់រងបណ្តឹងឲ្យឆាប់រហ័ស និងយុត្តិធម៌។

**៥.នៅពេលពាក្យបណ្តឹងឧទ្ធរណ៍ទៅដល់សាលាឧទ្ធរណ៍តើសាលាឧទ្ធរណ៍ត្រូវចាត់ការដូចម្តេច?**

នៅពេលពាក្យបណ្តឹងមកដល់សាលាឧទ្ធរណ៍នឹងពិនិត្យពាក្យបណ្តឹងនោះថា តើធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់កំណត់ឬយ៉ាងណា? បង់ពន្ធគ្រប់ចំនួនហើយឬនៅ? ជាអាទិ៍។ បន្ទាប់មកទៀត សាលាឧទ្ធរណ៍នឹងកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីត្រួតពិនិត្យឡើងវិញនូវចំណាត់ការរបស់សាលាដំបូង និងភាពស្របច្បាប់នៃសេចក្តីសម្រេចទុកជាមូលដ្ឋាននៃការសម្រេចបន្តថា តើច្រានចោលពាក្យបណ្តឹងឧទ្ធរណ៍ ឬលុបចោលសាលក្រមសាលាដំបូងរាជធានី-ខេត្ត ឬបញ្ជូនត្រឡប់មកសាលាដំបូងរាជធានី-ខេត្ត ចាត់ការបន្តឲ្យបានសមស្របតាមផ្លូវច្បាប់ឡើងវិញ។

**៦.ចុះបើភាគីណាមួយមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍តើអាចប្តឹងទៅណា ឬត្រូវធ្វើដូចម្តេចទៀត?**

ភាគីដែលមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ គប្បីប្តឹងសារទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍ទៅតុលាការកំពូល (តុលាការជាន់ចុងក្រោយ) ដោយការប្តឹងសារទុក្ខ ត្រូវធ្វើឡើងតាមរយៈពាក្យបណ្តឹងសារទុក្ខនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសាលដីកាដោយត្រូវបង់ពន្ធនៃបណ្តឹងសារទុក្ខស្មើនឹង ២ ដងនៃពន្ធដាក់ពាក្យសុំ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងសារទុក្ខ និងបានបង់ពន្ធគ្រប់ចំនួនសាលាឧទ្ធរណ៍នឹងបញ្ជូនពាក្យបណ្តឹងសារទុក្ខទៅតុលាការកំពូលក្នុងអំឡុងពេលសមរម្យដែលអាចគោរពបាននូវគោលការណ៍ស្តីពីតុលាការត្រូវរ៉ាប់រងបណ្តឹងឲ្យឆាប់រហ័ស និងយុត្តិធម៌។

**៧.នៅពេលពាក្យបណ្តឹងសារទុក្ខទៅដល់តើតុលាការកំពូលនឹងចាត់ការដូចម្តេច?**

នៅពេលពាក្យបណ្តឹងសារទុក្ខមកដល់តុលាការកំពូលនឹងពិនិត្យពាក្យបណ្តឹងសារទុក្ខនោះថា តើធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់កំណត់ ឬយ៉ាងណាបង់ពន្ធគ្រប់ចំនួនហើយឬនៅ? ជាអាទិ៍។ តមកតុលាការកំពូលនឹងចេញដីកាសម្រេចឲ្យដើមបណ្តឹងសារទុក្ខដាក់លិខិត បញ្ជាក់មូលហេតុនៃបណ្តឹងសារទុក្ខក្នុងអំឡុងពេលដែលច្បាប់កំណត់ (៣០ថ្ងៃ) គិតចាប់ពីថ្ងៃបានទទួលដីកាសម្រេច។ ប្រសិនបើមិនដាក់ក្នុងអំឡុងពេលច្បាប់កំណត់នោះទេ តុលាការកំពូលនឹងលើកបណ្តឹងចោលដោយដីកាសម្រេច។

ប្រសិនបើដើមបណ្តឹងសារទុក្ខបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសារទុក្ខ ក្នុងអំឡុងពេលដែលច្បាប់កំណត់ តុលាការកំពូលនឹងចាត់បញ្ជូនលិខិតនេះទៅចុងបណ្តឹងសារទុក្ខដើម្បីឲ្យឆ្លើយតបតាមរយៈឯកសារត្រៀម (សារណាតប) ក្នុងការឆ្លើយដោះបន្ទុកចំពោះការលើកឡើងរបស់ដើមបណ្តឹងសារទុក្ខ។ សាលដីការបស់តុលាការកំពូលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា (សាលដីកាអធិបតេយ្យ) ហើយការប្តឹងត្រូវបញ្ចប់ត្រឹមតុលាការកំពូលលើកលែងតែភាគីចាញ់ក្តីអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយមានហេតុផលតាមការកំណត់របស់ច្បាប់ភាគីនោះអាចដាក់ពាក្យបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី។

# ផ្នែកទី៩

# អ្វីទៅការជំនុំជម្រះមុនអង្គសេចក្តី

លោកមេធាវី សុក សំអឿន នាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

លោក សុក សំអឿន នាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយភ្នំពេញប៉ុស្តិ៍ជុំវិញនីតិវិធីនៃការជំនុំជម្រះមុនអង្គសេចក្តីរបស់តុលាការដោយផ្អែកលើនីតិវិធីច្បាប់ជាធរមានដែលមានខ្លឹមសារដូចខាងក្រោម៖

**១.អ្វីទៅជាការជំនុំជម្រះមុនអង្គសេចក្តីរបស់តុលាការ? ហើយតើតុលាការអាចធ្វើទៅបាននៅពេលណា?**

ករណីនេះ គឺជាការសម្រេច ឬក៏ជាសវនាការអំពីរឿងក្តីដែលត្រូវគេចោទប្រកាន់។ ឧទាហរណ៍: ដូចជា ការសុំនៅក្រៅឃុំការសុំបដិសេធភស្តុតាងជាដើម ដែលនេះគេហៅថា ជម្រះក្តីមុនអង្គសេចក្តីហើយហើយក៏មិនទាន់ដឹងថា ជននោះមានទោស ឬអត់ដែរទេ? ការជម្រះមុនអង្គសេចក្តីនេះ តុលាការអាចដំណើរការទៅបានពេលមានពាក្យបណ្តឹង ដែលលោកចៅក្រមអាចលើកយកសំណុំរឿងនោះមកបើកសវនាការដេញដោលគ្នាតាមដំណើររឿង។

**២.តើតុលាការអាចចោទប្រកាន់ និងដាក់ទោសលើជននោះដូចម្តេចក្នុងសំណុំរឿងបែបនេះ?**

ការជំនុំជម្រះសំណុំរឿងមុនអង្គសេចក្តី តុលាការមិនអាចដាក់ទោសបានទេដោយគ្រាន់តែនិយាយជុំវិញអង្គសេចក្តីដែលមេធាវីសុំដាក់ភស្តុតាងបន្ថែមសុំនៅក្រៅឃុំ ឬចៅក្រមត្រូវបដិសេធភស្តុតាងណាមួយតែប៉ុណ្ណោះ។

**៣.បើតុលាការមិនអាចដាក់ទោសបានហេតុអ្វីតុលាការបន្តឃុំខ្លួនគាត់ទៀត? តើការឃុំខ្លួនជនជាប់ចោទមានកំណត់រយៈពេលដូចម្តេចដែរ?**

រឿងនេះ គឺជាច្បាប់ឃុំខ្លួនរបស់តុលាការដែលត្រូវអនុវត្ត ហើយការឃុំខ្លួនសុទ្ធតែមានមូលហេតុ។ តាមផ្លូវច្បាប់ជាគោលការណ៍មេធាវីត្រូវសុំឲ្យជនជាប់ចោទនៅក្រៅឃុំអីចឹងហើយ ដើម្បីធានាថា រាល់សវនាការពេលណាមួយត្រូវតែមានវត្តមានរបស់ជនជាប់ចោទជានិច្ច។ តែបើចៅក្រមឲ្យជននោះនៅក្រៅឃុំ គេអាចនឹងរត់គេច ឬក៏អាចទៅគាបសង្កត់បំភិតបំភ័យដល់សាក្សី ឬក៏ទៅបំផ្លាញភស្តុតាងពោល គឺមានមូលហេតុច្រើនយ៉ាងទាក់ទងនឹងការឲ្យជនជាប់ចោទនៅក្រៅឃុំ។ ឯរយៈពេលឃុំខ្លួន អាចប្រែប្រួលទៅតាមបទល្មើស ដូចជា បទល្មើសមជ្ឈិមផ្សេងបទល្មើសឧក្រិដ្ឋផ្សេង តែបទល្មើសខ្លះជនជាប់ចោទអាយុក្រោម ១២ឆ្នាំ គឺគេឲ្យមានសេរីភាព។

**៤.ក្នុងសំណុំរឿងបែបនេះ តើជនជាប់ចោទមានសិទ្ធិសុំនៅក្រៅឃុំនៅក្នុងករណីបែបណាខ្លះ?**

ក្នុងសំណុំរឿងមុនអង្គសេចក្តីនេះ មេធាវីរបស់ជនជាប់ចោទ ឬជនជាប់ចោទផ្ទាល់អាចមានសិទ្ធិសុំនៅក្រៅឃុំបានហើយបើនៅសាលាដំបូងសុំមិនបាន គេអាចសុំក្រោយៗទៀតរហូតដល់តុលាការកំពូល។ បើតុលាការកំពូលមិនឲ្យនៅក្រៅឃុំទៀតជនជាប់ចោទអាចស្នើសុំទៅកាន់សភាស៊ើបសួរ។

**៥.តុលាការថ្នាក់ក្រោមតែងបដិសេធការសុំនៅក្រៅឃុំនេះ តើការអនុវត្តនីតិវិធីបែបនេះអាចធ្វើឲ្យខូចដល់ប្រយោជន៍ជនត្រូវចោទ ឬទេ?**

ជាធម្មតា បើតុលាការមិនអនុញ្ញាតឲ្យនៅក្រៅឃុំនោះជនជាប់ចោទអាចបាត់បង់សិទ្ធិសេរីភាព។ តែតុលាការគេមានកំណត់ដែរមិនចេះតែឃុំខ្លួនគេស្រេចតែចិត្តបានទេ។ ឧទាហរណ៍ថា ជនជាប់ចោទសារភាពឬក្មេងក្រោមអាយុ ១៤ឆ្នាំ គឺតុលាការអត់មានសិទ្ធិឃុំខ្លួនគេបានទេ។

**៦.ក្នុងករណីខ្លះបើឲ្យជនជាប់ចោទនៅក្រៅឃុំ តើអាចធ្វើឲ្យប៉ះពាល់អ្វីខ្លះដល់នីតិវិធីតុលាការ?**

ដូចខ្ញុំបញ្ជាក់ខាងលើបើតុលាការមិនឲ្យជនជាប់ចោទនៅក្រៅឃុំ គឺគាត់បាត់បង់សេរីភាព។ ប៉ុន្តែបើឲ្យនៅក្រៅឃុំ បានខ្លាចក្រែងគាត់ទៅបង្កបទល្មើស ឬធ្វើអ្វីផ្សេងទៀតដែលប៉ះពាល់ដល់នីតិវិធីស៊ើបអង្កេតរបស់តុលាការ។ ដូច្នេះនេះហើយជាមូលហេតុ។

**៧.ឧទាហរណ៍ថា ជននោះត្រូវសាលាដំបូងចោទប្រកាន់ពីបទល្មើសអ្វីមួយរហូតដល់តុលាការកំពូលរក្សាតម្កល់បទចោទនោះទុកដដែល តើជនជាប់ចោទត្រូវជាប់ឃុំរហូតដល់ពេលណា?**

ការសម្រេចមិនឲ្យជនជាប់ចោទនៅក្រៅឃុំ គឺអស់ត្រឹមតុលាការកំពូល។ តែជនជាប់ចោទ ឬមេធាវីរបស់គាត់អាចសុំនៅសាលាដំបូងម្តងទៀតបាន។ ក្នុងករណីសួរថា តើជនជាប់ចោទត្រូវឃុំខ្លួនប៉ុន្មាននោះ គឺវាអាស្រ័យទៅតាមបទល្មើសមជ្ឈិម ឬឧក្រិដ្ឋ ឬតាមអាយុជនជាប់ចោទ។

- អាយុក្រោម ១៤ឆ្នាំ អត់ឃុំបានទេ
- ពី ១៤ ទៅ ១៦ ឆ្នាំ បើបទមជ្ឈឹមឃុំខ្លួនបាន ២៤ ម៉ោង បទឧក្រិដ្ឋអាចឃុំបាន ៣៦ ម៉ោង
- ពីអាយុ ១៦ ទៅ ១៨ ឆ្នាំ: បទមជ្ឈិម ៣៦ ម៉ោង បទឧក្រិដ្ឋ ៤៥ ម៉ោង
- ជានីតិជន:បទមជ្ឈិមអាចឃុំខ្លួន ៤ខែ នឹងអាចសុំពន្យារបាន ២ ខែទៀត។ បើបទឧក្រិដ្ឋអាចឃុំខ្លួន ១៨ ខែ ហើយបើបទឧក្រិដ្ឋអន្តរជាតិឃុំបាន ៣ឆ្នាំ ដូចជាករណី ខៀវ សំផន នួន ជា (មេខ្មែរក្រហម) ជាដើម។

# ផ្នែកទី១០

# ស្វែងយល់ពីការស្នើសុំលើកលែងទោសរបស់ទណ្ឌិត

លោក ផេង ហេង មេធាវីនៅ BBC LAW FIRM សហការី

លោកមេធាវី ផេង ហេង បច្ចុប្បន្ននេះ គឺជាមេធាវីនៅក្រុមមេធាវី BBC LAW FIRM មានការិយាល័យ នៅផ្ទះលេខ ១៤ CEo ផ្លូវលេខ ៣៨៤ សង្កាត់ទួលស្វាយព្រៃ ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ លោកមេធាវីកើតនៅ ឆ្នាំ១៩៦៩ នៅភូមិព្រែកតាបែន ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និង មានបងប្អូនចំនួន ៤ នាក់ហើយលោក គឺជាកូនទី ៣។ លោកបានបញ្ចប់ការសិក្សាបរិញ្ញាបត្រគីមីវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ ១៩៩៥ បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ១៩៩៨ និងបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) នីតិសាធារណៈនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (PUC) នៅឆ្នាំ២០០៦។

លោកមេធាវី ផេង ហេង បានផ្តល់កិច្ចសម្ភាសន៍ជាមួយកាសែតភ្នំពេញប៉ុស្តិ៍ ផ្អែកលើច្បាប់ស្ថិតជាធរមានពាក់ព័ន្ធនឹងការសុំលើកលែង ការអនុវត្តទោស ការបន្ធូរបន្ថយទោស និងស្រូបទោសរបស់អ្នកទោស ឬទណ្ឌិត ដែលមានខ្លឹមសារជាអាទិ៍ដូចខាងក្រោមនេះ៖

**១.យោងតាមច្បាប់ប្រទេសកម្ពុជាយើងថា តើនៅពេលណាខ្លះ ដែលអ្នកទោស ឬទណ្ឌិតជាប់ឃុំនៅក្នុងពន្ធនាគារអាចស្នើសុំការប្រទានលើកលែងទោសពីព្រះមហាក្សត្របាន?**

ក្នុងការស្នើសុំលើកលែងការអនុវត្តទោស ឬបន្ធូរបន្ថយទោសអ្នកទោស ឬទណ្ឌិត អាចធ្វើទៅបាន ២ យ៉ាង គឺ

- ទី១៖ គឺការដាក់ពាក្យសុំបន្ធូរបន្ថយទោស។ ចំណុចនេះ អ្នកទោសដាក់ពាក្យស្នើសុំបាន មិនកំណត់ថា អ្នកទោសនោះបានអនុវត្តទោសបានពាក់កណ្តាល ឬអនុវត្តទោសចប់ជាស្ថាពរនោះទេ។ ពួកគេអាចដាក់ពាក្យស្នើសុំបន្ធូរបន្ថយទោសថ្វាយទៅព្រះមហាក្សត្របានតាមរយៈប្រធានពន្ធនាគារ ឬមូលវិចាររបស់ប្រធានពន្ធនាគារឡើងតាមលំដាប់លំដោយទៅប្រធានគណៈកម្មការអន្តរក្រសួងមួយ (ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ) សម្រាប់ធ្វើការវាយតម្លៃ និងដាក់សំណើតាមរយៈក្រសួងពីរនេះ ដាក់ជូនទៅនាយករដ្ឋមន្ត្រីដើម្បីសម្រេច។
- ទី២៖ គឺការស្នើសុំការលើកលែងអនុវត្តទោសមួយផ្នែករបស់ពួកគេ។ នេះមានន័យថា កាលណាអ្នកទោស ឬទណ្ឌិតនោះបានអនុវត្តទោសនៅក្នុងពន្ធនាគារបាន ២ ភាគ ៣ គិតចាប់តាំងពីថ្ងៃដែលគេឃុំខ្លួនគាត់ហើយ គឺគាត់អាចស្នើសុំទៅព្រះមហាក្សត្រ ដើម្បីសុំលើកលែងអនុវត្តទោសមួយផ្នែករបស់ខ្លួនបានដោយមានមូលវិចារពីប្រធានពន្ធនាគារ និងត្រូវធ្វើតាមលំដាប់លំដោយទៅប្រធានគណៈកម្មការអន្តរក្រសួងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ដាក់ជូននាយករដ្ឋមន្ត្រី ដើម្បីសម្រេច និងដើម្បីដាក់ថ្វាយព្រះមហាក្សត្រប្រទានការសម្រេច និងឡាយព្រះហស្តលេខាលើកលែងទោស។ តែការស្នើសុំខាងលើនេះ ជាទូទៅអ្នកទោសដែលជាប់ទោសក្រោម ៥ ឆ្នាំ អាចសុំបន្ធូរបន្ថយទោសម្តង បានត្រឹម ៦ ខែប៉ុណ្ណោះ ក្នុង ១ ឆ្នាំ រីឯអ្នកទោសដែលមានទោសលើសពី ១០ ឆ្នាំឡើងទៅម្តងអាចសុំបន្ធូរបន្ថយទោសបាន ១ ឆ្នាំ ក្នុង ១ ឆ្នាំ ចំណែកឯទណ្ឌិត ដែលបានអនុវត្តទោសបាន ២ ភាគ ៣ ហើយការលើកលែងអនុវត្តទោស គឺអាចធ្វើទៅបានទាំងស្រុងតែម្តង ប្រសិនមានការលើកលែងទោសពីអង្គព្រះមហាក្សត្រនោះ។ តែទោះជាមានការព្រះរាជទានលើកលែងទោស ឬបន្ធូរបន្ថយទោសពីព្រះមហាក្សត្រក៏ដោយ តែសំណងរដ្ឋប្បវេណីដែលមានចំពោះអ្នកទោស ឬទណ្ឌិតរូបនោះ នៅមានដដែលតាមសាលក្រម ឬសាលដីការបស់តុលាការ។

**២.បច្ចុប្បន្ននេះក្នុងមួយឆ្នាំៗ តើព្រះមហាក្សត្រមានអភ័យឯកសិទ្ធិប្រទានការលើកលែងទោសប៉ុន្មានដងដែរ?**

បច្ចុប្បន្ននេះការលើកលែងទោសពីព្រះមហាក្សត្រត្រូវធ្វើឡើងចំនួន ៣ លើកក្នុង ១ ឆ្នាំៗ។ ការលើកលែងទោសធ្វើនៅក្នុងពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ និងលយប្រទីប។

**៣.តើទណ្ឌិតប្រភេទណាដែលអាចដាក់ពាក្យសុំទៅតុលាការដើម្បីសុំស្រូបទោសបាន និងត្រូវភ្ជាប់ទៅដោយលក្ខខណ្ឌអ្វីខ្លះ? ក្នុងការសុំស្រូបទោសនោះ តើតុលាការត្រូវគណនាទោសយ៉ាងដូចម្តេចដែរ?**

តាមគោលការណ៍ច្បាប់ និងក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៥០១ អ្នកទោស ឬទណ្ឌិតម្នាក់អាចដាក់ពាក្យសុំតុលាការឲ្យស្រូបទោសបានលុះត្រាតែអ្នកទោសមានសាលក្រម ឬសាលដីកាផ្តន្ទាទោសច្រើន (យ៉ាងតិចពី ៣ សាលក្រមឡើងទៅ) ហើយសាលក្រមនោះទៀតសោត ក៏បានចូលជាស្ថាពរផង។ ដូច្នេះ ដើម្បីកុំឲ្យច្របូកច្របល់ នឹងសាលក្រម និងសាលដីកាជាច្រើននោះគេអាចដាក់ពាក្យសុំឲ្យតុលាការដើម្បីធ្វើការស្រូបទោសបាន។ ការស្រូបនេះ ឧទាហរណ៍ថា សំណុំរឿង ១ ជនជាប់ចោទត្រូវជាប់ទោស ៥ឆ្នាំ ១ ទៀតជាប់ទោស ៧ ឆ្នាំ និង ១ ផ្សេងទៀតជាប់ទោស ៨ ឆ្នាំ ដល់តុលាការស្រូបទោសសម្រាប់យកទៅអនុវត្តមានទោសតែ ៨ ឆ្នាំប៉ុណ្ណោះ។ ករណីនេះ ទាល់តែទណ្ឌិតនោះមានមូលហេតុច្បាស់លាស់ដែលអាចបញ្ជាក់តុលាការឲ្យជឿថា គាត់មានអត្តចរិតកែប្រែ មានអត្តចរិតល្អ គាត់ខំអប់រំកាយ និងចិត្ត នៅក្នុងមណ្ឌលកែប្រែ គាត់ចង់ក្លាយទៅជាបុគ្គលថ្មី ស្អាតសមជាពលរដ្ឋល្អ។ល។ និង។ល។ នោះទើបគាត់អាចទទួលបានផលប្រយោជន៍ ហើយអាចត្រូវតុលាការសម្រេចស្រូបទោសដោយសម្រេចកំណត់ទោសគាត់អតិបរមាណាមួយ ក្នុងសាលក្រមស្ថាពរណាមួយដែលគាត់មាន។

**៤.បច្ចុប្បន្នតើអ្នកទោស ឬទណ្ឌិតដែលកំពុងតែជាប់ឃុំនៅពន្ធនាគារនៅកម្ពុជា បានយល់ដឹងអំពីការសុំលើកលែងទោសពីព្រះមហាក្សត្រ ឬការសុំឲ្យតុលាការស្រូបទោសនេះកម្រិតណាដែរ?**

តាមការអង្កេតផ្ទាល់របស់ខ្ញុំ បច្ចុប្បន្ននេះទណ្ឌិតដែលកំពុងតែជាប់ពន្ធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងបានយល់ដឹងច្រើនអំពីគោលការណ៍សុំលើកលែងអនុវត្តទោស ឬបន្ធូរបន្ថយទោសពីព្រះមហាក្សត្រ ឬការសុំឲ្យតុលាការធ្វើការស្រូបទោស។ ក៏ប៉ុន្តែចំនួនអ្នកទោស ឬទណ្ឌិត ដែលបានដាក់ពាក្យសុំប៉ុន្មាននោះ ខ្ញុំមិនបានដឹងពិតប្រាកដទេ។

# ផ្នែកទី១១

## ហេតុអ្វីច្បាប់តម្រូវឲ្យមានការព្យួរទោស?

លោកមេធាវី ឡុង ដារ៉ា bakc.org.kh

លោកមេធាវី ឡុង ដារ៉ា មានអត្តលេខ ២២៧ ជាសមាជិកក្រុមប្រឹក្សា និងជាប្រធានក្រុមការងារស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយច្បាប់របស់ក្រុមប្រឹក្សាគណៈមេធាវីបានផ្ដល់បទសម្ភាសន៍ជាមួយភ្នំពេញប៉ុស្ដិ៍ ជុំវិញការសម្រេចព្យួរទោសជនជាប់ចោទណាម្នាក់ដោយផ្អែកលើបញ្ញត្តិច្បាប់នៅកម្ពុជាមានខ្លឹមសារដូចខាងក្រោម៖

**១.ដូចម្ដេចដែលហៅថា ការព្យួរទោស?**

ការព្យួរទោស គឺជាការប្រកាសរបស់តុលាការដែលអាចបង្គាប់ថា ត្រូវព្យួរការអនុវត្តនូវមូលទោស ហើយការប្រកាសទោសព្យួរនេះ ត្រូវគិតតែអំពីការផ្ដន្ទាទោសជាស្ថាពរខាងបណ្ដឹងអាជ្ញាតែប៉ុណ្ណោះ។ (មាត្រា ១០៤ និង ១០៥) ។

**២.តើការព្យួរទោសបែងចែកជាប៉ុន្មានផ្នែក?**

ការព្យួរទោសបែងចែកជាពីរផ្នែក គឺផ្នែកធម្មតា និងផ្នែកសាកល្បង។

***ការព្យួរទោសធម្មតា***

ការព្យួរទោសធម្មតាត្រូវតែពិនិត្យអំពីការចោទប្រកាន់របស់តំណាងអយ្យការពីបទឧក្រិដ្ឋបទមជ្ឈិមនិងបទលហុផងដែរ។

ក-ការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមៈ

- លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឲ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោសជាស្ថាពរឲ្យជាប់ពន្ធនាគារក្នុងរយៈពេល ០៥ឆ្នាំ មុនអំពើល្មើស។ (មាត្រា ១០៦)
- ទោសដែលនាំឲ្យមានការព្យួរ
  +ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាងឬស្មើនឹង ៥ឆ្នាំ។
  +ទោសពិន័យជាប្រាក់។ (មាត្រា ១០៧)
- ការព្យួរទោសមួយផ្នែកៈ តុលាការអាចសម្រេចថាការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសដាក់ពន្ធនាគារដែលតុលាការជាអ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់។ (មាត្រា ១០៨)
- ការដកហូតការព្យួរទោសៈ ប្រសិនបើក្នុងរយៈពេល០៥ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតាហើយមានការផ្ដន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី២បាន។ (មាត្រា ១០៩)
- ការមិនដកហូតទោសព្យួរៈ ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការមិនដកហូតទោសព្យួរ) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្ដន្ទាទោសថ្មីមិននាំឲ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុនទេ។ សេចក្ដីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស។ (មាត្រា ១១០)
- ការទុកជាអសារបង់នូវការផ្ដន្ទាទោសៈ ប្រសិនបើមានរយៈពេល ០៥ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតាហើយគ្មានការផ្ដន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ

ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានការព្យួរនោះត្រូវចាត់ទុកជាអសារបង់។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតដែរ។ (មាត្រា ១១១)

ខ-ការចោទប្រកាន់ចំពោះបទលហុ:

លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន "ក្នុងករណីការចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាសប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយនៅក្នុងរយៈពេល ០១ឆ្នាំ មុនបទល្មើសនេះ"។ (មាត្រា ១១២)

- ទោសដែលនាំឲ្យមានការព្យួរ
  - + ទោសដាក់ពន្ធនាគារ
  - + ទោសពិន័យជាប្រាក់ (មាត្រា ១១៣)
- ការដកហូតទោសព្យួរ ប្រសិនបើក្នុងរយៈពេល ០១ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុ ដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋបទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះត្រូវដកហូតវិញដោយពេញច្បាប់។ ទោស ទី១ ត្រូវអនុវត្តដោយគ្មានការស្រូបទោសជាមួយទោសទី២ ឡើយ។ (មាត្រា ១១៤)
- ការមិនដកហូតការព្យួរទោស: ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតទោសព្យួរ) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឲ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលសម្រេចពីមុននោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។ (មាត្រា ១១៥)
- ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស: ប្រសិនបើក្នុងរយៈពេល ០១ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុ ដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលត្រូវព្យួរនេះ ត្រូវចាត់ទុកជាអសារបង់។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។ (មាត្រា ១១៦)

***<u>ការព្យួរសាកល្បង</u>***

ក- លក្ខខណ្ឌនៃការព្យួរទោសសាកល្បង: តុលាការអាចសម្រេចព្យួរទោសសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារចាប់ពី ០៦ ខែទៅ ០៥ឆ្នាំ។ ការព្យួរទោសសាកល្បងមានអនុភាពដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យនិងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង។ (មាត្រា ១១៧)

ខ-រយៈពេលនៃការសាកល្បង: តុលាការកំណត់រយៈពេលនៃការសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ០១ឆ្នាំ និងមិនលើសពី ០៣ ឆ្នាំទេ។ (មាត្រា ១១៨)

គ-វិធានការត្រួតពិនិត្យ: វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិតមាន៖

- ទណ្ឌិតត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។
- ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។
- ទណ្ឌិតត្រូវប្រគល់អំណាចដល់ព្រះរាជអាជ្ញា ឬបុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឲ្យរស់នៅក្នុងសង្គមវិញ។
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។

- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបរ។
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាមុនពេលធ្វើដំណើរទៅបរទេស។ (មាត្រា ១១៩)

ឃ-កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត: កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិតមានៈ

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ
- ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ
- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់
- ទទួលឲ្យពេទ្យធ្វើការពិនិត្យនិងព្យាបាល
- បញ្ជាក់ថា ខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ
- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃការជានារបស់ខ្លួន។
- បញ្ជាក់ថា ខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោសតាមលទ្ធភាពនៃការជានារបស់ខ្លួន។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលអនុញ្ញាតឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។
- មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់។
- មិនត្រូវសេពគប់បនល្បែង និងមិនត្រូវសេពគប់ភេសជ្ជៈស្រវឹង និងមិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពី បុគ្គលដែលមិនត្រូវសេពគប់ជាមួយ។
- មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត។ (មាត្រា ១២០)

ង- ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការៈ នៅគ្រប់ពេលវេលាតុលាការអាចកែប្រែកាតព្វកិច្ចដោយឡែក ដែលតម្រូវលើទណ្ឌិតបាន។ តុលាការត្រូវទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធី ព្រហ្មទណ្ឌ។ (១២១)

ច- ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយ តុលាការនៅក្នុងករណីដូចខាងក្រោមៈ

- ប្រសិនបើ ក្នុងរយៈពេលសាកល្បងទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យឬកាតព្វកិច្ចដោយឡែកទេ។
- ប្រសិនបើក្នុងរយៈពេលសាកល្បងទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមថ្មីទៀត។

តុលាការអាចបង្គាប់ឲ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក។ នៅក្នុងករណីនេះទោសត្រូវបាន យកមកអនុវត្តទាំងមូលឬមួយផ្នែក។ តុលាការត្រូវបានទទួលបណ្តឹងក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធី ព្រហ្មទណ្ឌ។ (១២២)

ឆ- ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់ៈ ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ប្រសិនបើមានការផុតរយៈ ពេលសាកល្បងការផ្តន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូត ដែលមានសេចក្តីសម្រេចដកហូតទេ។ (មាត្រា ១២៣)

**៣.ហេតុអ្វីបានជាច្បាប់តម្រូវឲ្យមានការព្យួរទោស?**

បានជាច្បាប់តម្រូវឲ្យមានការព្យួរទោសដោយហេតុថា គ្រប់ការផ្តន្ទាទោសទាំងអស់ទៅលើជនល្មើសគឺជាវិធានការអប់រំជនល្មើសឲ្យទទួលនូវទោស និងកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តមកលើជនរងគ្រោះខាងផ្លូវកាយផ្លូវចិត្តទ្រព្យសម្បត្តិ និងកិត្តិយសកេរ្តិ៍ឈ្មោះក្នុងសង្គមបណ្តាលឲ្យមានព្យសនកម្មជា (រូបិយនិងអរូបិយ) ដែលជាបច្ច័យមិនល្អនៅក្នុងសង្គម។

ការព្យួរទោសមានន័យថា ជនល្មើស ឬទណ្ឌិតដែលបានប្រព្រឹត្តបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ជាជនដែលមានការទទួលខុសត្រូវអំពីទោសកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តលើជនរងគ្រោះ ហើយមានវិប្បដិសារីស្តាយក្រោយ ឬទទួលយល់ព្រមផ្តល់សំណងរដ្ឋប្បវេណីជូនជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីតាមទំហំនៃការខូចខាតដែលមានចែងក្នុងសាលក្រម ឬសាលដីការបស់តុលាការដែលបានប្រកាសរួចហើយ។

ការព្យួរទោស គឺជាវិធានការដាក់ទណ្ឌកម្មអប់រំជនល្មើស ឬទណ្ឌិតនៅក្រៅពន្ធនាគារដើម្បីបង្ហាញពីចរិតលក្ខណៈយល់ព្រមកែប្រែខ្លួនតាមការបង្គាប់របស់តុលាការ និងបង្ហាញពីទណ្ឌកម្មរបស់ជនល្មើស ឬទណ្ឌិតឲ្យជនរងគ្រោះទទួលបាននូវអារម្មណ៍ស្ងប់ខាងផ្លូវកាយ និងផ្លូវចិត្ត ដែលមានលក្ខណៈសមស្របនឹងអាចទទួលយកបាននូវយុត្តិធម៌តាមផ្លូវច្បាប់។

**៤.ប្រសិនជនដែលត្រូវតុលាការសម្រេចព្យួរទោស តែមិនរាងចាល តើត្រូវមានវិធានការយ៉ាងណា?**

ជនល្មើស ឬទណ្ឌិតដែលតុលាការប្រកាសទោសព្យួរធម្មតាក្តី ទោសព្យួរសាកល្បងក្តី ហើយមិនកែប្រែ ឬមិនរាងចាលដោយបាន៖

- ល្មើសនិងវិធានការត្រួតពិនិត្យរបស់តុលាការតាមមាត្រា ១២០ ចំណុច ទី១ ចែងថា៖ "ប្រសិនបើក្នុងរយៈពេលសាកល្បងទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬ កាតព្វកិច្ចដោយឡែកទេ"។
- ល្មើសដោយប្រព្រឹត្តបទល្មើសថ្មីតាមមាត្រា ១២០ ចំណុច ទី២ ចែងថា៖ "ប្រសិនបើក្នុងរយៈពេលសាកល្បងទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទ ឧក្រិដ្ឋឬបទមជ្ឈិមថ្មីទៀត"។ តុលាការត្រូវផ្តន្ទាទោសបទល្មើសថ្មីតាមច្បាប់ហើយទោសព្យួរឲ្យនៅក្រៅឃុំត្រូវយកមកអនុវត្តជាមូលទោសដាក់ពន្ធនាគារតាមការប្រកាសសាលក្រមឬសាលដីកាលើក ទី១ ដែលខ្លួនបានទទួលដោយមិនស្រូបបញ្ចូលនិងទោសថ្មីទៀតឡើយ។

# ផ្នែកទី១២

# អ្វីជាការស្រូបទោសដែលច្បាប់បានបញ្ញត្តិ

លោកមេធាវី ឡុង ដារ៉ា អត្តលេខ ២២៧ សមាជិកក្រុមប្រឹក្សាគណៈមេធាវី

លោកមេធាវី ឡុង ដារ៉ា អត្តលេខ ២២៧ ជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយច្បាប់ បានផ្តល់សម្ភាសន៍ឲ្យភ្នំពេញប៉ុស្តិ៍ ដោយធ្វើការពន្យល់ជុំវិញប្រធានបទស្តីពីសេចក្តីសម្រេចស្រូបទោសសម្រាប់ទណ្ឌិត ផ្អែកទៅលើបញ្ញត្តិច្បាប់របស់កម្ពុជា ដែលកំពុងស្ថិតជាធរមានមានខ្លឹមសារជាអាទិ៍ដូចខាងក្រោមៈ

**១.ដូចម្តេចហៅថា ការស្រូបទោស?**

ការស្រូបទោស គឺជាវិធានមួយដែលគេប្រើក្នុងការប្រកាសទោសរួមនៃបទល្មើសត្រួតគ្នាក្នុងព្រំដែននៃអតិបរមាស្របច្បាប់ ដែលត្រូវអនុវត្តលើបទល្មើសនីមួយៗ។ គឺមានន័យថា មានទោសច្រើនស្ថិតនៅក្នុងទោសប្រកាសដោយតុលាការ ហើយទោសទាំងនោះត្រូវយកទៅអនុវត្តនៅក្នុងពេលតែមួយប៉ុណ្ណោះ។

**២.តើការសម្រេចស្រូបទោសនេះ អាចមានចែកចេញជាប៉ុន្មានប្រភេទ?**

ការស្រូបទោសនេះចែកជា ២ ប្រភេទ គឺការស្រូបទោសមុនជំនុំជម្រះ និងការស្រូបទោសក្រោយជំនុំជម្រះ។

**៣.ដូចម្តេចដែលហៅថា ការស្រូបទោសមុនជំនុំជម្រះ និង ការស្រូបទោសក្រោយពេលជំនុំជម្រះ?**

- ការស្រូបទោសមុនជំនុំជម្រះ គឺប្រសិនបើសំណុំរឿងដែលកំពុងស្ថិតក្នុងដំណើរការ នីតិវិធីស៊ើបអង្កេតរបស់តុលាការនៅឡើយ នោះតុលាការអាចនឹងសម្រេចដោយឯកឯង មិនចាំបាច់មានបណ្តឹងសុំពីសំណាក់ភាគីដែលពាក់ព័ន្ធអំពីការស្រូបទោសនេះទេ ស្របតាមបញ្ញត្តិមាត្រា ១៣៧ និង មាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ។ លើសពីនេះទៀត ប្រសិនបើតុលាការមិនបានសម្រេចអំពីការស្រូបទោសនេះទេ ស្ថាប័នអយ្យការ ឬ ភាគីដែលពាក់ព័ន្ធអាចប្តឹងសុំឲ្យអនុវត្តការស្រូបទោសបញ្ចូលគ្នាទៅតុលាការដែលបានសម្រេចចុងក្រោយគេ ស្របតាមមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មិនតែប៉ុណ្ណោះនៅក្នុងការអនុវត្តវិធានស្រូបទោសនេះ គឺត្រូវឲ្យស្របតាមមាត្រា ១៣៧ ឬមាត្រា ១៣៨ កថាខណ្ឌ ១ វាក្យខណ្ឌ ទី២ នៃក្រមព្រហ្មទណ្ឌពោលគឺ កាលបើមានទោសច្រើន ដែលជាទោសប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។
- ការស្រូបទោសក្រោយជំនុំជម្រះ គឺតុលាការចុងក្រោយដែលជាអ្នកប្រកាសពិរុទ្ធភាពនៃជនល្មើសអាចប្រកាសវិធានស្រូបទោសលើបទល្មើសបន្ថែមដែលបានរកឃើញ ហើយតុលាការចុងក្រោយអាចសម្រេចថា ទោសដែលតុលាការចុងក្រោយបានប្រកាស ត្រូវតែអនុវត្តស្រូបបញ្ចូលគ្នាជាមួយនឹងទោស ដែលត្រូវបានប្រកាសពីលើកមុនរួចហើយ។

**៤.តើការស្រូបទោសនេះអាចធ្វើទៅបានលុះត្រាតែពិរុទ្ធជនដាក់ពាក្យប្តឹង ឬមាននីតិវិធីផ្សេងយ៉ាងដូចម្តេច?**

វិធាននៃការស្រូបទោសនេះ អាចធ្វើឡើងក្នុងលក្ខខណ្ឌ ២ គឺៈ

- តាមឆន្ទានុសិទ្ធិរបស់តុលាការប្រសិនបើតុលាការយល់ឃើញថា ទោសមានប្រភេទដូចគ្នា និងស្ថិតក្នុងកាលៈទេសៈផ្សេងៗដែលអាចឲ្យគាត់អនុវត្តវិធានស្រូបទោសបានដោយស្របតាមមាត្រា ១៣៧ និង មាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ។

– ប្រសិនបើតុលាការដំបូងមិនបានសម្រេចវិធានស្រូបទោសទេ គឺ ស្ថាប័នអយ្យការ ឬ ភាគីដែលពាក់ព័ន្ធអាចប្តឹងសុំឲ្យអនុវត្តការស្រូបទោសបញ្ចូលគ្នាទៅតុលាការសម្រេចចុងក្រោយគេ ស្របតាមមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បាន។

**៥.ហេតុអ្វីបានជាតម្រូវឲ្យមានការស្រូបទោសសម្រាប់ជនជាប់ចោទ?**

ជាទូទៅវិធាននៃការស្រូបទោសនេះ គឺជាគោលការណ៍មួយក្នុងច្បាប់ដែលមានលក្ខណៈ ផ្តល់ផលវិជ្ជមានដល់ទណ្ឌិត ពីព្រោះថា អ្នកដែលបង្កើតច្បាប់ព្រហ្មទណ្ឌ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civillaw) គេបានគិតទៅលើអាយុជាមធ្យមរបស់មនុស្សមានន័យថា មនុស្សម្នាក់អាចរស់បានជាមធ្យម (ប្រុស ៥៥ឆ្នាំ និងស្ត្រី ៦០ឆ្នាំ)។ ដូចនេះប្រសិនបើតុលាការប្រកាសទោសដោយការបូកទោសចូលគ្នា នោះទោសដែលត្រូវអនុវត្តមកលើទណ្ឌិត គឺវាហួសពីអាយុនៃទណ្ឌិតមានជីវិតរស់នៅទៅទៀត ហើយដែលកត្តាដូចនេះក៏ពុំមានផ្តល់ផលអ្វីវិជ្ជមានដល់សង្គម និងភាគីពាក់ព័ន្ធឡើយ។

**៦.តើកាលៈទេសៈខ្លះបែបណាតម្រូវឲ្យមានការស្រូបទោសនេះបាន?**

កាលៈទេសៈ ដែលតម្រូវឲ្យមានការស្រូបទោសទៅបានរួមមាន៖

ក-វិធានច្បាប់ដែលបានចែងអំពីការស្រូបទោស។

ខ-ឆន្ទានុសិទ្ធិរបស់ចៅក្រមដែលយល់ឃើញតាមលក្ខខណ្ឌនៃច្បាប់។

គ-បណ្តឹងស្នើសុំរបស់ភាគីដែលពាក់ព័ន្ធ។

**៧.ឧទាហរណ៍ថាៈ បើពិរុទ្ធជនម្នាក់មានសំណុំរឿង ៥ ករណីហើយមានទោសពី ៥ឆ្នាំ ដល់ ២០ឆ្នាំ តើតុលាការកំណត់ឲ្យគាត់ស្រូបទោសណាមួយ?**

នៅក្នុងអង្គហេតុនេះ យើងអាចបែងចែកជា ២ ករណី៖

– ករណីទី១៖ ការស្រូបទោសមុនជម្រះប្រសិនពិរុទ្ធជននោះ ត្រូវបានស្ថាប័នអយ្យការចោទប្រកាន់ច្រើនបទល្មើសដូចគ្នា តុលាការមិនទាន់កាត់ទោសនៅឡើយ ហើយទណ្ឌិត ឬភាគីពាក់ព័ន្ធស្នើសុំទៅចៅក្រមជំនុំជម្រះដំបូងកំណត់អំពីវិធានស្រូបទោសក្នុងបទល្មើសទាំង ៥ គឺកំណត់បទល្មើសណាដែលមានទណ្ឌកម្មខ្ពស់ជាងគេ តាមមាត្រា ១៣៧ និង ១៣៨ នៃក្រមព្រហ្មទណ្ឌ។

– ករណីទី២ៈ ការស្រូបទោសក្រោយជម្រះទណ្ឌិតត្រូវដាក់ពាក្យស្នើសុំបញ្ចូលសំណុំរឿងទាំងអស់ (៥ ករណី) ទៅចៅក្រមប្រឹក្សាជំនុំជម្រះចុងក្រោយដើម្បីកំណត់អំពីទណ្ឌកម្មស្រូបទោស។

ឧទាហរណ៍ៈ ទោសទាំង ៥ ករណី តុលាការសម្រេចរួចហើយ៖

- បទល្មើស ទី ១ ផ្តន្ទាទោស ០៧ ឆ្នាំ
- បទល្មើស ទី ២ ផ្តន្ទាទោស ០៨ ឆ្នាំ
- បទល្មើស ទី ៣ ផ្តន្ទាទោស ០៦ ឆ្នាំ
- បទល្មើស ទី ៤ ផ្តន្ទាទោស ០៩ ឆ្នាំ
- បទល្មើស ទី ៥ ផ្តន្ទាទោស ១០ ឆ្នាំ

ដូច្នេះក្នុងចំណោមទោសទាំង ៥ នេះ អតិបរមានៃទោសដែលខ្ពស់ជាងគេបំផុតគឺ ១០ឆ្នាំ។ តាមច្បាប់ទណ្ឌកម្ម ដែលត្រូវកំណត់ដើម្បីស្រូបទោសរបស់ទណ្ឌិតនោះ គឺ ១០ឆ្នាំ។

# វគ្គទី១៣

## ចៅក្រមចេញសាលក្រមចាត់វៀបពេលណា?

លោក មួង សុគន្ធ ជាមេធាវីបម្រើការនៅក្រុមមេធាវី អេ-ហ្សេត A-Z LAW FIRM និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ លោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយភ្នំពេញប៉ុស្តិ៍ លើប្រធានបទទាក់ទងនឹងការចាត់របៀបរបស់តុលាការមានខ្លឹមសារជាអាទិ៍ ដូចខាងក្រោមនេះ៖

**១.តើនៅពេលណា ឬមានសំអាងបែបណា ដែលតុលាការប្រកាសចាត់របៀបក្នុងសំណុំរឿងក្តីណាមួយបាន?**

នៅពេលដល់ដំណាក់កាលជំនុំជម្រះ ឬនៅពេលដែលតុលាការរកឃើញភាពចន្លោះប្រហោង និងមិនទាន់មានភាពច្បាស់លាស់ ឬតាមការស្នើសុំរបស់ភាគីណាមួយ ឬតាមការស្នើសុំរបស់មេធាវីដោយសារតែរឿងនោះមានភាពមិនទាន់ច្បាស់លាស់។ ដូច្នេះចៅក្រមត្រូវតែចេញសាលក្រមចាត់របៀបឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេតករណីឬសំណុំរឿងក្តីនោះឡើងវិញ។ ឧទាហរណ៍ថា៖ ពាក់ព័ន្ធនឹងការធ្វើកោសល្យវិច័យ ឬការសួរសាក្សីមិនទាន់អស់នៅក្នុងសំណុំរឿង ឬការបកប្រែភាសា ជាការជេរប្រមាថអ្វីមួយជាភាសាចិន ភាសាអង់គ្លេស ឬភាសារុស្ស៊ី ។ល។ ពីព្រោះថា នៅក្នុងភាសារបស់សាសន៍គេ ឬខ្លឹមសាររបស់គេ វាមានន័យផ្សេង ហើយភាគីម្ខាងបានបកប្រែដោយខ្លួនឯង ឬក្រៅផ្លូវការដាក់ជូនតុលាការ។ ក៏ប៉ុន្តែត្រូវភាគីក្តីម្ខាងទៀតជំទាស់ និងស្នើសុំទៅចៅក្រមជំនុំជម្រះធ្វើការចាត់របៀបដូច្នេះចៅក្រមជំនុំជម្រះក៏បានសម្រេចចេញដីកាចាត់របៀបដើម្បីអ្នកជំនាញឯករាជ្យធ្វើការបកប្រែជាផ្លូវការ និងពន្យល់ឡើងវិញ ឬ ធ្វើកោសល្យវិច័យឡើងវិញ។

ការប្រកាសចាត់របៀបនេះ អាចធ្វើទាំងនៅពេលកំពុងតែធ្វើសវនាការជំនុំជម្រះ នៅពេលដែលមានអង្គហេតុបានលេចឡើងពីក្នុងសំណុំរឿងក្តី ឬនៅពេលដែលមានការតវ៉ាពីភាគីណាមួយនៅក្នុងសំណុំរឿងដែលគេយល់ថា វាបានខាតប្រយោជន៍ដល់ភាគីខ្លួនហើយភាគីនោះអាចស្នើសុំឲ្យតុលាការចាត់របៀប។ ការស្នើសុំឲ្យតុលាការធ្វើការចាត់របៀបនេះអាចធ្វើឡើងដោយភាគីនៅក្នុងរឿងក្តី ឬព្រះរាជអាជ្ញាដែលកាន់រឿងក្តីនោះ។

**២.តើការចេញសាលក្រមចាត់របៀបនេះ មានផលវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះ ដល់គូភាគីក្នុងជម្លោះ?**

គោលការណ៍របស់ចៅក្រមជំនុំជម្រះធ្វើយ៉ាងណាគឺផ្តល់យុត្តិធម៌ដល់គូភាគីទាំងសងខាង គឺមានន័យថា ការពារទាំងភាគីដើមចោទ និងភាគីចុងចោទ។ ភាគីដើមចោទ មានតំណាងអយ្យការ និងម្ចាស់ដើមបណ្តឹង ទាំងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ ដូច្នេះគាត់ការពារទាំងផលប្រយោជន៍របស់តំណាងអយ្យការផង ទាំងផលប្រយោជន៍ភាគីដើមបណ្តឹងផង និងត្រូវតែគោរពសិទ្ធិរបស់ភាគីចុងចោទផងដែរ។ រឿងនេះប្រដូចទៅនឹងសុភាសិតខ្មែរយើង ដែលតែងតែនិយាយថា “កាន់កពស់កាន់ឲ្យជាប់កុំឲ្យក្រឡាប់ខាំឯប្រាណ អូសទូកកុំឲ្យ ល្អាន ទឹកថ្លាសោតកុំឲ្យល្អក់...។” ក្នុងការចាត់របៀបនេះ ជួនកាលនៅពេលចៅក្រមស៊ើបសួរ បើកការស៊ើបអង្កេតជាថ្មី វាអាចមានផលប្រយោជន៍ដល់ភាគីចុងចោទទៅវិញ។

ដូច្នេះ នៅពេលធ្វើសវនាការជំនុំជម្រះ និងប្រកាសសាលក្រមនោះចៅក្រមអាចសម្រេចឲ្យភាគីចុងចោទជាអ្នកឈ្នះក្តីឲ្យដើមបណ្តឹងអ្នកចាញ់ក្តីបាន។ ជួនកាលក៏អាចមានផលប្រយោជន៍ដល់ភាគីដើមបណ្តឹង ហើយនៅពេលប្រកាសសាលក្រមចៅក្រមជំនុំជម្រះអាចសម្រេចសេចក្តី ដោយឲ្យភាគីដើមបណ្តឹងជាអ្នកឈ្នះក្តីវិញ ហើយភាគីចុងចោទចាញ់ក្តីវិញបាន។

**៣.តើថេរវេលានៃការស៊ើបអង្កេតក្នុងដីកាចាត់របៀបរបស់តុលាការត្រូវប្រើពេលប៉ុន្មានដែរ តាមកំណត់ច្បាប់?**

ច្បាប់ពុំបានកំណត់ថេរវេលា ឬពេលវេលាជាក់លាក់ក្នុងការធ្វើការងារ ឬស៊ើបអង្កេតក្នុងដីកាចាត់របៀបនោះទេ។ តែជាគោលការណ៍ការចាត់របៀបនេះតម្រូវធ្វើឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ពីព្រោះថា បើធ្វើបានឆាប់រហ័ស វាបានផលប្រយោជន៍ដល់គូភាគីទាំងសងខាង។ ហេតុដូច្នេះហើយ បានជានៅក្នុងនីតិវិធីព្រហ្មទណ្ឌគេតម្រូវធ្វើឲ្យបានឆាប់តែបើរឿង

នេះអូសបន្លាយនោះ វាប៉ះពាល់និងធ្វើឲ្យអយុត្តិធម៌ដល់គូភាគីទាំងសងខាងដោយសារតែភាពយឺតយ៉ាវរបស់តុលាការ។ តុលាការធ្វើការយឺតយ៉ាវវាអាចផ្តល់ភាពអយុត្តិធម៌ដល់ភាគីជាគូក្តី។ ពីព្រោះនៅក្នុងដំណើរការនៃនីតិវិធីធ្វើការ និងស៊ើបអង្កេតរបស់តុលាការនាពេលសព្វថ្ងៃនេះ ត្រូវគេទទួលស្គាល់ថា រឿងមួយណាក៏យឺតយូរដែរ ដោយសារតែកត្តាផលប្រយោជន៍និងដោយសារតែចៅក្រមគាត់កាន់សំណុំរឿងច្រើនពេក ហើយមានពេលវេលាមិនគ្រប់គ្រាន់ផង។ សម្រាប់ការស៊ើបអង្កេត ក្នុងដីកាចាត់របៀបរបស់តុលាការសព្វថ្ងៃនេះ ខ្ញុំសូមស្នើឲ្យតុលាការធ្វើយ៉ាងម៉េចពន្លឿននីតិវិធី និងការងារឲ្យបានឆាប់ ដើម្បីផ្តល់ប្រយោជន៍សម្រាប់គូជម្លោះនៅក្នុងរឿងក្តីនីមួយៗ។

# ផ្នែកទី១៤
# បណ្តាំមរតកត្រូវធ្វើស្របតាមទម្រង់ច្បាប់

លោក ពិន វណ្ណៈ មេធាវីបម្រើការនៅក្រុមមេធាវីកម្ពុជាអន្តរជាតិនិងជាសមាជិករបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ លោកមេធាវីបញ្ចប់ការសិក្សា និងទទួលបានបរិញ្ញាបត្រច្បាប់នៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (បច្ចុប្បន្នសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) នៅក្នុងឆ្នាំ១៩៩៨។

លោកមេធាវី ពិន វណ្ណៈ បានផ្តល់កិច្ចសម្ភាសន៍ជាមួយភ្នំពេញប៉ុស្តិ៍ លើប្រធានបទទាក់ទងនឹងបណ្តាំមរតកនិងការបែងចែកទ្រព្យសម្បត្តិនៅក្នុងគ្រួសារដែលមានខ្លឹមសារដូចខាងក្រោម៖

**១.តើអ្វីទៅជាបណ្តាំមរតក? បណ្តាំមរតកមានប៉ុន្មានប្រភេទ និងត្រូវបានធ្វើឡើងដោយនរណាខ្លះ? និងសម្រាប់ជាប្រយោជន៍អ្វីដែរ?**

បណ្តាំមរតក ឬពាក្យច្បាប់ហៅថា មរតកសាសន៍។ មរតកសាសន៍ មានន័យថា ជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ដើម្បីសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនបន្ទាប់ពីទទួលមរណភាព។ បណ្តាំមរតក (មរតកសាសន៍) ពុំអាចធ្វើបានឡើយបើមិនគោរពតាមទម្រង់ដែលច្បាប់កំណត់ (ម.១១៧០)។ ផ្អែកតាមក្រមរដ្ឋប្បវេណីមរតកសាសន៍ត្រូវបានបែងចែកជា ៧ ទម្រង់។ ប៉ុន្តែ ខ្ញុំសូមលើកយកតែ ៥ ទម្រង់មកបកស្រាយ។ មរតកសាសន៍ត្រូវបានចាត់ជាទម្រង់ដោយឡែកៗពីគ្នាមានដូចជា៖

- មរតកសាសន៍ដោយលិខិតយថាភូត (តាមសេចក្តីពិតឬតាមដំណើរដែលកើតមានឡើងប្រាកដ) (ម.១១៧៣)៖ មរតកសាសន៍ប្រភេទនេះត្រូវធ្វើឡើងដោយសារការី ដោយតម្រូវឲ្យម្ចាស់បណ្តាំប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមរតកសាសន៍ចំពោះមុខសារការី ដោយមានសាក្សី ២ នាក់។
- មរតកសាសន៍ដោយលិខិតឯកជន (ម.១១៧៤)៖ មរតកសាសន៍ដោយលិខិតឯកជនត្រូវធ្វើឡើងដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់និងចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយចុះហត្ថលេខាលើលិខិតនោះ។ មរតកសាសន៍ក្នុងទម្រង់នេះចាំបាច់ត្រូវតែសរសេរផ្ទាល់ដៃរបស់ម្ចាស់បណ្តាំក្នុងករណីមានអ្នកសរសេរជំនួស ឬត្រូវសរសេរដោយកុំព្យូទ័រជាអាទិ៍ត្រូវចាត់ទុកជាមោឃៈ។
- មរតកសាសន៍ដោយលិខិតសម្ងាត់ (ម.១១៧៥)៖ មរតកសាសន៍ដោយលិខិតសម្ងាត់ត្រូវធ្វើឡើងដោយយោងតាមទម្រង់ដូចជា: (ក) ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ (ខ) ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិតហើយចុះហត្ថលេខា ឬសរសេរសញ្ញាសម្គាល់ជាអាទិ៍ដែលអាចឲ្យវិនិច្ឆ័យបានអំពីការបានបើកឬមិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិត (គ) ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះនៅចំពោះមុខសារការីម្នាក់និងសាក្សី ២ នាក់។
- មរតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ (ម.១១៧៦)៖ បើនិយាយក្នុងន័យជម្មតា មានន័យថា បណ្តាំមរតករបស់មនុស្សដែលមានសតិមិនប្រក្រតី។ ដូច្នេះ ដើម្បីធ្វើបានលុះណា តែជននោះបានធូរស្បើយនឹងអាចមានសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនទើបអាចធ្វើបាន ប៉ុន្តែត្រូវធ្វើនៅចំពោះមុខវេជ្ជបណ្ឌិតយ៉ាងតិច ២ រូប។
- មរតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (ម.១១៧៧)៖ មរតកសាសន៍នេះត្រូវបានធ្វើឡើងនៅពេលដែលមានជនដែលកំពុងមានគ្រោះថ្នាក់ដល់ជីវិត (ឧទាហរណ៍មនុស្សជិតស្លាប់) ឬមានជម្ងឺ ឬ ....

មានហេតុផលផ្សេងៗទៀត ដែលមិនអាចសង្ឃឹមថា នឹងអាចបន្តជីវិតបានហើយចង់ធ្វើមរតកសាសន៍។ ក្នុងស្ថានភាពនេះអាចធ្វើបានតែត្រូវមានវត្តមានសាក្សីយ៉ាងតិច ៣ នាក់ហើយម្ចាស់បណ្តាំត្រូវប្រកាសពីខ្លឹមសារទៅសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងអស់នោះ។ នៅក្នុងករណីនេះសាក្សីដែលស្តាប់ឮពីខ្លឹមសារដែលម្ចាស់បណ្តាំបានផ្តាំត្រូវអានឲ្យសាក្សីផ្សេងស្តាប់និងមើល ហើយសាក្សីទាំងអស់ត្រូវចុះហត្ថលេខា។

**២.ឧទាហរណ៍ថា ក្នុងគ្រួសារ ១ មានកូនប្រុសស្រីចំនួន ៥ នាក់ហើយឪពុកម្តាយបានធ្វើបណ្តាំមរតក បែងចែកទ្រព្យសម្បត្តិនៅមុនពេលគាត់ធ្វើមរណកាលទៅ តើក្រោយពួកគាត់ស្លាប់ទៅក្នុងករណីបែបនេះ ការបែងចែកទ្រព្យសម្បត្តិត្រូវធ្វើរបៀបណាដែរបើតាមច្បាប់?**

ដោយសារមរតកសាសន៍ត្រូវបានធ្វើឡើងតាមឆន្ទៈរបស់ម្ចាស់បណ្តាំដូច្នេះ បើនៅក្នុងបណ្តាំនោះម្ចាស់បណ្តាំបានបែងចែកទ្រព្យសម្បត្តិឲ្យអ្នកណាអ្នកនោះនឹងបានទទួលតាមចំណែកស្របតាមខ្លឹមសារនៃមរតកសាសន៍នោះ។

**២.ចំពោះករណីឪពុកម្តាយ ឬម្ចាស់មរតកដែលមានទ្រព្យសម្បត្តិច្រើនតែមិនបានធ្វើបណ្តាំមរតកទុកឲ្យកូនចៅវិញ។ តើក្រោយពេលពួកគាត់ស្លាប់ទៅ ក្នុងករណីបែបនេះ ការបែងចែកទ្រព្យសម្បត្តិគប្បីត្រូវធ្វើបែបណាដែរ?**

បើសិនជាមិនមានបណ្តាំមរតកទេ ការបែងចែកមរតកត្រូវបែងចែកតាមច្បាប់កំណត់ (សន្តតិកម្មតាមច្បាប់កំណត់) ពោលគឺទទួលចំណែកស្មើៗគ្នា។ ក្នុងករណីនេះដោយសារ កូនគឺជាសន្តតិជន (ជនដែលអាចទទួលបានមរតក) លំដាប់ ទី១ នោះបើកូនមាន ២ នាក់នោះមរតក ត្រូវបែងចែកឲ្យកូនក្នុងម្នាក់ ១ ភាគ ២ នៃទ្រព្យសរុប។

**៣.ចំពោះបុគ្គលដែលមានទ្រព្យសម្បត្តិតែគ្មានប្រពន្ធ ឬប្តីឬសាច់ញាតិអ្វីទាំងអស់(ជនឯកោ)។ នៅពេលដែលគាត់ស្លាប់ទៅ តើទ្រព្យសម្បត្តិរបស់គាត់នោះ ត្រូវបែងចែក ឬប្រគល់ឲ្យ ឬនរណាខ្លះដែលអាចទទួលបានបើតាមច្បាប់? តើសំអាងហេតុអ្វីដែរ?**

ក្នុងករណីនេះ ត្រូវរកមើលម្ចាស់បំណុលរបស់គាត់កាលនៅរស់សិន។ បើគាត់មានជាប់បំណុលពីគេត្រូវយកទ្រព្យរបស់គាត់ទៅទូទាត់នឹងបំណុលឲ្យរួចអស់សិន។ ក្នុងករណីគ្មានម្ចាស់បំណុល ឬទ្រព្យសម្បត្តិដែលទូទាត់ជាមួយម្ចាស់បំណុលនៅមានសេសសល់ អ្នកដែលមានសិទ្ធិត្រូវទទួលបានទ្រព្យសម្បត្តិរបស់ជនដែលទទួលមរណភាពនោះ គឺរដ្ឋ។

**៣.តាមផ្លូវច្បាប់តើស្ថាប័នណា ឬអាជ្ញាធរណាខ្លះជាអ្នកធ្វើការបែងចែកជាបណ្តាំមរតក ឬទ្រព្យសម្បត្តិជាកេរដែលបន្សល់ទុកខាងលើនេះ?**

គឺមានតែតុលាការមួយទេ ទើបមានសមត្ថកិច្ចចាត់ការលើរឿងនេះ។

*ចំណាំ: (ម.១១៧០, ម.១១៧៣, ម.១១៧៤... ជាមាត្រាសម្គាល់ក្នុងក្រមរដ្ឋប្បវេណីមរតកសាសន៍)*

# ផ្នែកទី១៥

# ដីការក្សាការពារនិងប្រសិទ្ធភាពក្នុងច្បាប់

លោកបណ្ឌិត ឡុង ដារ៉ា ជាសមាជិកក្រុមប្រឹក្សា និងជាប្រធានក្រុមការងារស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយច្បាប់នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយភ្នំពេញប៉ុស្តិ៍ លើការប្រើពាក្យក្នុងផ្លូវច្បាប់ “ដីការក្សាការពារ” ដែលមានខ្លឹមសារជាអាទិ៍ដូចខាងក្រោម ៖

**១. ក្នុងផ្លូវច្បាប់ទាំងភាសានិយាយ និងការសរសេរពាក្យ “ដីកាឬដីការក្សាការពារ” តើមានន័យងាយយល់យ៉ាងណាដែរក្នុងផ្លូវច្បាប់?**

មុននឹងធ្វើការបកស្រាយសំណួរទាំងអស់ពាក់ព័ន្ធនឹងដីការក្សាការពារ ខ្ញុំ សូមពន្យល់អំពីពាក្យថា ៖ ដីកា និង រក្សាការពារ ជូនជ្រាបជាមុនសិន។

- ពាក្យថា ដីកា: គឺជាសេចក្តីសម្រេច ឬ សេចក្តីបញ្ជារបស់អាជ្ញាធរតុលាការដល់អាជ្ញាធរពាក់ព័ន្ធឲ្យអនុវត្ត តាមខ្លឹមសារនៃដីកានោះ។
- ពាក្យថា រក្សាការពារ: គឺជាវិធានការចាត់ចែងរក្សាការពារជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិ សិទ្ធិ និងផលប្រយោជន៍របស់ភាគីក្នុងវិវាទ(ដែលគេប្រើពាក្យថា:ម្ចាស់បំណុល និងកូនបំណុល) ។

**២.ដូចម្តេចដែលហៅថា ដីការក្សាការពារ?**

ដីការក្សាការពារ គឺជាដីកាសម្រេចមុនអង្គសេចក្តី ដើម្បីហាមឃាត់ទ្រព្យសម្បត្តិ និងសិទ្ធិរបស់កូនបំណុល មិនឲ្យចាត់ចែង ឬក៏រឹបអូសទ្រព្យសម្បត្តិដែលកំពុងមានវិវាទ រក្សាទុក ឬប្រគល់ឲ្យភាគីណាមួយគ្រប់គ្រងជាបណ្តោះអាសន្ន រង់ចាំតុលាការអង្គសេចក្តីសម្រេចចប់ជាស្ថាពរ។

**៣.តើដីការក្សាការពារនេះ ប្រើប្រាស់ដើម្បីអ្វី?**

ដីការក្សាការពារ ប្រើប្រាស់ដើម្បី ហាមឃាត់ និងទប់ស្កាត់នូវទ្រព្យសម្បត្តិរបស់កូនបំណុល មិនឲ្យចាត់ចែងទៅឲ្យអ្នកដទៃជាបណ្តោះអាសន្ន ក្នុងគោលបំណងរក្សាការពារ ទុកសម្រាប់អនុវត្តដោយបង្ខំ ក្នុងការទូទាត់សំណងទៅឲ្យម្ចាស់បំណុល នៅពេលសាលក្រម ឬសាលដីការបស់តុលាការអង្គសេចក្តីមានអានុភាពអនុវត្តតាមផ្លូវច្បាប់។

**៤.តើដីការក្សាការពារ ចេញបាននៅ ពេលណាខ្លះ?**

ដីការក្សាការពារអាចចេញបាននៅពេលភាគីវិវាទ(ជាពិសេសគឺម្ចាស់បំណុល) បានដាក់ពាក្យប្តឹងសុំឲ្យតុលាការចេញដីការក្សាការពារហាមឃាត់ទ្រព្យសម្បត្តិរបស់កូនបំណុលមិនឲ្យលក់ ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ ធ្វើអំណោយ អច្ច័យទាន មរតកសាសន៍។ល។ តាមសំណូមពររបស់ខ្លួន ក្នុងករណីដែលមានមូលហេតុសមស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី ។ **ឧទាហរណ៍៖** កូនបំណុលមិនបាន បំពេញកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការ ទូទាត់បំណុលទៅឲ្យម្ចាស់បំណុល។ ធ្វើឲ្យម្ចាស់បំណុលមានការបារម្ភថា នៅពេលប្តឹងប្តល់ទៅតុលាការ ដូច្នេះ មុននឹងប្តឹងទាមទារសំណង ឬក្នុងពេលកំពុងប្តឹងទាមទារសំណងម្ចាស់បំណុលត្រូវប្តឹងសុំឲ្យតុលាការចេញដីការក្សាការពារ ហាមឃាត់នូវទ្រព្យ សម្បត្តិរបស់កូនបំណុល មិនឲ្យលក់ ដូរ ជួល ផ្ទេរ បញ្ចាំ ធ្វើអំណោយ អច្ច័យទាន មរតកសាសន៍។ល។ ទៅឲ្យអ្នកដទៃជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចអង្គសេចក្តីដោះស្រាយចប់ជាស្ថាពរសិន។

**៥.តើដីការក្សាការពារនេះ ប្រើចំពោះតែទ្រព្យសម្បត្តិ ឬប្រើចំពោះមនុស្សបានដែរឬទេ?**

តាមអត្ថន័យ និងខ្លឹមសារច្បាប់ ដែលភាគច្រើនយើងធ្លាប់អនុវត្តកន្លងមក គឺដីការក្សាការពារច្រើនសំដៅលើវត្ថុ និងសត្វ ដែលជាទ្រព្យសម្បត្តិកូនបំណុល (មានចលនវត្ថុ ឬអចលនវត្ថុ) តែប៉ុណ្ណោះ។ ប៉ុន្តែក្នុងខ្លឹមសារនិងអត្ថន័យនៃក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ក្នុងមាត្រា ៥៣០ និង៥៣១ នេះ ក៏បង្កប់នៅពាក្យទំនាក់ទំនងសិទ្ធិ និងឋានៈបុគ្គលផងដែរ។ ដូច្នេះ បើនិយាយពីពាក្យថា សិទ្ធិ និង ឋានៈ គឺសំដៅទៅលើមនុស្សមិន មែនវត្ថុ ឬ សត្វឡើយ។ **ឧទាហរណ៍ ៖** ក្នុងរឿងអាពាហ៍ពិពាហ៍ និងគ្រួសារ ឬអំពើហិង្សាក្នុងគ្រួសារ ជាដើម។ល។ តុលាការអាចចេញដីការក្សាការពារហាមឃាត់ភាគី មិនឲ្យរស់នៅជាមួយគ្នាបណ្តោះអាសន្ន (បំបែកលំនៅសង្វាស់) បាន។

**៦.តើដីការក្សាការពារនេះ មានកំណត់រយៈពេលដែរ ឬទេ?**

តាមច្បាប់ដីការក្សាការពារមិនមាន រយៈពេលកំណត់ជាក់លាក់ឡើយ។ ប៉ុន្តែ ដីកានេះ នឹងអស់សុពលភាពនៅពេលសំណុំរឿងអង្គសេចក្តីបានអនុវត្តចប់ជាស្ថាពរ ឬកូនបំណុលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនរួចហើយឬករណី ម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តី ក្នុងរយៈពេល២សប្តាហ៍ ឬការសុំលុប ដោយមានផ្លាស់ប្តូរស្ថានភាព។ល។ **ឧទាហរណ៍ ៖** ម្ចាស់បំណុលប្តឹងសុំឲ្យតុលាការចេញដីការក្សាការពារហាមឃាត់ផ្ទះរបស់កូនបំណុល មិនឲ្យលក់ ដូរ ជួល ផ្ទេរ បញ្ចាំ ធ្វើអំណោយ អច្ច័យទាន មរតកសាសន៍ ទៅឲ្យអ្នកដទៃ បណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តីចប់ជាស្ថាពរ។ ប៉ុន្តែ នៅពេលតុលាការអង្គសេចក្តីសម្រេចឲ្យកូនបំណុលទូទាត់សំណងទៅម្ចាស់បំណុលនូវចំនួនទឹកប្រាក់ជាក់លាក់ណាមួយ ហើយកូនបំណុលក៏បានយល់ព្រមទូទាត់សំណងទៅឲ្យម្ចាស់បំណុល តាមអំណាចសាលក្រមរបស់តុលាការហើយដែរ។ បើដូច្នេះ តុលាការត្រូវតែចេញដីកាផ្អាកផ្តាក់ឲ្យអាជ្ញាធរពាក់ព័ន្ធលុបចោលនូវដីការក្សាការពាររបស់កូនបំណុលវិញភ្លាមតែម្តង។

# ផ្នែកទី១៦

# វិធានការច្បាប់សម្រាប់ការល្មើសនឹងដីការក្សាការពារ

លោកបណ្ឌិត **ឡុង ដារ៉ា** សមាជិកក្រុមប្រឹក្សា និងជាប្រធានក្រុមការងារស្រាវជ្រាវអប់រំ និងផ្សព្វផ្សាយច្បាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សម្ភាសន៍ដល់ភ្នំពេញប៉ុស្តិ៍ ដោយបានលើកឡើងពីបទប្បញ្ញត្តិនានា សម្រាប់ការល្មើសនឹងដីការក្សាការពារបន្តពីលេខមុន ដែលមានខ្លឹមសារដូចខាងក្រោម ៖

**១.បើតុលាការចេញដីការក្សាការពាររួចហើយ ប៉ុន្តែជននោះល្មើសនឹងដីកាដោយលួចយកទ្រព្យសម្បត្តិលក់ តើច្បាប់អនុវត្តលើជននោះដូចម្តេច?**

មុននឹងបកស្រាយ ខ្ញុំសូមពន្យល់ពីអត្ថន័យ និងពាក្យពេចន៍ខ្លះដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី១ ផ្នែកទី២ ស្តីពីការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ ចាប់ពីមាត្រា ៥២០ដល់៥២៤ ក្នុងនោះមានខ្លឹមសារ និងអត្ថន័យដូចតទៅ ៖

- **មាត្រា ៥២០** "បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ" ចែងថា៖ អំពើអ្នករាជការសាធារណៈ ក្នុងមុខការរបស់ខ្លួនដែលមិនព្រមអនុវត្តសាលក្រម សាលដីកា ឬរាល់បញ្ជារបស់អាជ្ញាធរតុលាការត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២ឆ្នាំ ទៅ០៥ឆ្នាំ និងពិន័យជាប្រាក់ពី០៤លានរៀលដល់១០លានរៀល។
- **មាត្រា៥២១** "បទផ្តល់ដោយខុសច្បាប់នូវបញ្ជាឲ្យឃុំខ្លួនឬដោះលែង" ចែងថា៖ "អំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលទោះបីក្រោមរូបភាពណាក៏ដោយ ចេញបញ្ជាដោយខុសច្បាប់ ឲ្យឃុំ ឬឲ្យដោះលែងជនជាប់ឃុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២ឆ្នាំ ទៅ០៥ឆ្នាំ និងពិន័យជាប្រាក់ពី ០៤លានរៀល ដល់១០លានរៀល។"
- **មាត្រា៥២២**: បទផ្សព្វផ្សាយនូវការ អត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ ចែងថា៖"ការផ្សព្វផ្សាយមុនសេចក្តីសម្រេចជាស្ថាពររបស់តុលាការនូវអត្ថាធិប្បាយ ដោយមានគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការ ដែលទទួលបណ្តឹង ដើម្បីជះឥទ្ធិពលលើសេចក្តីសម្រេចរបស់តុលាការត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ខែទៅ០៦ខែ និងពិន័យជាប្រាក់ពី ០១សែនរៀលទៅ០១លានរៀល។"
- **មាត្រា៥២៣**: បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ចែងថា៖ "អំពើរិះគន់លិខិត ឬសេចក្តីសម្រេចរបស់តុលាការក្នុងគោលដៅបង្កឲ្យមានភាពរំកែរដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏បង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ខែ ទៅ០៦ខែ និងពិន័យជាប្រាក់ពី ០១សែនរៀលទៅ០១លានរៀល។ អំពើដែលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការត្រូវផ្តន្ទាទោសដូចគ្នា និងទោសដែលមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។"
- **មាត្រា ៥២៤**: បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ ចែងថា៖ "អំពើដែលប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការឬអាជ្ញាធររដ្ឋបាលនូវអំពើជាបទល្មើស កាលបើការប្តឹងបរិហារនេះនាំឲ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០១ខែទៅ០៦ខែ និងពិន័យជាប្រាក់ពី ០១សែនរៀល ទៅ០១លានរៀល។"

ដូច្នេះ តាមសំណួរខាងលើនេះបញ្ជាក់ថាជនដែលល្មើសនឹងដីកា ដោយលួច ទ្រព្យសម្បត្តិដែលតុលាការបានហាមឃាត់ទៅលក់ គឺអាចប្រឈមនឹងមាត្រា ៥២៣ ពីបទមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ក្នុងកថាខណ្ឌទី២ នៃក្រម

ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះអាជ្ញាធរដែលពាក់ព័ន្ធក្នុងករណីនេះក៏មានទោសផងដែរ គឺត្រូវប្រឈមនឹងមាត្រា ៥២០ បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ ឬមាត្រា២៩ ស្តីពីបទសមគំនិត ក្នុងអំពើនេះ ហើយត្រូវទទួលទោសដូចចារីផងដែរ។

**២.នៅពេលចេញដីការក្សាការពារហើយតែជននោះបែរជាគេចខ្លួន តើច្បាប់ត្រូវដោះស្រាយយ៉ាងដូចម្តេច?**

ដីការក្សាការពារ គឺគ្រាន់តែជាវិធានការហាមឃាត់ ទប់ស្កាត់ ឬរឹបអូសនូវទ្រព្យសម្បត្តិ ឬទំនាក់ទំនងសិទ្ធិបុគ្គលជាបណ្តោះអាសន្នតែប៉ុណ្ណោះ មិនមែនជាការកំណត់ទោស និងទណ្ឌកម្មនោះឡើយ។ ដូច្នេះ ប្រសិនបើជននោះគេចខ្លួនបាត់ ហើយមិនបានប្រព្រឹត្តអំពើ ឬសកម្មភាពអ្វីរាំងដល់ការអនុវត្តដីកាទេ ច្បាប់មិនមានកំណត់អំពីវិធានការអ្វីដល់ជននោះឡើយ។ ប៉ុន្តែដីការក្សាការពារនៅតែមានប្រសិទ្ធភាពអនុវត្តជាធម្មតារហូតដល់សំណុំ រឿងអង្គសេចក្តីបានដោះស្រាយបញ្ចប់ជាស្ថាពរ។ រីឯការអនុវត្តដោយបង្ខំលើទ្រព្យសម្បត្តិ និងទំនាក់ទំនងសិទ្ធិរបស់កូនបំណុលនិងម្ចាស់បំណុលត្រូវអនុវត្តតាមខ្លឹមសារសាលក្រមឬសាលដីកាអង្គសេចក្តីរបស់តុលាការ ដែលបានសម្រេចជាស្ថាពរតាមច្បាប់ ។

**បញ្ជាក់:** សូមកុំមានការភាន់ច្រឡំថាការគេចខ្លួនរបស់កូនបំណុលជាវិធានការរារាំងមិនឲ្យតុលាការ ឬអាជ្ញាធរសាធារណៈពាក់ព័ន្ធអនុវត្តដីការក្សាការពារនោះឡើយ ។

**៣.បើកូនបំណុលមានតែម្នាក់គត់ ហើយថៃដន្យគាត់ស្លាប់ក្រោយមានដីការក្សា ការពារតើសមាជិកក្នុងគ្រួសារត្រូវជំនួស ឬទុកឲ្យដីការក្សាការពារក្លាយជាមោឃភាពបានដែរ ឬទេ?**

ដីការក្សាការពារ មិនមែនជាសេចក្តី សម្រេចស្ថាពររបស់តុលាការឡើយ។ ដូចខ្ញុំបាទបានពន្យល់ពីសប្តាហ៍មុនរួចមកហើយថាសំណុំរឿងដីការក្សាការពារ គឺជាសំណុំរឿងមុនអង្គសេចក្តី ហើយគ្រាន់តែជាវិធានការចាត់ចែងរក្សាការពារជាបណ្តោះអាសន្នតែប៉ុណ្ណោះ គ្មានអានុភាពអនុវត្តដោយបង្ខំលើទ្រព្យសម្បត្តិ ឬទំនាក់ទំនងសិទ្ធិបុគ្គលដូចសេចក្តីសម្រេចអង្គសេចក្តីឡើយ។

ដូច្នេះ ប្រសិនបើកូនបំណុលបាត់ខ្លួន ឬស្លាប់ស្ថានភាពនៃដីការក្សាការពារ មានអនុភាពអនុវត្តដដែល ប៉ុន្តែកត្តាសំខាន់ស្ថិតនៅលើសំណុំរឿងអង្គសេចក្តីថា តើកូនបំណុលមានជាប់ពាក់ព័ន្ធទំនាក់ទំនងសិទ្ធិ និងទ្រព្យសម្បត្តិជាមួយម្ចាស់បំណុលដែរ ឬទេ? ប្រសិនបើមានទំនាក់ទំនងទ្រព្យសម្បត្តិ តុលាការអង្គសេចក្តី និងសម្រេចតាមផ្លូវច្បាប់ ទោះបីជាកូនបំណុលស្លាប់ហើយក៏ដោយ ។

**ឧទាហរណ៍:** កូនបំណុលជំពាក់ប្រាក់ម្ចាស់បំណុលមួយម៉ឺនដុល្លារអាមេរិក ដោយមានកិច្ចសន្យាដាក់បញ្ចាំដីមួយកន្លែងដែលជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ហើយនៅមុនពេលមានវិវាទទៅដល់តុលាការម្ចាស់បំណុលប្តឹងសុំហាមឃាត់ដីនេះមិនឲ្យកូនបំណុលលក់ ដូរ ជួល ផ្ទេរ បញ្ចាំ ធ្វើអំណោយ អច្ច័យទាន មរតកសាសន៍។ល។ ទៅឲ្យអ្នកដទៃបណ្តោះអាសន្នរង់ចាំតុលាការដោះស្រាយសំណុំរឿងអង្គសេចក្តីចប់ជាស្ថាពរសិន។

ក្រោយពេលចេញដីការក្សាការពាររួច កូនបំណុលស្លាប់បាត់ ដូច្នេះម្ចាស់បំណុលត្រូវរង់ចាំសំណុំរឿងអង្គសេចក្តីសម្រេចរួចហើយសិន ទើបស្នើសុំអនុវត្តដោយបង្ខំតាមផ្លូវច្បាប់។

ចំពោះកូនបំណុលស្លាប់បាត់ក៏មិនមែនជាឧបសគ្គរា រាំងមិនឲ្យតុលាការឬអាជ្ញាធរសាធារណៈអនុវត្តដីកា ឬសេចក្តីសម្រេចរបស់តុលាការឡើយ។ ចំពោះទ្រព្យសម្បត្តិ ដែលនៅសល់ត្រូវប្រគល់ឲ្យសាច់ញាតិតាមផ្លូវច្បាប់។ ប៉ុន្តែ ប្រសិនបើមានតែទំនាក់ទំនងសិទ្ធិក្នុងនាមជាឋានៈបុគ្គលតែប៉ុណ្ណោះទេ ហើយកូនបំណុលស្លាប់បាត់ ដីការក្សាការពារមិនអាចអនុវត្តបានឡើយ។

**ឧទាហរណ៍:** តុលាការ ចេញដីការក្សាការពារឲ្យភាគីបែកលំនៅសង្វាស ឬលំនៅឋានពីជនរងគ្រោះជាបណ្ដោះអាសន្ន។ ប៉ុន្តែក្រោយពេលចេញដីការក្សាការពាររួចហើយ ភាគីដែលត្រូវបំបែកលំនៅសង្វាស ឬលំនៅឋានបានស្លាប់បាត់ ដូច្នេះដីការក្សាការពារគ្មាន អនុភាពអនុវត្តឡើយព្រោះភាគីដែលត្រូវអនុវត្តកាតព្វកិច្ចបានរលត់សិទ្ធិក្នុងការអនុវត្តអស់ទៅហើយ ហើយករណីនេះ ភាគច្រើនជារឿងវិវាទពាក់ព័ន្ធច្បាប់អាពាហ៍ពិពាហ៍ និង អំពើហិង្សាក្នុងគ្រួសារ។

ចំពោះសមាជិកក្នុងគ្រួសារដែលមិនមែនជាភាគីក្នុងដីកានេះ មិនអាចចូលមកអនុវត្តសិទ្ធិ និងកាតព្វកិច្ចជំនួសបានឡើយ។ ប៉ុន្តែ អាចតាំងខ្លួនជាភាគីដាក់បណ្ដឹងតវ៉ាសុំចូលជាតតីយជនតាមផ្លូវច្បាប់ក្នុងករណីដែលយល់ឃើញថា មានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួន ។

**៤.បើមានដីការក្សាការពារពីតុលាការហើយ តែជននោះល្មើសនឹងដីកា តើច្បាប់ចាត់វិធានការលើជននោះយ៉ាងដូចម្ដេច?**

ការល្មើសនឹងដីការក្សាការពាររបស់ភាគី គឺគ្មានបទល្មើសឡើយ។ ប៉ុន្តែអ្នករាជការសាធារណៈ ក្នុងមុខការរបស់ខ្លួនដែលមិនព្រមអនុវត្តសាលដីកា សាលក្រម ដីកា ឬរាល់ការបញ្ជារបស់អាជ្ញាធរតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០២ឆ្នាំទៅ០៥ឆ្នាំ និងពិន័យជាប្រាក់ ពី០៤លានរៀលទៅ១០លានរៀល (មាត្រា៥២០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)។

ដូច្នេះ បើជននោះមិនព្រមគោរព ត្រូវបង្គាប់ឲ្យអាជ្ញាធរសាធារណៈចាត់វិធានការអនុវត្តទៅតាមផ្លូវច្បាប់។

# ផ្នែកទី១៧

# បណ្តឹងអាជ្ញា និងកម្មវត្ថុនៃបណ្តឹងអាជ្ញា

លោកមេធាវី ឡាច សំរោង សមាជិកគណៈកម្មការព្រហ្មទណ្ឌនៃគណៈមេធាវីបានផ្តល់សម្ភាសមកដល់ភ្នំពេញប៉ុស្តិ៍ ដោយបានលើកឡើងអំពីបណ្តឹងពីរ គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី និងបានពន្យល់ផ្អែកលើខ្លឹមសារច្បាប់ ដែលមានអត្ថន័យដូចខាងក្រោម ៖

**១.តើអ្វីទៅជាបណ្តឹងអាជ្ញា?**

បណ្តឹងអាជ្ញា គឺជាបណ្តឹងសុំឱ្យពិន័យជាប្រាក់ ឬដាក់ពន្ធនាគារមានកាលកំណត់ ឬដាក់ពន្ធនាគារអស់មួយជីវិត ឬប្រហារជីវិត(នៅព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នគ្មានទោសប្រហារជីវិតទេ) ចំពោះជនដែលប្រព្រឹត្តអំពើដែលនាំឱ្យគ្រោះថ្នាក់ដល់សង្គម ឬប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ។ បច្ចុប្បន្ន បណ្តឹង អាជ្ញា ត្រូវបានគេមើលឃើញថា ជាបណ្តឹងប្រឆាំងនឹងជនល្មើសដែលប្រព្រឹត្តបទល្មើសណាមួយ ដោយទាមទារឱ្យតុលាការ ផ្តន្ទាទោសជននោះទៅតាមច្បាប់។

**២.តើការចាប់ផ្តើមនៃបណ្តឹងអាជ្ញា កើតឡើងនៅពេលណា?**

បណ្តឹងអាជ្ញា ត្រូវបានអនុវត្តដោយអយ្យការក្នុងនាមការពារឲ្យផលប្រយោជន៍សាធារណៈ។ ការចាប់ផ្តើម បណ្តឹងអាជ្ញាដោយអយ្យការ មានន័យថា តំណាងអយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ (អាចជាបទឧក្រិដ្ឋ មជ្ឈិម ឬលហុ) និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយជនរងគ្រោះជាគោលការណ៍ថ្មីនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលអនុញ្ញាតឱ្យជនរងគ្រោះ អាចដាក់ពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

ពាក្យបណ្តឹងនេះមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌ ដែលបានបញ្ញត្តិដោយមាត្រា ១៣៨ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់) នៃក្រមនេះ។ ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយវិធីនេះ មានលក្ខណៈប្រថុយប្រថានខ្លាំង ព្រោះថាជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានទទួលការផាកពិន័យដោយចៅក្រមស៊ើបសួរនិងសងការខូចខាត ប្រសិនបើបណ្តឹងនោះធ្វើដោយរំលោភ ឬអូសបន្លាយពេលវេលា។

**៣.អ្វីទៅជាកម្មវត្ថុនៃបណ្តឹងអាជ្ញា?**

បណ្តឹងអាជ្ញា អនុវត្តលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធានឬស្ថានភាពឯទៀតឡើយ។ ផ្អែកតាមក្រមព្រហ្មទណ្ឌថ្មីគ្រប់បុគ្គលទាំងអស់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌទោះជានីតិបុគ្គល។ នីតិបុគ្គលថ្វីដ្បិតតែជាបុគ្គលសិប្បនិម្មិត ដែលបង្កើតឡើងដោយច្បាប់ ក៏ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដែរ មានន័យថា នីតិបុគ្គលនោះអាចទទួលរងនូវការពិន័យជាប្រាក់ ឬទទួលរងនូវទោសបន្ថែមណាមួយ ដូចជា ការរំលាយនីតិបុគ្គលជាដើម។ ចំណែក ឯរូបវន្តបុគ្គលតំណាងឱ្យនីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះក៏មិនអាចគេចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ (មាត្រា៣"ក្រមនីតិវិធីព្រហ្មទណ្ឌ" ២០០៧)។

**៤.តើបណ្តឹងអាជ្ញាមានគោលបំណងដើម្បីអ្វី?**

បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យទៅលើអត្ថិភាពនៃបទល្មើស និងបង្ហាញឲ្យឃើញនូវពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ ដូចនេះ គោលបំណងនៃបណ្តឹងអាជ្ញាគឺ កំណត់ពីអត្ថិភាពនៃបទល្មើសនិងផ្តន្ទាទោសជនល្មើសតាមច្បាប់ជាធរមាន។

**៥.តើអ្វីទៅជាបទល្មើស?**

ច្បាប់បញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កចលាចល ដល់សង្គម ជាបទល្មើស។ យោងតាមការកំណត់និយមន័យនេះ ទ្រឹស្តីព្រហ្មទណ្ឌបានកំណត់ពីចរិតនៃបទល្មើស ដូចខាងក្រោមនេះ ៖ អំពើដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម អំពើដែលច្បាប់ព្រហ្មទណ្ឌបានកំណត់ថា ជាបទល្មើស គោលការណ៍នៃកំហុស ដោយចេតនា ឬអចេតនា ។

ជាគោលការណ៍ មានតែអំពើដែលច្បាប់បានកំណត់ថាជាបទល្មើស ទើបអាចត្រូវបានផ្តន្ទាទោស ដែលហៅថា គោលការណ៍នីត្យានុកូលនៃបទល្មើស ហើយមានតែទោស ដែលមានចែងដោយច្បាប់ទេ ទើបអាចសម្រេចផ្តន្ទាទោសបាន ដែលហៅថា គោលការណ៍នីត្យានុកូលនៃទោស។ ដូចនេះប្រសិនបើជនណាមួយបានប្រព្រឹត្តនូវអំពើណាមួយ បើទោះជាអំពើនោះមានការប៉ះពាល់ដល់សង្គមក៏ដោយ តែអំពើនោះពុំមានច្បាប់កំណត់ថា ជាបទល្មើសជននោះមិនត្រូវបានតុលាការផ្តន្ទាទោសឡើយ។

**៦.តើបណ្តឹងអាជ្ញារលត់នៅពេលណា?**

ការរលត់បណ្តឹងអាជ្ញាមានដូចជា:

- មរណភាពនៃជនល្មើស។
- ការផុតអាជ្ញាយុកាល។
- ការលើកលែងទោសជាទូទៅ។
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ។
- អាជ្ញាអស់ជំនុំ (មាត្រា ៧ “ក្រមនីតិវិធីព្រហ្មទណ្ឌ” ២០០៧)។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងព្រហ្មទណ្ឌ មិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។ ឧទាហរណ៍ ៖ ប្រសិនបើជនសង្ស័យបានទទួលមរណភាពក្នុងដំណាក់កាលតំណាងអយ្យការ កំពុងធ្វើការចោទប្រកាន់នោះមានន័យថា បណ្តឹងអាជ្ញាត្រូវបានរលត់ តំណាងអយ្យការត្រូវតែតម្កល់រឿងទុកឥតចាត់ការ ។

**៧.អ្វីទៅជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញា?**

កាលណាច្បាប់ដោយឡែក បានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ ៖

- ដោយការសម្របសម្រួលជាមួយរដ្ឋ
- ដោយការដកពាក្យបណ្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះ ជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ដោយការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល (មាត្រា ៩ “ក្រមនីតិវិធីព្រហ្មទណ្ឌ” ២០០៧)។

តែទោះជាក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីមូលហេតុ នៃការរលត់បណ្តឹងអាជ្ញាខាងលើក៏ដោយ ក៏មានបទឧក្រិដ្ឋ មួយចំនួនដែលគ្មានអាជ្ញាយុកាលកំណត់ ដូចជា បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមជាដើម។

គួរកត់សម្គាល់ថា មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញានេះ គឺលុះត្រាតែមានចែងក្នុងច្បាប់ណាមួយជាក់លាក់ ជាឧទាហរណ៍: នៅក្នុងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ មាត្រា៣៦ចែងថា “ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិម ស្រាល ឬបទលហុ។ (**សូមរង់ចាំអានវគ្គបន្ត**)

# ផ្នែកទី១៨

## ការដកហូត រក្សាទុក ប្រើប្រាស់វត្ថុតាងរបស់ជនល្មើសជនជាប់ចោទ

លោក មួង សុគន្ធ ជាមេធាវីក្នុងក្រុមមេធាវីអេហ្សេត (AZ Law Firm) មានការិយាល័យនៅអគារលេខ 2A ផ្លូវលេខ ២០០២ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ លោកជាសមាជិកនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

លោកមេធាវីបានផ្តល់កិច្ចសម្ភាសន៍ជាមួយកាសែតភ្នំពេញប៉ុស្តិ៍ ទាក់ទងនឹងប្រធានបទ “ការដកហូត និងរក្សាទុកវត្ថុតាងរបស់ជនល្មើសឬជនជាប់ចោទ និងការដោះលែងទណ្ឌិត” ដែលមានខ្លឹមសារ ដូចខាងក្រោមនេះ៖

**១.នៅពេលសមត្ថកិច្ចនគរបាលចាប់ខ្លួនជនសង្ស័យណាម្នាក់និងរឹបអូសបានវត្ថុតាង ឬសម្ភារៈផ្ទាល់ខ្លួន ដូចជា ម៉ូតូ ឬរថយន្ត... របស់គាត់ តើវត្ថុទាំងនោះគេត្រូវរក្សាទុកយ៉ាងដូចម្តេចដែរ? តើនរណាជាអ្នកគ្រប់គ្រង?**

យោងតាមមាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលណាដែលមានការឆែកឆេរ គឺសមត្ថកិច្ចតែងតែមានការចាប់ដកហូតនូវវត្ថុដែលមានការពាក់ព័ន្ធ ឬវត្ថុដែលមានការសង្ស័យទៅនឹងការប្រព្រឹត្ត បទល្មើស ដូចជា ម៉ូតូឬរថយន្ត ជាដើមនោះ ហើយនៅពេលដែលមានការរឹបអូសយកវត្ថុដែលត្រូវបានឆែកឆេរទាំងនោះ និងដែលបានរកឃើញនៅកន្លែងកើតហេតុនោះ គឺសមត្ថកិច្ចត្រូវនាំមករក្សាទុកនៅក្នុងទីតាំង ឬកន្លែងរបស់គាត់និងត្រូវរាយការណ៍មកកាន់តំណាងអយ្យការសិន ដើម្បីឲ្យតំណាងអយ្យការធ្វើការប្រមូលភស្តុតាង និងធ្វើរបាយការណ៍បញ្ជូនមកកាន់សាលាដំបូង ខេត្ត-ក្រុង ដែលពាក់ព័ន្ធ។ ចំណែកអ្នកដែលត្រូវគ្រប់គ្រងវត្ថុតាងនោះ គឺខាងតុលាការជាអ្នកគ្រប់គ្រង។

និយាយរួម នៅពេលចាប់បានភស្តុតាង ពីជនជាប់សង្ស័យនៅពេលបង្ក្រាបបទល្មើសនោះ វត្ថុតាងនោះត្រូវបានសមត្ថកិច្ចនគរបាលយុត្តិធម៌ ជាអ្នកឃាត់ និងរក្សាទុករួចរាយការណ៍ និងបញ្ជូនភស្តុតាងដែលពាក់ព័ន្ធទាំងនោះមកតុលាការ និងសមត្ថកិច្ចដែលពាក់ព័ន្ធ ដើម្បីសម្រេចរក្សាទុកវត្ថុទាំងនោះទៅតាមផ្លូវច្បាប់ ដើម្បីស៊ើបអង្កេតបន្ត។ ឧទាហរណ៍ថា នៅភ្នំពេញតុលាការដែលពាក់ព័ន្ធ គឺអយ្យការអមសាលាដំបូងរាជធានី និងសាលាដំបូងរាជធានីភ្នំពេញ។ ប្រសិនបើនៅសាលាដំបូងខេត្ត-ក្រុងនានានោះ គឺអយ្យការអមសាលាដំបូងខេត្ត-ក្រុង និងសាលាដំបូងខេត្ត-ក្រុង ជាអ្នកទទួលបន្ទុករក្សាវត្ថុតាងនោះ ដែលចាប់បានពីជនល្មើសឬជនសង្ស័យនោះ។ វត្ថុតាងទាំងនោះត្រូវបានបិទជិតដោយស្លាក និងត្រូវមានចុះហត្ថលេខារបស់តំណាងអយ្យការនិងចៅក្រមស៊ើបសួរផងដែរ។

ចំពោះចលនវត្ថុ ដូចជា ម៉ូតូ ឬរថយន្តក្តី គឺសមត្ថកិច្ចតុលាការអាចរក្សាទុកនៅឯសាលាដំបូងខេត្ត-ក្រុង ឬមួយក៏ផ្ញើទុកនៅឯសមត្ថកិច្ចនគរបាលយុត្តិធម៌ ដែលជាម្ចាស់នៃករណីនោះដើម្បីរក្សាទុកបណ្តោះអាសន្នសិន។

ចំពោះវត្ថុតាង ឬភស្តុតាងដែលត្រូវបានសមត្ថកិច្ចដកហូតនេះ ត្រូវញែកចេញជាពីរ។ ទី១ គឺវត្ថុដែលពាក់ព័ន្ធ។ ឧទាហរណ៍ថា: សមត្ថកិច្ចបានធ្វើការបង្ក្រាបទៅលើជនសង្ស័យជួញដូរគ្រឿងញៀននិងដកហូតបានថ្នាំញៀនមួយចំនួនម៉ូតូ និងរថយន្ត ពីជនជាប់សង្ស័យនោះ ហើយនឹងសម្ភារៈដែលប្រើប្រាស់ផ្ទាល់ខ្លួនដូចជា លុយកាក់ គ្រឿងអលង្ការ អត្តសញ្ញាណប័ណ្ណ ឬ ឯកសារពាក់ព័ន្ធ ដទៃទៀតនោះវត្ថុទាំងនោះសមត្ថកិច្ចនឹងធ្វើការពិចារណាក្នុងការរក្សាទុក ឬប្រគល់ឲ្យម្ចាស់ដើមវិញស្របតាមមាត្រា ១១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

**២.នៅដំណាក់កាលបើកការស៊ើបសួរពីចៅក្រមស៊ើបសួរ ឬរឿងក្តីនោះកំពុងតែស្ថិតនៅក្នុងតុលាការ តើសមត្ថកិច្ចអាចដកហូតវត្ថុជាម៉ូតូ ឬរថយន្ត ឬក៏សម្ភារផ្ទាល់ខ្លួនរបស់ជនល្មើសមកប្រើប្រាស់បាន ឬទេ? តើមកពីហេតុអីដែរ?**

ជាគោលការណ៍នៃច្បាប់ដែលពាក់ព័ន្ធនឹងចលនវត្ថុ ដូចជា វត្ថុតាងជាម៉ូតូ ឬរថយន្ត ដែលជាប់ទាក់ទងទៅនឹងមធ្យោបាយដឹកជញ្ជូននោះតុលាការត្រូវសម្រេចដកហូត ដោយរក្សាទុកតាមច្បាប់សិន។ ក៏ប៉ុន្តែ ប្រសិនបើក្នុងករណីដែលសមត្ថកិច្ចណាដែលពាក់ព័ន្ធ និងខ្វះខាតមធ្យោបាយដឹកជញ្ជូន ហើយបានដាក់ពាក្យស្នើសុំមកតុលាការ ដើម្បីយកម៉ូតូ ឬរថយន្តនោះ ដើម្បីយកមកបម្រើការសិននោះ នៅក្នុងការទទួលខុសត្រូវរបស់អង្គភាពសាមី ឬចៅក្រមស៊ើបសួរ អាចសម្រេចអនុញ្ញាតឲ្យយកវត្ថុទាំងនោះមកប្រើប្រាស់បានក្នុងថិរវេលាកំណត់ណាមួយ ដែលបានកំណត់ដោយចៅក្រមស៊ើបសួរ និងការទទួលខុសត្រូវរបស់អង្គភាពដែលបានយកវត្ថុនោះទៅប្រើប្រាស់។ ក៏ប៉ុន្តែនៅពេលដែលមានការខូចខាតឬបាត់បង់នោះគឺសាមីអង្គភាពដែលយកវត្ថុនោះទៅប្រើប្រាស់ត្រូវទទួលខុសត្រូវលើវត្ថុទាំងនោះ។

**៣.ចំពោះវត្ថុផ្សេងៗដែលជាវត្ថុមានតម្លៃដូចជា លុយកាក់ ចិញ្ចៀន កង់ ម៉ូតូ ឬរថយន្ត ដែលត្រូវបានតុលាការរកឃើញថាមានជាប់ពាក់ព័ន្ធ ឬជាផលទទួលបានពីអំពើល្មើសច្បាប់នោះ តើសមត្ថកិច្ចអាចលក់ដូរវត្ថុទាំងនោះបានដែរឬទេ? ហើយប្រាក់ដែលទទួលបានពីការលក់នោះត្រូវយកទៅណាដែរ?**

ក្នុងករណីដែលតុលាការបានរកឃើញថា វត្ថុតាងដែលដកហូតទាំងនោះ មានការជាប់ទាក់ទងនឹងបទល្មើស ដូចជារថយន្ត ឬម៉ូតូ ដែលជាប់ពាក់ព័ន្ធនឹងបទល្មើស ហើយដែលបានទទួលផលពីការប្រព្រឹត្តនៃបទល្មើសនោះ តុលាការអាចដកហូតវត្ថុតាងទាំងនោះ ជាទ្រព្យសម្បត្តិរបស់រដ្ឋ និងត្រូវប្រកាសដាក់លក់ឡាយឡុងជាសាធារណៈ ដើម្បីបង្វិលប្រាក់ដាក់ចូលក្នុងថវិកាជាតិ។

**៤.ចំពោះប្រាក់ពិន័យដែលតុលាការបានផាកពិន័យពីជនជាប់ចោទ ឬទណ្ឌិតនោះតើប្រាក់ទាំងនោះ គេត្រូវយកទៅណាធ្វើអ្វីដែរ? ក្នុងករណីដែលជាប់ចោទ ឬទណ្ឌិតណាម្នាក់ដល់ពេលបញ្ចប់នូវទោសទណ្ឌរបស់គាត់ហើយ ហើយពុំមានប្រាក់បង់តាមការពិន័យរបស់តុលាការនោះ តើតុលាការអាចអនុញ្ញាតឲ្យគាត់ចេញពីពន្ធនាគារដែរ ឬទេ?**

ជាគោលការណ៍ផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៥១៦ និង ៥១៧ ស្ដី ពីការដោះលែង ដោយមានលក្ខខណ្ឌនោះគឺត្រូវធ្វើឡើងដោយតុលាការ ប្រសិនបើរកឃើញថា បុគ្គលនោះពិតជា បានកាន់ ឬអនុវត្តនូវទោសទណ្ឌរបស់គាត់ដល់ទីបញ្ចប់ហើយហើយគាត់ពុំមានប្រាក់សម្រាប់បង់ពិន័យចូលថវិការដ្ឋនោះ។ ក៏ប៉ុន្តែគាត់បានអនុវត្តទោសជាស្ថាពរហើយនោះ គឺគាត់មានសិទ្ធិសុំមកតុលាការ ឬ អយ្យការឲ្យបាននៅក្រៅឃុំដើម្បីរកប្រាក់បង់មកឲ្យតុលាការវិញនៅពេលក្រោយ ដោយមានការយល់ព្រមពីខាងតុលាការផងដែរ។ ចំណែកការដោះលែង ឬមិនដោះលែងនោះ គឺវាអាស្រ័យទៅលើជាការសម្រេចរបស់តុលាការ។

# ផ្នែកទី១៩

# បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ និងបណ្តឹងសើរើ

លោក ឡោ គឹមហ៊្កិច ជាមេធាវីនៃការិយាល័យមេធាវី អិល-អេស-អ (កម្ពុជា) មានទីតាំងនៅផ្ទះលេខ ១៦A ផ្លូវ ២៥២ ក្នុងសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយភ្នំពេញប៉ុស្តិ៍ ជុំវិញការធ្វើបណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ និងបណ្តឹងសើរើ ដោយផ្អែកលើការកំណត់ដោយច្បាប់ជាធរមាននៅកម្ពុជា ដែលមានខ្លឹមសារជាអាទិ៍ដូចខាងក្រោម៖

**១.ដូចម្តេចហៅថា បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខនិងបណ្តឹងសើរើ តើបណ្តឹងទាំងនេះធ្វើឡើងនៅពេលណា? នៅកន្លែងណា? ធ្វើឡើងដើម្បីអ្វី?**

- **បណ្តឹងទាស់** គឺជាបណ្តឹងដែលធ្វើឡើងដើម្បីឲ្យតុលាការដែលបានសម្រេចសេចក្តីរួចហើយមកជម្រះ សេចក្តីសាឡើងវិញម្តងទៀត។ មូលហេតុដែលមានបណ្តឹងទាស់ទៅលើសាលក្រម ឬសាលដីការបស់សាលាឧទ្ធរណ៍ព្រោះពេលជំនុំជម្រះ គឺជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬតំណាងស្របច្បាប់ អវត្តមាន ឬមិនបានដឹងពីការជំនុំជម្រះលើរឿងក្តីនេះ (មាត្រា ៣៦២ ៤០៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។ បណ្តឹងទាស់: បណ្តឹងទាស់អាចធ្វើឡើងបានក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីបានទទួលសាលក្រម សាលដីកា ឬបានដឹងយ៉ាងពិតប្រាកដ (មាត្រា ៣៦៥, ៣៦៨, ៤០៩, ៤១២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។ បណ្តឹងទាស់អាចធ្វើឡើងបានដោយដាក់ពាក្យបណ្តឹងសរសេរជាលាយលក្ខណ៍អក្សរ ដាក់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬសាលដីកា នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាលឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន (មាត្រា ៣៦៦ , ៤១០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។ បញ្ជាក់: ចំពោះតុលាការកំពូលពុំមានបណ្តឹងទាស់ទេ ព្រោះសាលដីកាដែល ប្រកាសរួចត្រូវចូលជាធរមានភ្លាម។
- **បណ្តឹងឧទ្ធរណ៍:** បណ្តឹងឧទ្ធរណ៍ធ្វើឡើងនៅពេលដែលព្រះរាជអាជ្ញា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីឬតំណាងស្របច្បាប់មិនសុខចិត្តចំពោះសាលក្រមដែលបានសម្រេចសេចក្តី (មាត្រា ៣៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។ រយៈពេលប្តឹងឧទ្ធរណ៍មួយខែ (មាត្រា ៣៨១, ៣៨២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។
- **បណ្តឹងសារទុក្ខ:** បណ្តឹងសារទុក្ខធ្វើឡើងនៅពេលដែលអគ្គព្រះរាជអាជ្ញាជនជាប់ចោទដើមបណ្តឹងរដ្ឋប្បវេណី ឬតំណាងស្របច្បាប់មិនសុខចិត្តចំពោះសាលដីការបស់សាលាឧទ្ធរណ៍ (មាត្រា ៤១៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។ រយៈពេលធ្វើបណ្តឹងសារទុក្ខមួយខែ (មាត្រា ៤២០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។
- **បណ្តឹងសើរើ:** បណ្តឹងសើរើ គឺជាបណ្តឹងតវ៉ាមួយប្រឆាំងទៅនឹងសាលក្រមឬសាលដីកាដែលបានចូលជាស្ថាពរ (មាត្រា ៤៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។ អ្នកដែលធ្វើបណ្តឹងសើរើបានគឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទណ្ឌិតឬអ្នកតំណាងស្របច្បាប់សហព័ទ្ធ ឪពុកម្តាយកូន និងជាទូទៅជនណាដែលមានប្រយោជន៍ខាងសម្ភារ ឬខាងផ្លូវចិត្តក្នុងការលុបបំបាត់ទណ្ឌកម្មនេះ។ បណ្តឹងសើរើអាចធ្វើបាននៅតុលាការកំពូល។ បណ្តឹងទាស់បណ្តឹងឧទ្ធរណ៍ បណ្តឹងសារទុក្ខ បណ្តឹងសើរើ ធ្វើឡើងដើម្បីផលប្រយោជន៍ស្របច្បាប់។

**២.តើនរណាខ្លះ មានសិទ្ធិប្តឹងទាស់ ឬប្តឹងជួសជនជាប់ចោទបានហើយក្នុងន័យច្បាប់បកស្រាយបែបណាដែរ?**

អ្នកដែលមានសិទ្ធិប្តឹងទាស់ ឬប្តឹងជំនួសពិរុទ្ធជនបានគឺ ពិរុទ្ធជនខ្លួនឯង មេធាវី ឪពុក ម្តាយឬអាណាព្យាបាលៈ

១-ពិរុទ្ធជនជានីតិជន (មានអាយុចាប់ពី ១៨ ឆ្នាំឡើង) អាចប្តឹងបានដោយខ្លួនឯងឬពឹងអ្នកតំណាងឲ្យប្តឹងជំនួស (អ្នកតំណាងស្របច្បាប់គឺមេធាវី)

២-ពិរុទ្ធជនជាអនីតិជន (មានអាយុ ១៤ឆ្នាំ ឡើងដល់ ១៨ឆ្នាំ) អ្នកដែលអាចប្តឹងទាស់បានមាន ឪពុក ម្តាយ អាណាព្យាបាលឬមេធាវីដែលមានការផ្ទេរសិទ្ធិពីឪពុក ម្តាយ អាណាព្យាបាល។

ការបកស្រាយតាមន័យច្បាប់គឺថា៖ ១- ពិរុទ្ធជនជានីតិជនអាចប្តឹងដោយខ្លួនឯង ឬមានសិទ្ធិពឹងមេធាវីឲ្យប្តឹងជំនួស ព្រោះថាច្បាប់នៅក្នុងប្រទេសកម្ពុជា បានកំណត់វ័យនីតិភាពពោលគឺអាយុ ១៨ ឆ្នាំឡើងព្រោះថា អាយុនេះអាចមានការគិតពិចារណាបានត្រឹមត្រូវទៅលើសកម្មភាពរបស់ខ្លួន។ ២- ពិរុទ្ធជនជាអនីតិជនចាប់ពីអាយុ ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ គឺអ្នកតំណាងស្របច្បាប់របស់គាត់ជាអ្នកប្តឹងជំនួស ឬអ្នកតំណាងនោះផ្ទេរសិទ្ធិឲ្យអ្នកតំណាងស្របច្បាប់ប្តឹងជំនួសបន្តទៀតបាន។ (មាត្រា ៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។

មូលហេតុបានជាពិរុទ្ធជនជាអនីតិជនមិនអាចប្តឹងដោយខ្លួនឯងបាន ព្រោះគាត់ពុំទាន់មានសមត្ថភាពតាមផ្លូវច្បាប់នៅឡើយ។

**៣.មូលហេតុអ្វីបានជាច្បាប់ចែងឲ្យមានការប្តឹងជំទាស់ ឬប្តឹងជំនួស?**

មូលហេតុដែលច្បាប់ចែងឲ្យមានការប្តឹងជំទាស់ ឬប្តឹងជំនួស ព្រោះថា ច្បាប់ត្រូវបានជានារក្សាសិទ្ធិដល់ជនជាប់ចោទ និងផលប្រយោជន៍ស្របច្បាប់នៅចំពោះមុខយុត្តាធិការតុលាការ។

**៤.តើការប្តឹងនេះមានផលប្រយោជន៍បែបណាដល់ជនជាប់ចោទ?**

កាលណាបណ្តឹងជំទាស់ត្រូវបានធ្វើឡើងនោះ សាលក្រម ឬសាលដីកា ដែលបានសម្រេចត្រូវចាត់ទុកជាអត់បានការ ហើយតុលាការដដែលនោះនឹងបើកសវនាការជំនុំជម្រះសាជាថ្មីឡើងវិញ។

**៥.តើព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អាចប្តឹងបដិសេធលើសាលក្រមឬសាលដីកាបានដែរ ឬយ៉ាងណា?**

ព្រះរាជអាជ្ញាអាចប្តឹងទៅសាលាឧទ្ធរណ៍ដោយមិនសុខចិត្តលើសាលក្រមសាលាដំបូងខេត្ត-ក្រុងបាន។ ចំណែកអគ្គព្រះរាជអាជ្ញា អាចប្តឹងសារទុក្ខទៅតុលាការកំពូលចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។ ជាឧទាហរណ៍៖

១-ជនជាប់ចោទត្រូវមានទោសក្នុងបទឧក្រិដ្ឋដែលច្បាប់បានកំណត់ទោសពី ៣ ឆ្នាំទៅ ១០ ឆ្នាំហើយតុលាការនៃសាលាដំបូងផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំ តែព្រះរាជអាជ្ញាសាលាដំបូងមិនសុខចិត្តប្តឹងទៅសាលាឧទ្ធរណ៍។ សាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការទាំងមូល។

២-ជនជាប់ចោទត្រូវមានទោសក្នុងបទឧក្រិដ្ឋ ដែលច្បាប់បានកំណត់ទោសដាក់ពន្ធនាគារពីបីឆ្នាំទៅដប់ឆ្នាំ តែត្រូវសាលាដំបូងផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តែត្រូវជនជាប់ចោទប្តឹងឧទ្ធរណ៍។ ពេលជម្រះសាលាឧទ្ធរណ៍បានសម្រេចកែប្រែទណ្ឌកម្មទោសពីដាក់ពន្ធនាគារ ៩ឆ្នាំ មក ៤ ឆ្នាំវិញក្នុងករណីនេះ៖

ក- អគ្គព្រះរាជអាជ្ញាមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍បានប្តឹងសារទុក្ខទៅតុលាការកំពូល។

ខ- ពិរុទ្ធជនឬតំណាងស្របច្បាប់ មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍បានប្តឹងសារទុក្ខទៅតុលាការកំពូល។ តែដោយសំណុំរឿងមានច្រើន តុលាការកំពូលមិនទាន់បានបើកសវនាការជំនុំជម្រះរឿងក្តីនេះរយៈពេលបួនឆ្នាំ បានមកដល់។

**៦.ដោយយោងតាមសាលដីកា របស់សាលាឧទ្ធរណ៍ដែលបានដល់ថ្ងៃកំណត់ផុតទោស។ ក្នុងករណីនេះតើមន្ត្រីពន្ធនាគារអាចដោះលែងពិរុទ្ធជននោះបានទេ?**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិប្តឹងសារទុក្ខទៅតុលាការកំពូលបាន។

ក- ចំពោះបណ្តឹងសារទុក្ខរបស់អគ្គព្រះរាជអាជ្ញាៈ មន្ត្រីពន្ធនាគារមិនអាចដោះលែងពិរុទ្ធជនបានទេ ទាល់តែមានសេចក្តីសម្រេចរបស់តុលាការកំពូលឬដល់កំណត់ទោសរបស់សាលាដំបូងទើបអាចដោះលែងពិរុទ្ធជននោះបាន។

ខ- ចំពោះបណ្តឹងសារទុក្ខរបស់ពិរុទ្ធជនឬអ្នកតំណាងស្របច្បាប់ៈ មន្ត្រីពន្ធនាគារដោះលែងពិរុទ្ធជននោះបាន។

បញ្ជាក់ៈ - បណ្តឹងធ្វើឡើងដោយព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា ទណ្ឌកម្មអាចត្រូវបានតុលាការសម្រេចបន្ថែម ឬបន្ថយទណ្ឌកម្មទោស។

- បណ្តឹងធ្វើឡើងដោយពិរុទ្ធជន ឬអ្នកតំណាងស្របច្បាប់តុលាការសម្រេចទណ្ឌកម្មនៅដដែល ឬបន្ថយ (មិនសម្រេចដំឡើងទណ្ឌកម្មឡើយ)។

# ផ្នែកទី២០

# ដីកា ការចេញដីកា និងអនុវត្តដីកាក្នុងផ្នែកតុលាការ

លោកមេធាវី សេង រ៉ុន ជាសមាជិកនៃគណៈមេធាវីអន្តរជាតិ អត្តលេខ ០៦៣ ប្រើអាស័យដ្ឋានៈ រ៉ុន & ដៃគូមន្ទីរមេធាវីអន្តរជាតិ លេខ ១១២ A ផ្លូវ ១៦៧ សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន ភ្នំពេញ បានផ្ដល់សម្ភាសន៍ជាមួយភ្នំពេញប៉ុស្តិ៍ លើប្រធានបទនៃការប្រើដីកានៅក្នុងតុលាការ និងផ្អែកលើបញ្ញត្តិច្បាប់ជាធរមានដែលមានខ្លឹមសារដូចខាងក្រោម៖

**១.ដូចម្ដេចហៅថា ដីកា?**

ពាក្យថា ដីកានេះមានន័យថា លិខិតឬសេចក្ដីសម្រេច ឬជាលិខិតបង្គាប់បញ្ជា។ ដីកាប្រើបានទាំងព្រះសង្ឃ ទាំងគ្រហស្ថ ទាំងរដ្ឋបាលសាធារណៈ មានទាំងរដ្ឋមន្ត្រីអភិបាលខេត្ត/ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់ និងខាងផ្នែកតុលាការជាដើម។ ឧទាហរណ៍៖ សង្ឃដីកា ព្រះសង្ឃដីកា សម្ដេចសង្ឃ ដីការបស់រដ្ឋមន្ត្រី រហូតដល់ដីការបស់មេ/ឃុំ ចៅសង្កាត់ និងដីការបស់ចៅក្រម ។ល។

**២.ចំពោះដីកានេះនៅក្នុងតុលាការ តើប្រើបានយ៉ាងម៉េចដែរ?**

ខ្ញុំសុំបកស្រាយតែដីកា ខាងផ្នែកតុលាការសម្រាប់ប្រជាពលរដ្ឋទូទៅ។ នៅតុលាការផ្នែករដ្ឋប្បវេណី ដោយគិតទាំងតុលាការព្រហ្មទណ្ឌផងទម្រង់បែបបទនៃដីកា គឺមានច្រើនសណ្ឋាន ក៏ប៉ុន្តែ ជារួមនៅតែជាសេចក្ដីសម្រេចរបស់ចៅក្រមព្រះរាជអាជ្ញា ឬសាលាក្តី។ ដីកាខ្លះមានលក្ខណៈជាលិខិតអញ្ជើញធម្មតា និងដីកា ខ្លះទៀត មានលក្ខណៈដាក់កំហិត ឬជាបញ្ជា។

**៣.តើដីកាមានសណ្ឋាន ឬមានការបែងចែកជាប៉ុន្មានប្រភេទ?**

អំពីសណ្ឋានដីកាផ្សេងៗ ខាងផ្នែកតុលាការព្រហ្មទណ្ឌរួមមាន :

- ដីកាកោះ ចេញដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ គឺប្រើបាននៅក្នុងរឿងព្រហ្មទណ្ឌសម្រាប់កោះហៅដើមបណ្ដឹងក្នុងកាលកំណត់ណាមួយ ដើម្បីឲ្យបុគ្គលនោះទៅឆ្លើយបំភ្លឺបន្ថែមជាបឋម នៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរអំពីបណ្ដឹងរបស់ខ្លួន។ ដោយឡែក ព្រះរាជអាជ្ញាមានតួនាទីចេញដីកាកោះសម្រាប់អញ្ជើញគូក្តីឲ្យចូលសវនាការនៅថ្ងៃជំនុំជម្រះក្តី។ ចំពោះដីកាសម្រាប់មេធាវីវិញតុលាការច្រើនប្រើពាក្យ "អញ្ជើញ" មេធាវី ដែលមានន័យ ដូចតែដីកាអញ្ជើញដែរ។
- ដីកាបង្គាប់ឲ្យចូលខ្លួន ដីកានេះ ចេញដោយចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលមានលក្ខណៈបង្គាប់ដាក់កំហិតឲ្យជនជាប់ចោទ(អ្នកប្រព្រឹត្តល្មើស) ឬក៏បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពចូលខ្លួនក្នុងកាលកំណត់ណាមួយ(ថ្ងៃ.ខែ.ឆ្នាំ.ម៉ោង) នៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឆ្លើយបំភ្លឺអំពីករណីដែលគេប្តឹងមកលើរូបខ្លួន អំពីបទចោទប្រកាន់ណាមួយ។
- ដីកាបង្គាប់ឲ្យនាំខ្លួនក្នុងនីតិវិធីព្រហ្មទណ្ឌ គឺសេចក្ដីសម្រេចចេញដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ បញ្ជាឲ្យកងកម្លាំងសាធារណៈមាននគរបាល និងកងរាជអាវុធហត្ថ ដើម្បីឲ្យចាប់និងនាំខ្លួនបុគ្គលណាម្នាក់ ដែលមានចារឈ្មោះច្បាស់លាស់ (ជីវប្រវត្តិសង្ខេប) ចៀសវាងការភាន់ច្រឡំ មកចំពោះមុខខ្លួនក្នុងរយៈពេលយ៉ាងខ្លី អំពីករណីសង្ស័យថាបានប្រព្រឹត្តបទល្មើស ឬចូលរួមក្នុងការប្រព្រឹត្តបទល្មើសជាក់ស្តែងណាមួយ ឬជាកម្មវត្ថុនៃការចោទប្រកាន់ណាមួយ។ ដីកាបង្គាប់ឲ្យនាំខ្លួននេះ ចៅក្រមស៊ើបសួរប្រើប្រាស់ក្នុងនីតិវិធីព្រហ្មទណ្ឌ ក្រោយពីលោកចៅក្រមចេញដីកាបង្គាប់ឲ្យជនជាប់ចោទចូលខ្លួនហើយជនជាប់ចោទ នៅតែព្រងើយកន្តើយពុំព្រមចូលខ្លួន មកចំពោះមុខចៅក្រមស៊ើបសួរ ដោយមូលហេតុថា ការបញ្ជូនដីកាបង្គាប់ឲ្យចូលខ្លួនពុំបានដល់ដៃជនជាប់ចោទ ដោយហេតុថា រកពុំឃើញ

......

ដោយផ្លាស់ទីលំនៅ ឬទីលំនៅមិនច្បាស់លាស់ឬគេចវេះ ឬដោយមូលហេតុរឹងទទឹងពុំចូល ទើបលោកចៅក្រមបង្គាប់បញ្ជាទៅគ្រប់កម្លាំងសាធារណៈថា ឃើញជនជាប់ចោទនេះនៅកន្លែងណា ត្រូវនាំជនជាប់ចោទនេះមកឲ្យលោកចៅក្រមស៊ើបសួរភ្លាម។

**៤.ពេលខ្លះតុលាការបើកសវនាការតែពុំមានជនជាប់ចោទលុះក្រោយមកជនជាប់ចោទថា មិនបានទទួលដីកា តើករណីនេះលោកអង្កេតឃើញដូចម្តេចដែរ?**

ខ្ញុំសុំនិយាយអំពីការបញ្ជូនដីកាផ្សេងៗទៅឲ្យសាមីជនដើមចោទ ចុងចម្លើយ និងជនជាប់ចោទ ជាដើម មានការខ្វះខាតច្រើន ដោយសារតែអ្នកបញ្ជូនដីកា គឺអាជ្ញាសាលា។ អាជ្ញាសាលា ជាអ្នកបញ្ជូនឯកសាររបស់តុលាការសព្វថ្ងៃត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអាជ្ញាសាលាដែលចេញពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈពិតប្រាកដ។ អាជ្ញាសាលាភាគច្រើន បំពេញការងារប្រកបដោយវិជ្ជាជីវៈខ្ពស់ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ក៏ប៉ុន្តែមួយភាគតូចមិនបានប្រកាន់យកក្រមសីលធម៌ដ៏ល្អរបស់ខ្លួនទេ។ ដោយសារការធ្វេសប្រហែស ហើយក៏ផ្ទុកផ្តាក់ការងារឲ្យទៅជំនួយការខ្លួនធ្វើ។ ជំនួយការនេះឯងដែលជួនកាលធ្វើផ្តេសផ្តាស់ ដោយត្រូវរ៉ូវបានលុយបានកាក់ខ្លះពីជនជាប់ចោទម្ល៉ោះហើយក៏តាំងចារដីកាថា រកសាមីជនពុំឃើញ ឬរកអាសយដ្ឋានពុំឃើញ ដែលធ្វើឲ្យខូចផលប្រយោជន៍ដល់គូក្តី និងអូសបន្លាយរឿងក្តី។ ជួនកាលមានអាជ្ញាសាលាខ្លះហ៊ានរហូតដល់ទូរស័ព្ទទៅមេធាវី ឬដើមបណ្តឹងថា បើយកដីកាឲ្យជនជាប់ចោទក្នុងរឿងក្តីនេះ តើឲ្យខ្លួនប៉ុន្មានដុល្លារក៏មាន? ហេតុនេះហើយទើបក្នុងពេលសវនាការខ្លះជួបបញ្ហាអវត្តមានជនជាប់ចោទ ឬបុគ្គលដើមបណ្តឹង ឬចុងចោទ។

- ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាការបញ្ជាឲ្យកងកម្លាំងសាធារណៈមាននគរបាលនិងកងរាជអាវុធហត្ថ ស្រាវជ្រាវរកចាប់និងនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារឬមណ្ឌលឃុំខ្លួននិងប្រាប់ដល់ប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន ឲ្យទទួលយកនិងឃុំខ្លួនបុគ្គលនោះ។

នេះជានីតិវិធីព្រហ្មទណ្ឌ ក្រៅពីលោកចៅក្រមស៊ើបសួរបានចេញជាបន្តបន្ទាប់នូវដីកាបង្គាប់ឲ្យចូលខ្លួន និងដីកាបង្គាប់ឲ្យនាំខ្លួនរួចហើយ ជនត្រូវចោទនៅតែពុំព្រមបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យចាប់ខ្លួនក៏ជានីតិវិធីរបស់សាលាក្តីព្រហ្មទណ្ឌដើម្បីរកចាប់ខ្លួនទណ្ឌិតណាម្នាក់នាំយកទៅមន្ទីរឃុំឃាំងវិញ។ មុននឹងចេញដីកាចាប់ខ្លួននេះចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីលោកព្រះរាជអាជ្ញា ហើយត្រូវបញ្ជាក់ពីមូលហេតុដែលនាំឲ្យចេញដីកាឲ្យចាប់ខ្លួននេះ ដូចជាបទល្មើសដែលបានចោទប្រកាន់នេះគឺបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមដែលត្រូវជាប់គុក។ ម្យ៉ាងទៀតដោយមូលហេតុថាជនដែលពាក់ព័ន្ធនេះបានគេចខ្លួនមិនដឹងថា ស្ថិតនៅកន្លែងណាឬស្ថិតនៅក្រៅប្រទេស។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ តាមឆន្ទានុសិទ្ធិរបស់ខ្លួនអាចរំលងនីតិវិធីមិនធ្វើតាមលំដាប់លំដោយ ដោយចេញដីកាបង្គាប់ឲ្យចាប់ខ្លួនតែម្តងក្រោយពីពិនិត្យរួចហើយដោយពិចារណាថា ជនជាប់ចោទជាមនុស្សគ្រោះថ្នាក់ អាចបង្កវិនាសកម្មគ្រោះថ្នាក់ផ្សេងៗដល់សង្គម ដល់សាធារណជនដល់អ្នកប្តឹងប្តល់ ឬដោយហេតុថា រឿងក្តីនេះជារឿងភេរវកម្ម ឬដោយមូលហេតុជនជាប់ចោទអាចគេចខ្លួនទៅបរទេស។ល។ និង ។ល។

**៥.ឧទាហរណ៍ជាក់ស្តែងមានករណីខ្លះតុលាការបានចេញដីកាទៅដល់ដៃសមត្ថកិច្ចហើយ តែសមត្ថកិច្ចមិនបញ្ជូនដល់ជនត្រូវកោះនោះ។ តើលោកមេធាវីមានបានកត់សម្គាល់ដែរទេ?**

អំពីការមិនអនុវត្តបាននូវដីកាបែបនេះដែលមានចំនួនយ៉ាងច្រើននៅក្នុងដៃសមត្ថកិច្ចដែលជាមន្ត្រីយុត្តិធម៌មានតួនាទីក្នុងការអនុវត្ត ការរកចាប់ខ្លួនជនជាប់ចោទ និងទណ្ឌិតខ្លះ ម្ល៉ោះហើយ ជនជាប់ចោទ និងទណ្ឌិតដែលតុលាការបានសម្រេចកាត់ទោសរួចហើយដើររំភើយដោយគ្មានព្រួយបារម្ភ។ មេធាវី ឬដើមបណ្តឹងត្រូវចំណាយលុយកាក់ផ្ទាល់ខ្លួន និងពេលវេលាដើរ

រកជនជាប់ចោទនោះឬទណ្ឌិត ដោយខ្លួនឯង ដោយមធ្យោបាយខ្លួនឯងហើយចង្អុលប្រាប់សមត្ថកិច្ច ទើបសមត្ថកិច្ចធ្វើការជូន បើពុំដូច្នេះទេ គឺមោឃៈតែម្តង ទោះបីជាប៉ុន្មានឆ្នាំក៏ដោយ។

- ដីកាបង្គាប់ឲ្យឃុំខ្លួន ចេញដោយចៅក្រមស៊ើបសួរឬតុលាការព្រហ្មទណ្ឌបញ្ជាឲ្យលោកប្រធានពន្ធនាគារ មន្ទីរឃុំឃាំង ឬមណ្ឌលកែប្រែ ពាក្យសាមញ្ញថា ប្រធានគុកទទួលឃុំជនជាប់ចោទពុំទាន់កាត់ទោសពីតុលាការ (ឃុំខ្លួនបណ្តោះអាសន្ន) ឬទទួលឃុំទណ្ឌិត ដែលតុលាការបានសម្រេចដាក់ទោសទណ្ឌរួចហើយ។

នៅមានដីកាផ្សេងៗជាច្រើនទៀតខាងផ្នែកតុលាការដែលខ្ញុំពុំបានបកស្រាយជូនឲ្យអស់នៅពេលនេះ។ គួរកត់សម្គាល់ថា ការផ្តិតមេដៃឬការចុះហត្ថលេខាទទួលយកនូវរាល់ដីកានានា សាមីខ្លួនអ្នកទទួលចាំបាច់ត្រូវទទួលចុះថ្ងៃ-ខែ-ឆ្នាំ ម៉ោង ទទួលឲ្យបានត្រឹមត្រូវពីព្រោះការគិតគូរពីពេលវេលាគឺចាប់រាប់ពីថ្ងៃទទួលដីកានេះឯង។

# ផ្នែកទី២១

## តួនាទីសិទ្ធិអំណាចរបស់អង្គការអយ្យការ ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា(ភាគ១)

លោក គង់ ទីលីន អត្តលេខ ៤៤៧ ដែលជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធាននៃក្រុមការងារវិស័យព្រហ្មទណ្ឌបានផ្តល់បទសម្ភាសន៍ដល់កាសែតភ្នំពេញប៉ុស្ដិ៍ ស្ដីអំពីតួនាទីនិងសិទ្ធិអំណាចរបស់អង្គការអយ្យការ ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា និងសិទ្ធិអំណាចរបស់អគ្គមហាអយ្យការ ដែលមានខ្លឹមសារដូចខាងក្រោមៈ

**១.តើស្ថាប័នអយ្យការ និងមហាអយ្យការមានប៉ុន្មានថ្នាក់? និងតំណាងដោយអ្នកណា?**

ស្ថាប័នអយ្យការនិងមហាអយ្យការមាន ៣ ថ្នាក់:

ទី១-អយ្យការអមសាលាដំបូងខេត្ត-រាជធានី ដែលតំណាងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង

ទី២-មហាអយ្យការអមសាលាឧទ្ធរណ៍ដែលតំណាងឲ្យអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា

ទី៣-មហាអយ្យការអមតុលាការកំពូល ដែលតំណាងដោយអគ្គព្រះរាជអាជ្ញា អមតុលាការកំពូល អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា។ (យោងតាមមាត្រា ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**២.តើអង្គការអយ្យការមានតួនាទីអ្វីខ្លះ?**

អង្គការអយ្យការមានតួនាទីធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យអនុវត្តច្បាប់។ អង្គការអយ្យការជានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងជានាលើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចចៅក្រមអយ្យការ (ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង) មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌចៅក្រមអយ្យការ(ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង) ត្រូវតែមានវត្តមាន ក្នុងពេលសវនាការចំពោះរឿងក្តីព្រហ្មទណ្ឌ។ (យោងតាមមាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**៣.តើសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត-រាជធានីមានអ្វីខ្លះ?**

ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត-រាជធានីមានសិទ្ធិអំណាចដូចខាងក្រោមៈ

- ដឹកនាំនិងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។
- ប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ស៊ើបអង្កេត។
- អាចចុះទៅកាន់កន្លែងស៊ើបអង្កេតនិងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌។
- អាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញា អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។ (យោងតាមមាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**៤.តើអគ្គមហាអយ្យការអមសាលាឧទ្ធរណ៍ មានតួនាទីធ្វើអ្វីខ្លះ?**

មហាអយ្យការអមសាលឧទ្ធរណ៍ ដឹកនាំដោយអគ្គព្រះរាជអាជ្ញា ហើយមានតួនាទី ក្នុងការឃ្លាំមើល ការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដី នៃសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ច នៅអង្គការអយ្យការអមសាលាដំបូងខេត្ត-រាជធានីទូទាំងព្រះរាជាណាចក្រកម្ពុជា។ (យោងតាមមាត្រា ៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**៥.តើសិទ្ធិអំណាចរបស់អគ្គព្រះ រាជអាជ្ញាអមសាលាឧទ្ធរណ៍មានអ្វីខ្លះ?**

អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ មានសិទ្ធិអំណាចដូចខាងក្រោម៖

- ធ្វើការឃ្លាំមើល និងត្រួតពិនិត្យនគរបាលយុត្តិធម៌
- អាចកោះអញ្ជើញអ្នកទទួលខុសត្រូវ នៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនិងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាលទាំងនោះ
- អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឲ្យបំពេញភារកិច្ចទាំងឡាយ ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការល្អ នៃនគរបាលយុត្តិធម៌។
- អាចធ្វើអធិការកិច្ចគ្រប់ពេលវេលា នៅអង្គភាពនគរបាលយត្តិធម៌។
- អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។ ប្រធានអង្គភាពនគរបាលយុត្តិធម៌មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូបត្រូវគោរពអធិបញ្ជារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ (យោងតាមមាត្រា ៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)...

# ផ្នែកទី២២

## តួនាទីសិទ្ធិអំណាចរបស់អង្គការអយ្យការ ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា(ភាគ២)

តពីលេខចេញផ្សាយថ្ងៃសុក្រមុន

**១.នៅពេលមានរឿងព្រហ្មទណ្ឌកើតឡើង តើយើងអាចដាក់ពាក្យបណ្ដឹងទៅអង្គការអយ្យការណាមួយបាន ឬក៏យើងអាចដាក់ពាក្យបណ្ដឹងទៅមហាអយ្យការអមសាលាឧទ្ធរណ៍បានទេ?**

ដូចដែលបានជម្រាបជូនខាងលើរួចមកហើយ នៅតាមខេត្ត-រាជធានី មានអង្គការអយ្យការ អមសាលាដំបូងខេត្ត-រាជធានីទូទាំងប្រទេសក្នុងករណីមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ជនរងគ្រោះ ឬដើមបណ្ដឹង រដ្ឋប្បវេណី អាចដាក់ពាក្យបណ្ដឹងទៅអង្គការអយ្យការអមសាលាដំបូង ខេត្ត-រាជធានី នោះ ដោយពុំអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ មកមហាអយ្យការអមសាលាឧទ្ធរណ៍នោះទេ ពីព្រោះមហាអយ្យការអមសាលាឧទ្ធរណ៍ អាចទទួលសំណុំរឿងក្ដីព្រហ្មទណ្ឌណាមួយមកចាត់ការបានលុះត្រាតែអយ្យការអមសាលាដំបូងខេត្ត-រាជធានី ដែលបានទទួលសំណុំរឿងនោះ បានសម្រេចតម្កល់រឿងទុកឥតចាត់ការហើយមានបណ្ដឹងឧទ្ធរណ៍លើដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនោះ ទើបអង្គការអយ្យការអមសាលាដំបូងខេត្ត-រាជធានី បញ្ជូនមកមហាអយ្យការអមសាលាឧទ្ធរណ៍ដើម្បីពិនិត្យចាត់ការ។

**២.នៅពេលបណ្ដឹងកំពុងចាត់ការដោយព្រះរាជអាជ្ញា តើស្ថាប័នណា មានសិទ្ធិធ្វើអធិបញ្ញា មកអយ្យការអមសាលាដំបូងខេត្ត-រាជធានី ដែលកំពុងកាន់សំណុំរឿងនោះ?**

យោងតាមមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍មានសិទ្ធិធ្វើអធិបញ្ញា ឲ្យចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណា ដែលខ្លួនយល់ឃើញថា ជាការគួរមកអង្គការអយ្យការអមសាលាដំបូងខេត្ត-រាជធានី។ បានន័យថា ទោះបីជាបណ្ដឹងព្រហ្មទណ្ឌនោះ កំពុងចាត់ការដោយអង្គការអយ្យការអមសាលាដំបូងខេត្ត-រាជធានីណាមួយក៏ដោយ ក្នុងករណីមានការស្នើសុំអន្តរាគមន៍ ដើម្បីចេញអធិបញ្ញា ហើយប្រសិនបើយល់ឃើញថា មានបទល្មើស រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិតាមផ្លូវច្បាប់ បញ្ជាឲ្យព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ធ្វើការចោទប្រកាន់ ឬសន្និដ្ឋានយ៉ាងណា តាមការយល់ឃើញរបស់ខ្លួន។

**៣.ក្នុងករណីមានបណ្ដឹងព្រហ្មទណ្ឌណាមួយ កំពុងចាត់ការដោយសមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ តើចាំបាច់ដែរ ឬទេក្នុងការសុំយោបល់ ឬសុំការអនុញ្ញាតពីព្រះរាជអាជ្ញា?**

ដូចបានជម្រាបជូនខាងលើមកហើយ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងជាអ្នកដឹកនាំ និងសម្របសម្រួល សកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ហេតុនេះ ទោះជាក្នុងករណីនៃការបើកការស៊ើបអង្កេតបឋមឬស៊ើបអង្កេតជាក់ស្ដែងក៏ដោយ មន្ត្រីឬភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវមានការសុំយោបល់ និងអនុញ្ញាតពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង លើកិច្ចការងារស៊ើបអង្កេតរបស់ខ្លួនជាដាច់ខាត។ រាល់ការស៊ើបអង្កេត និងចំណាត់ការណាមួយ ដោយគ្មានការអនុញ្ញាតពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវទទួលខុសត្រូវ លើកំហុសវិន័យពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរបាយការណ៍ របស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ។ (យោងតាមមាត្រា ៦៤ និង ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**៤.តើការដាក់វិន័យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ លើមន្ត្រីនគរបាលយុត្តិធម៌ ដែលបានប្រព្រឹត្តកំហុសមានកម្រិតណាខ្លះ?**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទទួលដំណឹងពីកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ តាមរបាយការណ៍ពីព្រះរាជអាជ្ញា ឬពីចៅក្រមស៊ើបសួរ បន្ទាប់ពីទទួលរបាយការណ៍ពីករណីនីមួយៗ អគ្គព្រះរាជអាជ្ញា ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រី

ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ។ ក្នុងករណី អគ្គព្រះរាជអាជ្ញាយល់ឃើញថា មានសភាពធ្ងន់ធ្ងរនៃកំហុសប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ អគ្គព្រះរាជអាជ្ញា មានសិទ្ធិប្រកាសចេញនូវវិធានការដូចខាងក្រោម៖

- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ ឆ្នាំយ៉ាងច្រើនបំផុត។
- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។ (យោងតាម មាត្រា ៦៤ និង ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

# វគ្គទី២៣

## អ្វីទៅជាតួនាទីនិងភារកិច្ចក្រឡាបញ្ជីនៅក្នុងរឿងក្ដី?

លោកមេធាវី ឡោ គីមហ៊ួច ហៅ សីហា ដែលបម្រើការនៅការិយាល័យមេធាវី ឈី សម្បត្តិ បានផ្ដល់បទសម្ភាសន៍ជាមួយភ្នំពេញប៉ុស្ដិ៍ ដោយបានលើកឡើងអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីរបស់ចៅក្រម និងព្រះរាជអាជ្ញាដែលទទួលសំណុំរឿងក្ដីនីមួយៗ មានខ្លឹមសារជាអាទិ៍ដូចខាងក្រោម៖

**១.តើតួនាទី និងភារកិច្ចសំខាន់របស់ក្រឡាបញ្ជីមានអ្វីខ្លះ?**

តួនាទី និងភារកិច្ចសំខាន់របស់ក្រឡាបញ្ជី គឺជាជំនួយការរបស់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងរឿងក្ដីព្រហ្មទណ្ឌ និងនៅក្នុងរឿងរដ្ឋប្បវេណី។

**២.ចុះអ្វីជាភារកិច្ចរបស់ក្រឡាបញ្ជីនៅពេលទទួលសំណុំរឿងព្រហ្មទណ្ឌ?**

ក្រឡាបញ្ជីមានភារកិច្ចសំខាន់ខ្លាំងណាស់ចាប់តាំងពីសំណុំរឿងព្រហ្មទណ្ឌបានចូលមកដល់។ ក្រឡាបញ្ជីត្រូវមានវត្តមានជានិច្ចនៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងបី គឺ ទី១.ទាំងនៅដំណាក់កាលអយ្យការ (ដំណាក់កាលស៊ើបអង្កេតបឋម) ទី២.នៅដំណាក់កាលចៅក្រមស៊ើបសួរ និង ទី៣.នៅដំណាក់កាលចៅក្រមជំនុំជម្រះ។

**៣.លោកមេធាវីសំណុំរឿងនេះតើនៅដំណាក់កាលអយ្យការ (ដំណាក់កាលស៊ើបអង្កេតបឋម) តើក្រឡាបញ្ជីមានភារកិច្ចអ្វីខ្លះ?**

សម្រាប់នៅដំណាក់កាលអយ្យការនេះ ក្រឡាបញ្ជីមានភារកិច្ចសំខាន់រួមមាន៖

-ទី១ ទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ឬពីសាធារណជន ឬពីជនអនាមិក

-ទី២ សរសេរកំណត់ហេតុ តាមការសាកសួររបស់អយ្យការទៅលើជនសង្ស័យ ឬសាក្សី

-ទី៣ ទទួលវត្ថុតាងយកមករក្សាទុក (ចុះបញ្ជីក្នុងសៀវភៅវត្ថុតាង)។

-ទី៤ ព្រាងដីកាផ្សេងៗជូនព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង

-ទី៥ ត្រូវចុះជាប់ជាមួយព្រះរាជអាជ្ញានិងព្រះរាជអាជ្ញារងដើម្បីពិនិត្យកន្លែងកើតហេតុ ឆែកឆេរលំនៅឋាននិងប្រតិបត្តិការផ្សេងទៀតរបស់តំណាងមហាអយ្យការ។

ក្នុងករណីសំណុំរឿងដែលមានជនសង្ស័យមកជាមួយ ក្នុងដំណាក់កាលនេះក្រឡាបញ្ជីត្រូវសរសេរចុះក្នុងសៀវភៅបណ្ដឹងព្រហ្មទណ្ឌ តាមសេចក្ដីពិស្ដារនៃការចាប់ខ្លួនរួចសរសេរនៅលើក្របសំណុំរឿងនៅថ្ងៃខែឆ្នាំឃាត់ខ្លួន។ ប៉ុន្តែនៅក្នុងករណីទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ភារកិច្ចក្រឡាបញ្ជី ជាដំបូងត្រូវពិនិត្យលើៈ បញ្ជីរាយលិខិតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងធ្វើការពិនិត្យលើឯកសារទូទៅ។

**៤.ចុះនៅក្នុងដំណាក់កាលការសួរយកចម្លើយវិញ តើក្រឡាបញ្ជីមានតួនាទីសំខាន់ដូចម្ដេចខ្លះដែរ?**

ក្នុងដំណាក់ការសួរយកចម្លើយ ក្រឡាបញ្ជីត្រូវឲ្យអ្នកគ្មានភារកិច្ចចេញពីបន្ទប់សួរចម្លើយ។ អ្នកគ្មានភារកិច្ច គឺអ្នកទាំងឡាយដែលក្រៅពីៈ ព្រះរាជអាជ្ញា ឬចៅក្រម ក្រឡាបញ្ជីខ្លួនឯង មេធាវី ជនសង្ស័យឬដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សី អ្នកបកប្រែ ហើយនិង អាណាព្យាបាល (ករណីជនសង្ស័យជាអនីតិជន)។ ក្រៅពីនេះក្រឡាបញ្ជីត្រូវរៀបចំតាំប៉ុងសម្រាប់ផ្ដិតមេដៃ ក្រដាសសម្រាប់កត់ត្រា និងសម្រាប់គូសវាសធ្វើជាផែនទីកំណត់ទីតាំង។ ក្រោយពេលបញ្ចប់ការសួរយកចម្លើយពីជនសង្ស័យរួចហើយ ហើយជននោះព្រះរាជអាជ្ញារកឃើញថា មានពិរុទ្ធភាព ហើយព្រះរាជអាជ្ញាផ្ដើមចោទប្រកាន់ តាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ពេលនោះក្រឡាបញ្ជីត្រូវប្រគល់ខ្លួនជនសង្ស័យ និងសំណុំរឿងព្រមទាំងវត្ថុតាងទៅឲ្យចៅក្រមស៊ើបសួរតាមនីតិវិធីដើម្បីចាត់វិធានការបន្តតាមច្បាប់កំណត់។

**៥.ចុះបើនៅក្នុងដំណាក់កាលចៅក្រម ស៊ើបសួរវិញ តើក្រឡាបញ្ជីមាន ភារកិច្ចចាំបាច់អ្វីខ្លះដែរទៅ?**

នៅក្នុងដំណាក់កាលចៅក្រមស៊ើប សួរនេះក្រឡាបញ្ជីមានភារកិច្ចៈ

- ទី១.ទទួលសំណុំរឿងពីអយ្យការ
- ទី២.ទទួលឯកសារបន្ថែមពីភាគីពាក់ព័ន្ធក្នុងសំណុំរឿង (ចុះហត្ថលេខាលើលិខិតទទួល)
- ទី៣.ពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ
- ទី៤.ពិនិត្យដីកាបញ្ជូនឬបញ្ជីរាយលិខិត
- ទី៥.ពិនិត្យឯកសារទាក់ទងនឹងវត្ថុតាង
- ទី៦.ពេលសាកសួរយកចម្លើយជនដែលពាក់ព័ន្ធក្នុងសំណុំរឿងត្រូវរៀបចំដូចក្រឡាបញ្ជីអយ្យការ សួរយកចម្លើយ
- ទី៧. ត្រូវរៀបចំដីកា។

ដីកាដែលក្រឡាបញ្ជីនឹងត្រូវរៀបចំរួមមាន ដីកាលើកលែងចោទប្រកាន់ ដីកាឆែកឆេរ ដីកានាំខ្លួនសាក្សី ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកាបញ្ជូនរឿងទៅពិនិត្យមូលហេតុ ដីកាបង្គាប់ឲ្យស៊ើបសួរបន្ថែម ដីកាសុំកែប្រែបទល្មើស ដីកាចាត់តាំងមេធាវី ដីកាផ្ទេរសមត្ថកិច្ច ដីកាឲ្យធ្វើកោសល្យវិច័យ ដីកាសុំឲ្យស៊ើបអង្កេតបទល្មើសថ្មីបន្ថែម ដីកាចាត់ឲ្យសួរជំនួស ដីកាបង្គាប់ឲ្យចូលខ្លួន ដីកានាំខ្លួន ដីកាចាប់ខ្លួន ដីកាឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និងដីកាបង្គាប់ឲ្យដោះលែង។ល។

**៦.បើនៅក្នុងដំណាក់កាលចៅក្រមជំនុំជម្រះវិញ តើក្រឡាបញ្ជីមានភារកិច្ចអ្វីខ្លះដែរ?**

នៅពេលទទួលសំណុំរឿងពីចៅក្រមស៊ើបសួររួច ក្រឡាបញ្ជីត្រូវរៀបចំសំណុំរឿងដាក់តាមផ្នែក និងដំណាក់កាលនីមួយៗ ដើម្បីងាយស្រួលចៅក្រមត្រូវការមើលនៅពេលសវនាការទៅតាមដំណាក់កាលណាមួយដែលអាចពិនិត្យមើលបានយ៉ាងឆាប់។ ក្នុងពេលបើកសវនាការក្រឡាបញ្ជីចាំបាច់ត្រូវៈ

- ទី១. ប្រមូលលិខិតអញ្ជើញ ដីកាកោះ និងចុះឈ្មោះអ្នកចូលរួមសវនាការ
- ទី២. ត្រូវនាំសាក្សីទៅស្បថ
- ទី៣. ប្រមូលវត្ថុតាងពីតំណាងអយ្យការដាក់លើតុ
- ទី៤. មុនពេលបើកសវនាការត្រូវអានបទបញ្ជាផ្ទៃក្នុងនិងនីតិវិធីសម្រាប់សវនាការឲ្យអ្នកចូលរួមបានដឹង
- ទី៥. ក្រឡាបញ្ជីត្រូវប្រកាសឲ្យអ្នកចូលរួមសវនាការក្រោកឈរ ពេលចៅក្រមចូលដល់បន្ទប់សវនាការ
- ទី៦. ពេលចៅក្រមលើករឿងមកជំនុំជម្រះ ក្រឡាបញ្ជីត្រូវក្រោកឈររាយនាមវត្តមាននិងអវត្តមានជនដែលពាក់ព័ន្ធក្នុងរឿងក្តីជូនអង្គសវនាការស្តាប់
- ទី៧.កត់ត្រានូវសំណួរចម្លើយនិងសកម្មភាពទាំងអស់ក្នុងពេលដំណើរសវនាការ (កំណត់ត្រាទុកជាបន្ទាល់)
- ទី៨. ពេលបញ្ចប់ការសាកសួរដេញដោល ក្រឡាបញ្ជីត្រូវឲ្យជនពាក់ព័ន្ធក្នុងសំណុំរឿងផ្តិតមេដៃលើសៀវភៅកំណត់ហេតុ (ការផ្តិតមេដៃមានន័យថា បានចូលរួមសវនាការមិនមែនទទួលស្គាល់កំណត់ត្រាដែលក្រឡាបញ្ជីបានសរសេរនោះទេ)។ ក្រៅពីនេះក្រឡាបញ្ជីនៅមានកិច្ចក្នុងការបន្តចេញសាលក្រមថែមទៀត។

## ផ្នែកទី២៤

# ការជំនុំជម្រះនិងការប្រកាសសាលក្រមរបស់តុលាការ

លោកមេធាវី ហ៊ាង ហុង គឺជាក្រុមមេធាវីពន្លឺយុត្តិធម៌ (The Light of Justice law Firm) និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ លោកបានផ្តល់បទសម្ភាសន៍ជាមួយភ្នំពេញ ប៉ុស្តិ៍ កាលថ្ងៃទី៣១ ធ្នូឆ្នាំ២០១៤ ពាក់ព័ន្ធនឹងការលើកយកសំណុំរឿងក្តីរបស់ជនជាប់ចោទមកជំនុំជម្រះនិងការប្រកាសសាលក្រមរបស់អង្គតុលាការ ដោយយោងតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

បទសម្ភាសន៍នោះមានខ្លឹមសារ ដូចខាងក្រោមនេះ៖

**១.តើពេលណាទើបតុលាការ ឬចៅក្រមសម្រេចលើកយកសំណុំរឿងរបស់ជនជាប់ចោទមកធ្វើការជំនុំជម្រះ?**

នៅពេលចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរចប់សព្វគ្រប់ ចៅក្រមចេញដីកាបិទការស៊ើបសួរបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានជាស្ថាពរ។ ចៅក្រមស៊ើប សួរធ្វើការបញ្ជូនសំណុំរឿងព្រហ្មទណ្ឌទៅជំនុំជម្រះតាមមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមមាត្រា ២៥០ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌមានចែងថា៖ "ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។"

ចំពោះបទឧក្រិដ្ឋ ការជំនុំជម្រះត្រូវធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះមានបីរូប ១រូបជាប្រធានក្រុមប្រឹក្សា ពីររូបទៀតជាចៅក្រមប្រឹក្សា រួមមានតំណាងអយ្យការម្នាក់ ក្រឡាបញ្ជីម្នាក់ និងមេធាវីការពារជនជាប់ចោទនិងមេធាវីដើមបណ្តឹង (ក្នុងរឿងបទឧក្រិដ្ឋ ត្រូវតែមានមេធាវីការពារក្តីជាដាច់ខាត)។

ចំពោះបទល្មើស មជ្ឈិម ការជំនុំជម្រះដោយចៅក្រមទោល (ចៅក្រមម្នាក់) តំណាងអយ្យការម្នាក់ ក្រឡាបញ្ជីម្នាក់ មេធាវីម្នាក់ ឬពីរនាក់។ ក្នុងករណីស្មុគស្មាញរឿងក្តីមជ្ឈិមអាចជំនុំជម្រះជាក្រុមចៅក្រមបី (០៣) នាក់ (អាចមានមេធាវី ឬគ្មានមេធាវី)។

**២.បន្ទាប់ពីតុលាការបញ្ចប់ការជំនុំជម្រះ និងជជែកដេញដោល គូក្តី សាក្សីក្នុងសវនាការតើនៅពេលណាទើបតុលាការធ្វើការប្រកាសសាលក្រម?**

ការប្រកាសសាលក្រមនៅពេលដែលតុលាការបានធ្វើការជំនុំជម្រះ និងជជែកដេញ ដោលចប់សព្វគ្រប់ហើយលោកចូលទៅពិភាក្សាដើម្បីរៀបចំប្រកាសសាលក្រម ប្រសិនបើនៅក្នុងបទល្មើសមជ្ឈិម ជាបទល្មើសតូចតាច វាមិនមានភាពស្មុគស្មាញនោះ ចៅក្រមនឹងធ្វើការប្រកាសសាលក្រមនៅក្នុងថ្ងៃតែមួយបាន។ ក៏ប៉ុន្តែ ប្រសិនជាបទឧក្រិដ្ឋឬបទមជ្ឈិម មានភាពស្មុគស្មាញនោះ ចៅក្រមអាចលើកការប្រកាសសាលក្រមទៅធ្វើនៅពេលក្រោយ ឬធ្វើទៅតាមកាលវេលាណាមួយសមរម្យទៅតាមរឿងក្តី។ បើរឿងណាវាស្មុគស្មាញ ការប្រកាសសាលក្រមក៏យូរដែរ តែបើរឿងក្តីនោះមិនស្មុគស្មាញ ការប្រកាសសាលក្រមក៏ធ្វើបានឆាប់ដែរ។

យោងតាមច្បាប់ ចំពោះរឿងក្តីព្រហ្មទណ្ឌ ចិរវេលានៃការប្រកាសសាលក្រមនេះពុំមានការកំណត់នោះទេ។ តែបើរឿងរដ្ឋប្បវេណីនោះ ច្បាប់បានកំណត់ថា: ការប្រកាសសាលក្រមត្រូវធ្វើឡើងមិនឲ្យហួសពី ១ខែនោះទេ។ សាលក្រមមានសាលក្រមចំពោះមុខនិងសាលក្រមកំបាំងមុខ។

ក្នុងករណីដែលជនជាប់ចោទត្រូវបានចាប់ខ្លួននិងឃុំខ្លួននៅក្នុងពន្ធនាគារនោះ ការជំនុំជម្រះនិងប្រកាសសាលក្រម ត្រូវធ្វើនៅចំពោះមុខជនជាប់ចោទ។ ក៏ប៉ុន្តែ បើស្ថិតនៅក្រៅឃុំ ឬរត់គេចខ្លួននោះ ការជំនុំជម្រះនិងប្រកាសសាលក្រមត្រូវធ្វើឡើងដោយកំបាំងមុខ។

ក្នុងករណីដែលជនជាប់ចោទរត់គេចខ្លួនដែលត្រូវបានតុលាការកាត់ទោសកំបាំងមុខជាប់ពន្ធនាគារ តែក្រោយមកត្រូវបានចាប់ខ្លួន តាមអំណាចសាលក្រមកំបាំងមុខរបស់តុលាការនោះជនជាប់ចោទមានសិទ្ធិប្តឹងតវ៉ាឬប្តឹងទៅសាលាឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមកំបាំងមុខរបស់តុលាការ។ នេះសម្រាប់តែជនជាប់ចោទដែលបានរត់គេចខ្លួន។ តែចំពោះជនជាប់ចោទដែលស្ថិតនៅក្នុងឃុំនោះ ត្រូវតែមានវត្តមានក៏ប៉ុន្តែនៅពេលចូលរួម ក្នុងសវនាការជំនុំជម្រះនោះ ជនជាប់ចោទមានសិទ្ធិឆ្លើយ និងមិនឆ្លើយនូវសំណួរពេលសាកសួរនៅក្នុងអង្គសវនាការ ដែលនេះគឺជាសិទ្ធិរបស់ពួកគាត់។

## ផ្នែកទី២៥

## ការដាក់ជនជាប់ចោទក្រោមការត្រួតពិនិត្យរបស់តុលាការ

លោកមេធាវី សុក សំអឿន ប្រធានក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ប្រធានសម្របសម្រួលសម្ព័ន្ធអង្គការដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម និងជាប្រធានសម្របសម្រួលគណៈកម្មការប្រព្រឹត្តិកម្មនៃអង្គការសិទ្ធិមនុស្សបានផ្តល់កិច្ចសម្ភាសន៍ខ្លី ជាមួយកាសែតភ្នំពេញប៉ុស្តិ៍ កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០១៥ ជាប់ពាក់ព័ន្ធនឹងការដាក់ជនជាប់ចោទស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដោយយោងតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ បទសម្ភាសន៍មានខ្លឹមសារដូចខាងក្រោមនេះ៖

**១.តាមនីតិវិធីព្រហ្មទណ្ឌ តើនៅពេលណាដែលចៅក្រមស៊ើបសួរសម្រេចដាក់ជនត្រូវចោទណាម្នាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ?**

ការដាក់ជនជាប់ចោទណា ម្នាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ មានន័យថា តុលាការនឹងចាប់ផ្តើមស៊ើបអង្កេតលើរឿងក្តី ឬលើជនត្រូវចោទនោះហើយ ដើម្បីពិនិត្យមើលថា តើជននោះពិតជាមានពិរុទ្ធភាព ដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះឬទេ? ក្នុងពេលនោះ ប្រសិនមិនមែន ជាការបញ្ជូនទៅជម្រះផ្ទាល់ទេនោះ គឺមានន័យថា ព្រះរាជអាជ្ញាមិនទាន់សម្រេចចោទប្រកាន់ជាផ្លូវការនៅឡើយទេ តែគ្រាន់តែសម្រេចចោទប្រកាន់បណ្តោះអាសន្នប៉ុណ្ណោះ។ ប្រសិនបើនៅពេលស៊ើបអង្កេតទៅ បើចៅក្រមស៊ើបសួររកពុំឃើញមានបទល្មើសនោះទេ តុលាការនឹងសម្រេចលើកការចោទប្រកាន់តែម្តង។

ទោះយ៉ាងណាក្តី នេះគឺជាទ្រឹស្តីច្បាប់តែប៉ុណ្ណោះទេ តែការជាក់ស្តែងឲ្យតែមានរឿងព្រហ្មទណ្ឌ តុលាការងាយនឹងដាក់គុកណាស់ ទោះជាមានតែពាក្យបណ្តឹងមួយសន្លឹកក៏ដោយ។ នៅក្នុងច្បាប់គេកំណត់ថា ប្រសិនបើច្បាប់ពុំច្បាស់លាស់ ឬក៏មានភស្តុតាងមិនច្បាស់លាស់នោះ តុលាការត្រូវផ្តល់ផលប្រយោជន៍ទៅដល់ជនត្រូវចោទ តែជាការជាក់ស្តែង គឺវាផ្ទុយទៅវិញ បើអត់ច្បាស់ទេនោះប្រាកដជាអ្នកខាតបង់ប្រយោជន៍ គឺជនត្រូវចោទនោះហើយ។

យោងតាមមាត្រា ២២៣ នៃនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជាកាតព្វកិច្ចនៃការដាក់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការ)៖ ចៅក្រមស៊ើបសួរ អាចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទ ដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយឬច្រើនដូចតទៅនេះ៖

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដី កំណត់ដោយចៅក្រមស៊ើបសួរ

២-មិនត្រូវផ្លាស់ប្តូរលំនៅឋាន ដោយគ្មានការអនុញ្ញាតពីចៅក្រុមស៊ើបសួរ

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះ ដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤- ត្រូវចូលមកបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥- ត្រូវឆ្លើយតបនឹងដីកាកោះហៅពីគ្រប់បុគ្គល ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦- ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី គ្រប់ឯកសារបញ្ជាក់ពីអត្តសញ្ញាណ

៧-មិនត្រូវបើកបររថយន្ត

៨- មិនត្រូវទទួលឬជួបនឹងបុគ្គលមួយចំនួន ដែលកំណត់ចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩- ដាក់ប្រាក់ធានា ដែលចំនួនប្រាក់ធានានិងថិរវេលាបង់ប្រាក់នេះត្រូវកំណត់ ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនដែលនឹងត្រូវចោទ

១០-មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

**២.ចំពោះអនីតិជនមានអាយុក្រោម ១៤ ឆ្នាំវិញ តើច្បាប់តម្រូវយ៉ាងណាដែរ?**

អនីតិជនអាយុតិចជាង ១៤ ឆ្នាំ មិនអាចត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ (មាត្រា ២២៤ នៃនីតិវិធីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)។

## ផ្នែកទី២៦

## ភារកិច្ចក្រឡាបញ្ជីនៅដំណាក់ចៅក្រមជំនុំជម្រះ

លោកមេធាវី ឡោ គីម ហ្គេច អត្តលេខ ៨៥៧ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីនៃការិយាល័យមេធាវី អិល-អេស-អ (កម្ពុជា) មានអាសយដ្ឋាន ផ្ទះលេខ ១៦R ផ្លូវ ២៥២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បានធ្វើបទសម្ភាសន៍ជាមួយភ្នំពេញ ប៉ុស្ដិ៍ បន្តពីលេខមុន ដោយលើកមករៀបរាប់អំពី ភារកិច្ចរបស់ក្រឡាបញ្ជីនៅដំណាក់កាលចៅក្រមជំនុំជម្រះ ផ្អែកលើខ្លឹមសារច្បាប់ដែលមានខ្លឹមសារជាអាទិ៍ដូចខាងក្រោមនេះ៖

**១.តើក្រឡាបញ្ជីមានតួនាទីអ្វីផ្សេងទៀតទេ ក្រៅតែពីអ្នកកត់ត្រា ហើយតួនាទីរបស់ក្រឡាបញ្ជីតាមច្បាប់ចែកជាប៉ុន្មានដំណាក់កាល?**

ភារកិច្ចរបស់ក្រឡាបញ្ជីជា អ្នកចាំកត់ត្រាកំណត់ហេតុជា ជំនួយការរបស់ចៅក្រម និងព្រះរាជអាជ្ញា។ ក្រឡាបញ្ជីមានភារកិច្ចសំខាន់ចាប់តាំងពីសំណុំរឿងព្រហ្មទណ្ឌចូលមកដល់អយ្យការ។ ក្រៅតែពីជំនួយការព្រះរាជអាជ្ញានិងចៅក្រម គឺក្រឡាបញ្ជី មាននាទីសំខាន់ផ្សេងទៀតដើម្បីដំណើរការរឿងក្ដីទៅតាមនីតិវិធីឲ្យបានល្អប្រសើរ ហើយតួនាទីរបស់ក្រឡាបញ្ជីត្រូវបានបែងចែកជា ៤ ដំណាក់ រួមមាន ដំណាក់កាលមុនបើកសវនាការ ដំណាក់កាលបើកសវនាការ ដំណាក់កាលប្រកាសសាលក្រម និងចុងក្រោយដំណាក់កាលក្រោយចេញសាលក្រម។

**២.នៅក្នុងដំណាក់កាលបើកសវនាការ តើក្រឡាបញ្ជីនៅមានភារកិច្ចសំខាន់អ្វីផ្សេងទៀតទេ?**

ដំណាក់កាលនេះ គឺក្រឡាបញ្ជីមាននាទីតាមដាន កត់ត្រារាល់ចម្លើយក្នុងអំឡុងពេលសវនាការ។ ក្រឡាបញ្ជីគប្បីចែកប្រភេទលិខិតព្រមទាំងអ្នកចូលរួមក្នុងកម្មវិធី ដែលមាន ដូចជាដីកាទាក់ទងនិងអយ្យការ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកែប្រែបទល្មើស ដីកាបញ្ជូនរឿងទៅពិនិត្យ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដីកាសន្និដ្ឋានស្ថាពរ ដីកាចោទប្រកាន់បន្ថែម ដីកាបង្អង់បណ្ដឹងអាជ្ញា ដីកាលើកលែងការចោទប្រកាន់ និងដីការំលត់បណ្ដឹងអាជ្ញា។

**៣.ក្នុងដំណាក់ការចៅក្រមប្រឹក្សាសាកសួរក្នុងអង្គសវនាការចប់ហើយ តើក្រឡាបញ្ជីត្រូវរៀបចំដីកាអ្វីខ្លះ?**

ក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ភារកិច្ចក្រឡាបញ្ជីត្រូវរៀបចំដីកាទាំងនោះ មានដូចជា ដីកាចាប់ខ្លួន ដីកាឃុំខ្លួន ដីកាចាត់តាំងចៅក្រមស៊ើបសួរ ដីកាឆែកឆេរលំនៅឋាន ដីកាបង្គាប់ឲ្យស៊ើបសួរបន្ថែម ដីកាដោះលែងបណ្ដោះអាសន្ន លិខិតឆ្លើយតបនិងដីកាស៊ើបសួរផ្សេងៗ។

**៤.ក្រៅពីត្រូវរៀបចំដីកាដូចបានរៀបរាប់ខាងលើនេះ តើក្រឡាបញ្ជីមាននាទីចេញលិខិតអ្វីទៀតទេ?**

ក្រឡាបញ្ជីត្រូវរៀបចំលិខិតទាក់ទង និងមេធាវី ឬពាក្យសុំរបស់គូភាគី ដូចជា មេធាវីខាងជនជាប់ចោទ មេធាវីខាងដើមបណ្ដឹងរដ្ឋប្បវេណី លិខិតប្រគល់សិទ្ធិពាក្យសុំរបស់មេធាវី លិខិតចាត់តាំងមេធាវី ពាក្យសុំដូរមេធាវី ពាក្យសុំធានា ពាក្យសុំដោះលែងជាបណ្ដោះអាសន្នរបស់មេធាវី ពាក្យសុំឲ្យចៅក្រមឃុំខ្លួនជនសង្ស័យដែលនៅក្រៅឃុំ។

**៥.តើក្រឡាបញ្ជីនឹងអាចរៀបចំលិខិតស្នាមណាទៀតបាន? ក្រឡាបញ្ជីត្រូវរៀបចំកំណត់ហេតុចម្លើយជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណីនៅដំណាក់កាលណាខ្លះ?**

ក្រឡាបញ្ជី មានតួនាទីរៀបចំកំណត់ហេតុសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរចម្លើយរបស់សាក្សី សាក្សីខាងដើមបណ្ដឹងរដ្ឋប្បវេណី សាក្សីខាងជនជាប់ចោទ សាក្សីតាមឆន្ទានុសិទ្ធិ (អយ្យការ,ចៅក្រម) វត្ថុតាងកំណត់ហេតុទទួលវត្ថុតាង ប្លង់កន្លែងកើតហេតុ លិខិតធ្វើកោសល្យវិច័យលទ្ធផលធ្វើកោសល្យវិច័យ ប្រមូលវត្ថុតាង បើអាចយកមកបង្ហាញពេលសវនាការបាន។

## ផ្នែកទី២៧

## បទល្មើសព្រហ្មទណ្ឌ និងការសម្រុះសម្រួលក្រៅប្រព័ន្ធច្បាប់

លោក មេធាវី សេង រ៉ុន អត្តលេខ ០៦៣ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាសយដ្ឋានផ្ទះលេខ ១១២ A ផ្លូវ ១៦៧ សង្កាត់ទួលស្វាយព្រៃ ១ ខណ្ឌចំការមន ភ្នំពេញ។

លោកមេធាវីបានផ្តល់កិច្ចសម្ភាសន៍ជាមួយ ភ្នំពេញ ប៉ុស្តិ៍ ដោយលើកឡើងពីបទល្មើសព្រហ្មទណ្ឌមួយចំនួន ហើយនិងការសម្រុះសម្រួលគ្នាក្រៅប្រព័ន្ធតុលាការ ផ្អែកលើបញ្ញត្តិច្បាប់ជាធរមាន ដែលមានខ្លឹមសារដូចខាងក្រោម៖

**១.តើអ្វីទៅជាបទល្មើសព្រហ្មទណ្ឌ តើរឿងក្តីព្រហ្មទណ្ឌអាចសម្រុះសម្រួលគ្នាក្រៅប្រព័ន្ធច្បាប់បានទេ?**

រឿងក្តីព្រហ្មទណ្ឌ ជារឿងក្តីដែលតុលាការសម្រេចឲ្យអ្នកប្រព្រឹត្តល្មើសច្បាប់ទទួលទណ្ឌកម្មជាប់ទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ហើយដូចមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។ រឿងក្តីព្រហ្មទណ្ឌ បើតាមច្បាប់គឺមិនអាចសម្រុះសម្រួលគ្នាដោយគ្មានការជំនុំជម្រះពីសំណាក់តុលាការបានទេ។

**២.លោកអាចរៀបរាប់ខ្លះៗជាឧទាហរណ៍បានទេ ដើម្បីឲ្យមិត្តអ្នកអានស្វែងយល់ តើបទល្មើសព្រហ្មទណ្ឌមានអ្វីខ្លះដែលមិនអាចសម្រុះសម្រួលក្រៅតុលាការ?**

ខ្ញុំសូមជម្រាបត្រួសៗស្តីពីបទល្មើសព្រហ្មទណ្ឌ ដែលប្រឆាំងបុគ្គលរួមមាន៖ បទល្មើសប្រល័យពូជសាសន៍ បទប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម។

ការប៉ះពាល់ដល់ជីវិត ដល់រូបកាយ ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើហិង្សា ការគំរាមកំហែង ការបង្កឲ្យមានរបួស ការបំពានផ្លូវភេទ ការប៉ះពាល់ដល់សេរីភាព ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ អំពើពុករលួយ បទសញ្ជូរកម្ម ការប៉ះពាល់ដល់បុគ្គលភាពដែលមានការប៉ះពាល់ដល់ជីវិតឯកជន ការបរិហារកេរ្តិ៍និងការជេរប្រមាថ ការប៉ះពាល់ដល់អាថ៌កំបាំងវិជ្ជាជីវៈ ការប៉ះពាល់ដល់ការសម្ងាត់នៃការឆ្លើយឆ្លងតាមលិខិតនិងទូរគមនាគមន៍ ការប៉ះពាល់ដល់អនីតិជន និងក្រុមគ្រួសារ។

**៣.តើបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិបុគ្គលនិងសម្បត្តិសាធារណៈ អាចចាត់ចូលជាបទល្មើសព្រហ្មទណ្ឌដែរទេ? ជាឧទាហរណ៍ មានបទល្មើសអ្វីខ្លះ?**

បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិមាន ដូចជា ការលួច ការកំហែងយក ការគំរាមកំហែងយកកេរ្តិ៍ ការឆបោកបន្លំ ការប៉ះពាល់ ការដេញថ្លៃ ការរំលោភលើទំនុកចិត្ត ការទទួលផលចោរកម្ម បទល្មើសប៉ះពាល់ដល់ទ្រព្យសម្បត្តិដែលមានការបំផ្លិចបំផ្លាញនិងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា។

**៤.តើបទល្មើសប្រឆាំងនឹងការសម្ងាត់ និងសន្តិសុខជាតិអាចចាត់ចូលបទល្មើសព្រហ្មទណ្ឌក្នុងកម្រិតណាដែរ?**

បទល្មើសប្រឆាំងនឹងជាតិក៏ជាបទល្មើសព្រហ្មទណ្ឌដែរ ដូចជា ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ការប៉ះពាល់ដល់សន្តិសុខរដ្ឋ ឧបឃាត (ការបៀតបៀនគេដោយកាយឬការប្រហារជីវិតគេ) កុបកម្ម ការដណ្តើមយកអំណាច ការញុះញង់ឲ្យប្រព្រឹត្តបទល្មើសនិងសមាគមជនទុច្ចរិត។ ក្រៅពីនេះមានការប៉ះពាល់ដល់វិស័យយុត្តិធម៌ដូចជា អំពើពុករលួយនៃអង្គចៅក្រម ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ ការលួចរត់។ ជាមួយគ្នានេះដែរ មានការប៉ះពាល់ដល់វិស័យរដ្ឋបាលសាធារណៈដូចជា ការរំលោភអំណាច ការស៊ីសំណូក ជំនួញឥទ្ធិពលអកម្ម (អាងអ្នកមានបុណ្យស័ក្តិ ឬអាងអ្នកមានអំណាច) ការកេងយកប្រយោជន៍ដោយខុសច្បាប់, ការបំផ្លាញនិងគៃបំបាត់និងការជ្រៀតជ្រែកក្នុងមុខងារសាធារណៈ។ ក្នុងនោះ ក៏មានការប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ ដូចជា ការក្លែងបន្លំឯកសារនិងការក្លែងបន្លំមូលបត្ររដ្ឋ និងតែមប្រៃប្រែសណីយ៍ ។

ខ្ញុំសូមបញ្ជាក់ជូនទៀតថា ក្រៅពីបទល្មើសដែលបានរៀបរាប់ខាងលើក៏នៅមានបទល្មើសជាច្រើនទៀតដែលបានថ្លែងបញ្ជាក់នៅក្នុងច្បាប់ដទៃទៀត នៅក្នុងជំពូកនៃទោសប្បញ្ញត្តិ ដែលអាចត្រូវតុលាការសម្រេចឲ្យជាប់ពន្ធនាគារទៅតាមមាត្រាទាំងនេះផងដែរ។

**៥.និយាយខ្លីងាយយល់ តើច្បាប់ព្រហ្មទណ្ឌមានន័យថា ជាច្បាប់សម្រាប់តែឲ្យតុលាការកាត់ទោសដាក់ពន្ធនាគារទៅលើជនល្មើសឬ?**

តាមពិតទៅវាមិនមែនដូច្នេះនោះទេ ច្បាប់ទូទៅធ្វើឡើងក្នុងគោលបំណងដើម្បីបង្ការការពារកុំឲ្យមនុស្សជាតិប្រព្រឹត្តល្មើសនឹងច្បាប់ បើពុំដូច្នោះទេ គឺលទ្ធផលទីបំផុតត្រូវតែទទួលទោស តែមនុស្សនៅតែមិនរាងចាលទៅទៀត។

**៦.ដូចម្ដេចទៅដែលហៅថាបណ្ដឹងអាជ្ញា តើបណ្ដឹងនេះមានគោលបំណងអ្វី?**

បណ្ដឹងអាជ្ញា បើតាមមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថាៈ បណ្ដឹងអាជ្ញាមានគោលបំណងពិនិត្យអាទិភាពនៃបទល្មើសបង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្ដន្ទាទោសជននោះទៅតាមច្បាប់ដែលបានកំណត់។

**៧.មានអ្នកយល់ថា រឿងក្ដីព្រហ្មទណ្ឌអាចសម្រុះសម្រួលគ្នាបានក្រៅប្រព័ន្ធច្បាប់នឹងអាចបញ្ចប់រឿងក្ដីក្រៅតុលាការបាន ដូចជា គ្រោះថ្នាក់ចរាចរណ៍ រឿងចេញសែកស្អុយជាដើម តើអាចដែរទេ?**

ជាគោលការណ៍នៃច្បាប់រឿងក្ដីព្រហ្មទណ្ឌ គូភាគីមិនអាចសម្រុះសម្រួលគ្នាបានឡើយ ហើយជាពិសេស បើរឿងក្ដីនោះធ្ងន់ធ្ងរជាបទល្មើសមជ្ឈិម ឬបទល្មើសឧក្រិដ្ឋ។ ជាទូទៅតែងតែកើតមានករណីនេះ (ការដោះស្រាយក្រៅច្បាប់) នគរបាលដោះលែងជនល្មើសដែលបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍ដល់អាយុជីវិតមនុស្ស។ ឯខាងជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះព្រមទទួលយកសំណងសមរម្យណាមួយ និងធ្វើកិច្ចសន្យាលែងប្ដឹងទៀត។ ជួនកាលខាងនគរបាលត្អូញត្អែរពីតុលាការដោះលែងជនល្មើសចរាចរណ៍។

ករណីនេះ ការពិតយ៉ាងណាក៏យើងមិនបានដឹងទេ ប៉ុន្តែតាមផ្លូវច្បាប់ ការសម្រុះសម្រួលក្រៅច្បាប់បែបនេះ គឺធ្វើទៅបានតែក្នុងសំណងខូចខាតទ្រព្យសម្បត្តិ និងជំងឺចិត្តតែប៉ុណ្ណោះ។ ចំពោះរឿងបទល្មើសរបស់ជនល្មើសដែលបង្កឡើង នៅតែដំណើរការតាមនីតិវិធីទៅតុលាការដដែល។ សូម្បីតែអយ្យការនិងលោកចៅក្រមស៊ើបសួរក៏មិនអាចបញ្ចប់រឿងក្ដីព្រហ្មទណ្ឌនេះបានដែរ។

នៅក្នុងច្បាប់ នីតិវិធីព្រហ្មទណ្ឌ ក៏បានចែងច្បាស់ត្រង់មាត្រា ២៥ អំពីការលះបង់និងការដកពាក្យបណ្ដឹងរបស់ជនរងគ្រោះ។ មាត្រានេះបានបញ្ជាក់ថា ជនរងគ្រោះអាចលះបង់មិនធ្វើពាក្យបណ្ដឹងសុំទាមទារសំណង ឬដកពាក្យប្ដឹងរបស់ខ្លួន។ ការលះបង់មិនប្ដឹង ឬក៏ដកពាក្យបណ្ដឹងរបស់ជនរងគ្រោះមិនអាចបញ្ឈប់ ឬព្យួរការអនុវត្តនៃបណ្ដឹងអាជ្ញាបានទេ លើកលែងតែបញ្ញត្តិចំណុចទី ២ នៃមាត្រា ៨ (មូលហេតុផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញានៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**៨.តើបណ្ដឹងអាជ្ញាអាចរលត់បាននៅពេលណា ហេតុម៉េចបានមានការលើកលែង?**

បណ្ដឹងអាជ្ញាអាចរលត់បាន ឬបញ្ឈប់ឲ្យដំណើរការបានតែក្នុងករណីដែលច្បាប់ដទៃផ្សេងក្រៅពីច្បាប់ព្រហ្មទណ្ឌ និងច្បាប់នីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ច្បាស់។ ចំណុចទី២ មាត្រា៨ នៃក្រមព្រហ្មទណ្ឌចែងថា មូលហេតុផ្សេងទៀត នៃការរលត់បណ្ដឹងអាជ្ញា គឺដោយសារការដកពាក្យបណ្ដឹងនៅក្នុងករណីនៃពាក្យប្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។ ខ្ញុំសូមលើកឧទាហរណ៍ថា នៅក្នុងច្បាប់ឯកព័ន្ធភាពឬ ប្រពន្ធមួយប្ដីមួយ បើខាងភរិយាប្ដឹងប្ដីថា មានស្រី ឬមានប្រពន្ធចុង ដោយមានភស្ដុតាងគ្រប់គ្រាន់នោះ គឺទាមទារឲ្យតុលាការសម្រេចឲ្យខ្លួនបានលែងលះគ្នា ចែកទ្រព្យសម្បត្តិគ្នា ហើយសុំឲ្យតុលាការសម្រេចផ្ដន្ទាទោសប្ដីពីបទផិតដែលត្រូវជាប់ពន្ធនាគារពី ១ខែ ទៅ ១ ឆ្នាំនិងពិន័យជាប្រាក់ពី ពីររយពាន់

រៀលដល់មួយលានរៀលឬផ្តន្ទាទោសមួយណាក៏បាន។ ករណីនេះព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើមានបណ្តឹងថ្មីរបស់សហព័ន្ធ គឺប្រពន្ធស្នើសុំមិនឲ្យធ្វើការចោទប្រកាន់វិញ។

**៩.តើការរលត់បណ្តឹងអាជ្ញានៅតាមវិធីផ្សេងពីនេះទៀតទេ?**

ខ្ញុំសូមបញ្ជាក់ថា មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញាក៏មានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ៧ ដូចជា មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល (អាជ្ញាយុកាល នៃបទល្មើស) ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំជម្រះ តែក៏មានរឿងក្តីព្រហ្មទណ្ឌខ្លះមិនអាចបញ្ចប់បានដែរ ដោយគ្រាន់តែដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះបានដកពាក្យបណ្តឹងពីតុលាការ។

ប៉ុន្តែ មានករណីខ្លះគឺរឿងក្តីនោះប្រហែលជាអាចដេកនៅបាតតុ ឬបាតទូររបស់តុលាការរាប់សិបឆ្នាំ មិនដល់សាលាក្តីណាមួយឡើយ។ ខ្ញុំមិនដឹងថា តុលាការគ្រប់ជាន់ថ្នាក់បានដឹង ពីដំណោកដ៏សែនយូរនៃសំណុំរឿងព្រហ្មទណ្ឌទាំងនេះ ឬក៏អត់ទេ? ហើយខាងផ្នែកអធិការកិច្ចលើកិច្ចការតុលាការ នៃក្រសួងយុត្តិធម៌ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរតែរកថ្នាំដាក់ឲ្យរឿងក្តីព្រហ្មទណ្ឌដែលបានដេកលក់ ឲ្យធ្វើដំណើរទៅសាលាក្តីគ្រប់ជាន់ថ្នាក់ផងទៅ ដើម្បីឲ្យប្រព័ន្ធយុត្តិធម៌បានប្រសើរឡើង នឹងបង្កើនទំនុកចិត្តពីប្រជាពលរដ្ឋ។

## ផ្នែកទី២៨

## វិសមិតភាព ប្រើក្នុងតុលាការមានន័យដូចម្តេច?

លោកបណ្ឌិត ឡុង ដារ៉ា សមាជិកក្រុមប្រឹក្សា និងជាប្រធាន ក្រុមការងារស្រាវជ្រាវ អប់រំ និង ផ្សព្វផ្សាយច្បាប់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សម្ភាសន៍ជាមួយភ្នំពេញ ប៉ុស្តិ៍ លើប្រធានបទស្តីពី វិសមិតភាពដែលប្រើក្នុងប្រព័ន្ធតុលាការ មានខ្លឹមសារដូចខាងក្រោម:

**១.តើ "វិសមិតភាព" ជាឃ្លា ឬ ពាក្យ ហើយមានន័យយ៉ាងដូចម្តេច ? និងប្រើបានតែសម្រាប់ផ្នែកច្បាប់ឬយ៉ាងណា ?**

**វិសមិតភាព** (Incompatibility) ប្រែថា មិនស្របគ្នា ឬមិនស៊ីចង្វាក់គ្នា ដែលជាពាក្យមួយចេញមកពីពាក្យ វិសម ដែលជាពាក្យប្រឆាំង ឬផ្ទុយគ្នានៅក្នុងអត្ថន័យឬពាក្យដើមនៃពាក្យនេះ ហើយពាក្យនេះមានអត្ថន័យជ្រៅជ្រះដែលអាចប្រើប្រាស់បានជាទូទៅ គ្រាន់តែប្រជាជនសាមញ្ញពិបាកនឹងយល់។ ដូច្នេះហើយបានជាអ្នកច្បាប់គេជ្រើសពាក្យមានអត្ថន័យស៊ីជម្រៅខ្ពស់មកប្រើប្រាស់ក្នុងអត្ថបទច្បាប់ ដើម្បីឲ្យមានអានុភាពល្អប្រសើរក្នុងការប្រតិបត្តិ។ ឧទាហរណ៍១ ៖ មុខងារមន្ត្រីរាជការសាធារណៈ មានវិសមិតភាពនឹងមុខរបរពាណិជ្ជកម្ម ដូចជា មន្ត្រីរាជការមិនត្រូវយកម៉ោងរដ្ឋបាល យកឥទ្ធិពល ឬអំណាចដើម្បីសម្លុត គំរាមកំហែងបំពានសិទ្ធិរបស់ពលរដ្ឋ។ ប្រកបមុខរបរ ឬចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល ឬបោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធអង្គភាពខ្លួន ឬប្រកបមុខរបរបន្ថែមត្រួតលើមុខងារខ្លួនជាមន្ត្រីរាជការ ដែលជាអំពើបំពានច្បាប់នេះអាចបណ្តាលឲ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែង ក្នុងមាត្រា៤០នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង (មាត្រា ៣៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល) ។ ឧទាហរណ៍២ ៖ វិជ្ជាជីវៈមេធាវី មានវិសមិតភាពជាមួយនឹងមុខងារសាធារណៈនិងការប្រកបមុខរបរពាណិជ្ជកម្ម (មាត្រា ៥៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា) ។

**២.ពេលខ្លះគេឃើញចៅក្រមបើកសវនាការសំណុំរឿងមួយ ប៉ុន្តែគាត់ថារឿងក្តីនេះមានវិសមិតភាពមិនអាចជំនុំជម្រះបានទេ ករណីនេះហេតុអ្វីមិនអាចជំនុំជម្រះបាន?**

ពាក្យវិសមិតភាពនៅក្នុងវិស័យតុលាការ ពិសេសពេលជំនុំជម្រះក្តី ឬសវនាការ គឺពាក្យនេះសំដៅទៅលើភាពមិនស៊ីចង្វាក់គ្នា ឬប្រឆាំងគ្នា ចំពោះអង្គសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រម ឬព្រះរាជអាជ្ញាជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាមួយ ឬច្រើននាក់ពាក់ព័ន្ធសំណុំរឿងក្តីដែលខ្លួនធ្លាប់ជំនុំជម្រះឬដោះស្រាយរឿងក្តីនេះម្តងរួចហើយ។ ឧទាហរណ៍ ៖ រឿងក្តីមួយត្រូវបានចៅក្រមម្នាក់ធ្លាប់កាត់ក្តីម្តងរួចទៅហើយ ហើយចៅក្រមរូបនេះ មានឈ្មោះនៅក្នុងសមាជិកក្រុមប្រឹក្សាជំនុំជម្រះដោះស្រាយសំណុំរឿងក្តីដដែលនេះម្តងទៀត។ ដូច្នេះចៅក្រម ឬព្រះរាជអាជ្ញារូបនោះ មានវិសមិតភាពក្នុងរឿងក្តីនេះ មិនអាចចូលរួមជាសមាសភាពក្រុមប្រឹក្សាជំនុំជម្រះសវនាការបានទៀតឡើយ។ មាត្រា ៣៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីអនុបវាទនៃចៅក្រមមួយចំនួន ៖ ចៅក្រមណាម្នាក់ដែលបានបំពេញកិច្ចចោទប្រកាន់ឬស៊ើបសួរ ឬដែលបានចូលរួមជំនុំជម្រះសាលាដំបូងរួចហើយនោះ មិនអាចនឹងចូលរួមជំនុំជម្រះនៅសាលាឧទ្ធរណ៍ក្នុងឋានៈជាប្រធាន ឬចៅក្រមចំពោះរឿងដដែលឡើយ។

**៣.តើអត្ថន័យវិសមិតភាពពាក់ព័ន្ធអ្វីក្នុងសវនាការទើបមិនអាចជំនុំជម្រះបាន ?**

អត្ថន័យនៃពាក្យ វិសមិតភាព គឺសំដៅលើភាពដែលមានវិការ ប្រឆាំង ឬផ្ទុយ ដែលអាចបណ្តាលឲ្យប៉ះពាល់ដល់សេចក្តីវិនិច្ឆ័យក្នុងសាលក្រម ឬសាលដីកាទាំងមូល ឬអាចនិយាយ បានថាការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះនេះមិនមានភាពយុត្តិធម៌ ឬគ្មានតម្លាភាពផ្នែកសតិអារម្មណ៍ខាងផ្លូវចិត្តរបស់តុលាការមកលើភាគីដែលមានវិវាទក្នុងរឿងក្តីនេះ។

ឧទាហរណ៍ ៖ ចៅក្រមម្នាក់ ឬសមាសភាពក្រុមប្រឹក្សាជំនុំជម្រះណាមួយដែលត្រូវជាបងប្អូនសាច់ញាតិភាគីមានវិវាទក៏ជាកត្តានាំឲ្យមានវិសមិតភាពក្នុងពេលសវនាការឬជំនុំជម្រះរឿងក្តីនេះដែរ។ មាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីមូលហេតុនៃការប្តឹងជិតចិត្តចៅក្រមអាសនៈ ៖ បណ្តឹងជិតចិត្តអាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈប៉ុណ្ណោះ។

*...(តទៅលេខក្រោយ)*

# ផ្នែកទី២៩

## វិសមិតភាពប្រើក្នុងតុលាការមានន័យដូចម្តេច?

លោកបណ្ឌិត ឡុង ដារ៉ា ជាសមាជិកក្រុមប្រឹក្សា និងជាប្រធានក្រុមការងារស្រាវជ្រាវអប់រំ និងផ្សព្វផ្សាយច្បាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយ ភ្នំពេញ ប៉ុស្តិ៍ ពាក់ព័ន្ធប្រធានបទស្តីពីវិសមិតភាពដែលប្រើក្នុងប្រព័ន្ធតុលាការដែលមានខ្លឹមសារតពីលេខមុនដូចខាងក្រោម៖

ចៅក្រមទាំងឡាយ អាចត្រូវប្តឹងជិតចិត្ត ដោយមូលហេតុចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី។ ចៅក្រមជាញាតិ លោហិតរហូតដល់ថ្នាក់ ទី៦ ឬញាតិពន្ធរហូតដល់ថ្នាក់ ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ ទី៣ របស់ភាគីណាមួយ។ ចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ។ ចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។ ចៅក្រមបានធ្វើជាសាក្សី ឬ អ្នកជំនាញក្នុងរឿងក្តី។ ចៅក្រម ជា ឬ ធ្លាប់ជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី ឬ ចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករចំពោះរឿង ក្តីឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូង ដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី។

**១.តើវិសមិតភាពនេះអាចយក មកជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីបានដែរ ឬទេ?**

ពាក្យថា វិសមិតភាពរបស់ចៅក្រមនៅពេលសវនាការ ឬជំនុំជម្រះក្តី វាជាការកំណត់ក្នុងច្បាប់ ដូច្នេះ មិនថារឿងក្តីព្រហ្មទណ្ឌ ឬរឿងក្តីរដ្ឋប្បវេណីទេ បើមានវិសមិតភាពពាក់ព័ន្ធចៅក្រម ឬសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ដូចការបកស្រាយខាងលើ មិនអាចដំណើរការនីតិវិធីបានឡើយ ។ មាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្តីពីការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ៖ ចៅក្រមត្រូវដកហូតពីការអនុវត្តមុខការរបស់ខ្លួនក្នុងករណីចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី។ ចៅក្រមជាញាតិលោហិតក្នុងថ្នាក់ ទី៦ (ប្រាំមួយ) ឬញាតិពន្ធក្នុងថ្នាក់ ទី៣ (បី) ឬអតីតញាតិពន្ធក្នុងថ្នាក់ ទី៣ (បី) របស់ភាគីណាមួយ។ ចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ។

ចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។ ចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី។ ចៅក្រមជាអ្នកតំណាង ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី។ ចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីមជ្ឈត្តករចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅក្នុងការជំនុំជម្រះលើក ទី១ ដែលបានឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី។ ក្នុងករណីដូចមានមូលហេតុនៃការដកហូតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេចសេចក្តីអំពីការដកហូតនោះ តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

**២.ប្រសិនបើសមាសភាពចៅក្រមជំនុំជម្រះនៅតែដដែល តាមច្បាប់ តើនឹងនាំឲ្យអង្គជំនុំជម្រះទៅជាយ៉ាងណា?**

ក្នុងករណីដែលសមាសភាពចៅក្រមជំនុំជម្រះ មានវិសមិតភាព ហើយនីតិវិធីនៅតែបន្តសវនាការ ឬជំនុំជម្រះជាមូលហេតុនាំឲ្យ៖

-ទី១៖ នាំឲ្យមោឃភាព នីតិវិធីនៃការស៊ើបសួរមួយផ្នែក ឬ ទាំងស្រុង និង

-ទី២៖ នាំឲ្យសាលក្រម ឬ សាលដីការបស់តុលាការត្រូវចាត់ទុកជាមោឃៈ។

(មាត្រា ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីវិសមិតភាពរវាងមុខងារផ្សេងៗរបស់ចៅក្រម៖ រវាងមុខងារជាចៅក្រមនិងមុខងារជាព្រះរាជអាជ្ញា ឬជាព្រះរាជអាជ្ញារងនោះ គឺមានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត។ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញាជាព្រះរាជអាជ្ញារង ឬជាចៅក្រមសាកសួរលើរឿងក្តីណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះនោះបានទេ បើពុំដូច្នោះទេ សាលក្រមសម្រេចក្តីនោះ នឹងទុកជាមោឃៈ)។

## ផ្នែកទី៣០

# កិច្ចសន្យាការងារស្របច្បាប់របស់កម្មករនិយោជិត

លោកមេធាវី លី ច័ន្ទតុលា ជាមេធាវីនៃការិយាល័យ "ក្រុមមេធាវីកម្ពុជា" និងជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់កិច្ចសម្ភាសន៍ដល់កាសែតភ្នំពេញប៉ុស្តិ៍ ពាក់ព័ន្ធនឹងកិច្ចសន្យាការងាររបស់បុគ្គលិកកម្មករនិយោជិតដែលត្រឹមត្រូវតាមលក្ខណៈច្បាប់ដែលស្ថិតជាធរមានមានខ្លឹមសារដូចខាងក្រោម៖

**១.តើអ្វីទៅដែលហៅថាកិច្ចសន្យាការងារស្របច្បាប់?**

កិច្ចសន្យាការងារ គឺជាកិច្ចព្រមព្រៀងរវាងបុគ្គលពីរនាក់ដែលម្នាក់ហៅថា និយោជក និង ម្នាក់ទៀតហៅថា កម្មករ-និយោជិត ដែលនៅក្នុងនោះ កម្មករនិយោជិតយល់ព្រមផ្តល់ការងាររបស់ខ្លួនឲ្យនិយោជកដោយទទួលមកវិញនូវប្រាក់ឈ្នួល ហើយបំពេញការងារក្រោមការគ្រប់គ្រង និងដឹកនាំរបស់និយោជក។

កិច្ចសន្យានេះអាចធ្វើជាផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ប៉ុន្តែជាទូទៅកិច្ចសន្យានេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាការងារនេះ កំណត់អំពីប្រភេទនៃកិច្ចសន្យា (ជាកិច្ចសន្យាមានថិរវេលាកំណត់ ឬគ្មានថិរវេលាកំណត់) មុខងារ ឬភារកិច្ចរបស់កម្មករនិយោជិតប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗដែលត្រូវផ្តល់ជូនកម្មករនិយោជិតរយៈពេលសាកល្បងការងារប្រភេទផ្សេងៗ នៃលក្ខខណ្ឌការងារក៏ដូចជាក្របខណ្ឌទូទៅនៃសិទ្ធិនិងកាតព្វកិច្ចរបស់និយោជក និងកម្មករនិយោជិត។

**២.តើទំនាក់ទំនងការងារមួយនៅប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយច្បាប់សំខាន់ៗអ្វីខ្លះ?**

ទំនាក់ទំនងការងារនៅប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងដោយច្បាប់សំខាន់ៗមួយ គឺច្បាប់ស្តីពីការងារ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស.រកម.០៣៩៧.០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។ បន្ថែមពីលើនេះយើងមានរដ្ឋធម្មនុញ្ញ អនុសញ្ញាអន្តរជាតិ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យការងារ និងក្រមរដ្ឋប្បវេណី។ ក្រៅពីលិខិតបទដ្ឋាន គតិយុត្តទាំងអស់នេះ វិធានផ្ទៃក្នុងរបស់ក្រុមហ៊ុនក៏មានសារៈសំខាន់ក្នុងការគ្រប់គ្រងទំនាក់ទំនងនេះផងដែរ ដូចជា កិច្ចសន្យាការងារ បទបញ្ជាផ្ទៃក្នុងអនុសញ្ញារួម។ល។ កិច្ចសន្យាការងារត្រូវគោរពទៅតាមលិខិតបទដ្ឋានដែលខ្ញុំបានរៀបរាប់ខាងលើនេះ។

**៣.តើនិយោជកនិងកម្មករនិយោជិតត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ដើម្បីចុះកិច្ចសន្យាការងារ?**

តាមច្បាប់ការងារ និយោជកអាចជារូបវន្តបុគ្គល (មនុស្ស) ឬជានីតិបុគ្គល (ក្រុមហ៊ុន រោងចក្រ អង្គការ សមាគម សហជីព...)។ ជាគោលការណ៍និយោជកត្រូវចុះបញ្ជីពាណិជ្ជកម្ម មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្មនិងបានបំពេញបែបបទនៃការជូនដំណឹងពីការបើកសហគ្រាសជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ លើសពីនេះទៀតបុគ្គលដែលតំណាងឲ្យនិយោជកត្រូវតែជានីតិជន (អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ) និងមានឯកសារតែងតាំង ឬផ្ទេរសិទ្ធិឲ្យចុះកិច្ចសន្យាការងារ។

ចំពោះកម្មករនិយោជិតវិញជាគោលការណ៍ទូទៅច្បាប់ការងារកំណត់ថា មនុស្សអាយុចាប់ពី ១៥ឆ្នាំ ឡើងទៅអាចធ្វើការងារបានហើយ។ ប៉ុន្តែមានការងារប្រភេទខ្លះច្បាប់កំណត់ថា ទាល់តែ ១៦ ឆ្នាំ ឬ ១៨ ឆ្នាំទើបអាចធ្វើការងារបាន ឬក្នុងករណីខ្លះ អាយុ ១២ឆ្នាំ ក៏អាចធ្វើការងារបានផងដែរ។ ដូច្នេះទាក់ទងនឹងអាយុដែលអាចធ្វើការងារនេះ គេត្រូវគោរពទៅតាមលក្ខខណ្ឌលម្អិត ដែលកំណត់នៅក្នុងច្បាប់ការងារ។

សូមកត់សម្គាល់ថា នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង អ្នកបញ្ជាទិញបានដាក់លក្ខខណ្ឌមករោងចក្រកាត់ដេរនៅកម្ពុជាឲ្យទទួលយកមកធ្វើការតែមនុស្សដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅប៉ុណ្ណោះ។ បុគ្គលដែលជានីតិជនអាចចុះកិច្ចសន្យាការងារដោយខ្លួនឯងបាន។ ចំពោះបុគ្គលដែលជាអនីតិជន (អាយុក្រោម ១៨ឆ្នាំ) ដែលអាចធ្វើការងារបាន គឺឪពុកម្តាយ ឬអាណាព្យាបាលជាអ្នកចុះកិច្ចសន្យាជំនួស។

ឯកសារដែលកម្មករនិយោជិតត្រូវផ្តល់ឲ្យនិយោជក មានដូចជា សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សញ្ញាបត្រ ឬវិញ្ញាបនបត្រ លិខិតបញ្ជាក់លំនៅ លិខិតបញ្ជាក់អំពីចរិយាឬមាយាទរបស់កម្មករ និយោជិត លិខិតថ្កោលទោស។ល។ ទៅតាមប្រភេទនៃមុខងារដែលពួកគេត្រូវធ្វើ។

**៤.តើកិច្ចសន្យាការងារស្របច្បាប់មានប៉ុន្មានប្រភេទដែរ?**

កិច្ចសន្យាការងារ មានពីរប្រភេទធំៗ គឺកិច្ចសន្យាការងារមានថិរវេលាកំណត់ និងកិច្ចសន្យាការងារគ្មានថិរវេលាកំណត់។ កិច្ចសន្យាការងារមានថិរវេលាកំណត់ គឺជាកិច្ចសន្យាដែលភាគីនិយោជកនិងកម្មករនិយោជិតបានព្រមព្រៀងគ្នាដោយកំណត់កាលបរិច្ឆេទឬពេលវេលាដែលកិច្ចសន្យាត្រូវបញ្ចប់។ ឧទាហរណ៍ និយោជក ជួលកម្មករនិយោជិតមកធ្វើការរយៈពេល ៦ខែ ឬ ១២ខែ ដែលមានកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ច្បាស់លាស់។

ពេលខ្លះទៀត និយោជកជួលកម្មករនិយោជិតថ្មីមកធ្វើការដើម្បីជំនួសកម្មករនិយោជិតដែលអវត្តមាន ឬឲ្យមកធ្វើការងារបន្ទាន់: ក្នុងករណីនេះកិច្ចសន្យារបស់កម្មករនិយោជិតថ្មី ត្រូវចប់នៅពេលណាដែលកម្មករនិយោជិតដែលអវត្តមានចូលមកធ្វើការងារវិញឬនៅពេលណាដែលការងារបន្ទាន់នោះត្រូវបានបំពេញចប់។ កិច្ចសន្យាមានថិរវេលាកំណត់នេះត្រូវតែធ្វើជាលាយលក្ខណ៍អក្សរហើយមិនអាចមានថិរវេលាលើសពី ២ឆ្នាំ នោះទេ។

កិច្ចសន្យាការងារគ្មានថិរវេលាកំណត់ គឺជាកិច្ចសន្យាមួយដែលភាគីនិយោជកនិង កម្មករ និយោជិត មិនបានបញ្ជាក់ឬសរសេរជាមួយគ្នានៅក្នុងកិច្ចសន្យាអំពីកាលបរិច្ឆេទឬពេលវេលាដែលកិច្ចសន្យាត្រូវបញ្ចប់នោះទេ។

កិច្ចសន្យាគ្មានថិរវេលាកំណត់នេះអាចធ្វើដោយមាត់ទទេ ឬជាលាយលក្ខណ៍អក្សរ។ ការបែងចែករវាងកិច្ចសន្យាទាំងពីរប្រភេទនេះមានសារៈសំខាន់ណាស់ ពីព្រោះបែបបទនិងមូលហេតុនៃការបញ្ចប់កិច្ចសន្យាប្រភេទនីមួយៗមានភាពខុសគ្នា។

## ផ្នែកទី៣១

## ផ្អែកលើខ្លឹមសារច្បាប់ការងារជុំវិញការកំណត់ប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិត

លោកមេធាវី លី ច័ន្ទតុលា ជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយភ្នំពេញប៉ុស្តិ៍ ផ្អែកលើខ្លឹមសារច្បាប់ការងារជុំវិញការកំណត់ប្រាក់ឈ្នួលសម្រាប់កម្មករ និយោជិត តាមរោងចក្រ និងសហគ្រាសដែលមានខ្លឹមសារជាអាទិ៍ដូចខាងក្រោមៈ

**១.តើអ្វីទៅជាប្រាក់ឈ្នួល?**

ប្រាក់ឈ្នួល គឺជាប្រាក់និងអត្ថប្រយោជន៍ផ្សេងៗដែលនិយោជក ឬថៅកែត្រូវផ្តល់ឲ្យកម្មករនិយោជិតរបស់ខ្លួន។ ប្រាក់ឈ្នួលនេះត្រូវបានគ្រប់គ្រងដោយច្បាប់ការងារឆ្នាំ ១៩៩៧ នៅក្នុងជំពូក ទី៦ ផ្នែកទី១។ តាមមាត្រា ១០៣ នៃច្បាប់ការងារនេះ ប្រាក់ឈ្នួលរួមមានប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ថ្លៃធ្វើការបន្ថែមម៉ោង ប្រាក់រង្វាន់ ប្រាក់បំណាច់ ផលប្រយោជន៍ជាវត្ថុ ប្រាក់ផលិតភាពការងារ ប្រាក់កម្រៃជើងសា ប្រាក់ថ្លៃ អាហារ។ល។ និយាយរួមតាមគោលការណ៍ច្បាប់ប្រាក់ឈ្នួល គឺជាប្រាក់និងអត្ថប្រយោជន៍ទាំងអស់ដែលនិយោជកផ្តល់ឲ្យកម្មករ និយោជិត។

គួរបញ្ជាក់ថាក្នុងចំណោមប្រាក់ឈ្នួលទាំងនេះមានចំនួនខ្លះជាចំនួន “ថេរ” ប្រចាំខែ ដែលគេតែងហៅថា “ប្រាក់ខែ ឬប្រាក់ខែគោល” ចំនួនខ្លះ “ប្រែប្រួល” ទៅតាមផលិតភាពរបស់កម្មករនិយោជិត ក្នុង១ខែៗ ដូចជា ប្រាក់ម៉ោង បន្ថែម ឬប្រាក់រង្វាន់ចំពោះអ្នកធ្វើការបានច្រើនឬប្រាក់កម្រៃជើងសាដែលប្រាក់ទាំងនេះ ប្រែប្រួលតិចឬច្រើនទៅតាមខែនីមួយៗ។

**២.តើប្រាក់ឈ្នួលនេះ ត្រូវកំណត់ដោយនីតិវិធីរបៀបម៉េច?**

ទំនាក់ទំនងការងារ កើតចេញពីកិច្ចសន្យាការងាររវាងថៅកែ (និយោជក) និងកម្មករនិយោជិត។ កិច្ចសន្យានេះជាកិច្ចសន្យាឯកជនដូចគ្នានឹងកិច្ចសន្យាឯកជនផ្សេងៗទៀត។ ដូច្នេះ ពេលចុះកិច្ចសន្យាការងារជាមួយគ្នា ភាគីទាំង ២ មានសេរីភាពពេញលេញនៅក្នុងការចរចាគ្នាអំពីប្រាក់ឈ្នួលនេះ។ ប៉ុន្តែ ជាទូទៅនៅក្នុងការអនុវត្ត និយោជកជាអ្នកកំណត់ប្រាក់ឈ្នួលជាមុនហើយ កម្មករនិយោជិតមានលទ្ធភាពចរចាតិចតួចណាស់។ យោងលើហេតុផលនៃអំណាចខុសគ្នារវាងនិយោជក និងកម្មករនិយោជិត ហេតុផលប្រកួតប្រជែងរវាងអ្នករកការងារធ្វើ និងដើម្បីចៀសវាងការរំលោភបំពានដោយនិយោជកច្បាប់បានអន្តរាគមន៍ដោយបង្កើតជា សញ្ញាណមួយហៅថា “ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា” (មាត្រា ១០៤ ច្បាប់ការងារ)។ ប្រាក់ឈ្នួលអប្បបរមានេះ គឺជាចំនួនប្រាក់ឈ្នួលតិចបំផុតដែលនិយោជកត្រូវផ្តល់ឲ្យកម្មករនិយោជិត។ តាមរយៈនេះទោះបីជាកម្មករ និយោជិតយល់ព្រមទទួលយកប្រាក់ឈ្នួលតិចជាងប្រាក់ឈ្នួលអប្បបរមានេះក៏ដោយ ក៏កិច្ចព្រមព្រៀងនោះគ្មានតម្លៃតាមច្បាប់ដែរ។

តាមមាត្រា ១០៤ នៃច្បាប់ការងារប្រាក់ឈ្នួលអប្បបរមានេះត្រូវមានចំនួនមួយដែលអនុញ្ញាតឲ្យកម្មករនិយោជិតមានកម្រិតជីវភាពសមរម្យទៅតាមសេចក្តីថ្លៃថ្នូររបស់មនុស្ស។ តាមមាត្រា ១០៧ ប្រាក់ឈ្នួលអប្បបរមានេះត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមរយៈក្រសួងការងារ។ មុននឹងក្រសួងកំណត់ឬសើរើ នូវប្រាក់ឈ្នួលអប្បបរមានេះឡើងវិញ ក្រសួងត្រូវទទួលយោបល់ពីគណៈកម្មការប្រឹក្សាការងារ។ គណៈកម្មការប្រឹក្សាការងារនេះ គឺជាគណៈកម្មការជំនាញមួយដែលមានសមាសភាព តំណាងពីក្រសួងការងារ សហជីពកម្មករនិយោជិតនិងសមាគមនិយោជក។ គណៈកម្មការនេះធ្វើការសិក្សាលើកត្តាផ្សេងៗទាំងជីវភាពនិងសេដ្ឋកិច្ច ហើយលើកជាយោបល់អំពីចំនួនប្រាក់ឈ្នួលអប្បបរមាជូនទៅក្រសួងការងារ។

តាមមាត្រា ១០៧ ចំណុច ទី៣ ដើម្បីកំណត់ប្រាក់ឈ្នួលអប្បបរមានេះគេត្រូវគិតទៅលើកត្តា ២ សំខាន់ៗៈ

ក. តម្រូវការនិងតម្លៃជីវភាពរស់នៅរបស់កម្មករនិយោជិតនិងគ្រួសារ

ខ. កត្តាទាំងឡាយនៃវិស័យសេដ្ឋកិច្ចៈ តម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច ការថែរក្សាមុខរបរឬការងារ ចិរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច លទ្ធភាពហិរញ្ញវត្ថុរបស់និយោជក ការទាក់ទាញការវិនិយោគ ការថែរក្សាអ្នកវិនិយោគ ភាពប្រកួតប្រជែងរវាងប្រទេសយើងជាមួយប្រទេសផ្សេងៗ។ល។

ក្រសួងការងារ ត្រូវផ្តល់ការយកចិត្តទុកដាក់ដល់កត្តាទាំងពីរខាងលើស្មើគ្នានៅក្នុងការចេញប្រកាសកំណត់អំពីប្រាក់ឈ្នួលអប្បបរមានេះ។

សូមបញ្ជាក់ថារហូតមកដល់បច្ចុប្បន្ននេះ មានការកំណត់ប្រាក់ឈ្នួលអប្បបរមា តែនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងប៉ុណ្ណោះ។ វិស័យផ្សេងៗទៀត នឹងមានការកំណត់នៅពេលក្រោយ។

**៣.ដោយលោកមេធាវីបានលើកឡើងពីវិស័យកាត់ដេរ តើប្រាក់ឈ្នួលកម្មករនិយោជិតក្នុងវិស័យនេះ តាមច្បាប់មានការកំណត់ដូចម្តេចដែរ?**

នៅក្នុងវិស័យកាត់ដេរនេះ កម្មករ និយោជិត បានទទួលប្រាក់ឈ្នួល ២ ប្រភេទ៖ ប្រាក់ឈ្នួលប្រចាំខែដែលស្មើនឹងប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍បន្ថែម ដែលនិយោជកត្រូវផ្តល់ឲ្យកម្មករ។

ប្រាក់ឈ្នួលអប្បបរមានេះនៅកម្ពុជាយើងត្រូវបានកំណត់និងដំឡើងជាបន្តបន្ទាប់ តាំងតែពីឆ្នាំ ១៩៩៧ មក

- ពីឆ្នាំ ១៩៩៧ ប្រាក់ឈ្នួលអប្បរមានេះ មានចំនួន ៤០ ដុល្លារ
- ពីឆ្នាំ ២០០០ មានចំនួន ៤៥ ដុល្លារ
- ពីឆ្នាំ ២០០៦ មានចំនួន ៥០ ដុល្លារ
- ពីឆ្នាំ ២០១០ មានចំនួន ៦១ ដុល្លារ
- ពីឆ្នាំ ២០១៣ មានចំនួន ៨០ ដុល្លារ
- កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ក្រសួងការងារ បានចេញប្រកាសមួយសម្រេចដំឡើងប្រាក់ឈ្នួលអប្បបរមានេះរហូតដល់ ១០០ ដុល្លារ ហើយការដំឡើងនេះចាប់អនុវត្តពីថ្ងៃ ទី១ ខែ កុម្ភៈ ឆ្នាំ ២០១៤ តទៅ។

ខ្ញុំសូមបញ្ជាក់ថា បន្ថែមលើប្រាក់ឈ្នួលអប្បបរមានេះ កម្មករនិយោជិតវិស័យកាត់ដេរទទួលបានប្រាក់ឈ្នួលដែលជាអត្ថប្រយោជន៍បន្ថែម ដែលនិយោជក ត្រូវផ្តល់ឲ្យដូចតទៅ៖

- ប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ១០ ដុល្លារ ក្នុង ១ខែ
- ប្រាក់សោហ៊ុយធ្វើដំណើរនិងស្នាក់នៅចំនួន ៧ ដុល្លារ ក្នុង ១ខែ
- ប្រាក់អតីតភាពការងារ ចាប់ពី ២ ដល់ ១១ ដុល្លារក្នុងមួយខែទៅតាមចំនួនឆ្នាំដែលកម្មករបានធ្វើការ
- ប្រាក់ថ្លៃអាហារចំពោះអ្នកដែលធ្វើការបន្ថែមម៉ោងដែលមានចំនួន ២០០០ រៀល ក្នុង ១ថ្ងៃ
- ប្រាក់បន្ថែមម៉ោង ទៅតាមចំនួនម៉ោងបន្ថែម ដែលបានធ្វើជាក់ស្តែង។

ដូច្នេះតាមរយៈការដំឡើងថ្មីស្មើនឹងយ៉ាងតិច ១០០ ដុល្លារ នេះ ក្នុងមួយខែកម្មករនិយោជិតរោងចក្រកាត់ដេរទូទៅអាចទទួលបានប្រាក់ខែយ៉ាងហោចស្មើនឹង ១២០ ដុល្លារអាមេរិកដោយមិនទាន់គិតបញ្ចូលប្រាក់បន្ថែមម៉ោង។ បើតាមការសិក្សារបស់សមាគមនិយោជក កម្មករ និយោជិតរោងចក្រកាត់ដេរទទួលបានជាមធ្យម ១៥០ ដុល្លារ។ ដូច្នេះ ជាមួយការបន្ថែមនេះ មធ្យមភាគនេះអាចឡើងដល់ ១៧០ ដុល្លារ។

ខ្ញុំក៏សូមបញ្ជាក់ផងដែរថា និយោជកមានសិទ្ធិពេញលេញនៅក្នុងការផ្តល់ប្រាក់ឈ្នួលអប្បបរមា ជូនកម្មករនិយោជិតច្រើនជាង ១០០ ដុល្លារបាន។ កិច្ចសន្យាការងារឬអនុសញ្ញារួមរវាងនិយោជកនិងសហជីពកម្មករ និយោជិតអាចកំណត់ប្រាក់ឈ្នួលអប្បបរមាច្រើនជាងប្រាក់ឈ្នួលអប្បបរមា ដែលក្រសួងការងារកំណត់។

**៤.តើទាំងនិយោជក និងកម្មករនិយោជិត ត្រូវតែគោរពតាមប្រកាសរបស់ក្រសួងការងារ ដែលកំណត់អំពីប្រាក់ឈ្នួលអប្បបរមានេះ ឬអាចមានការជំទាស់បានដែរ?**

ប្រកាសរបស់ក្រសួងការងារ មានតម្លៃគតិយុត្តិដូចជាច្បាប់មួយអ៊ីចឹងដែរ។ ដូច្នេះទាំងភាគីនិយោជកនិងទាំងកម្មករនិយោជិតត្រូវតែគោរពតាមប្រកាសនេះ។ តាមមាត្រា ៣៦៩ នៃច្បាប់ការងារ និយោជកដែលផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតតិចជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវជានាត្រូវទទួលការពិន័យជាប្រាក់ពី ៦១ ថ្ងៃទៅ ៩០ ថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃឬអាចត្រូវជាប់ពន្ធនាគារពី ៦ថ្ងៃ ទៅ ១ខែ។ សហជីព ឬកម្មករនិយោជិតដែលចង់ធ្វើកូដកម្មឬបាតុកម្មគាំអាចធ្វើបាន ប៉ុន្តែ ត្រូវតែគោរពតាមច្បាប់និងនីតិវិធីនៃការធ្វើកូដកម្ម (ច្បាប់ការងារ) និងបាតុកម្ម (ច្បាប់បាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩) ជាអាទិ៍ ត្រូវជូនដំណឹងមុនទៅនិយោជក ៧ ថ្ងៃមុនការជូនដំណឹងទៅអាជ្ញាធរដែនដី ៥ ថ្ងៃមុន គោរពសិទ្ធិរបស់អ្នកមិនមែនជា កូដករឬបាតុករ អហិង្សានិងមិនត្រូវបំផ្លិច បំផ្លាញទ្រព្យសម្បត្តិរបស់រោងចក្រ ឬទ្រព្យ សម្បត្តិសាធារណៈត្រូវគោរពច្បាប់ទាក់ទង នឹងការប្រើប្រាស់ផ្លូវសាធារណៈ ជាពិសេសមិនត្រូវបិទផ្លូវសាធារណៈទេ...។

## ផ្នែកទី៣២

# ភាពខុសគ្នានៃដីកាបង្គាប់ឲ្យចូលខ្លួននិងដីកាឲ្យនាំខ្លួន

លោក ផែង ហេង ជាមេធាវី បម្រើការនៅក្រុមមេធាវី BBC LAW FIRM មានការិយាល័យស្ថិតនៅផ្ទះលេខ ១៤ CEo ផ្លូវលេខ ៣៨៤ សង្កាត់ទួលស្វាយព្រៃ ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

លោកមេធាវីកើតនៅ ឆ្នាំ១៩៦៩ នៅ ភូមិព្រែកតាបែន ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ លោក បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ១- បរិញ្ញាបត្រគីមីវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅ ឆ្នាំ១៩៩៥, ២- បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅ ឆ្នាំ១៩៩៨ និងបរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) នីតិសាធារណៈនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា PUCនៅ ឆ្នាំ២០០៦។

លោកមេធាវី ផែង ហេង បានផ្តល់កិច្ចសម្ភាសន៍ដល់កាសែត ភ្នំពេញ ប៉ុស្តិ៍ ស្តីពីដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នរបស់តុលាការដែលមានខ្លឹមសារដូចខាងក្រោម៖

**១.ដីកាបង្គាប់ឲ្យចូលខ្លួន និងដីកាបង្គាប់ឲ្យនាំខ្លួនមានអត្ថន័យនិងការអនុវត្តខុសគ្នាដូចម្តេចដែរ?**

- ដីកាបង្គាប់ឲ្យចូលខ្លួន មានចែងក្នុងមាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ កាលណាមាន តម្រុយលើជនណាថាមានពិរុទ្ធភាព ចៅក្រមស៊ើបសួរ អាចចេញដីកាឲ្យចូលខ្លួន។ ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវចុះនិទ្ទេស អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធបទល្មើសត្រូវចោទ កាលបរិច្ឆេទ និងទីកន្លែងត្រូវចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនិងឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា។ នគរបាលយុត្តិធម៌ឬអាជ្ញាសាលាត្រូវជូនដីកានេះឲ្យសាមីជនពាក់ព័ន្ធចុះហត្ថលេខាឬផ្តិតមេដៃទទួល ហើយត្រូវបង្វិលដីកានេះមួយច្បាប់ឲ្យទៅចៅក្រមវិញ។ ដីកាបង្គាប់ឲ្យចូលខ្លួនមិនមានលក្ខណៈបង្ខំទេ ដូចនេះបានជាអ្នកប្រគល់ដីកាត្រូវឲ្យសាមីខ្លួនចុះហត្ថលេខាឬផ្តិតស្នាមមេដៃទទួល ដើម្បីតាមដាននិងរាប់ចំនួនដង តើសាមីខ្លួនបានទទួលហើយតែពុំព្រមចូលប៉ុន្មានដង?
- ដីកាបង្គាប់ឲ្យនាំខ្លួន មានចែងមាត្រា ១៨៩ និង ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកា នេះមានន័យថា៖ ក្រោយពីកោះហៅមួយលើក ពីរលើកឲ្យចូលខ្លួន សាមីខ្លួនមិនចូល អ៊ីចឹង ចៅក្រមស៊ើបសួរចេញដីកាមួយទៀតហៅថា ដីកាបង្គាប់ឲ្យនាំខ្លួន។ ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវប្រគល់ឲ្យនគរបាលយុត្តិធម៌។ ដីកានេះត្រូវតែចុះនិទ្ទេសគ្រប់ជ្រុងជ្រោយ ដូចគ្នានឹងដីកាឲ្យចូលខ្លួនដែរ ហើយមានសិទ្ធិចូលទៅនាំខ្លួនជនពាក់ព័ន្ធក្នុងម៉ោងការងារពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច។
- ដីកាបង្គាប់ឲ្យចាប់ខ្លួន មានន័យថា៖ ចៅក្រមស៊ើបសួរ អាចចេញដីកាឲ្យចាប់ខ្លួនបាន។ អាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបាន ចៅក្រមស៊ើបសួរត្រូវតែមានទទួលយោបល់ពីព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវសរសេរមូលហេតុក្រោយពីមានយោបល់ពីព្រះរាជអាជ្ញា។ ការចេញដីកានេះ កាលណាបទល្មើសជាបទឧក្រិដ្ឋ ឬមជ្ឈិមត្រូវផ្តន្ទាទោសដាក់គុកឬបុគ្គលពាក់ព័ន្ធគេចខ្លួន។ ដីកានេះគឺបង្គាប់ឲ្យកម្លាំងសាធារណៈស្រាវជ្រាវរកចាប់និងនាំខ្លួនទៅពន្ធនាគារឬមន្ទីរឃុំឃាំង។ ដីកានេះអាច បិទផ្សាយជាសាធារណៈ។
- ដីកាបង្គាប់ឲ្យឃុំខ្លួនមានចែងក្នុងមាត្រា ២១៩ នៃក្រមនីតិវិធីព្រហ្មទន្ឌ។ ដីកានេះ មានន័យថា គឺជាបញ្ជាដល់ប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួនឲ្យទទួលនិងឲ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចចេញដីកាឲ្យឃុំខ្លួនបាន លុះត្រាជនត្រូវចោទ ជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។ ការសម្រេចឃុំខ្លួនជនត្រូវចោទ

ត្រូវផ្អែកលើមូលហេតុ ដូចមានចែងនៅមាត្រា ២០៥ គឺដើម្បីបញ្ចប់បទល្មើសកុំឲ្យគាបសង្កត់ដល់សាក្សី រក្សាភស្តុតាង រក្សាជនល្មើសទុកឲ្យតុលាការចាត់ការតាមនីតិវិធី ការពារសុវត្ថិភាព ជូនជនល្មើស និងរក្សាសណ្តាប់ធ្នាប់សង្គម។

**២.តើការឃុំខ្លួនបណ្តោះអាសន្ននេះមានកម្រិត និងនីតិវិធីបែបណាដែរ?**

ការឃុំខ្លួនជាបណ្តោះអាសន្ននេះ គឺមានកម្រិតរបស់វាយោងទៅតាមប្រភេទនៃបទល្មើសនីមួយៗ។ ឧទាហរណ៍ បទល្មើសមជ្ឈិម ការឃុំខ្លួនជាបណ្តោះអាសន្ន គឺមានរយៈពេល ៤ខែ រីឯបទល្មើសឧក្រិដ្ឋ ការឃុំខ្លួនជាបណ្តោះអាសន្ន មានរយៈពេល ៦ខែ។ ប៉ុន្តែចៅក្រមស៊ើបសួរ អាចពន្យារបានទៀត អាស្រ័យលើការលំបាកនៃការស្រាវជ្រាវស៊ើបអង្កេត។ ចំពោះការសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ...(នៅមានត)

## ផ្នែកទី៣៣

# ការដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យពីតុលាការ

លោក ផែង ហេង ជាមេធាវី បម្រើការនៅក្រុមមេធាវី BBC LAW FIRM ការិយាល័យស្ថិតនៅផ្ទះលេខ ១៤CEo ផ្លូវលេខ ៣៨៤ សង្កាត់ទួលស្វាយព្រៃ ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ លោកបានបញ្ចប់ ការសិក្សានៅមហាវិទ្យាល័យ៖ ១-បរិញ្ញាប័ត្រគីមីវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅឆ្នាំ ១៩៩៥, ២-បរិញ្ញាប័ត្រនីតិសាស្ត្រសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ ១៩៩៨ និង ៣-បរិញ្ញាប័ត្រជាន់ខ្ពស់ (អនុបណ្ឌិត) នីតិសាធារណៈនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (PUC) ឆ្នាំ ២០០៦។

លោកមេធាវី ផែង ហេង បានផ្តល់កិច្ចសម្ភាសន៍ជាមួយកាសែតភ្នំពេញប៉ុស្តិ៍ ស្តីពីដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ បន្តពីលេខមុនដែលមានខ្លឹមសារដូចខាងក្រោម ៖

**១.(ត)...ដោយឡែកពីនេះ សម្រាប់ការសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ តើមាននីតិវិធីអនុវត្តដូចម្តេចដែរ ?**

ចំណែកឯ ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការវិញ គឺមានន័យប្រហាក់ប្រហែលនឹងការឃុំខ្លួនជាបណ្តោះអាសន្នដែរ គឺខុសគ្នាត្រង់ថា នៅក្នុងចំណុច នៃការឃុំខ្លួនជាបណ្តោះអាសន្ន គឺជនត្រូវចោទ ត្រូវគេឃុំខ្លួននៅក្នុងពន្ធនាគារជាបណ្តោះអាសន្ន។ ចំណែកឯ ការដាក់ឲ្យស្ថិតនៅក្រៅឃុំវិញ គឺជនត្រូវចោទ មិនត្រូវបានគេឃុំខ្លួននោះក៏ប៉ុន្តែជាប់ចោទពីតុលាការដូចគ្នា។

ក្នុងករណីដែលវាមានបណ្តឹងអាជ្ញា ហើយតុលាការបានធ្វើការចោទប្រកាន់ហើយនោះ ប៉ុន្តែ ជនល្មើសបានរត់គេចខ្លួននោះ ការតាមចាប់ខ្លួន និងអាជ្ញាយុកាលនៃការចាប់ខ្លួននោះ គឺមិនកំណត់អាជ្ញាយុកាលទេ។ ប៉ុន្តែអាជ្ញាយុកាលនៃបទល្មើសមានចែងក្នុងមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺយោងទៅតាមប្រភេទនៃបទល្មើសនីមួយៗ ឧទាហរណ៍ថា ដូចជាបទល្មើសមជ្ឈិម គឺមានអាជ្ញាយុកាលកំណត់ពេល ៥ ឆ្នាំ បទឧក្រិដ្ឋមានអាជ្ញាយុកាល ១៥ ឆ្នាំ ចំណែកបទល្មើសប្រល័យពូជសាសន៍ ប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម គឺពុំផុតអាជ្ញាយុកាលឡើយ ដូចមានចែងក្នុងមាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមមាត្រា ២២៣ នៃនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការបានសរសេរថា៖ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

១-មិនត្រូវចេញក្រៅព្រំដែនកំណត់ ដោយចៅក្រម។

២-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រម។

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះ ដែលកំណត់ដោយចៅក្រម ស៊ើបសួរ។

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រម។

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារអំពីអត្តសញ្ញាណ។

៧-មិនត្រូវបើកបររថយន្ត។

...........

៨-មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩-ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នោះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០-មិនត្រូវកាន់កាប់ ឬយកតាមខ្លួន នូវអាវុធ។ ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជី នូវអាវុធត្រូវជនជាប់ចោទកាន់កាប់។

១១-ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុឲ្យដាក់នៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

មាត្រា ២២៤៖ អនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ។

## ផ្នែកទី៣៤

# តើអ្វីទៅជាសិទ្ធិខាងរូបភាពនៃបុគ្គល?

ដោយ សេង ឌីណា

សិទ្ធិខាងរូបភាព គឺជាផ្នែកមួយនៃសិទ្ធិបុគ្គល ដែលទទួលបានការការពារដោយក្រមរដ្ឋប្បវេណី។ មាត្រា ១០ នៃក្រមរដ្ឋប្បវេណីខ្មែរ ចែងថា៖ "សិទ្ធិរបស់បុគ្គល សំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិតរូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬសិទ្ធិផ្សេងទៀត ដែលជាផលប្រយោជន៍ ទាក់ទងនឹងលក្ខណៈបុគ្គល"។ ខាងក្រោមនេះជាសំណួរ-ចម្លើយជុំវិញសិទ្ធិខាងរូបភាពនៃបុគ្គល។

**១.តើអ្វីទៅជាសិទ្ធិខាងរូបភាពនៃបុគ្គល?**

សិទ្ធិខាងរូបភាព គឺជាសិទ្ធិរបស់បុគ្គលក្នុងការហាមឃាត់អ្នកដទៃមិនឲ្យថត ឬផ្សព្វផ្សាយរូបភាពរបស់ខ្លួន។

ដូច្នេះ បើទោះបីត្រឹមតែថតរូប ហើយមិនយករូបថតទៅផ្សព្វផ្សាយក៏ដោយ ក៏ជាការរំលោភលើសិទ្ធិខាងរូបភាពដែរ ប្រសិនបើគ្មានការព្រមព្រៀងពីម្ចាស់រូប។

**២.តើអ្នករំលោភលើសិទ្ធិខាងរូបភាពនេះ អាចត្រូវទទួលទោសបែបណា?**

អ្នករំលោភលើសិទ្ធិខាងរូបភាពអាចនឹងត្រូវទទួលទោសខាងរដ្ឋប្បវេណីផង និងខាងព្រហ្មទណ្ឌផង។

យោងតាមក្រមរដ្ឋប្បវេណី ក្នុងករណីមានការថត ឬផ្សព្វផ្សាយរូបភាពដោយគ្មានការព្រមព្រៀងពីម្ចាស់រូប ម្ចាស់រូបមានសិទ្ធិ៖

- ទាមទារឲ្យបញ្ឈប់ (មាត្រា ១១)៖ ដូចជា ពេលឃើញគេលើកម៉ាស៊ីនថតចង់ថត សាមីខ្លួនអាចហាមឃាត់មិនឲ្យថត។
- ទាមទារឲ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ(មាត្រា ១២)៖ បើសិនជារូបភាពត្រូវបានថតរួចទៅហើយ សាមីខ្លួនអាចទាមទារឲ្យលុបរូបនេះចេញពីម៉ាស៊ីនថតវិញ។ បើសិនជារូបថតនេះ ត្រូវបានយកទៅចុះផ្សាយរួចហើយ (ដូចជាចុះផ្សាយនៅលើទំព័រវិបសៃត៍ជាដើម) ម្ចាស់រូបអាចទាមទារឲ្យដករូបនេះចេញវិញ។
- ទាមទារសំណងការខូចខាត (មាត្រា ១៣)៖ ប្រសិនបើការថតរូប ឬការផ្សព្វផ្សាយរូបភាពនេះ បានបង្កការខូតខាតណាមួយ ម្ចាស់រូបអាចទាមទារសំណងខូតខាតពីអ្នកប្រព្រឹត្តល្មើសបាន។ សិទ្ធិទាមទារសំណងខូតខាតនេះ អាចអនុវត្តព្រមគ្នាជាមួយសិទ្ធិទីពីរខាងលើ មានន័យថា ម្ចាស់រូបអាចទាមទារឲ្យបញ្ឈប់ការចុះផ្សាយរូបភាពផង ហើយអាចទាមទារឲ្យសងការខូតខាតផង។

ក្នុងពេលជាមួយគ្នា អ្នកដែលប្រព្រឹត្តអំពើដែលប៉ះពាល់ដល់សិទ្ធិខាងរូបភាពបុគ្គល ក៏អាចត្រូវទទួលទោសព្រហ្មទណ្ឌដែរ។ នៅក្នុងក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ៣០២ មានចែងថា "*អំពើថតរូបភាពនៃបុគ្គលនៅក្នុងទីកន្លែងឯកជន ដោយគ្មានការព្រមព្រៀងពីបុគ្គលនេះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ ពី១សែន ទៅ ២លានរៀល លើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត*"។

**៣.ដូច្នេះ មានន័យថា រាល់ពេលដែលចង់ថតរូបអ្នកណាម្នាក់ គឺដាច់ខាតត្រូវតែមានការព្រមព្រៀងពីសាមីខ្លួនជាមុនជានិច្ច ឬយ៉ាងណា?**

ជាគោលការណ៍ គឺត្រូវតែមានការព្រមព្រៀងពីម្ចាស់រូបជាមុនសិន ទាំងការថតរូប និងការយករូបថតទៅផ្សព្វផ្សាយ ព្រោះថា ការព្រមព្រៀងឲ្យថត មិនមែនមានន័យថា ឲ្យយករូបថតនេះទៅផ្សព្វផ្សាយទេ។

ការព្រមព្រៀងឲ្យថត ឬឲ្យចុះផ្សាយរូបថត អាចជាការព្រមព្រៀងដោយជាក់ច្បាស់ (ម្ចាស់រូបប្រាប់អ្នកថតថា ខ្លួនអនុញ្ញាតឲ្យថតរូប ឬយករូបថតទៅផ្សព្វផ្សាយ) ឬដោយតុណ្ហី (ម្ចាស់រូបដឹងដែរថា គេថត តែមិនជំទាស់ ឬដឹងដែរថា គេយករូបទៅចុះផ្សាយតែមិនជំទាស់ គឺមានន័យស្មើនឹងយល់ព្រមឲ្យគេថតរូប ឬឲ្យគេយករូបថតទៅចុះផ្សាយ)។

ក៏ប៉ុន្តែ អ្នកថតគួរតែស្វែងរកការព្រមព្រៀងឲ្យបានជាក់ច្បាស់ពីម្ចាស់រូប ប្រសើរជាងការព្រមព្រៀងដោយតុណ្ហី ជាពិសេស បើចង់យករូបថតគេទៅផ្សព្វផ្សាយ ពីព្រោះថា បើគ្មានការព្រមព្រៀងដោយជាក់ច្បាស់ជាមុនទេ ម្ចាស់រូបមិនត្រឹមតែអាចទាមទារឲ្យដករូបនេះចេញវិញទេ ប៉ុន្តែ ថែមទាំងអាចទាមទារសំណងជំងឺចិត្តទៀតផង។

**៤.តើការថតរូបភាពក្រុមមនុស្សកកកុញ ត្រូវតែសុំការអនុញ្ញាតពីម្ចាស់រូបគ្រប់ៗគ្នាឬយ៉ាងណា?**

ការថតរូប ឬចុះផ្សាយរូបថតក្រុមមនុស្ស មិនចាំបាច់មានការព្រមព្រៀងពីម្ចាស់រូបនោះទេ ប្រសិនបើក្នុងរូបថតនេះ គេមិនអាចមើលដឹងថាជារូបរបស់អ្នកណាច្បាស់លាស់ទេ។

តាមការពិត ទោះបីថតរូបមនុស្សច្រើនគ្នាជាក្រុមក៏ដោយ ឬថតមនុស្សម្នាក់ឯងក៏ដោយឲ្យតែមនុស្សក្នុងរូបថត គេមិនអាចមើលស្គាល់ទេ គឺមិនមានការប៉ះពាល់ដល់សិទ្ធិខាងរូបភាពទេ។ ដូច្នេះ គេមិនចាំបាច់សុំការព្រមព្រៀងពីម្ចាស់រូបទេ។

**៥.ការថត ឬចុះផ្សាយរូបថតរបស់មន្ត្រីរដ្ឋាភិបាល ក្នុងទំព័រសារព័ត៌មាន ដោយគ្មានការអនុញ្ញាត តើជាការប៉ះពាល់ដល់សិទ្ធិខាងរូបភាពដែរ ឬទេ?**

ការថតរូប ឬចុះផ្សាយរូបថត របស់មន្ត្រីដែលកាន់មុខងារសាធារណៈ មិនមែនជាការប៉ះពាល់ដល់សិទ្ធិខាងរូបភាពនោះទេ ប្រសិនបើរូបថតនោះ ត្រូវយកទៅប្រើប្រាស់ក្នុងផលប្រយោជន៍សាធារណៈ។ បុគ្គលដែលកាន់មុខងារសាធារណៈ (ដូចជា រដ្ឋមន្ត្រី ប្រធានស្ថាប័នសាធារណៈ ឬមន្ត្រីនាំពាក្យស្ថាប័នសាធារណៈ ជាដើម) សុទ្ធតែបានដឹងខ្លួនជាមុនថា ខ្លួនអាចត្រូវគេថតរូប និងចុះផ្សាយរូបថត ដើម្បីបម្រើផលប្រយោជន៍សាធារណៈ។ ដូច្នេះ គេសន្មត់ជាទូទៅថា បុគ្គលសាធារណៈទាំងនោះបានព្រមព្រៀងជាមុនឲ្យគេថតរូប និងចុះផ្សាយរូបថតរបស់ខ្លួន។ ប៉ុន្តែ រូបថតនោះអាចប្រើបាន តែក្នុងគោលដៅផលប្រយោជន៍សាធារណៈប៉ុណ្ណោះ មិនអាចប្រើក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជន ឬគោលដៅពាណិជ្ជកម្មបានទេ។

## ផ្នែកទី៣៥

## ការទទួលខុសត្រូវចំពោះខ្លឹមសារដែលចុះផ្សាយលើប្រព័ន្ធអ៊ីនធ័រនែត

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា សូមធ្វើការពន្យល់ជុំវិញការទទួលខុសត្រូវ ចំពោះខ្លឹមសារដែលចុះផ្សាយនៅលើប្រព័ន្ធអ៊ីនធ័រនែត។ នៅពេលដែលការចុះផ្សាយនៅលើ វិបសៃត៍ណាមួយ មានបង្កប់នូវខ្លឹមសារមិនស្របច្បាប់ តើអ្នកណាជាអ្នកទទួលខុសត្រូវ?

**១-នៅក្នុងសម័យកាលអ៊ីនធ័រនែតបច្ចុប្បន្ននេះ រាល់ការចុះផ្សាយអត្ថបទ រូបភាព ឬវីដេអូ គឺជារឿងដែលងាយស្រួលបំផុត ដែលនរណាក៏អាចធ្វើបានដែរ។ ក៏ប៉ុន្តែ ប្រសិនបើការចុះផ្សាយទាំងអស់នេះ មានចោទជាបញ្ហាច្បាប់ តើអ្នកណាខ្លះដែលជាអ្នកទទួលខុសត្រូវ?**

មុននឹងពិចារណាអំពីការទទួលខុសត្រូវ យើងគួរពិនិត្យមើលសិនថា តើតួអង្គសំខាន់ៗ នៅក្នុងការចុះផ្សាយលើប្រព័ន្ធអ៊ីនធ័រនែត មានអ្នកណាខ្លះ?

- **អ្នកនិពន្ធ៖** អ្នកបង្កើតខ្លឹមសារដែលត្រូវចុះផ្សាយ (អ្នកនិពន្ធអត្ថបទ, អ្នកថតរូប, អ្នកថតវីដេអូ, អ្នកគូរគំនូរ ។ល។)
- **អ្នកទទួលខុសត្រូវចុះផ្សាយ៖** ម្ចាស់វិបសៃត៍, ម្ចាស់ប្លក (Blog), ម្ចាស់ Forum
- **អ្នកផ្តល់សេវាកម្មវិបសៃត៍** (Hébergeur/Host)
- **ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធ័រនែត**(Fournisseur d'accès à internet/Internet Service Provider)

ឧទាហរណ៍៖ បុគ្គល "ក" បង្កើត Blog ផ្ទាល់ខ្លួនមួយ តាមរយៈវិបសៃត៍របស់ Blogspot.com (dynaseng.blogspot.com)។ តួអង្គសំខាន់ៗដែលពាក់ព័ន្ធនឹងខ្លឹមសារចុះផ្សាយនៅលើប្លក dynaseng.blogspot.com នេះ គឺមាន៖

- Blogspot គឺជាអ្នកផ្តល់សេវាកម្មវិបសៃត៍ (Héberbeur/Host)
- ខ្លួនខ្ញុំផ្ទាល់ ដែលជាម្ចាស់ប្លក គឺជាអ្នកទទួលខុសត្រូវចុះផ្សាយ
- បើសិនជាអត្ថបទ ដែលចុះផ្សាយនៅលើប្លកនេះ ជាអត្ថបទ ដែលខ្ញុំសរសេរដោយខ្លួនឯង ខ្ញុំគឺជាអ្នកទទួលខុសត្រូវចុះផ្សាយផង និងជាអ្នកនិពន្ធផង
- បើសិនជាខ្ញុំចុះផ្សាយអត្ថបទ ឬរូបថត ដែលសរសេរ ឬថតដោយអ្នកផ្សេង អ្នកសរសេរអត្ថបទ ឬអ្នកថតរូបនេះ គឺជាអ្នកនិពន្ធ ហើយខ្ញុំគ្រាន់តែជាអ្នកទទួលខុសត្រូវចុះផ្សាយប៉ុណ្ណោះ។
- ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធ័រនែត បើនៅក្នុងប្រទេសកម្ពុជា គឺមានដូចជា Online, CityLink, Angkornet, Camnet ...

ទាក់ទងនឹងបណ្តាញទំនាក់ទំនងសង្គមវិញ ឧទាហរណ៍ ដូចជា៖

- Facebook គឺត្រូវចាត់ទុកដូចជាអ្នកផ្តល់សេវាកម្មវិបសៃត៍ (Héberbeur/Host) ឯម្ចាស់ទំព័រហ្វេសប៊ុក គឺជាអ្នកទទួលខុសត្រូវចុះផ្សាយ
- Youtube ក៏ដូចគ្នា គឺត្រូវចាត់ទុកដូចជាអ្នកផ្តល់សេវាកម្មវិបសៃត៍ (Héberbeur/Host) ឯអ្នកដែលបង្កើត Account នៅលើ Youtube គឺជាអ្នកទទួលខុសត្រូវចុះផ្សាយ។

ទាក់ទងទៅនឹងការទទួលខុសត្រូវលើខ្លឹមសារ ដែលចុះផ្សាយនៅលើវិបសៃត៍ Blog ឬបណ្តាញទំនាក់ទំនងសង្គមទាំងអស់នេះ ដោយសារតែច្បាប់ខ្មែរនៅមានចំណុចខ្វះចន្លោះច្រើនទាក់ទងនឹងបញ្ហានេះ ខ្ញុំសូមធ្វើការពន្យល់ ដោយយោងទៅលើច្បាប់នៅប្រទេសបារាំង។

ច្បាប់បារាំងបានកំណត់នូវគោលការណ៍មួយថា អ្នកទទួលខុសត្រូវចុះផ្សាយ មានន័យថា ម្ចាស់វិបសៃត៍ ឬម្ចាស់ Blog គឺជាអ្នកដែលមានការទទួលខុសត្រូវច្រើនជាងគេ និងមុនគេ ចំពោះខ្លឹមសារ ដែលចុះផ្សាយនៅលើវិបសៃត៍ ឬ Blog របស់ខ្លួន។

ចំពោះអ្នកនិពន្ធ គាត់អាចមានការទទួលខុសត្រូវ ឬក៏អត់ គឺអាស្រ័យទៅលើករណីជាក់ស្តែង។ ជម្មតា អ្នកនិពន្ធត្រូវមានចំណែកទទួលខុសត្រូវជាមួយនឹងម្ចាស់វិបសៃត៍ បើសិនជាគាត់បានសហការជាមួយម្ចាស់វិបសៃត៍ក្នុងការចុះផ្សាយ ឬបានព្រមព្រៀងឲ្យមានការចុះផ្សាយខ្លឹមសារ ដែលគាត់បានបង្កើត។ អ្នកនិពន្ធអាចចៀសផុតពីការទទួលខុសត្រូវ បើសិនជាម្ចាស់វិបសៃត៍យកស្នាដៃរបស់គាត់ទៅចុះផ្សាយ ដោយគ្មានការដឹងឮ គ្មានការព្រមព្រៀង គ្មានការអនុញ្ញាតពីគាត់។ ក្នុងករណីនេះ អ្នកនិពន្ធអាចប្តឹងម្ចាស់វិបសៃត៍វិញផង បើសិនជាចូលក្នុងករណីរំលោភលើសិទ្ធិអ្នកនិពន្ធ។

ចំពោះអ្នកផ្តល់សេវាកម្មវិបសៃត៍ (Hébergeur/Host) និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធ័រនែត ច្បាប់បារាំងកំណត់ជាគោលការណ៍មិនឲ្យជាប់ការទទួលខុសត្រូវ ចំពោះខ្លឹមសារដែលចុះផ្សាយនៅលើប្រព័ន្ធអ៊ីនធ័រនែតទេ ក្នុងហេតុផលថា ទាំងអ្នកផ្តល់សេវាកម្មវិបសៃត៍ និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធ័រនែត មានតួនាទី និងការទទួលខុសត្រូវ តែទៅលើផ្នែកបច្ចេកទេសប៉ុណ្ណោះ មិនមានតួនាទីត្រួតពិនិត្យមើលខ្លឹមសារ ដែលចុះផ្សាយនៅលើវិបសៃត៍ ដែលប្រើសេវាកម្មរបស់គាត់ទេ។

ក៏ប៉ុន្តែ គោលការណ៍មិនទទួលខុសត្រូវនេះ អាចមានករណីលើកលែង គឺក្នុងករណីដែលអ្នកផ្តល់សេវាកម្មវិបសៃត៍ ឬក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធ័រនែតបានដឹងថា មានអត្ថបទ រូបភាព ឬអ្វីផ្សេងទៀត ដែលមានខ្លឹមសារមិនស្របច្បាប់ (មានអត្ថន័យបរិហាកេរ្តិ៍ រំលោភលើសិទ្ធិបុគ្គល ឬរំលោភលើកម្មសិទ្ធិបញ្ញា ជាដើម) ត្រូវបានចុះផ្សាយនៅលើវិបសៃត៍ ដែលប្រើសេវាកម្មរបស់ខ្លួន ក៏ប៉ុន្តែ មិនបានប្រញាប់ប្រញាល់បិទខ្ទប់លែងឲ្យសាធារណជនចូលទៅមើលវិបសៃត៍ដែលមានចុះផ្សាយខ្លឹមសារខុសច្បាប់ទាំងនេះ។

នៅក្នុងការអនុវត្តជាក់ស្តែង តុលាការបារាំងបានកំណត់ថា នៅពេលណាដែលមានការជូនដំណឹងអំពីការចុះផ្សាយដោយមិនស្របច្បាប់ណាមួយនៅលើវិបសៃត៍ដែលស្ថិតក្នុងបណ្តាញអ៊ីនធ័រនែតរបស់ខ្លួន អ្នកផ្តល់សេវាកម្មវិបសៃត៍ ឬក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធ័រនែត ត្រូវតែបិទវិបសៃត៍នេះភ្លាម ហើយ "ភ្លាម" ក្នុងន័យនេះ គឺមានន័យថា ទទួលបានដំណឹងថ្ងៃណា ត្រូវបិទនៅថ្ងៃនោះ មិនមែនចាំ ពីរ-បីថ្ងៃ បានបិទទេ។

**២.តើអ្នកដែលគ្រាន់តែយកខ្លឹមសារដែលបានចុះផ្សាយរួចហើយ ទៅចុះផ្សាយបន្ត ត្រូវទទួលខុសត្រូវលើខ្លឹមសារនេះដែរឬទេ?**

បើសិនជាអត្ថបទ ឬរូបភាព ដែលត្រូវបានចុះផ្សាយរួចហើយនេះ ជាអត្ថបទ ឬរូបភាព ដែលមានអត្ថន័យបរិហាកេរ្តិ៍ ជេរប្រមាថ ឬរំលោភលើសិទ្ធិឯកជនរបស់អ្នកដទៃ អ្នកដែលយកទៅចុះផ្សាយបន្ត ក៏អាចមានការទទួលខុសត្រូវដែរ។ ជនរងគ្រោះអាចប្តឹងទាមទារឲ្យអ្នកចុះផ្សាយបន្តនេះ បញ្ឈប់ការចុះផ្សាយ ហើយអាចទាមទារសំណងជំងឺចិត្តបាន។

ដូច្នេះ អ្នកប្រើប្រាស់អ៊ីនធ័រនែតត្រូវតែប្រយ័ត្នប្រយែង ពិនិត្យមើលឲ្យបានហ្មត់ចត់ មុននឹងយកអត្ថបទ ឬរូបភាពណាមួយទៅចុះផ្សាយបន្ត។ ជាពិសេស អ្នកប្រើ Tweeter! នៅលើ Tweeter មានប៊ូតុងមួយ សម្រាប់ Tweet បន្តនូវអ្វី ដែលអ្នកផ្សេងបាន Tweet រួចហើយ ដែលហៅថា "Retweet"។ ដូច្នេះ ចង់ Tweet របស់គេបន្ត ស្រួលណាស់ ហើយមើលទៅ

សាមញ្ញបំផុត ដូចជាអត់មានបញ្ហាអ្វីទាំងអស់។ ក៏ប៉ុន្តែ សូមកុំភ្លេចថា Retweet នេះ គឺជាការចុះផ្សាយបន្ត។ ដូច្នេះ មុននឹងចុច Retweet ត្រូវពិនិត្យ ពិចារណាឲ្យបានច្បាស់ បើសិនជា Tweet ដើម មានខ្លឹមសារបរិហាកេរ្តិ៍ ជេរប្រមាថ ឬរំលោភលើសិទ្ធិឯកជនរបស់អ្នកដទៃ ការ Tweet បន្ត អាចនឹងនាំឲ្យមានការទទួលខុសត្រូវលើខ្លឹមសារខុសច្បាប់នេះដែរ។

# ផ្នែកទី៣៦

# ករណីលក់អចលនវត្ថុដែលជាប់សិទ្ធិហ៊ីប៉ូតែកមិនទាន់ជម្រះ

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា នឹងពន្យល់បន្ថែម ជុំវិញការបង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុល។ នៅក្នុងការបង្កើតហ៊ីប៉ូតែក កូនបំណុលមិនចាំបាច់ផ្ទេរអចលនទ្រព្យទៅឲ្យម្ចាស់បំណុលកាន់កាប់ទេ ហើយប័ណ្ណកម្មសិទ្ធិក៏មិនចាំបាច់ប្រគល់ទៅឲ្យម្ចាស់បំណុលដែរ។ សំណួរចោទឡើងថាចុះបើកូនបំណុលយកអចលនទ្រព្យនេះទៅបង្កើតហ៊ីប៉ូតែក ដើម្បីជានាបំណុលថ្មីទៀត ឬក៏យកអចលនទ្រព្យទៅលក់ឲ្យអ្នកដទៃ តើនឹងមានអ្វីកើតឡើង?

**១.បើកូនបំណុលដែលបានបង្កើតហ៊ីប៉ូតែកលើទ្រព្យរបស់ខ្លួនហើយ ប៉ុន្តែនៅមានទាំងទ្រព្យ និងទាំងប័ណ្ណកម្មសិទ្ធិនៅក្នុងដៃ ហើយក៏យកទ្រព្យនេះទៅដាក់ហ៊ីប៉ូតែក ដើម្បីខ្ចីបំណុលថ្មីៗបន្ថែមទៀត តើនឹងមានអ្វីកើតឡើង?**

តាមការពិត អចលនទ្រព្យតែមួយ អាចត្រូវបង្កើតជាហ៊ីប៉ូតែក ដើម្បីធានាបំណុលច្រើនបាន មិនមែនជារឿងខុសច្បាប់ទេ។ ក្រមរដ្ឋប្បវេណីខ្មែរ មានទាំងចែងច្បាស់ អំពីករណីហ៊ីប៉ូតែកលើអចលនវត្ថុតែមួយ ដើម្បីធានាបំណុលច្រើននេះ គឺចែងក្នុងមាត្រា **៨៥១** ស្តីពីលំដាប់នៃហ៊ីប៉ូតែក។ ក្នុងករណីនេះ ម្ចាស់បំណុលមុនត្រូវមានអាទិភាពហ៊ីប៉ូតែកខ្ពស់ជាងម្ចាស់បំណុលក្រោយ មានន័យថា នៅពេលអនុវត្តហ៊ីប៉ូតែក លុយដែលបានពីការលក់អចលនទ្រព្យជាប់ហ៊ីប៉ូតែកនេះ គេត្រូវយកទៅសងម្ចាស់បំណុលមុន រួចហើយនៅសល់ប៉ុន្មានទើបយកទៅសងម្ចាស់បំណុលក្រោយ។ មានគ្រប់សង ឬមិនគ្រប់ គឺម្ចាស់បំណុលក្រោយជាអ្នករងហានិភ័យ។

***ឧទាហរណ៍៖*** កូនបំណុលម្នាក់ មានផ្ទះមួយល្វែង យកទៅដាក់ហ៊ីប៉ូតែក ដើម្បីធានាបំណុល ៧ម៉ឺនដុល្លារ ដែលខ្ចីពីធនាគារ ឈ្មោះ “ក”។ បន្ទាប់មកទៀត កូនបំណុលនេះក៏ទៅខ្ចីបំណុលថ្មីមួយទៀតពីធនាគារ “ខ” ក្នុងទឹកប្រាក់ ៣ម៉ឺនដុល្លារ ដោយយកផ្ទះដដែលទៅដាក់ហ៊ីប៉ូតែកធានា។ ប្រសិនបើកូនបំណុលអត់មានលុយសង ម្ចាស់បំណុលត្រូវទាមទារឲ្យលក់ផ្ទះជាប់ហ៊ីប៉ូតែកនេះ ដើម្បីសងបំណុល។ ក៏ប៉ុន្តែ បើសិនជាផ្ទះនេះលក់ទៅបានតែ ៩ម៉ឺនដុល្លារ គេត្រូវយក ៧ម៉ឺនដុល្លារទៅសងធនាគារ “ក” ជាមុន។ នៅសល់ ២ម៉ឺនដុល្លារ ទើបយកទៅសងធនាគារ “ខ”។ ចំពោះ បំណុល ១ម៉ឺន ដែលនៅសេសសល់ធនាគារ “ខ” អាចទាមទារឲ្យប្រមែប្រមូលទ្រព្យផ្សេងទៀតមកលក់ ដើម្បីបង្គ្រប់។ បើកូនបំណុលអត់មានលុយ ឬក៏ទ្រព្យអ្វីផ្សេងទៀតទេ គឺមានន័យថា ធនាគារ “ខ” នឹងមិនអាចទទួលបានសំណងគ្រប់ចំនួនទេ គឺអាចនឹងត្រូវខាតបង់ ១ម៉ឺនដុល្លារនេះ។

ហេតុដូច្នេះហើយបានជាច្បាប់តម្រូវឲ្យការបង្កើតហ៊ីប៉ូតែក ត្រូវធ្វើជាលិខិតយថាភូត និងត្រូវចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីដីធ្លី ដើម្បីជាព័ត៌មានឲ្យអ្នកផ្សេងទៀតបានដឹង។ ក្នុងករណីម្ចាស់ទ្រព្យចង់បង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុលថ្មីទៀត ម្ចាស់បំណុលថ្មីនេះអាចដឹងថា អចលនទ្រព្យនេះមានជាប់ហ៊ីប៉ូតែករួចហើយ ជាប់ដើម្បីធានាបំណុលទំហំប៉ុន្មាន តម្លៃអចលនទ្រព្យនេះអាចសល់គ្រប់គ្រាន់ ដើម្បីធានាបំណុលក្រោយបានដែរ ឬអត់?

កាលបរិច្ឆេទនៃការចុះបញ្ជីហ៊ីប៉ូតែកនេះហើយ ដែលត្រូវកំណត់លំដាប់អាទិភាពនៃហ៊ីប៉ូតែក៖ ហ៊ីប៉ូតែកដែលចុះបញ្ជីមុនត្រូវមានលំដាប់អាទិភាពក្នុងការទទួលសំណងមុន ហ៊ីប៉ុតែកដែលចុះបញ្ជីក្រោយ។

ក្នុងករណីហ៊ីប៉ូតែកបង្កើតឡើងដោយការព្រមព្រៀងត្រឹមតែរវាងម្ចាស់បំណុល និងកូនបំណុល ហើយមិនមានធ្វើលិខិតយថាភូត (មានន័យថា មិនមានការចុះហត្ថលេខា និងប្រថាប់ត្រាដោយសាការី ឬក្នុងទម្រង់បែបបទផ្សេងទៀតដែលកំណត់ដោយច្បាប់) និងមិនបានធ្វើការចុះបញ្ជីត្រឹមត្រូវទេ ហ៊ីប៉ូតែកនេះមានអានុភាពតែរវាងម្ចាស់បំណុល និងកូនបំណុលប៉ុណ្ណោះ ដោយមិនអាចយកទៅតតាំងជាមួយនឹងតតិយជន (អ្នកផ្សេង) បានឡើយ។

ក្នុងន័យនេះ បើម្ចាស់បំណុលមុន បានធ្វើហ៊ីប៉ូតែកដែរ ប៉ុន្តែ មិនបានធ្វើតាមលិខិតយថាភូត និងមិនបានចុះបញ្ជី ចំណែកម្ចាស់បំណុលក្រោយបានចុះបញ្ជីហ៊ីប៉ូតែករបស់ខ្លួនត្រឹមត្រូវ គឺម្ចាស់បំណុលក្រោយនេះ ដែលត្រូវមានអាទិភាពទទួលសំណងពីការលក់ទ្រព្យ។

**២.តើកូនបំណុលអាចលក់ទ្រព្យដែលកំពុងជាប់ហ៊ីប៉ូតែកបានដែរ ឬទេ?**

ទ្រព្យ ដែលកូនបំណុលយកទៅដាក់ហ៊ីប៉ូតែក ដើម្បីជានាបំណុល នៅតែស្ថិតជាកម្មសិទ្ធិផ្តាច់មុខរបស់កូនបំណុលដដែល។ ដូច្នេះ កូនបំណុលមានសិទ្ធិចាត់ចែងទ្រព្យនេះបាន ក្នុងឋានៈជាម្ចាស់កម្មសិទ្ធិ ដូចជា អាចយកទៅជួលយកទៅលក់ ឬធ្វើជាអំណោយ ជាដើម។

ក៏ប៉ុន្តែ ការលក់ទ្រព្យដែលជាប់ហ៊ីប៉ូតែកនេះ មិនធ្វើឲ្យរលត់សិទ្ធិលើហ៊ីប៉ូតែកនោះទេ។ ម្ចាស់បំណុល ដែលមានការជានាដោយហ៊ីប៉ូតែក ហើយហ៊ីប៉ូតែកនេះត្រូវបានបង្កើតឡើងដោយលិខិតយថាភូត និងបានចុះបញ្ជីក្នុងសៀវភៅដីធ្លីត្រឹមត្រូវ នៅតែអាចទាមទារឲ្យរឹបអូសទ្រព្យនេះមកលក់សងបំណុលរបស់ខ្លួនបាន បើទោះជាទ្រព្យនេះត្រូវបានលក់ទៅឲ្យជនទីពណាមួយផ្សេងទៀតហើយក៏ដោយ។ អ្នកទិញ ត្រូវតែរ៉ាប់រងហានិភ័យនេះ ពីព្រោះខ្លួនត្រូវតែដឹងថា អចលនទ្រព្យនេះមានជាប់ហ៊ីប៉ូតែក។ អ្នកទិញមិនអាចឆ្លើយដោះសារថាមិនដឹងបានទេ ព្រោះហ៊ីប៉ូតែកនេះមានចុះបញ្ជីក្នុងសៀវភៅដីធ្លីច្បាស់លាស់។ នេះហើយ ដែលគេហៅថា លក្ខខណ្ឌតតាំងនឹងតតិយជននៃហ៊ីប៉ូតែកដែលបានចុះបញ្ជី។

តាមពិតបើតាមការអនុវត្តជាក់ស្តែង នៅក្នុងប្រទេសបារាំង ទាំងការបង្កើតហ៊ីប៉ូតែក និងការទិញលក់អចលនវត្ថុ គឺធ្វើដោយឆ្លងកាត់សាការី (Notaire)។ សាការី គេអាចមើលបញ្ជីដីធ្លីនៅទូទាំងប្រទេស ដែលអាចដឹងច្បាស់ថា អចលនទ្រព្យណាមានជាប់ហ៊ីប៉ូតែក ហើយជាប់ក្នុងទំហំបំណុលសរុបប៉ុន្មាន។

នៅពេលមានការទិញលក់អចលនទ្រព្យដែលជាប់ហ៊ីប៉ូតែក បើសិនមើលទៅឃើញថា ថ្លៃលក់ទាបជាងបំណុលសរុប ដែលជាប់ហ៊ីប៉ូតែក (មានន័យថា លុយដែលបានពីការលក់ទ្រព្យមិនគ្រប់គ្រាន់ក្នុងការសងបំណុល) សាការីនឹងមិនប្រថាប់ត្រាលក់ឲ្យទេ គឺទាមទារឲ្យម្ចាស់ទ្រព្យជម្រះហ៊ីប៉ូតែកឲ្យជ្រះស្រឡះសិនទើបអាចលក់បាន។

ផ្ទុយទៅវិញ បើសិនជាថ្លៃលក់ខ្ពស់ជាងបំណុលសរុប ដែលជាប់ហ៊ីប៉ូតែក (មានន័យថា លុយដែលបានពីការលក់ទ្រព្យអាចយកទៅសងបំណុលគ្រប់ចំនួនបាន) សាការីអាចប្រថាប់ត្រាលក់ទ្រព្យនេះបាន ក៏ប៉ុន្តែ មុននឹងធ្វើការទូទាត់ថ្លៃលក់រវាងអ្នកទិញ និងម្ចាស់ទ្រព្យ សាការីនឹងជូនដំណឹងទៅម្ចាស់បំណុលដែលពាក់ព័ន្ធនឹងហ៊ីប៉ូតែកទាំងអស់ឲ្យបានដឹងពីការលក់នេះ ដើម្បីធ្វើការទូទាត់បំណុលឲ្យជ្រះស្រឡះអស់សិន ទើបប្រគល់លុយដែលនៅសេសសល់ទៅឲ្យម្ចាស់ទ្រព្យ ដែលជាកូនបំណុល។

# ផ្នែកទី៣៧

# ការទិញ/លក់អចលនវត្ថុ តើត្រូវធ្វើយ៉ាងណា ដើម្បីជៀសវាងវិវាទ

*<u>បកស្រាយដោយលោកមេធាវី ប៊ុន យូឌី</u>*

ដោយ <u>សេង ឌីណា</u>

នៅក្នុងនាទីស្វែងយល់អំពីច្បាប់ ថ្ងៃនេះយើងសិក្សាមើលថា តើគេត្រូវធ្វើដូចម្ដេច ដើម្បីជៀសវាងកុំឲ្យទិញប៉ះចំដីដែលមានជាប់បញ្ហា? តើត្រូវធ្វើដូចម្ដេច ដើម្បីឲ្យកិច្ចសន្យាទិញ/លក់ដី មានសុពលភាពពេញលេញតាមផ្លូវច្បាប់ ដែលមិនមានអ្នកណាអាចមកតវ៉ាជំទាស់បានទៅថ្ងៃក្រោយ?

ជាការពិតថា បញ្ហាទាំងនេះអាចមានលក្ខណៈស្មុគស្មាញ ដែលពេលខ្លះ គេចាំបាច់ត្រូវស្វែងរកអ្នកច្បាប់ ឬក៏មេធាវីជាជំនួយ ដើម្បីធានាឲ្យមានសុវត្ថិភាពខាងផ្លូវច្បាប់។ ក៏ប៉ុន្តែ លោកមេធាវី ប៊ុន យូឌី (មកពីការិយាល័យមេធាវីឈ្មោះ ប៊ុន និង សហការី) នឹងពន្យល់បំភ្លឺជុំវិញចំណុចសំខាន់ៗជាមូលដ្ឋានខ្លះ ដែលប្រជាពលរដ្ឋគួរតែដឹង។

នៅប្រទេសកម្ពុជា ការចុះបញ្ជីដីធ្លី នៅមានការខ្វះចន្លោះច្រើន។ មានអ្នកខ្លះកាន់កាប់ដីធ្លី ដោយគ្មានប័ណ្ណកម្មសិទ្ធិ។ ខ្លះក៏កាន់កាប់ដោយស្របច្បាប់ ខ្លះក៏មិនស្របច្បាប់។ ភាពស្រពិចស្រពិលទាំងនេះ អាចបង្កឲ្យមានវិវាទនៅក្នុងករណីមានការទិញ/លក់។ ដើម្បីជៀសវាងទិញប៉ះចំដី ដែលជាប់មានបញ្ហាចម្រូងចម្រាស់អ្នកទិញត្រូវតែមានការប្រយ័ត្នប្រយែង ពិនិត្យមើលឲ្យបានគ្រប់ជ្រុងជ្រោយមុននឹងឈានទៅចុះកិច្ចសន្យា។

**១.មុននឹងឈានទៅចុះកិច្ចសន្យា តើគេត្រូវពិនិត្យមើលចំណុចណាខ្លះ ដើម្បីជៀសវាងមានវិវាទទៅថ្ងៃក្រោយ?**

គេត្រូវពិនិត្យមើលចំណុចសំខាន់ៗ ចំនួន ៤៖

**-ប្រភេទនៃប័ណ្ណកាន់កាប់របស់ម្ចាស់ដី**

អ្នកទិញគួរពិនិត្យមើលថា តើអ្នកលក់មានប័ណ្ណកាន់កាប់ប្រភេទណា? តើជា "វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ" (ឬហៅតាមភាសាសាមញ្ញថា "ប្លង់រឹង") ក៏ជា "វិញ្ញាបនប័ត្រសម្គាល់ការកាន់កាប់អចលនវត្ថុ" (ប្លង់ទន់)?

ប្រសិនបើអ្នកលក់មានប្លង់រឹង មានន័យថា គាត់គឺជាកម្មសិទ្ធិករពេញសិទ្ធិលើដីរបស់គាត់។ ក្នុងករណីនេះ គេអាចមានការទុកចិត្តច្រើនជាង ពីព្រោះថា នៅលើប្លង់រឹងនេះ គេអាចមើលឃើញអំពីទំហំ និងទីតាំងរបស់ដី និងឈ្មោះរបស់ម្ចាស់ដី។ ម្យ៉ាងទៀត គេមានការងាយស្រួលក្នុងការផ្ទៀងផ្ទាត់ប័ណ្ណប្រភេទនេះ ជាមួយនឹងបញ្ជីដែលចុះនៅអាជ្ញាធរសុរិយោដី។

ផ្ទុយទៅវិញ ប្រសិនបើអ្នកលក់មានត្រឹមតែប្លង់ទន់ មានន័យថា គាត់គ្រាន់តែជាភោគី (អ្នកកាន់កាប់ស្របច្បាប់) ប៉ុណ្ណោះ។ គាត់មិនទាន់ជាម្ចាស់កម្មសិទ្ធិពេញលេញនៅឡើយទេ។ តាមច្បាប់ ភោគី ក៏មានសិទ្ធិលក់ដីរបស់គាត់ដែរ។ ក៏ប៉ុន្តែ អ្នកទិញគួរមានការប្រយ័ត្នប្រយែងខ្ពស់ក្នុងការទិញដីប្រភេទនេះ។

ចំណុចដែលត្រូវពិនិត្យមើល គឺអំពីប្រវត្តិរបស់ដីនេះ។ ត្រូវមើលថា តើដីនេះបានផ្ទេរជាដំណាតៗគ្នាប៉ុន្មានដំណាក់មក ហើយៗក្នុងដំណាក់នីមួយៗ តើមានបានធ្វើការផ្ទេរ ដោយគោរពទៅតាមនីតិវិធីកំណត់ដោយច្បាប់ដែរ ឬទេ។ ការផ្ទៀងផ្ទាត់បែបនេះដើម្បីឲ្យប្រាកដថា ប្លង់ទន់ ដែលអ្នកលក់កំពុងមានក្នុងដៃនេះ បានធ្វើឡើងដោយស្របច្បាប់ ហើយម្ចាស់ដីក៏កាន់កាប់ដោយស្របច្បាប់ ជៀសវាងដីមានម្ចាស់ពីរ-បីមកឈ្លោះដណ្ដើមគ្នាទៅថ្ងៃក្រោយ។

**-ស្ថានភាពដី**

ក្រោយពីបានពិនិត្យឃើញច្បាស់លាស់ អំពីប្រភេទនៃឯកសារកាន់កាប់ដីធ្លីនេះហើយ បើទោះជាដីនោះជាដីភោគៈ ឬក៏ជាដីកម្មសិទ្ធិក៏ដោយ អ្នកទិញគួរតែពិនិត្យមើលអំពីស្ថានភាពជុំវិញដីនោះ។ ត្រូវមើលថា តើនៅជុំវិញនោះ មានដីផ្សេងទៀតដែរ ឬទេ? តើមានរបង ឬព្រំដីកំណត់ច្បាស់លាស់ដែរ ឬទេ។

ប្រសិនបើមើលទៅឃើញថា ព្រំដីនៅមិនទាន់កំណត់បានច្បាស់លាស់ គេត្រូវធ្វើការវាស់វែងកំណត់ព្រំដី មុននឹងចុះកិច្ចសន្យា។ ការវាស់វែងកំណត់ព្រំដីនេះ ត្រូវតែធ្វើឡើងដោយមានវត្តមានអាជ្ញាធរសុរិយោដី ជាអ្នកដឹងឮ។

ទាំងនេះ គឺដើម្បីជៀសវាងជម្លោះជាមួយអ្នកជិតខាង ក្រោយពីទិញដីនេះបានហើយ។

**-បន្ទុកនៅលើដី**

គេត្រូវពិនិត្យមើលថា តើដីនេះត្រូវបានយកទៅដាក់បញ្ចាំជានាបំណុល ឬជួល ឬប្រវាស់ ដែរឬទេ? តើដីនេះមានជាប់ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់តុលាការ ដែលហាមមិនឲ្យលក់ ឬក៏ជាកម្មវត្ថុ ដែលត្រូវតុលាការរឹបអូស ដែរ ឬទេ?

ប្រសិនបើមានគេត្រូវតែដោះបន្ទុកនេះឲ្យជ្រះស្រឡះជាមុនសិន មុននឹងចុះកិច្ចសន្យាទិញ។

**-ដីជាចំណែកផ្លូវ**

ដោយពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងអភិវឌ្ឍ ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធ មុននឹងទិញដីណាមួយ អ្នកទិញគួរពិនិត្យមើលថា តើដីនេះមានជាប់ជាចំណែកផ្លូវ ឬក៏ត្រូវចំកន្លែង ដែលជាគម្រោងអភិវឌ្ឍរបស់រដ្ឋាភិបាលដែរ ឬទេ។ បើសិនជាមែន តើមានការប៉ះពាល់ត្រឹមកម្រិតណា?

**២.តើកិច្ចសន្យាទិញ/លក់អចលនវត្ថុត្រូវធ្វើឡើងក្នុងទម្រង់បែបណា ដើម្បីឲ្យមានសុពលភាពពេញលេញតាមផ្លូវច្បាប់?**

គេត្រូវពិនិត្យជាបឋមថា តើអ្នកចុះកិច្ចសន្យានេះ មានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះដែរ ឬទេ? គេត្រូវមើលត្រង់ចំណុចពីរៈ តើអ្នកចុះកិច្ចសន្យានេះជារូបវន្តបុគ្គល ឬក៏ជានីតិបុគ្គល (ក្រុមហ៊ុន ឬអង្គការ)?

ប្រសិនបើជារូបវន្តបុគ្គល គេត្រូវពិនិត្យមើលថា តើដីដែលគាត់លក់នេះ ជាទ្រព្យឯកជនរបស់គាត់ ឬក៏ជាទ្រព្យរួមដែលមានម្ចាស់ផ្សេងទៀត។ ប្រសិនបើជាទ្រព្យរួម គាត់មិនអាចចុះកិច្ចសន្យាលក់តែឯងបានទេ គឺត្រូវតែមានការព្រមព្រៀងលក់ពីសំណាក់ម្ចាស់ផ្សេងទៀត។

ប្រសិនបើជានីតិបុគ្គល គេត្រូវពិនិត្យមើលថា តើអ្នកមកចុះកិច្ចសន្យា បានទទួលសិទ្ធិត្រឹមត្រូវពីក្រុមប្រឹក្សាភិបាល (អង្គការ) ឬក៏ម្ចាស់ភាគហ៊ុន (ក្រុមហ៊ុន) ដែរទេ?

សម្រាប់អ្នកលក់ គឺត្រូវពិនិត្យមើលថា តើអ្នកទិញមានសញ្ជាតិខ្មែរដែរឬទេ? ពីព្រោះថា តាមច្បាប់កម្ពុជា ជនបរទេសមិនអាចធ្វើជាម្ចាស់កម្មសិទ្ធិលើដីបានទេ។

បើសិនជាពិនិត្យទៅឃើញថា គូភាគីពិតជាមានសិទ្ធិចុះកិច្ចសន្យាហើយ គេត្រូវនិយាយពីទម្រង់នៃកិច្ចសន្យាម្តង។ ការទិញដូរអចលនវត្ថុ គឺជាកិច្ចសន្យា ដែលមានលក្ខណៈពិសេស។ គូភាគីមិនអាចចុះហត្ថលេខាតាមទម្រង់ជាលិខិតឯកជនបាននោះទេ។ ដើម្បីឲ្យកិច្ចសន្យាមានសុពលភាពពេញលេញតាមផ្លូវច្បាប់ កិច្ចសន្យាទិញដូរអចលនវត្ថុត្រូវតែធ្វើឡើងក្នុងទម្រង់ជាលិខិតយថា ភូត ដោយគោរពតាមទម្រង់ និងនីតិវិធី ដែលកំណត់ដោយច្បាប់ ពោលគឺកិច្ចសន្យាត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានការទទួលដឹងឮពីអាជ្ញាធរមានសមត្ថកិច្ច។

**ក.ដីកម្មសិទ្ធិ (ប្លង់រឹង)**

ប្រសិនបើការទិញដូរនេះធ្វើឡើងលើដីកម្មសិទ្ធិ មានន័យថា អ្នកលក់គឺជាកម្មសិទ្ធិករកាន់ "ប្លង់រឹង" ការចុះកិច្ចសន្យាត្រូវធ្វើឡើងតាមទម្រង់បែបបទ ដែលដាក់ឲ្យប្រើដោយក្រសួងសុរិយោដី ដែលគេហៅថា "លិខិតលក់ផ្តាច់"។

អ្នកទិញ និងអ្នកលក់ ដោយច្បាប់តម្រូវឲ្យមានសាក្សីម្នាក់១ផងនោះ ត្រូវផ្ដិតមេដៃលើលិខិតលក់ ដោយមានការដឹងឮពីអាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក/ខណ្ឌ។

បន្ទាប់មក គេត្រូវយកកិច្ចសន្យានេះ ទៅអាជ្ញាធរសុរិយោដី ដើម្បីធ្វើការចុះបញ្ជីផ្ទេរសិទ្ធិ (កាត់ឈ្មោះ)។

ដំបូងភាគីទាំងពីរត្រូវយកកិច្ចសន្យាលក់ ទៅឲ្យការិយាល័យសុរិយោដីស្រុក/ខណ្ឌ ដើម្បីពិនិត្យមើលថា តើកិច្ចសន្យានេះពិតជាបានចុះត្រឹមត្រូវតាមនីតិវិធីដែរ ឬទេ។ បើសិនជាការិយាល័យសុរិយោដីស្រុក/ខណ្ឌ ពិនិត្យមើលឃើញថា ត្រឹមត្រូវហើយ គេនឹងបញ្ជូនសំណុំរឿងនេះទៅមន្ទីរសុរិយោដីខេត្ត/ក្រុង ជាអ្នកពិនិត្យមើលចុងក្រោយ មុននឹងធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

មុននឹងមន្ទីរសុរិយោដី ចុះបញ្ជីផ្ទេរសិទ្ធិ អ្នកទិញត្រូវទៅបង់ពន្ធជាមុនសិន (៤%នៃតម្លៃដី)។ បន្ទាប់ពីបានបង្ហាន់ដៃពន្ធហើយ ទើបមន្ទីរសុរិយោដី ចារលើប្លង់ដីនេះថា អ្នកទិញនឹងក្លាយទៅជាម្ចាស់ដី ចាប់ពីពេលនេះតទៅ។

**ខ. ដីភោគ: (ប្លង់ទន់)**

សម្រាប់ ដីភោគ: (ឬដីប្លង់ទន់) មិនមាននីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅអាជ្ញាធរសុរិយោដីទេ ពីព្រោះថា ដីនេះមិនទាន់ជាដីកម្មសិទ្ធិ ដូច្នេះ មិនទាន់មានចុះនៅក្នុងបញ្ជីរដ្ឋបាលដីធ្លីនៃអាជ្ញាធរសុរិយោដីនៅឡើយទេ។

កិច្ចសន្យាទិញ/លក់ដីប្រភេទនេះ ច្បាប់តម្រូវឲ្យមានការចុះ ដោយមានការដឹងឮត្រឹមអាជ្ញាធរដែនដីប៉ុណ្ណោះ ដោយមិនចាំបាច់ទៅដល់អាជ្ញាធរសុរិយោដីទេ។

នៅក្នុងការអនុវត្តជាក់ស្ដែង នៅកន្លែងខ្លះកិច្ចសន្យាលក់ដីភោគ:គេធ្វើដោយមានការដឹងឮតែពីអាជ្ញាធរឃុំ/សង្កាត់ប៉ុណ្ណោះ។ ក៏ប៉ុន្តែ នៅកន្លែងខ្លះទៀត គេធ្វើនៅឃុំ/សង្កាត់ហើយ គេទៅឲ្យអាជ្ញាធរស្រុក/ខណ្ឌជួយដឹងឮមួយដំណាក់ទៀត។ ការដឹងឮពីសំណាក់អាជ្ញាធរថ្នាក់កាន់តែខ្ពស់ គឺកាន់តែមានសុវត្ថិភាព។

# ផ្នែកទី៣៨

# ស្វែងយល់អំពីកិច្ចសន្យាទិញលក់ក្នុងក្រមរដ្ឋប្បវេណីខ្មែរ

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងអំពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា សូមធ្វើការពន្យល់ជុំវិញ កិច្ចសន្យាទិញលក់ ដែលមានចែង នៅក្នុងក្រមរដ្ឋប្បវេណីខ្មែរ។ កិច្ចសន្យាទិញលក់ ជាកិច្ចសន្យាដែលគេតែងតែជួបប្រទះយ៉ាងញឹកញាប់បំផុត នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ហើយដែលគ្រប់គ្នាគួរតែស្វែងយល់អំពីសិទ្ធិ និងករណីយកិច្ចរបស់គូភាគីនៃកិច្ចសន្យានេះ។

**១.តើអ្វីទៅជាកិច្ចសន្យាទិញលក់?**

តាមនិយមន័យ ដែលមានចែងក្នុងមាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាទិញលក់ គឺជាកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា "អ្នកលក់" មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិលើវត្ថុណាមួយទៅឲ្យភាគីម្ខាងទៀតហៅថា "អ្នកទិញ" ហើយអ្នកទិញនេះមានករណីយកិច្ចទូទាត់លុយជាថ្លៃវត្ថុនោះទៅឲ្យអ្នកលក់។

បើមើលទៅលើនិយមន័យនេះ យើងឃើញថា កិច្ចសន្យាទិញលក់ គឺជាកិច្ចសន្យា ដែលយើងធ្វើញឹកញាប់ជាងគេនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ពេលខ្លះយើងក៏ចាប់អារម្មណ៍ដឹងថា វាជាកិច្ចសន្យាទិញលក់ ដូចជា ការទិញលក់ដីធ្លី ផ្ទះ ជាដើម។ ពេលខ្លះក៏យើងធ្វើកិច្ចសន្យាទិញលក់ ដោយមិនចាប់អារម្មណ៍ដឹងខ្លួនថា កំពុងតែចុះកិច្ចសន្យាទិញលក់ ដូចជាពេលយើងទៅផ្សារទិញខោអាវ ទិញសាច់ត្រី បន្លែ ឬក៏ទៅទិញគ្រឿងទេស(ប៊ីចេង អំបិល ស្ករ)គឺសុទ្ធសឹងជាកិច្ចសន្យាទិញលក់។

**២.ក៏ប៉ុន្តែ នៅក្នុងការទិញលក់ ដូចដែលរៀបរាប់ខាងក្រោយនេះ យើងមិនដែលមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរទេ គឺធ្វើឡើងត្រឹមតែផ្ទាល់មាត់ទទេ។ តើវាជាកិច្ចសន្យាទិញលក់ ដែលមានសុពលភាពតាមផ្លូវច្បាប់ដែរ ឬទេ?**

កិច្ចសន្យាទិញលក់ជាទូទៅ ច្បាប់មិនតម្រូវថាត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរទេ(មាត្រា៥១៦នៃក្រមរដ្ឋប្បវេណី) លើកលែងតែករណីដែលមានបញ្ញត្តិពិសេសណាមួយ (ឧទាហរណ៍ កិច្ចសន្យាទិញលក់ផ្ទះ ឬដីធ្លី ជាដើម)។

ដូច្នេះ ការព្រមព្រៀងទិញលក់ ធ្វើឡើងដោយផ្ទាល់មាត់ គឺជាកិច្ចសន្យាដែលមានសុពលភាពពេញលេញតាមផ្លូវច្បាប់។ ក៏ប៉ុន្តែ គូភាគីនៃកិច្ចសន្យាអាចព្រមព្រៀងគ្នាកំណត់ធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរបាន។ អាចធ្វើត្រឹមតែជាលិខិតឯកជន (កិច្ចសន្យាធ្វើឡើងជាលក្ខណៈឯកជន រវាងអ្នកលក់ និងអ្នកទិញ) ឬអាចធ្វើជាទម្រង់លិខិតយថាភូត (កិច្ចសន្យាដែលតាក់តែង និងមានប្រថាប់ត្រាដោយមន្ត្រីសាធារណៈ)។

ផលប្រយោជន៍នៃការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ(បើទោះបីជាច្បាប់មិនតម្រូវក៏ដោយ) គឺទាក់ទងនឹងភស្តុតាងនៅក្នុងករណីមានវិវាទ។ បើធ្វើត្រឹមតែផ្ទាល់មាត់ កិច្ចសន្យាទិញលក់នេះមានសុពលភាពពេញលេញពិតមែន ក៏ប៉ុន្តែ នៅពេលមានវិវាទការបង្ហាញភស្តុតាងអំពីអ្វីដែលនិយាយគ្នាតែមាត់ទទេ គ្មានលិខិតជាលាយលក្ខណ៍អក្សរ វាអាចនឹងមានបញ្ហាស្មុគស្មាញ។

ណាមួយទៀត ការព្រមព្រៀងគ្នាត្រឹមតែផ្ទាល់មាត់ វាអាចនាំឲ្យមានភាពស្រពិចស្រពិល ការយល់ច្រឡំទៅលើអ្វីដែលបានព្រមព្រៀងគ្នា ឬក៏ការភ្លេចភ្លាំងជាដើម។ បើសរសេរជាលាយលក្ខណ៍អក្សរ វាអាចធ្វើឲ្យគូភាគីយល់ច្បាស់លាស់ជាង អំពីខ្លឹមសារនៃកិច្ចសន្យា។

ដូច្នេះ កិច្ចសន្យាទិញលក់ បើទោះបីជាច្បាប់មិនតម្រូវក៏ដោយ ក៏គូភាគីគួរតែពិចារណារៀបចំធ្វើជាលាយលក្ខណ៍អក្សរដែរ ជាពិសេស ចំពោះកិច្ចសន្យាដែលមានទំហំទឹកប្រាក់ច្រើន ឬក៏មានលក្ខណៈស្មុគស្មាញ អាចនាំឲ្យមានការយល់ច្រឡំ ឬយល់មិនច្បាស់អំពីខ្លឹមសារនៃកិច្ចសន្យា។

**៣.ចុះបើសិនជាការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរនេះ ចាំបាច់ត្រូវរកមេធាវីឲ្យសរសេរឲ្យ តើសោហ៊ុយក្នុងការធ្វើលិខិតស្នាមនេះ ខាងណាជាអ្នកចេញ?**

ក្រមរដ្ឋប្បវេណី (មាត្រា ៥២២) កំណត់ថា សោហ៊ុយធ្វើលិខិត ឬសោហ៊ុយផ្សេងៗទៀតដែលចំណាយក្នុងការធ្វើកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងត្រូវចេញស្មើគ្នា(ពាក់កណ្ដាលម្នាក់)។ ក៏ប៉ុន្តែ បើសិនជាគូភាគីព្រមព្រៀងគ្នាចង់កំណត់ផ្សេងក្រៅពីនេះ ក៏ច្បាប់មិនហាមឃាត់ដែរ។

ត្រង់ចំណុចនេះ យើងសង្កេតឃើញថា ក្រមរដ្ឋប្បវេណីខ្មែរចែងខុសពីច្បាប់បារាំង ព្រោះក្រមរដ្ឋប្បវេណីបារាំងចែងកំណត់ឲ្យអ្នកទិញជាអ្នកទទួលបន្ទុកលើសោហ៊ុយក្នុងការធ្វើលិខិត និងសោហ៊ុយពាក់ព័ន្ធផ្សេងទៀត ក្នុងការធ្វើកិច្ចសន្យាទិញលក់ គឺជាបន្ទុករបស់អ្នកទិញ (មាត្រា ១៥៩៣ ក្រមរដ្ឋប្បវេណីបារាំង)។ ដូចជា នៅក្នុងកិច្ចសន្យាទិញលក់ផ្ទះ អ្នកទិញ គឺជាអ្នកត្រូវទទួលបន្ទុកបង់ថ្លៃធ្វើលិខិតស្នាមផ្ទេរកម្មសិទ្ធិ ដែលត្រូវធ្វើដោយសាការី (Notaire)។

**៤.តើអ្នកទិញ និងអ្នកលក់ត្រូវមានកាតព្វកិច្ចអ្វីខ្លះ?**

**ក. ករណីយកិច្ចរបស់អ្នកទិញ**

ចំពោះអ្នកទិញ កាតព្វកិច្ចមានតិចជាងអ្នកលក់។ កាតព្វកិច្ចធំបំផុតរបស់អ្នកទិញ គឺបង់ថ្លៃទិញទៅតាមកិច្ចសន្យា។ ការបង់ថ្លៃទិញនេះ គឺត្រូវធ្វើទៅតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា។

កាតព្វកិច្ចមួយទៀត គឺកាតព្វកិច្ចទទួលវត្ថុទៅតាមការកំណត់ក្នុងកិច្ចសន្យា។ តាមមាត្រា ៥៥៩ នៃក្រមរដ្ឋប្បវេណី ប្រសិនបើអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួលវត្ថុ អ្នកលក់អាចទាមទារសំណង ប្រសិនបើការយឺតយ៉ាវនេះនាំឲ្យគាត់ទទួលរងនូវការខូចខាតអ្វីមួយ ឬក៏អាចទាមទាររំលាយកិច្ចសន្យាទិញលក់នេះវិញបាន។ ម្យ៉ាងទៀត ប្រសិនបើដល់ថ្ងៃកំណត់ទទួលវត្ថុ ហើយអ្នកទិញមកមិនទទួលទេ អ្នកទិញត្រូវជាអ្នកទទួលបន្ទុកហានិភ័យនៃការបាត់បង់ ឬខូចខាតវត្ថុនេះ។

**ខ. ករណីយកិច្ចរបស់អ្នកលក់**

ចំពោះអ្នកលក់វិញ កាតព្វកិច្ចសំខាន់ទីមួយរបស់គាត់ គឺត្រូវប្រគល់វត្ថុ ឬផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ដែលគាត់បានព្រមព្រៀងលក់ទៅឲ្យអ្នកទិញ (មាត្រា ៥៣០)។ សិទ្ធិលើទ្រព្យ ឬវត្ថុ ដែលត្រូវប្រគល់ទៅឲ្យអ្នកទិញនេះ ត្រូវតែមានបរិមាណ និងគុណភាពដូចអ្វីដែលបានព្រមព្រៀងគ្នា។

ម្យ៉ាងទៀត ប្រសិនបើការប្រគល់វត្ថុ ឬការផ្ទេរសិទ្ធិលើទ្រព្យ ត្រូវធ្វើនៅក្រោយការបង្កើតកិច្ចសន្យាទិញលក់ អ្នកលក់មានករណីយកិច្ចថែរក្សាវត្ថុ ឬទ្រព្យនោះឲ្យបានគង់វង្សល្អ រហូតដល់ពេលប្រគល់ទៅឲ្យអ្នកទិញ (មាត្រា ៥៥២)។ ច្បាប់តម្រូវឲ្យអ្នកលក់ថែរក្សាវត្ថុ ឬទ្រព្យ ដែលជាកម្មវត្ថុនៃការលក់នេះ ឲ្យបានហ្មត់ចត់ "*ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ*" (គឺថែរក្សាដូចជាការថែរក្សាទ្រព្យផ្ទាល់ខ្លួនឯងផ្សេងទៀតអ៊ីចឹងដែរ) មិនមែនអាងតែបានចុះកិច្ចសន្យាលក់រួចហើយ ទុកវត្ថុនោះចោល លែងរវីរវល់ថែទាំ នាំឲ្យបាត់បង់ ឬខូចខាតនោះទេ។

ក្នុងករណីដែលអ្នកលក់ធ្វើឲ្យបាត់បង់ ឬធ្វើឲ្យខូចខាតវត្ថុ ដែលជាកម្មវត្ថុនៃការលក់ ដោយសារតែមានការធ្វេសប្រហែស មិនបានគោរពករណីយកិច្ចថែរក្សាវត្ថុ ដូចមានចែងក្នុងច្បាប់នេះទេ គាត់នឹងត្រូវទទួលខុសត្រូវចំពោះអ្នកទិញទៅតាមអ្វីដែលបានចែងក្នុងកិច្ចសន្យា ឬត្រូវសងសំណងខូចខាត ទៅតាមការចែងក្នុងក្រមរដ្ឋប្បវេណីទាក់ទងនឹងសំណងខូចខាតក្នុងករណីមិនគោរពកាតព្វកិច្ចតាមកិច្ចសន្យា (ផ្នែកទី៣ ជំពូកទី៤ គន្ថីទី៤ នៃក្រមរដ្ឋប្បវេណី)។

ករណីយកិច្ចសំខាន់មួយទៀតរបស់អ្នកលក់ គឺករណីយកិច្ចផ្តល់ព័ត៌មាន ចំពោះអ្នកទិញ គឺព័ត៌មានចាំបាច់ដែលជាប់ពាក់ព័ន្ធនឹងវត្ថុដែលខ្លួនលក់នេះ ជាពិសេសក្នុងករណីលក់ផ្ទះ ឬក៏ដីធ្លី អ្នកលក់ត្រូវពន្យល់ដល់អ្នកទិញឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃសិទ្ធិលើអចលនវត្ថុអំពីព្រំដែននៃអចលនវត្ថុ និងពីបន្ទុកផ្សេងៗដែលអាចមានលើអចលនវត្ថុនេះ ដូចជា ករណីមានសេវភាពតម្រូវឲ្យបើកផ្លូវឆ្លងកាត់ទៅដីអ្នកជិតខាងជាដើម។

ប្រសិនបើអ្នកលក់មិនបំពេញតាមករណីយកិច្ចផ្តល់ព័ត៌មាននេះទេ ឬផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ គាត់ជាអ្នកទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលកើតឡើង ដោយសារការខកខានមិនបានផ្តល់ព័ត៌មាននេះ។ ម្យ៉ាងទៀត ប្រសិនបើអ្នកលក់ផ្តល់ព័ត៌មានមិនពិត ឬលាក់បាំងការពិតដោយចេតនា ហើយព័ត៌មានមិនពិត ឬព័ត៌មានដែលលាក់កំបាំងនេះ គឺជាចំណុចសំខាន់ ដែលមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកទិញ ក្នុងករណីនេះអ្នកទិញអាចសុំលុបចោលកិច្ចសន្យានេះវិញបាន ដោយលើកយកការឆបោកមកធ្វើជាមូលហេតុ។

**៥.នៅក្នុងការអនុវត្តជាក់ស្តែង យើងឃើញនៅក្នុងការទិញលក់ ពេលខ្លះមានការតម្រូវឲ្យអ្នកទិញកក់លុយទុកជាមុន។ តើការបង់លុយកក់នេះ មានចែងកំណត់នៅក្នុងច្បាប់ដែរ ឬទេ?**

នៅក្នុងកិច្ចសន្យាទិញលក់ ការបង់ប្រាក់កក់មិនមែនជាកាតព្វកិច្ចដែលត្រូវតែធ្វើទេ ក៏ប៉ុន្តែច្បាប់ក៏មិនបានហាមឃាត់ដែរ មានន័យថា វាអាស្រ័យទៅតាមការកំណត់របស់អ្នកទិញ និងអ្នកលក់។ ក្រមរដ្ឋប្បវេណីមានចែងអំពីរឿងប្រាក់កក់នេះ គឺចែងត្រង់មាត្រា ៥១៨ ដែលថា បើអ្នកទិញបានបង់ប្រាក់កក់ទៅឲ្យអ្នកលក់ អ្នកទិញអាចរំលាយកិច្ចសន្យាទិញលក់វិញ ដោយបោះបង់ប្រាក់កក់នេះចោល។ ចំពោះអ្នកលក់វិញ ក៏អាចរំលាយកិច្ចសន្យានេះបានដែរ ដោយត្រូវសងប្រាក់ស្មើនឹង ២ដងនៃប្រាក់កក់នេះមកវិញ (មានន័យថា ត្រូវប្រគល់ប្រាក់កក់មកឲ្យអ្នកទិញវិញ ហើយត្រូវបូកបន្ថែមពីលើនូវប្រាក់សំណងដែលស្មើនឹងប្រាក់កក់នេះ)។

## ផ្នែកទី៣៩

## អំពីសិទ្ធិ ភាតព្វកិច្ច និងទម្រង់នៃកិច្ចសន្យាជួលផ្ទះ ឬដីធ្លី

ដោយ សេង ឌីណា

កិច្ចសន្យាជួល (តាមភាសាច្បាប់ថា ភតិសន្យា) មានចែងនៅក្នុងក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧) ពីមាត្រា ៥៩៦ ដល់មាត្រា៦២១(ជំពូកទី៥)។ យោងតាមនិយមន័យក្នុងក្រមរដ្ឋប្បវេណីនេះ "ភតិសន្យា សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងឲ្យភាគីម្ខាងទៀតប្រើប្រាស់ និងអាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃ"។ ខាងក្រោមនេះ គឺជាសំណួរ-ចម្លើយជុំវិញកិច្ចសន្យាជួលអចលនវត្ថុ (អគារ និងដីធ្លី)។

**១.តើកិច្ចសន្យាជួលអចលនវត្ថុចាំបាច់ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរដែរ ឬទេ?**

ចំពោះកិច្ចសន្យាជួលជាទូទៅ ទោះជាជួលចលនវត្ថុក៏ដោយ ជួលអចលនវត្ថុក៏ដោយ ច្បាប់មិនតម្រូវឲ្យធ្វើជាលាយលក្ខណ៍អក្សរទេ។ លើកលែងតែក្នុងករណីពិសេសណាមួយ ដែលច្បាប់កំណត់ផ្សេង។

តាមមាត្រា ៥៩៧ នៃក្រមរដ្ឋប្បវេណីខ្មែរ កិច្ចសន្យាជួលត្រូវមានអានុភាព នៅពេលណាដែលមានការព្រមព្រៀងពីគូភាគី មានន័យថា ឲ្យតែកាលណាភាគីម្ចាស់វត្ថុ (ភតិបតី) ព្រមព្រៀងដាក់វត្ថុឲ្យភាគីអ្នកជួល (ភតិកៈ) ប្រើប្រាស់ និងអាស្រ័យផល ហើយភាគីអ្នកជួលព្រមព្រៀងជួលដោយបង់ថ្លៃឈ្នួលដែលបានកំណត់ គឺច្បាប់ទទួលស្គាល់ថាមានកិច្ចសន្យាជួល ទោះបីភាគីមិនបានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរក៏ដោយ។

ដូច្នេះ ភាគីណាមួយមិនអាចបដិសេធកិច្ចសន្យាជួល ដោយលើកហេតុផលថា មិនបានធ្វើជាលាយលក្ខណ៍អក្សរនោះទេ។

ក៏ប៉ុន្តែ បើទោះជាច្បាប់មិនតម្រូវក៏ដោយ ក្នុងការអនុវត្តជាក់ស្តែង ការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ គឺវាធ្វើឲ្យគូភាគីមានសុវត្ថិភាពជាងការធ្វើកិច្ចសន្យាដោយផ្ទាល់មាត់។ បញ្ហានៃកិច្ចសន្យាផ្ទាល់មាត់ គឺភស្តុតាង។ បើសិនជាមានភាគីម្ខាងបដិសេធមិនទទួលស្គាល់ ភាគីម្ខាងទៀតអាចនឹងជួបបញ្ហាស្មុគស្មាញក្នុងការបង្ហាញភស្តុតាងថា គូភាគីទាំងពីរពិតជាបានព្រមព្រៀងគ្នាជួលវត្ថុនេះមែន។ បើមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរចែងច្បាស់លាស់ គូភាគីមិនអាចប្រកែកបានទេ។

**២.តើកិច្ចសន្យាជួលអចលនវត្ថុចាំបាច់ត្រូវតែមានកំណត់រយៈពេលជួលច្បាស់លាស់ ឬក៏អាចធ្វើដោយមិនមានកំណត់ពេលបាន?**

កិច្ចសន្យាជួលអាចធ្វើឡើងដោយមានកំណត់រយៈពេលជួលក៏បាន ឬដោយគ្មានពេលកំណត់ក៏បាន។ វាអាស្រ័យនឹងការព្រមព្រៀងគ្នារវាងម្ចាស់វត្ថុ និងអ្នកជួល។ ក៏ប៉ុន្តែ បើចង់ជួលដោយមានកំណត់ពេលច្បាស់លាស់ គូភាគីចាំបាច់ត្រូវតែធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ព្រោះ ច្បាប់កំណត់ថា កិច្ចសន្យាជួលអចលនវត្ថុដែលធ្វើត្រឹមតែមាត់ទទេ ដោយមិនធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ គឺត្រូវចាត់ទុកថាជាកិច្ចសន្យាដែលគ្មានកំណត់ពេល (មាត្រា ៥៩៨)។

គួរបញ្ជាក់ថា "កិច្ចសន្យាជួលដោយគ្មានកំណត់ពេល" មិនមែនមានន័យថា គូភាគីត្រូវតែជួលអស់មួយជីវិតនោះទេ! គ្រាន់តែថា បើជួលមានរយៈពេលកំណត់ កិច្ចសន្យាជួលត្រូវបញ្ចប់ នៅពេលផុតពេលកំណត់ (បើកំណត់ថា ជួលរយៈពេល ១ឆ្នាំ ដល់គ្រប់ ១ឆ្នាំ កិច្ចសន្យាជួលនេះត្រូវបញ្ចប់) លើកលែងតែគូភាគីព្រមព្រៀងបន្តកិច្ចសន្យានេះតទៅទៀត។

ផ្ទុយទៅវិញ កិច្ចសន្យាជួលដោយគ្មានកំណត់ពេលត្រូវមានសុពលភាព រហូតទាល់តែគូភាគីស្នើសុំបញ្ចប់។ ការស្នើសុំបញ្ចប់កិច្ចសន្យានេះអាចធ្វើឡើងដោយភាគីណាមួយក៏បានដែរ (ពីខាងម្ចាស់វត្ថុក៏បាន ឬពីខាងអ្នកជួលក៏បាន) ហើយអាចសុំបញ្ចប់កិច្ចសន្យានេះនៅពេលណាក៏បានដែរ ក៏ប៉ុន្តែ ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតឲ្យបានយ៉ាងតិច ៣ខែ មុនដល់ថ្ងៃបញ្ចប់កិច្ចសន្យា ចំពោះការជួលផ្ទះ ឬអគារផ្សេងទៀត។ មានន័យថា ម្ចាស់ផ្ទះមិនមែននឹកឃើញចង់ឈប់ជួល ក៏ប្រាប់ទៅអ្នកជួល

ឲ្យរើចេញភ្លាមៗបានទេ។ អ្នកជួលក៏មិនអាចថា ចង់ចេញក៏ប្រាប់ទៅម្ចាស់ផ្ទះថ្ងៃនេះ ហើយរើចេញស្អែកបានដែរនោះដែរ (អាចរើចេញភ្លាមៗបាន ក៏ប៉ុន្តែ ត្រូវនៅបន្តបង់ថ្លៃឈ្នួលផ្ទះ ៣ខែទៀត)។

ចំពោះការជួលដីធ្លី ការសុំបញ្ចប់កិច្ចសន្យាត្រូវមានការជូនដំណឹងទៅភាគីម្ខាងទៀតយ៉ាងតិច ១ឆ្នាំ។ បើសិនជាដីនោះជាដីកសិកម្ម មានរដូវដាំដុះ ប្រមូលផល ការបញ្ចប់កិច្ចសន្យាជួលត្រូវធ្វើឡើងនៅចន្លោះរដូវដាំដុះ មានន័យថា នៅក្រោយពេលប្រមូលផលរដូវមួយ និងមុនពេលចាប់ផ្តើមដាំដុះរដូវបន្ទាប់។

**៣.ចំពោះការជួលដោយមានរយៈពេលកំណត់ តើកិច្ចសន្យាត្រូវបញ្ចប់ជាស្វ័យប្រវត្តិ នៅពេលដល់កំណត់ ឬក៏ត្រូវមានការបញ្ជាក់ច្បាស់លាស់ពីគូភាគី?**

ចំពោះការជួលអចលនវត្ថុ ទោះបីជាកិច្ចសន្យាជួលមានរយៈពេលកំណត់ក៏ដោយ ដើម្បីបញ្ចប់កិច្ចសន្យា គឺទាល់តែមានភាគីម្ខាង (ម្ចាស់វត្ថុក៏ដោយ ឬក៏អ្នកជួលក៏ដោយ) បង្ហាញឆន្ទៈថាចង់បញ្ចប់កិច្ចសន្យា។ ការជូនដំណឹងពីការបញ្ចប់កិច្ចសន្យានេះ ត្រូវធ្វើឡើងឲ្យបានមុន ៣ខែ មុនដល់ពេលផុតកំណត់ បើសិនជាការជួលផ្ទះ ឬអគារផ្សេងទៀត ហើយឲ្យបានមុន ១ឆ្នាំ បើសិនជាការជួលដី។

បើសិនផុតរយៈពេលនេះ មិនមានភាគីណាមួយបង្ហាញឆន្ទៈចង់បញ្ចប់កិច្ចសន្យាទេ គឺត្រូវចាត់ទុកថា ភាគីទាំងសងខាងបានយល់ព្រមក្នុងការបន្តកិច្ចសន្យានេះជាថ្មី។ ប៉ុន្តែ ក្នុងករណីនេះ កិច្ចសន្យាដែលបន្តថ្មី ត្រូវចាត់ទុកជាកិច្ចសន្យាជួលដោយគ្មានកំណត់ពេល។

និយាយសរុបមកវិញ ចំពោះកិច្ចសន្យាជួលអចលនវត្ថុដោយមានរយៈពេលកំណត់ ពេលជិតដល់កំណត់ វាអាចមានករណី៣៖

- មានភាគីម្ខាងសុំបញ្ចប់កិច្ចសន្យា ដោយជូនដំណឹងទៅភាគីម្ខាងទៀតទៅតាមពេលដែលកំណត់ខាងលើ។ ក្នុងករណីនេះ កិច្ចសន្យាគឺត្រូវបញ្ចប់។
- គូភាគីអាចជជែកគ្នាបន្តកិច្ចសន្យានេះជាថ្មីទៀត។ ក្នុងករណីនេះ គូភាគីអាចកំណត់ពេលវេលានៃកិច្ចសន្យាថ្មីនេះដោយកំណត់ពេលដូចមុន តិចជាងមុន ឬក៏យូរជាងមុន ហើយថ្លៃឈ្នួលដូចមុន ឬខុសពីមុន ទៅតាមការជជែកគ្នា និងព្រមព្រៀងគ្នា។
- បើសិនជាមិនមានភាគីណាមួយបង្ហាញពីឆន្ទៈចុងបញ្ចប់កិច្ចសន្យានេះទេ កិច្ចសន្យាចាស់នឹងត្រូវបន្តជាថ្មីក្នុងលក្ខខណ្ឌដដែល (ថ្លៃឈ្នួលដដែល) ប៉ុន្តែ កិច្ចសន្យាថ្មីនេះ ត្រូវក្លាយជាកិច្ចសន្យាដែលគ្មានកំណត់ពេល។ កាលណាជាកិច្ចសន្យាជួលដោយមិនកំណត់ពេល ការស្នើសុំបញ្ចប់កិច្ចសន្យាត្រូវមានការជូនដំណឹងទៅភាគីម្ខាងទៀត ដោយគោរពទៅតាមពេលវេលាកំណត់ដោយច្បាប់ដូចមានលើកឡើងខាងលើ។

**៤.ចុះបើភាគីម្ខាងចង់បញ្ចប់កិច្ចសន្យាជួលនេះនៅមុនដល់ពេលផុតកំណត់ តើបានដែរ ឬទេ?**

បាន! បើសិនជាក្នុងពេលចុះកិច្ចសន្យា ភាគីម្ខាង ឬទាំងសងខាង រក្សាសិទ្ធិបញ្ចប់កិច្ចសន្យាមុនផុតពេលកំណត់ (មាត្រា ៦១៦)។ ក្នុងករណីនេះ ភាគីដែលស្នើសុំបញ្ចប់កិច្ចសន្យា ត្រូវជូនដំណឹងទៅភាគីម្ខាងទៀត ដោយគោរពទៅតាមពេលវេលា ដូចក្នុងករណីកិច្ចសន្យាគ្មានកំណត់ពេលដែរ គឺ យ៉ាងតិច ៣ខែ សម្រាប់ការជួលអគារ និង ១ឆ្នាំ សម្រាប់ការជួលដីធ្លី។

**៥.នៅក្នុងអំឡុងពេលជួល បើសិនជាមានការខូចខាតណាមួយកើតឡើងលើអចលនវត្ថុ តើអ្នកណាជាអ្នកទទួលបន្ទុកជួសជុល?**

តាមមាត្រា ៦០១ នៃក្រមរដ្ឋប្បវេណី ភតិក: (អ្នកជួល) មានករណីយកិច្ចគ្រប់គ្រងវត្ថុជួលដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត គឺមានន័យថា គាត់ត្រូវមើលថែទាំវត្ថុជួលឲ្យបានហ្មត់ចត់ ហើយត្រូវទទួលបន្ទុកធ្វើការជួសជុលតូចតាចដែលមានលក្ខណៈជាការថែទាំប្រចាំថ្ងៃ។

រីឯការជួសជុលធំៗដែលចាំបាច់ ដើម្បីជានាការប្រើប្រាស់ និងការអាស្រ័យផលនៃអចលនវត្ថុជួល ដូចជា ជញ្ជាំងប្រេះត្រូវបិទភ្ជិតឡើងវិញ ទ្វារបង្អួចពុកបាក់បិទលែងជិតត្រូវប្តូរថ្មី ដំបូលចាស់លិចទឹកត្រូវធ្វើថ្មី ។ល។ គឺជាបន្ទុករបស់ម្ចាស់វត្ថុ (មាត្រា ៦០២)។ ក៏ប៉ុន្តែ បើសិនជាការខូចខាតទាំងអស់នោះកើតឡើងពីទង្វើរបស់អ្នកជួល ឬក៏ខូចខាតដោយសារតែអ្នកជួលប្រើប្រាស់មិនសមរម្យ ឬធ្វេសប្រហែស មិនបានគ្រប់គ្រង ថែទាំវត្ថុជួលឲ្យបានហ្មត់ចត់ ទៅតាមករណីយកិច្ចខាងលើ ក្នុងករណីនេះ គឺអ្នកជួលដែលត្រូវទទួលបន្ទុកជួសជុល។

# ផ្នែកទី៤០

## ក្រមរដ្ឋប្បវេណីៈ ការដាក់ទ្រព្យធានាកាតព្វកិច្ចលើបំណុល

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា សូមឆ្លើយនឹងសំណួរអ្នកស្តាប់របស់យើង ជុំវិញការដាក់ទ្រព្យដើម្បីធានាបំណុល។ តើអ្វីទៅជាប្រតិបត្តិការដែលមានកិច្ចធានា? តើការបញ្ចាំ និងហ៊ីប៉ូតែកខុសគ្នាត្រង់ចំណុចណាខ្លះ? តើការដាក់ប័ណ្ណកម្មសិទ្ធិ(ប្លង់ដី ឬផ្ទះ) ដើម្បីធានាបំណុល ជាការបញ្ចាំ ឬជាហ៊ីប៉ូតែក?

**១.តើអ្វីទៅជាប្រតិបត្តិការដែលមានកិច្ចធានា?**

ប្រតិបត្តិការដោយមានកិច្ចធានា ដែលមានចែងក្នុងច្បាប់ ឆ្នាំ២០០៧ គឺសំដៅទៅលើការធានាកាតព្វកិច្ចលើបំណុលដោយដាក់ទ្រព្យធានា។ ឧទាហរណ៍ជាក់ស្តែង ដែលយើងតែងតែជួប គឺការយកទ្រព្យទៅបញ្ចាំ ដើម្បីធានាបំណុល។ ក៏ប៉ុន្តែ ទ្រព្យធានា ដែលត្រូវអនុវត្តក្នុងច្បាប់ ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានេះ គឺសំដៅតែទៅលើចលនទ្រព្យតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលការធានាដោយអចលនទ្រព្យទេ (មាត្រា ៦ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា)។

តាមការពិត ការធានាបំណុល គឺមានចែងសរុបជារួម នៅក្នុងក្រមរដ្ឋប្បវេណីដែលទើបនឹងចូលជាធរមានក្រោយច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ការធានាបំណុលនៅក្នុងក្រមរដ្ឋប្បវេណីនេះ គឺមានទាំងៈ

- ការធានាបំណុលដោយបុគ្គល
- ការធានាបំណុលដោយទ្រព្យ (ចលនទ្រព្យ និងអចលនទ្រព្យ)

ការធានាបំណុលដោយបុគ្គល (កិច្ចសន្យាធានា) គឺមានន័យថា បុគ្គលទី៣ណាមួយជាអ្នកចេញមុខធានាចំពោះម្ចាស់បំណុលថានឹងសងបំណុល ជំនួសកូនបំណុល ក្នុងករណីកូនបំណុលមិនសង។

ការធានាបំណុលដោយដាក់ទ្រព្យធានា គឺជាកិច្ចសន្យាមួយដែលកូនបំណុល ឬក៏បុគ្គលទី៣ណាមួយផ្សេងទៀតព្រមព្រៀងដាក់ទ្រព្យរបស់ខ្លួនជាកិច្ចធានា ដើម្បីឲ្យម្ចាស់បំណុលមានសិទ្ធិទាមទារលក់ទ្រព្យធានានេះ ដើម្បីយកលុយមកសងបំណុល ដោយមានអាទិភាពលើម្ចាស់បំណុលផ្សេងទៀត។ ប្រតិបត្តិការដាក់ទ្រព្យធានាបំណុលនេះ អាចធ្វើចំពោះចលនទ្រព្យ ដូចជា ការបញ្ចាំចលនទ្រព្យ ជាដើម ឬក៏ចំពោះអចលនទ្រព្យ ដូចជា ការបញ្ចាំអចលនទ្រព្យ ឬក៏ហ៊ីប៉ូតែក។

ដូច្នេះ និយាយសរុបជារួមមកវិញ ប្រតិបត្តិការដែលមានកិច្ចធានា ដូចដែលមានចែងនៅក្នុងច្បាប់ ចុះថ្ងៃទី២២ ឧសភា ឆ្នាំ២០០៧ ស្តីពី “ប្រតិបត្តិការដែលមានកិច្ចធានា” គឺទាក់ទងនឹងការធានាបំណុល ដោយដាក់ចលនទ្រព្យ ជាទ្រព្យធានាពោលគឺ វាគ្រាន់តែជាផ្នែកមួយ នៃការធានាកាតព្វកិច្ចបំណុល ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។

**២.តើការធានាបំណុលដោយការបញ្ចាំទ្រព្យ និងធានាដោយហ៊ីប៉ូតែក ខុសគ្នាត្រង់ណាខ្លះ?**

ជាដំបូងគួរបញ្ជាក់ថា ការបញ្ចាំ អាចធ្វើឡើងទាំងចំពោះចលនទ្រព្យ និងអចលនទ្រព្យ។ ចំណែក ហ៊ីប៉ូតែកវិញ អាចធ្វើឡើងតែចំពោះអចលនទ្រព្យតែប៉ុណ្ណោះ។

ចំណុចខុសគ្នាធំបំផុតរវាងការធានាបំណុល ដោយការបញ្ចាំ និងការធានាបំណុលដោយហ៊ីប៉ូតែក គឺនៅត្រង់ការកាន់កាប់ទ្រព្យធានា។

នៅក្នុងករណីបញ្ចាំ ទោះបីជាការបញ្ចាំចលនទ្រព្យក៏ដោយ ការបញ្ចាំអចលនទ្រព្យក៏ដោយ ទ្រព្យដែលដាក់បញ្ចាំត្រូវដាក់ឲ្យម្ចាស់បំណុល (ម្ចាស់សិទ្ធិបញ្ចាំ) ជាអ្នកកាន់កាប់ (មាត្រា ៨១៦ ក្រមរដ្ឋប្បវេណី)។

ចំណែក ក្នុងករណីហ៊ីប៉ូតែកវិញ មិនមានការផ្ទេរទ្រព្យជានាទៅឲ្យម្ចាស់បំណុលជាអ្នកកាន់កាប់ទេ (មាត្រា ៨៤៣ ក្រមរដ្ឋប្បវេណី)។ ប្រសិនបើអចលនទ្រព្យដែលដាក់ហ៊ីប៉ូតែកនេះ ជាទ្រព្យរបស់កូនបំណុល កូនបំណុលនៅតែបន្តកាន់កាប់ទ្រព្យនេះដដែល។ បើវាជាទ្រព្យរបស់បុគ្គលទីពាណាមួយផ្សេងទៀត បុគ្គលដែលជាម្ចាស់ទ្រព្យនោះ នៅតែបន្តកាន់កាប់ទ្រព្យរបស់ខ្លួនដដែល។

នៅក្នុងករណីដែលកូនបំណុលមិនសងបំណុល ទោះបីជាក្នុងករណីបញ្ចាំក៏ដោយ ករណីហ៊ីប៉ូតែកក៏ដោយ ម្ចាស់បំណុលត្រូវសុំទៅតុលាការឲ្យលក់ទ្រព្យនេះ ដើម្បីយកលុយមកសងបំណុល ប៉ុន្តែ មិនអាចរឹបអូសទ្រព្យដែលដាក់ជានាបំណុលនេះមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនឯងបានទេ។

**៣.ក៏ប៉ុន្តែ នៅក្នុងការអនុវត្តនៅក្នុងសង្គមខ្មែរតាំងពីដើមមក យើងតែងតែឃើញមានករណីយកទ្រព្យ (ដូចជា ឡាន ម៉ូតូ ឬ គ្រឿងអលង្ការ ជាដើម) ទៅបញ្ចាំ ហើយបានកំណត់គ្នាថា ក្នុងរយៈពេលប៉ុណ្ណេះថ្ងៃត្រូវយកលុយមកលោះ បើមិនលោះតាមកំណត់ទេត្រូវដាច់។ តើការអនុវត្តបែបនេះជាការស្របច្បាប់ដែរ ឬទេ?**

កន្លងមក យើងឃើញថា ការអនុវត្តបែបនេះតែងតែកើតមានជាធម្មតាមែន ក៏ប៉ុន្តែ ក្នុងក្រមរដ្ឋប្បវេណីថ្មី មានចែងយ៉ាងច្បាស់ ហាមមិនឲ្យបង្កើតកិច្ចសន្យាបញ្ចាំផ្តាច់ទេ (មាត្រា ៨២៧ ក្រមរដ្ឋប្បវេណី)។

នៅក្នុងករណីបញ្ចាំចលនទ្រព្យ (ឡាន ម៉ូតូ ឬគ្រឿងអលង្ការ ... ) ក្រមរដ្ឋប្បវេណីចែងអនុញ្ញាតឲ្យម្ចាស់បំណុលអាចទាមទារយកទ្រព្យបញ្ចាំមកធ្វើជាកម្មសិទ្ធិ ដើម្បីជំនួសបំណុលបាន បើសិនកូនបំណុលមិនសង ក៏ប៉ុន្តែ ការទាមទារនេះចាំបាច់ត្រូវតែធ្វើឡើងតាមផ្លូវតុលាការ មិនអាចធ្វើឡើងតាមរយៈកំណត់ជាមុនក្នុងកិច្ចសន្យាបញ្ចាំបានទេ។ ម្យ៉ាងទៀត ការទាមទារយកទ្រព្យបញ្ចាំមកធ្វើជាកម្មសិទ្ធិ ដើម្បីជំនួសបំណុល ត្រូវតែមានការវាយតម្លៃទ្រព្យ ដោយអ្នកជំនាញទៅតាមតម្លៃទីផ្សារ។ ប្រសិនបើតាមការវាយតម្លៃនេះ ឃើញថា ទ្រព្យបញ្ចាំមានតម្លៃលើសពីលុយដែលត្រូវសង (ទាំងដើម ទាំងការ) ម្ចាស់បំណុលត្រូវសងចំនួនទឹកប្រាក់ដែលនៅសល់ ទៅម្ចាស់កម្មសិទ្ធិនៃទ្រព្យបញ្ចាំនេះវិញ (មាត្រា ៨៣២)។

**៤.នៅក្នុងករណីបញ្ចាំ ម្ចាស់បំណុលជាអ្នកកាន់កាប់ទ្រព្យបញ្ចាំ ប៉ុន្តែ ចង់ដឹងថា តើម្ចាស់បំណុលមានសិទ្ធិប្រើប្រាស់ទ្រព្យបញ្ចាំនេះដែរ ឬទេ?**

បើសិនជាការបញ្ចាំចលនទ្រព្យ (ឡាន ម៉ូតូ នាឡិការ ឬគ្រឿងអល្លង្ការ ជាដើម) ម្ចាស់បំណុលមានសិទ្ធិកាន់កាប់ទ្រព្យដែលដាក់បញ្ចាំ ក៏ប៉ុន្តែ មិនមានសិទ្ធិយកទ្រព្យនេះទៅប្រើប្រាស់ ឬយកទៅជួលបានទេ លើកលែងតែមានការព្រមព្រៀងពីកូនបំណុល។ ការប្រើប្រាស់អាចធ្វើទៅបាន ប្រសិនបើវាជាការចាំបាច់ ក្នុងការរក្សា ថែទាំ វត្ថុបញ្ចាំ (មាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណី)។

ចំពោះការបញ្ចាំអចលនទ្រព្យ (ដី ឬផ្ទះ ជាដើម) ម្ចាស់បំណុលមានសិទ្ធិកាន់កាប់ទ្រព្យបញ្ចាំ ហើយមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើទ្រព្យនេះបាន ប៉ុន្តែ ត្រូវប្រើប្រាស់ និងអាស្រ័យផល ទៅតាមវិធីប្រើប្រាស់សមរម្យនៃអចលនទ្រព្យនោះ (មាត្រា ៨៣៤ ក្រមរដ្ឋប្បវេណី)។ មានន័យថា បើទ្រព្យដែលដាក់បញ្ចាំ គឺជាដីកសិកម្ម ម្ចាស់បំណុលអាចធ្វើការដាំដុះនៅលើដីនេះបាន ប៉ុន្តែ មិនអាចយកវាទៅធ្វើអ្វីផ្សេងឲ្យខុសលក្ខណៈដើម (ឧទាហរណ៍ ដូចជា ជីកដី ធ្វើស្រះចិញ្ចឹមត្រី នៅលើដីនេះបានទេ) ពីព្រោះ កុំភ្លេចថា នៅពេលដែលទូទាត់បំណុលចប់សព្វគ្រប់ ដីនេះត្រូវប្រគល់ទៅឲ្យកូនបំណុលវិញ។

**៥.និយាយដល់ការដែលម្ចាស់បំណុលយកដីបញ្ចាំទៅធ្វើការដាំដុះ សំណួរចោទឡើងថា បើសិនជាការបញ្ចាំត្រូវបញ្ចប់នៅមុនពេលដល់រដូវប្រមូលផល តើផលដំណាំនៅលើដីនេះត្រូវបានទៅលើអ្នកណា?**

មាត្រា ៨៣៤ នៃក្រមរដ្ឋប្បវេណី ធ្វើការបែងចែករឿងនេះជាពីរករណីៈ

ទីមួយ ក្នុងករណីការបញ្ចាំធ្វើឡើងចំពោះបំណុល ដែលគ្មានពេលកំណត់សងច្បាស់លាស់ បើទោះជាកូនបំណុលបានសងបំណុលរួចរាល់អស់ហើយក៏ដោយ បើសិនជាម្ចាស់បំណុលបានធ្វើការដាំដុះរួចហើយនៅលើដីបញ្ចាំ ហើយរដូវប្រមូលផលនឹងត្រូវមកដល់ក្នុងរយៈពេលមិនលើសពីមួយឆ្នាំ ម្ចាស់បំណុលអាចបន្តប្រើដីនេះ រហូតដល់រដូវប្រមូលផលបាន។

ទីពីរ ក្នុងករណីការបញ្ចាំធ្វើឡើងចំពោះបំណុល ដែលមានកំណត់ពេលត្រូវសងច្បាស់លាស់ បើសិនជាដល់ពេលកំណត់ត្រូវសង កូនបំណុលសងបំណុលគ្រប់ចំនួន ម្ចាស់បំណុលត្រូវប្រគល់ដីបញ្ចាំនេះទៅឲ្យម្ចាស់ដីដើមវិញភ្លាម បើទោះជាមិនទាន់បានប្រមូលផលលើដំណាំដែលខ្លួនដាំក៏ដោយ។ ផ្ទុយទៅវិញ ប្រសិនបើកូនបំណុលសងបំណុលមុនពេលកំណត់ ហើយរដូវប្រមូលផលត្រូវដល់ក្នុងរយៈពេលមិនលើសពីមួយឆ្នាំ ហើយមិនលើសពីពេលកំណត់សងបំណុលដែលបានព្រមព្រៀងគ្នាពីមុន ម្ចាស់បំណុលមានសិទ្ធិបន្តកាន់កាប់ និងប្រើប្រាស់ដីបញ្ចាំនេះរហូតដល់រដូវប្រមូលផល។ ប៉ុន្តែ បើសិនជារដូវប្រមូលផលនៅសល់យូរទៀត គឺយូរលើសពីមួយឆ្នាំ ឬក៏តិចជាងមួយឆ្នាំ ប៉ុន្តែ លើសពីពេលកំណត់សងបំណុលដែលបានព្រមព្រៀងគ្នាជាមួយកូនបំណុលពីមុន ម្ចាស់បំណុលត្រូវប្រគល់ដីបញ្ចាំទៅឲ្យម្ចាស់ដើមវិញភ្លាម ទោះបីមិនទាន់បានប្រមូលផលក៏ដោយ។

**៦.និយាយពីការធ្វើហ៊ីប៉ូតែកវិញ។ នៅក្នុងករណីហ៊ីប៉ូតែកផ្ទះ ឬដី មិនមានការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យនេះទៅឲ្យម្ចាស់បំណុលទេ ប៉ុន្តែ ចង់ដឹងថា តើចាំបាច់ត្រូវប្រគល់ប្លង់ផ្ទះ ឬប្លង់ដីទៅឲ្យម្ចាស់បំណុលដែរ ឬទេ?**

នៅក្នុងការបង្កើតហ៊ីប៉ូតែក ម្ចាស់ទ្រព្យមិនត្រូវផ្ទេរសិទ្ធិកាន់កាប់ទៅឲ្យម្ចាស់បំណុល ហើយក៏មិនចាំបាច់ត្រូវយកប័ណ្ណកម្មសិទ្ធិ (ប្លង់ដី ឬប្លង់ផ្ទះ) ទៅឲ្យម្ចាស់បំណុលដែរ។

នៅក្នុងការអនុវត្តជាក់ស្តែង កន្លងមក យើងឃើញករណីភាគច្រើន នៅពេលខ្ចីលុយ គឺកូនបំណុលតែងតែយកប័ណ្ណកម្មសិទ្ធិអចលនទ្រព្យ ទៅប្រគល់ឲ្យម្ចាស់បំណុល ដើម្បីជានាបំណុល។ ការអនុវត្តបែបនេះ គឺធ្វើទៅតាមច្បាប់ភូមិបាលដែលជាច្បាប់ចាស់ មុនមានក្រមរដ្ឋប្បវេណី។

នៅក្នុងច្បាប់ភូមិបាល ការដាក់អចលនទ្រព្យ ដើម្បីជានាបំណុល អាចធ្វើឡើងជា ៣រូបភាព គឺៈ

- ការបញ្ចាំដែលត្រូវផ្ទេរអចលនទ្រព្យទៅឲ្យម្ចាស់បំណុលកាន់កាប់
- ហ៊ីប៉ូតែក ដែលមិនមានការផ្ទេរសិទ្ធិកាន់កាប់ទ្រព្យ
- ការដាក់ធានា (ដែលនៅចន្លោះកណ្តាលរវាងការបញ្ចាំ និងហ៊ីប៉ូតែក) គឺកូនបំណុលមិនត្រូវប្រគល់ទ្រព្យទៅឲ្យម្ចាស់បំណុលកាន់កាប់ទេ តែត្រូវដាក់ប័ណ្ណកម្មសិទ្ធិទុកជាការធានា

ក៏ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណី ដែលទើបនឹងចូលជាធរមានក្រោយច្បាប់ភូមិបាលនេះលែងមានចែងពី “ការដាក់ធានា” នេះទៀតហើយ គឺមានតែការបញ្ចាំ និងហ៊ីប៉ូតែកប៉ុណ្ណោះ។ នៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនេះ (ច្បាប់ចុះថ្ងៃទី៣១ ឧសភា ឆ្នាំ២០១១) មានចែងក្នុងមាត្រា ៥៦ ថា ចាប់ពីពេលក្រមរដ្ឋប្បវេណីត្រូវចាប់អនុវត្ត រាល់កិច្ចសន្យាបង្កើតសិទ្ធិលើការដាក់ធានាដែលបានចុះរួចហើយ (មានន័យថា ការដាក់ប័ណ្ណកម្មសិទ្ធិដើម្បីជានាបំណុល) ទៅតាមច្បាប់ភូមិបាលចាស់ត្រូវចាត់ទុកថាជាការបង្កើតហ៊ីប៉ូតែក ហើយបើសិនជាកិច្ចសន្យានេះត្រូវបានចុះបញ្ជីជាហ៊ីប៉ូតែកហើយ ម្ចាស់បំណុលត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅឲ្យម្ចាស់ទ្រព្យវិញ។

# ផ្នែកទី៤១

# នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ




ប័ណ្ណកម្មសិទ្ធិដី

ដោយ <u>សេង ឌីណា</u>

ការចុះបញ្ជីដីធ្លី និងការចេញប័ណ្ណកម្មសិទ្ធិ មាននីតិវិធីពីរ គឺការចុះបញ្ជីតាមការស្នើសុំរបស់ម្ចាស់ដី ដែលគេឲ្យឈ្មោះថា ការចុះបញ្ជីដាច់ដោយដុំ និងការចុះបញ្ជីមួយឃុំម្ដងៗតាមការកំណត់របស់រដ្ឋាភិបាល ដែលគេហៅថា ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។

កាលពីសប្ដាហ៍មុន លោក-អ្នកបានជ្រាបរួចមកហើយអំពីនីតិវិធីនៃការចុះបញ្ជីដាច់ដោយដុំ។ នៅថ្ងៃនេះ សេង ឌីណា សូមលើកយកនីតិវិធីនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ មកជូនលោក-អ្នកស្ដាប់។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ រាល់ប័ណ្ណកម្មសិទ្ធិលើដីធ្លី នៅទូទាំងប្រទេសត្រូវបាត់បង់ទាំងអស់។ ច្បាប់បានកំណត់លុបចោលរាល់របបកម្មសិទ្ធិទាំងអស់ ដែលមានមុនឆ្នាំ១៩៧៩។ ដើម្បីរៀបចំកសាងបញ្ជីដីធ្លី និងចេញប័ណ្ណកម្មសិទ្ធិដីធ្លី នៅទូទាំងប្រទេសឡើងវិញ ច្បាប់បានកំណត់បង្កើតនីតិវិធីពិសេសមួយ គឺ “ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ”។

ការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ គឺជាការចុះបញ្ជីដីធ្លីដែលកើតចេញពីគំនិតផ្ដួចផ្ដើមរបស់រដ្ឋាភិបាល ដោយមិនចាំបាច់មានការស្នើសុំពីម្ចាស់ដីឡើយ។ រដ្ឋាភិបាលជាអ្នកកំណត់ជ្រើសរើសភូមិ ឬឃុំណាមួយ ដែលត្រូវធ្វើការចុះបញ្ជីដីធ្លី។

នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ ត្រូវបែកចេញជា ៥ដំណាក់កាលសំខាន់ៗ៖

**ដំណាក់កាលទី១៖ ត្រៀមរៀបចំ**

នៅក្នុងដំណាក់កាលនេះ រដ្ឋាភិបាលនឹងត្រូវធ្វើការប្រកាសកំណត់តំបន់វិនិច្ឆ័យថា តើត្រូវធ្វើការចុះបញ្ជីដីធ្លី នៅក្នុងឃុំណាមួយ។

នៅក្នុងដំណាក់កាលនេះ អាជ្ញាធរត្រូវធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋនៅក្នុងឃុំឲ្យបានជ្រាបអំពីការចុះបញ្ជីដីធ្លីនេះ ដើម្បីឲ្យប្រជាពលរដ្ឋត្រៀមខ្លួនចូលរួមក្នុងដំណើរការនេះ។

គណៈកម្មការមួយត្រូវបង្កើតឡើង ដើម្បីជួយដល់ដំណើរការនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ គណៈកម្មការនេះមានសមាសភាពដូចតទៅ៖

- អភិបាលខេត្ត-ក្រុង ជាប្រធាន
- អភិបាលស្រុក-ខណ្ឌ ជាសមាជិក
- ប្រធានក្រុមបច្ចេកទេសវាស់វែង ជាសមាជិក
- មេឃុំ-ចៅសង្កាត់ ឬតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ជាសមាជិក
- គ្រប់មេភូមិទាំងអស់ នៅក្នុងឃុំ-សង្កាត់ ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យ ២រូប ដែលស្គាល់ប្រវត្តិដី នៅក្នុងឃុំ ជាសមាជិក

**ដំណាក់កាលទី២៖ វាស់វែង និងកសាងប្លង់សុរិយោដី**

ម្ចាស់ដី គឺជាអ្នកកំណត់ព្រំជាមួយអ្នកជិតខាង។ ចំណែក មន្ត្រីបច្ចេកទេសគ្រាន់តែជាអ្នកចុះទៅវាស់វែងទៅតាមព្រំដែលចង្អុលបង្ហាញដោយម្ចាស់ដីតែប៉ុណ្ណោះ។ ដូច្នេះ នៅក្នុងដំណាក់កាលនេះ ការចូលរួមចំណែកពីម្ចាស់ដីមានសារៈសំខាន់ណាស់។

ម្ចាស់ដី ក៏ត្រូវត្រៀមនូវឯកសារចាំបាច់មួយចំនួនផងដែរ។ ឯកសារទាំងនេះ រួមមាន សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រអាពាហ៍ពិពាហ៍ បណ្តាំមរតក សាលក្រមតុលាការ លិខិតទិញ-លក់ ។ល។

**ដំណាក់កាលទី៣៖ ផ្សព្វផ្សាយ**

អាជ្ញាធរ ត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ដើម្បីឲ្យប្រជាពលរដ្ឋពាក់ព័ន្ធអាចធ្វើការត្រួតពិនិត្យ និងតវ៉ាសុំធ្វើការកែប្រែ ប្រសិនបើមានកន្លែងមិនត្រឹមត្រូវ។

គួរបញ្ជាក់ថា នៅក្នុងដំណើរការចុះបញ្ជីនេះ ប្រសិនបើកើតមានវិវាទណាមួយ ដូចជា វិវាទរឿងព្រំដីជាដើម ភាគីជម្លោះអាចសុំឲ្យគណៈកម្មការរដ្ឋបាលជួយដោះស្រាយ និងសម្រុះសម្រួលឲ្យ ដោយមិនចាំបាច់ប្តឹងផ្តល់គ្នាទៅដល់តុលាការនោះទេ។

**ដំណាក់កាលទី៤៖ វិនិច្ឆ័យ និងសម្រេច**

ដំណាក់កាលនេះ គឺមានពាក់ព័ន្ធតែជាមួយស្ថាប័នរដ្ឋតែប៉ុណ្ណោះ។ ផុតរយៈពេល ៣០ថ្ងៃ ដែលបើកឲ្យមានការតវ៉ា មន្ត្រីមានសមត្ថកិច្ច ត្រូវធ្វើការពិនិត្យទៅលើប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ដែលត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ដីទាំងឡាយណាដែលមិនជាប់មានទំនាស់ ហើយមិនមែនចូលជាដីរបស់រដ្ឋនឹងត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយប្រធានមន្ទីរភូមិបាលខេត្ត-ក្រុង នឹងចុះហត្ថលេខាលើប័ណ្ណកម្មសិទ្ធិស្ថាពរ។

**ដំណាក់កាលទី៥៖ ការចែកប័ណ្ណ**

គឺជាដំណាក់កាលចុងក្រោយ។ ក្រោយពីអាជ្ញាធរចុះហត្ថលេខាចេញប័ណ្ណហើយ ប័ណ្ណទាំងនេះនឹងត្រូវចែកជូនដល់ម្ចាស់ដីវិញ។ ម្ចាស់ដីត្រូវទៅទទួលប័ណ្ណ ដោយផ្ទាល់ដៃ ហើយប័ណ្ណនេះ គឺជាប័ណ្ណកម្មសិទ្ធិស្ថាពរ។

គិតរហូតមកទល់ពេលនេះ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះទើបតែធ្វើបានប្រមាណជាង២០% តែប៉ុណ្ណោះ។

គួរបញ្ជាក់ថា បើទោះជាការចុះបញ្ជីលក្ខណៈជាប្រព័ន្ធនៅមិនទាន់បានចប់សព្វគ្រប់នៅទូទាំងប្រទេសក៏ដោយ ប៉ុន្តែការចុះបញ្ជីដាច់ដោយដុំទៅតាមការស្នើសុំរបស់ម្ចាស់ដី នៅតែអាចធ្វើទៅបានក្នុងពេលទន្ទឹមគ្នានេះ។

# ផ្នែកទី៤២
# នីតិវិធីក្នុងការសុំប័ណ្ណកាន់កាប់ដីធ្លី



ប័ណ្ណកម្មសិទ្ធិដី

ដោយ សេង ឌីណា

ការកាន់កាប់ដីធ្លី ដោយមិនមានប័ណ្ណកាន់កាប់ត្រឹមត្រូវអាចនឹងបង្កឲ្យមានវិវាទ បើទោះជាការកាន់កាប់នោះ ជាការកាន់កាប់ដោយស្របច្បាប់ក៏ដោយ។ ប័ណ្ណកាន់កាប់ដីធ្លី គឺជាឯកសារច្បាប់ដ៏សំខាន់ដែលភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិ ឬការកាន់កាប់ដោយស្របច្បាប់។ ក៏ប៉ុន្តែ សំណួរសួរថា ដើម្បីឲ្យមានតម្លៃត្រឹមត្រូវតាមផ្លូវច្បាប់ តើប័ណ្ណនេះត្រូវចេញដោយអាជ្ញាធរថ្នាក់ណា? ដើម្បីបានប័ណ្ណនេះ អ្នកសុំត្រូវគោរពតាមនីតិវិធីអ្វីខ្លះ?

ដូចដែលលោក-អ្នកស្ដាប់ បានជ្រាបរួចមកហើយ នៅក្នុងកម្មវិធីយល់ដឹងអំពីច្បាប់ លើកមុនថា ការកាន់កាប់ដីធ្លី ឬការកាន់កាប់អចលនវត្ថុជាទូទៅ អាចមានទ្រង់ទ្រាយពីរ៖ ជាការកាន់កាប់ក្នុងឋានៈជាភោគី ឬការកាន់កាប់ក្នុងឋានៈជាម្ចាស់ដី (ឬកម្មសិទ្ធិករ)។

អ្នកកាន់កាប់ដីធ្លី ទោះជាក្នុងរូបភាពណាមួយក៏ដោយ ជាម្ចាស់កម្មសិទ្ធិក៏ដោយ គ្រាន់តែជាភោគីក៏ដោយ សុទ្ធតែមានសិទ្ធិសុំប័ណ្ណកាន់កាប់ ដើម្បីទុកជាភស្តុតាងផ្លូវច្បាប់បញ្ជាក់អំពីសិទ្ធិរបស់ខ្លួនលើដីនេះ។

ដោយការកាន់កាប់ដីធ្លី អាចធ្វើឡើង ក្នុងរូបភាពពីរ ប័ណ្ណកាន់កាប់ក៏មានពីរប្រភេទដែរ៖ គឺប័ណ្ណភោគៈ និងប័ណ្ណកម្មសិទ្ធិ។

ដើម្បីទទួលបានប័ណ្ណនេះ ម្ចាស់ដីត្រូវដាក់ពាក្យសុំទៅការិយាល័យភូមិបាលស្រុក/ខណ្ឌ តាមរយៈមេឃុំ/ចៅសង្កាត់ដែលដីនោះតាំងនៅ។

នៅក្នុងជំហានដំបូង មេឃុំ/ចៅសង្កាត់ ត្រូវធ្វើការបញ្ជាក់លើចំណុចពីរ៖ ទី១ បញ្ជាក់អំពីអត្តសញ្ញាណ ស្ថានភាព និងប្រវត្តិដី (កាលបរិច្ឆេទនៃការចូលកាន់កាប់) និងទី២ គឺបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់ដី (ឈ្មោះ អត្រានុកូលដ្ឋាន ទីលំនៅជាដើម)។

នៅក្នុងករណីដែលម្ចាស់ដី មានទីលំនៅ នៅឃុំ/សង្កាត់ផ្សេង ពីឃុំ/សង្កាត់ ដែលដីតាំងនៅ ការបញ្ជាក់ត្រូវធ្វើឡើងដោយឃុំ/សង្កាត់ពីរ៖ គឺឃុំ/សង្កាត់ ដែលដីតាំងនៅ ជាអ្នកបញ្ជាក់អំពីអត្តសញ្ញាណ និងស្ថានភាពដី ចំណែកឃុំ/សង្កាត់ដែលជាលំនៅរបស់ម្ចាស់ដី គឺជាអ្នកបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់ដី។

បន្ទាប់ពីបាន ទទួលការបញ្ជាក់ពីពីមេឃុំ ឬចៅសង្កាត់រួចរាល់ហើយ ដំណាក់កាលបន្ទាប់មកទៀត គឺសុំទៅសាលាស្រុក/ខណ្ឌ ដែលដីតាំងនៅ ដើម្បីចាត់ចែងឲ្យមន្ត្រីសុរិយោដីស្រុកចុះវាស់វែងកំណត់ព្រំដី។ នៅក្នុងការវាស់វែងនេះ ម្ចាស់ដី គឺជាចង្អុលបង្ហាញអំពីព្រំដី ចំណែកមន្ត្រីសុរិយោដី គ្រាន់តែជាអ្នកវាស់ប៉ុណ្ណោះ។ បន្ទាប់ពីបានវាស់វែងហើយ មន្ត្រីសុរិយោដីស្រុកនឹងរៀបចំគូសប្លង់ក្បាលដី។

គួរបញ្ជាក់ថា នៅក្នុងការកសាងប្លង់សុរិយោដីនេះ សាលាស្រុកត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ដើម្បីទុកឱកាសឲ្យបុគ្គលពាក់ព័ន្ធធ្វើការតវ៉ា។ នៅមុនពេលចុះវាស់វែង ក៏មានការជូនដំណឹងជាសាធារណៈ (១៤ថ្ងៃមុនពេលចុះវាស់)។ នៅក្រោយពេលគូសប្លង់សុរិយោដីរួចហើយ ក៏មានការផ្សព្វផ្សាយជាសាធារណៈជាថ្មីម្តងទៀត អំពីប្លង់ដី និងអត្តសញ្ញាណម្ចាស់ដី។

៣០ថ្ងៃ ក្រោយការប្រកាសផ្សាយនេះ ប្រសិនបើគ្មានការតវ៉ាណាមួយទេនោះ អាជ្ញាធរស្រុក/ខណ្ឌ នឹងបញ្ជូនសំណុំរឿងទៅឲ្យអាជ្ញាធរសុរិយោដីថ្នាក់ខេត្ត/ក្រុង ជាអ្នកពិនិត្យសម្រេចជាចុងក្រោយក្នុងការចេញប័ណ្ណជូនដល់ម្ចាស់សាមុី ដែលជាអ្នកសុំ។

## វគ្គទី៤៣

# តើម្ចាស់ដីអាចបិទផ្លូវឯកជនដែលខ្លួនធ្វើកាត់តាមដីរបស់ខ្លួនមិនឲ្យអ្នកជិតខាងឆ្លងកាត់បានដែរ ឬទេ?

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងពីច្បាប់របស់យើង នៅថ្ងៃនេះ សេង ឌីណា សូមឆ្លើយនឹងសំណួររបស់អ្នកស្តាប់របស់យើងជុំវិញការបើកច្រកផ្លូវចេញចូលដែលកាត់លើដី ដែលជាកម្មសិទ្ធិឯកជន។ តើម្ចាស់ដីជាកម្មសិទ្ធិឯកជននេះអាចបិទច្រកផ្លូវចេញចូលដែលកាត់តាមដីរបស់គាត់បានដែរ ឬទេ?

ខាងក្រោមនេះជាការសង្ខេបដោយត្រួសៗ នូវករណីដែលបានលើកឡើងដោយអ្នកស្តាប់របស់វិទ្យុបារាំងអន្តរជាតិ។

ប្អូនស្រីរបស់គាត់មានដីមួយកន្លែងដែលជាកម្មសិទ្ធិឯកជន ហើយបានធ្វើផ្លូវកាត់ចំកណ្តាលដីនោះ ដើម្បីទុកប្រើប្រាស់សម្រាប់ការដឹកជញ្ជូនភោគផលដំណាំផ្ទាល់ខ្លួនរបស់គាត់។ ក៏ប៉ុន្តែ ក្រោយមកមានម្ចាស់ដីជិតខាង ដែលនៅពីក្រោយដីរបស់គាត់ ក៏បានប្រើប្រាស់ផ្លូវនេះដែរ ដោយមិនមានសុំការអនុញ្ញាត ឬបង់ថ្លៃអ្វីទេ ដោយរាប់ថាជារឿងធម្មតាក្នុងនាមជាអ្នកភូមិផងរបងជាមួយ។

ក៏ប៉ុន្តែ ក្រោយមកទៀត នៅពេលដែលក្រុមយុវជនស្ម័គ្រចិត្តចុះវាស់វែងដីធ្លី ដើម្បីចេញប័ណ្ណកម្មសិទ្ធិឲ្យគាត់ ម្ចាស់ដីជិតខាងនេះក៏បានតវ៉ាមិនឲ្យដាក់ច្រកផ្លូវនេះ ទៅក្នុងប្លង់កម្មសិទ្ធិទេ ដើម្បីទុកជាច្រកផ្លូវសម្រាប់ឆ្លងកាត់។ ដើម្បីជាការសម្រុះសម្រួលគ្នា ហើយអាចវាស់វែងដីធ្លីទទួលប័ណ្ណកម្មសិទ្ធិ គាត់ក៏សុខចិត្តធ្វើកិច្ចសន្យាជាមួយអ្នកជិតខាងរបស់គាត់ដោយព្រមព្រៀងគ្នាថា ច្រកផ្លូវនេះអាចដាក់បញ្ចូលទៅក្នុងប្លង់ដីរបស់គាត់បាន ប៉ុន្តែ គាត់ត្រូវបើកច្រកផ្លូវនេះឲ្យអ្នកជិតខាងរបស់គាត់ប្រើប្រាស់ជារៀងរហូតទៅ។

អ្នកស្តាប់របស់យើងខាងលើនេះបានចោទជាសំណួរថា តើម្ចាស់ដីមានសិទ្ធិយកផ្លូវដែលគាត់ធ្វើលើដីរបស់គាត់ដាក់ក្នុងប័ណ្ណកម្មសិទ្ធិរបស់គាត់ដែរឬទេ? តើគាត់អាចបិទច្រកផ្លូវចេញចូលនេះទាំងស្រុងបានដែរឬទេ? ចុះបើសិនជាគ្រាន់តែធ្វើរបងព័ទ្ធជុំវិញ ដោយទុកទ្វាររបងសម្រាប់ចេញចូល តើអាចធ្វើបានដែរ ឬទេ?

មុននឹងឆ្លើយទៅនឹងសំណួរទាំងនេះ ខ្ញុំសូមបញ្ជាក់ថា មានតែស្ថាប័នមានសមត្ថកិច្ច ជាពិសេសតុលាការទេ ដែលអាចកំណត់ខុសត្រូវពិតប្រាកដបាន តាមរយៈការស្តាប់ការពន្យល់បកស្រាយរបស់គ្រប់ភាគី ដែលពាក់ព័ន្ធពិនិត្យភស្តុតាង និងស្ថានភាពជាក់ស្តែងនៃដី។ ខ្ញុំគ្រាន់តែអាចលើកយកទិដ្ឋភាពផ្នែកច្បាប់ខ្លះៗមកពន្យល់ ដើម្បីជាវិភាគទានក្នុងការពិចារណាតែប៉ុណ្ណោះ។

តាមគោលការណ៍ច្បាប់នៃកម្មសិទ្ធិឯកជន ដីដែលជាកម្មសិទ្ធិឯកជនត្រូវតែស្ថិតនៅជាកម្មសិទ្ធិឯកជន ហើយអ្វីៗដែលនៅលើដីនោះ គឺជាកម្មសិទ្ធិឯកជន ដែលត្រូវដាក់បញ្ចូលក្នុងប័ណ្ណកម្មសិទ្ធិឯកជនទាំងអស់។ ដូច្នេះ មិនមានបុគ្គលឯកជនណាម្នាក់អាចទាមទារយកចំណែកផ្លូវនៅលើដីឯកជន មកដាក់ជាផ្លូវសាធារណៈបានទេ។ លើកលែងតែក្នុងករណី "អស្សាមិករណ៍" មានន័យថា ករណីដែលរដ្ឋដកហូតកម្មសិទ្ធិលើដីឯកជន ដើម្បីយកទៅសាងសង់ ឬពង្រីកហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ។ ការដកហូតកម្មសិទ្ធិឯកជន ក្នុងករណីនេះ ក៏ត្រូវតែមានការដោះស្រាយជាសំណងជាមុនដោយសមរម្យ និងដោយយុត្តិធម៌ ហើយត្រូវធ្វើទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់ដែរ គឺច្បាប់ ស្តីពីអស្សាមិករណ៍ដែលត្រូវបានប្រកាសឲ្យប្រើកាលពីឆ្នាំ២០១០។

ដូច្នេះ ក្នុងករណី ដូចដែលអ្នកស្តាប់របស់យើងបានលើកឡើងខាងលើ ម្ចាស់ដីមានសិទ្ធិដាក់បញ្ចូលផ្លូវដែលគាត់ធ្វើលើដីរបស់គាត់ទៅក្នុងប័ណ្ណកម្មសិទ្ធិរបស់គាត់បាន ហើយដីដែលជាចំណែកផ្លូវនេះ នៅតែជាដីកម្មសិទ្ធិឯកជន មិនមែនជាផ្លូវសាធារណៈទេ។

ក៏ប៉ុន្តែ ក្រមរដ្ឋប្បវេណីខ្មែរ ត្រង់មាត្រា ១៤៤ មានចែងអំពី "សិទ្ធិចេញចូលដីបិទជិត"។

"ដីបិទជិត" ក្នុងន័យនេះ គឺសំដៅទៅលើដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃ ហើយគ្មានច្រកចេញទៅផ្លូវសាធារណៈ ឬក៏មានច្រកចេញចូលដែរ ក៏ប៉ុន្តែ ច្រកចេញចូលនោះមិនគ្រប់គ្រាន់ ឬមានឧបសគ្គខ្លាំង មិនអាចប្រើប្រាស់ដីនោះ សម្រាប់ការធ្វើកសិកម្ម ឬឧស្សាហកម្មបាន។

ក្នុងករណីនេះ ម្ចាស់ដីបិទជិតមានសិទ្ធិស្នើសុំឆ្លងកាត់ដីរបស់អ្នកជិតខាងបាន ប៉ុន្តែ ត្រូវបង់ប្រាក់សំណង តាមការខូចខាត ដែលបង្កឡើងដោយការឆ្លងកាត់នោះ។

ជាគោលការណ៍ ផ្លូវឆ្លងកាត់នេះត្រូវរៀបចំធ្វើទៅតាមទិស ឬផ្លូវ ដែលមានចម្ងាយជិតបំផុតពីដីបិទជិតទៅផ្លូវសាធារណៈ ក៏ប៉ុន្តែ ត្រូវរកវិធីធ្វើយ៉ាងណាឲ្យការឆ្លងកាត់នេះ បង្កការខូចខាតតិចបំផុត ដល់ម្ចាស់ដី ដែលត្រូវឆ្លងកាត់។

ការបើកច្រកឆ្លងកាត់ និងការកំណត់ប្រាក់សំណង អាចធ្វើឡើងតាមរយៈការព្រមព្រៀងគ្នារវាងម្ចាស់ដីជិតខាងទាំងពីរ។ ក្នុងករណីមិនមានការព្រមព្រៀងគ្នាទេ ម្ចាស់ដីបិទជិតអាចស្នើសុំទៅតុលាការឲ្យសម្រេចសេចក្តី។

ចំពោះករណី ដែលបានចោទសួរដោយអ្នកស្តាប់វិទ្យុបារាំងអន្តរជាតិខាងលើ ប្រសិនបើដីអ្នកជិតខាងរបស់គាត់ គឺជាដីបិទជិត ដូចដែលបានកំណត់ក្នុងច្បាប់ ពោលគឺជាដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃ ហើយគ្មានច្រកចេញទៅផ្លូវសាធារណៈសោះ ឬក៏មានច្រកចេញចូលដែរ ក៏ប៉ុន្តែ ច្រកចេញចូលនោះមិនគ្រប់គ្រាន់ ឬមានឧបសគ្គខ្លាំង មិនអាចប្រើប្រាស់ដីនោះ សម្រាប់ការធ្វើកសិកម្ម ឬឧស្សាហកម្មបាន ម្ចាស់ដីបិទជិតនេះមានសិទ្ធិប្រើប្រាស់ផ្លូវ ដែលកាត់តាមដីជិតខាងរបស់គាត់បាន បើទោះបីជាដីនេះជាដីឯកជន ហើយផ្លូវនេះត្រូវបង្កើតឡើង ដើម្បីប្រើប្រាស់ជាលក្ខណៈឯកជនក៏ដោយ។ តាមពិត បើទោះបីជាមិនមានផ្លូវនេះ ក៏ម្ចាស់ដីបិទជិតនោះ អាចស្នើសុំឲ្យធ្វើផ្លូវឆ្លងកាត់ដីនេះបានដែរ ទៅតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី។ ក៏ប៉ុន្តែ ម្ចាស់ដីជិតខាង ដែលជាដីបិទជិតនេះត្រូវបង់ប្រាក់សំណងទៅឲ្យម្ចាស់ដីដែលខ្លួនឆ្លងកាត់ ប្រសិនបើការឆ្លងកាត់នេះ បង្កឲ្យមានការខូចខាតអ្វីមួយ ដូចជា ការខូចខាតដល់ដំណាំ ការខកខានមិនបានប្រើដីជាចំណែកផ្លូវនេះ ដើម្បីធ្វើការដាំដុះ ឬក៏ការរំខានដោយសំឡេងជាដើម។

ម្ចាស់ដី ដែលមានផ្លូវឆ្លងកាត់នេះ អាចធ្វើរបងព័ទ្ធជុំវិញដីរបស់ខ្លួនបាន ក៏ប៉ុន្តែ ត្រូវទុកច្រកផ្លូវឲ្យម្ចាស់ដីជិតខាង ដែលជាដីបិទជិត ឆ្លងកាត់ទៅកាន់ផ្លូវសាធារណៈបាន ដោយមិនអាចបិទច្រកផ្លូវនេះទាំងស្រុងបានទេ។ គាត់អាចបិទច្រកផ្លូវនេះទាំងស្រុងបាន នៅពេលណាដែលដីអ្នកជិតខាងរបស់គាត់ លែងជាដីបិទជិត ដូចជា ក្នុងករណីមានការសង់ផ្លូវសាធារណៈទៅដល់ដីនោះ ជាដើម។

តាមពិត ករណីយកិច្ចបើកច្រកចេញចូលដល់ដីបិទជិតនេះគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះនៃសិទ្ធិ និងករណីយកិច្ច ក្នុងទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីខ្មែរ។ ក្រៅពីករណីដីបិទជិតនេះ នៅមានករណីផ្សេងទៀតដែលស្រដៀងគ្នានេះ គឺទំនាក់ទំនងរវាងដីលើ និងដីក្រោម។

ម្ចាស់ដីលើ ដែលនៅជាប់នឹងផ្លូវទឹកហូរ មានករណីយកិច្ចទុកឲ្យទឹកហូរទៅដីអ្នកជិតខាងដែលនៅខាងក្រោម ទៅតាមតម្រូវការសម្រាប់ប្រកបរបរកសិកម្ម។ ហើយម្ចាស់ដីក្រោម ដែលនៅជាប់នេះ ក៏ត្រូវមានករណីយកិច្ចដូចគ្នាអ៊ីចឹងដែរ ចំពោះម្ចាស់ដី ដែលនៅខាងក្រោមបន្ទាប់ៗទៅទៀត។ ម្ចាស់ដីលើមិនអាចធ្វើទំនប់ទប់ទឹកនេះប្រើតែម្នាក់ឯងបានទេ។

ទោះបីជាក្នុងករណីមិនទាន់មានប្រឡាយទឹកក៏ដោយ ក៏ម្ចាស់ដីក្រោម នៅតែអាចស្នើសុំឲ្យធ្វើប្រឡាយ ឬផ្លូវទឹក ដែលឆ្លងកាត់ដីលើនេះបានដែរ ដើម្បីយកទឹកពីប្រភពទឹកធម្មជាតិណាមួយមកប្រើប្រាស់សម្រាប់ការប្រកបរបរកសិកម្ម ឬឧស្សាហកម្មរបស់គាត់ ដោយគ្រាន់តែត្រូវបង់ប្រាក់សំណងខូចខាតដល់ម្ចាស់ដីលើ ដែលត្រូវឆ្លងកាត់នេះ។

## ផ្នែកទី៤៤

# សិទ្ធិ និងករណីយកិច្ចនៃម្ចាស់ដីដែលមានព្រំប្រទល់ជាប់គ្នា

ដោយ សេង ឌីណា

ពាក្យចាស់លោកថា "អ្នកជិតខាង ភូមិផង របងជាមួយ" ត្រូវចេះរាប់អាន អត់អាស្រ័យគ្នា និងជួយយកអាសារគ្នា។ ក៏ប៉ុន្តែ ពេលខ្លះ រឿង "របងជាមួយ" នេះ ក៏អាចបង្កជាជម្លោះដែរ។ ច្បាប់ភូមិបាលខ្មែរ និងក្រមរដ្ឋប្បវេណីថ្មី ដែលទើបនឹងចូលជាធរមាននាពេលថ្មីៗនេះ មានចែងអំពីវិធានដែលត្រូវអនុវត្ត ដើម្បីបង្ការ និងដោះស្រាយវិវាទ។

**១.តាមច្បាប់របងដែលធ្វើពីលើព្រំប្រទល់ដី៖ តើត្រូវជាកម្មសិទ្ធិរបស់អ្នកណា? អ្នកណាជាអ្នកទទួលបន្ទុកសាងសង់ ថែទាំ និងជួសជុលរបងហ្នឹង?**

ជាគោលការណ៍ កំពែង (រួមមានទាំងរបងផង) ដែលនៅត្រង់ព្រំប្រទល់ដី គឺជាកម្មសិទ្ធិរួមរបស់ម្ចាស់ដីទាំងសងខាង (តាមភាសាច្បាប់គេហៅថា របងអវិភាជ្យសិទ្ធិ)។ ក្នុងករណីនេះ ម្ចាស់ដីទាំងសងខាងត្រូវទទួលបន្ទុកចំណាយក្នុងការសង់ ជួសជុល ថែទាំ ចាត់ចែង និងប្រើប្រាស់របងនេះរួមគ្នា។

*មាត្រា ២២៣ នៃក្រមរដ្ឋប្បវេណី៖ "កំពែងទាំងអស់ដែលនៅត្រង់ព្រំខ័ណ្ឌអចលនវត្ថុ ត្រូវសន្មត់ថា ជាវត្ថុអវិភាជ្យសិទ្ធិរបស់កម្មសិទ្ធិករនៃអចលនវត្ថុនីមួយ"។*

ម្ចាស់ដីម្ខាងអាចដកខ្លួនពីការទទួលបន្ទុកចំណាយខាងលើនេះបាន ក៏ប៉ុន្តែ ត្រូវបោះបង់អវិភាជ្យសិទ្ធិរបស់ខ្លួន (មាត្រា ២២៤)។ ក្នុងករណីនេះ ម្ចាស់ដីម្ខាងទៀត ដែលជាអ្នកទទួលបន្ទុកចំណាយតែម្នាក់ឯង លើការសាងសង់ ជួសជុល និងថែទាំរបង គឺជាម្ចាស់កម្មសិទ្ធិដោយផ្តាច់មុខលើរបងនេះ។ គាត់អាចប្រើប្រាស់ កែប្រែ ឬរុះរើរបងនេះបាន ដោយមិនចាំបាច់មានការឯកភាពពីម្ចាស់ដីម្ខាងទៀតទេ។

**២.នៅក្នុងករណីនេះ តើម្ចាស់ដីម្ខាង អាចជំទាស់មិនឲ្យម្ចាស់ដីម្ខាងទៀត សង់របងនៅលើព្រំដីបានដែរ ឬទេ?**

បើសិនជារបងនេះ សង់ត្រឹមតែក្នុងដីគេ ឬត្រឹមតែពីលើព្រំប្រទល់ដី ដោយមិនមានលយចូលមកក្នុងដីរបស់គាត់ទេ ម្ចាស់ដីជិតខាងនេះមិនអាចជំទាស់នឹងការសាងសង់នេះបានទេ។

លើសពីនេះទៅទៀត នៅក្នុងការសាងសង់ ថែទាំ ឬជួសជុលរបងនេះ ម្ចាស់របងមានសិទ្ធិទាមទារប្រើដីអ្នកជិតខាងបានក្នុងទំហំមួយដែលចាំបាច់ ដោយគ្រាន់តែត្រូវសងសំណងខូចខាតទៅម្ចាស់ដីជិតខាង បើសិនជាមានការខូចខាតអ្វីមួយ (ដូចជាបាក់ដី ខូងដី បាក់ដើមឈើ ឬខូចខាតដំណាំ ជាដើម)។

*មាត្រា ១៤៣៖ "កម្មសិទ្ធិករនៃដីអាចទាមទារប្រើដីដែលជាប់គ្នាបាន ក្នុងទំហំចាំបាច់ ដើម្បីធ្វើរបង ឬសង់សំណង់ ឬជួសជុលរបស់ទាំងពីរនេះ នៅព្រំប្រទល់ដី ឬនៅក្បែរព្រំប្រទល់នោះ។ ប្រសិនបើអ្នកជិតខាងទទួលការខូចខាត ដោយសារការសងសង់ ឬជួសជុលនេះ កម្មសិទ្ធិករនៃដីត្រូវបង់ប្រាក់សំណង"។*

**៣.ក្នុងករណីដែលរបងសង់រួចរាល់ហើយ តើម្ចាស់ដីជិតខាងដែលមិនបានសហការសង់ អាចទាមទារឲ្យដាក់របងនេះជាកម្មសិទ្ធិរួមវិញបានដែរ ឬទេ?**

*មាត្រា ២២៥៖ "កម្មសិទ្ធិករដែលមានអចលនវត្ថុជាប់នឹងកំពែង ក្រៅពីជញ្ជាំង ដែលមិនមែនជាវត្ថុអវិភាជ្យសិទ្ធិ មិនអាចទាមទារឲ្យកម្មសិទ្ធិករនៃកំពែងនោះធ្វើជាវត្ថុអវិភាជ្យសិទ្ធិ បានឡើយ"។*

ដូច្នេះ តាមន័យនេះ ម្ចាស់ដីជិតខាង ដែលមិនបានសហការសង់របង មិនអាចទាមទារឲ្យដាក់របងនេះជាកម្មសិទ្ធិរួម (វត្ថុអវិភាជ្យសិទ្ធិ) បានទេ។

វាខុសពីករណីជញ្ជាំង ឧទាហរណ៍ ដូចជាក្នុងករណីជញ្ជាំងផ្ទះល្វែង ជាដើម។ ក្នុងករណីនេះ ប្រសិនបើម្ចាស់ដីម្ខាងបានសង់ផ្ទះរបស់គាត់រួចហើយ ដោយជញ្ជាំងផ្ទះនេះស្ថិតនៅជាប់នឹងព្រំប្រទល់ដី។ ក្រោយមកម្ចាស់ដីម្ខាងទៀតចង់សង់ផ្ទះល្វែងមួយដែរ គាត់អាចទាមទារយកជញ្ជាំងផ្ទះអ្នកជិតខាងរបស់គាត់មកធ្វើជា ជញ្ជាំងរួមបាន (មានន័យថាជាជញ្ជាំងអវិភាជ្យសិទ្ធិ)។ ប៉ុន្តែ គាត់ត្រូវបង់ទៅឲ្យម្ចាស់ជញ្ជាំងនូវចំណែកពាក់កណ្ដាលនៃថ្លៃជញ្ជាំង បូកជាមួយនឹងពាក់កណ្ដាលនៃថ្លៃដី ដែលនៅក្រោមជញ្ជាំងនោះ។

*មាត្រា ២២០៖ "កម្មសិទ្ធិករនៃដីដែលជាប់នឹងជញ្ជាំង អាចធ្វើជញ្ជាំងនោះឲ្យទៅជាជញ្ជាំងអវិភាជ្យសិទ្ធិបាន ដោយចេញពាក់កណ្ដាលនៃថ្លៃជញ្ជាំងនោះ និងពាក់កណ្ដាលនៃថ្លៃដីដែលសង់ជញ្ជាំងពីលើនោះ"។*

**៤.និយាយពីដើមឈើដែលដាំនៅក្បែរព្រំដីវិញ។ ដើមឈើ ដែលដាំនៅក្នុងដីម្ខាង ហើយមែក ឬក៏ឫសឈើនោះឆ្លងទៅដីម្ខាងទៀត តើម្ចាស់ដីនោះមានសិទ្ធិកាប់មែក ឬឫសឈើដែលឆ្លងទៅនោះបានដែរ ឬទេ?**

ក្នុងករណីនេះ ម្ចាស់ដីជិតខាងនោះអាចយកផលពីមែកឈើ ឬឫសឈើនោះក៏បាន (ដូចជា អាចបេះផ្លែពីមែកឈើដែលឆ្លងចូលទៅដីរបស់គាត់នោះ) ហើយអាចកាប់មែកឈើ ឬឫសឈើដែលលយចូលនោះចោលក៏បាន។

*មាត្រា ១៤២៖ "នៅពេលដែលមែកឈើ ឬឫសឈើនៃដីជិតខាង បានលយចូលមកដីរបស់ខ្លួន កម្មសិទ្ធិករនៃដីអាចយកផលពីមែកឈើ ឬឫសឈើនោះ ឬកាប់មែកឈើ ឬឫសឈើនោះបាន"។*

ម៉្យាងទៀត បើសិនជាដើមឈើនោះដាំក្បែរព្រំប្រទល់ដីពេក ដោយមិនគោរពតាមចម្ងាយដែលកំណត់ដោយច្បាប់ ម្ចាស់ដីជិតខាងអាចទាមទារឲ្យម្ចាស់ដើមឈើ កាប់ដើមឈើនោះចោលបាន។

ចម្ងាយដើមឈើពីព្រំប្រទល់ដី ដែលបានកំណត់ក្នុងមាត្រា ១៥៤ នៃក្រមរដ្ឋប្បវេណី គឺ យ៉ាងតិច ២ម៉ែត្រ ពីព្រំប្រទល់ដី បើសិនជាដើមឈើនោះមានកម្ពស់លើសពី ២ម៉ែត្រ។

*មាត្រា ១៥៤៖ "កម្មសិទ្ធិករនៃដីមិនអាចដាំដើមឈើ គុម្ពោត ឬចុល្លព្រឹក្សដែលមានកម្ពស់លើសពី ២ម៉ែត្រ ក្នុងចម្ងាយ ២ម៉ែត្រ ពីព្រំប្រទល់ដីអ្នកជិតខាងបានឡើយ។ ក្នុងករណីដែលធ្វើផ្ទុយពីបញ្ញត្តិនេះ កម្មសិទ្ធិករនេះមានករណីយកិច្ចដកចេញ តាមការទាមទាររបស់កម្មសិទ្ធិករនៃដីជិតខាង"។*

គួរបញ្ជាក់បន្ថែមថា ឲ្យតែដើមឈើនោះកម្ពស់លើសពី ២ម៉ែត្រ ហើយដាំតិចជាង ២ម៉ែត្រពីព្រំប្រទល់ដី ទោះបីមិនមានមែកឈើ ឬក៏ឫសឈើលយចូលទៅដីអ្នកជិតខាងក៏ដោយ ក៏ម្ចាស់ដីជិតខាងអាចទាមទារឲ្យកាប់ដើមឈើនេះចោលបានដែរ។

**៥.ចុះចំពោះម្ចាស់ដី ដែលចង់ដាំដើមឈើនៅពីលើព្រំប្រទល់ដី ដើម្បីធ្វើជារបងតែម្ដង តើអាចធ្វើបានដែរ ឬទេ?**

អាចធ្វើទៅបាន ឲ្យតែដើមឈើនោះមានកម្ពស់មិនលើសពី ២ម៉ែត្រ! ប្រសិនបើដើមឈើ នោះ មានកម្ពស់លើសពី ២ម៉ែត្រ ក៏ប៉ុន្តែ ម្ចាស់ដីទាំងសងខាងព្រមព្រៀងគ្នាឲ្យដាំធ្វើជារបង គឺអាចដាំបាន។

គួរបញ្ជាក់ថា គោលដៅនៃច្បាប់រដ្ឋប្បវេណីមិនមែនចែងជាបម្រាមដាច់ខាតទេ ប៉ុន្តែចែងដើម្បីបង្ការ និងដោះស្រាយវិវាទ។ បើសិនជាម្ចាស់ដីទាំងសងខាងរស់នៅសុខស្រួលនឹងគ្នា ធ្វើអ្វីដោយមានការព្រមព្រៀងគ្នា ក៏គ្មានអ្នកណាមកចាប់បង្ខំឲ្យត្រូវតែធ្វើតាមអ្វីដែលមានចែងក្នុងរដ្ឋប្បវេណីនោះដែរ។ ក៏ប៉ុន្តែ តែកាលណាមានវិវាទនឹងគ្នា មិនអាចស្រុះស្រួលគ្នាទេ គេត្រូវយកច្បាប់រដ្ឋប្បវេណីនេះមកធ្វើជាគោលក្នុងការដោះស្រាយ។

**៦.ចំពោះដីបិទជិត ដែលមិនមានច្រកចេញចូលទៅផ្លូវសាធារណៈតើម្ចាស់ដីនោះមានសិទ្ធិទាមទារឲ្យម្ចាស់ដីដែលនៅជុំវិញបើកច្រកចេញចូលទៅផ្លូវសាធារណៈដែរ ឬទេ?**

ទោះបីជាដីភូមិសម្រាប់រស់នៅក៏ដោយ ដីសម្រាប់ប្រកបរបរកសិកម្ម ឬឧស្សាហកម្មក៏ដោយ បើសិនជាដីនោះត្រូវព័ទ្ធជុំជិត មិនមានច្រកចេញចូលទៅផ្លូវសាធារណៈទេ ឬមានដែរ ប៉ុន្តែ ច្រកចេញចូលនោះវាតូចចង្អៀតពេក ឬក៏វាមានឧបសគ្គមិនអាចចេញចូល ដើម្បីប្រើប្រាស់ដីនោះសម្រាប់រស់នៅ ឬសម្រាប់ធ្វើកសិកម្ម ឬឧស្សាហកម្មទេ ម្ចាស់ដីបិទជិតនោះមានសិទ្ធិទាមទារឲ្យបើកច្រកចេញចូល ឆ្លងកាត់ដីជិតខាងបាន ប៉ុន្តែ ត្រូវបង់ប្រាក់សំណងទៅតាមការខូចខាត ដោយសារការឆ្លងកាត់នោះ។

ការបើកច្រកចេញចូលនេះ ត្រូវធ្វើនៅកន្លែងណាដែលបង្កការខូចខាតតិចបំផុតដល់ម្ចាស់ដីជិតខាង ដែលត្រូវឆ្លងកាត់ ហើយត្រូវបើកទៅតាមទិសណា ដែលមានចម្ងាយជិតបំផុតពីដីបិទជិតទៅផ្លូវសាធារណៈ។

*មាត្រា ១៤៤៖*

*“១-ដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃ ហើយគ្មានច្រកចេញទៅផ្លូវសាធារណៈ និងដីដែលមានច្រកចេញនោះមិនគ្រប់គ្រាន់ ហើយមានឧបសគ្គដ៏ខ្លាំង ដើម្បីប្រើប្រាស់ដីនោះ សម្រាប់ការធ្វើកសិកម្ម ឬឧស្សាហកម្ម ហៅថា ដីបិទជិត។*

*២-កម្មសិទ្ធិករនៃដីបិទជិត មានសិទ្ធិស្នើសុំឆ្លងកាត់ដីអ្នកជិតខាងបាន ដោយបង់ប្រាក់សំណង តាមការខូចខាតដោយសារការឆ្លងកាត់នោះ។*

*៣-ជាគោលការណ៍ សិទ្ធិឆ្លងកាត់នេះ ត្រូវរៀបចំតាមទិស ឬផ្លូវដែលមានចម្ងាយជិតបំផុតពីដីបិទជិតទៅផ្លូវសាធារណៈ។ ទោះបីជាមានបញ្ញត្តិនៃវាក្យខណ្ឌទី១ នៃកថាខណ្ឌនេះក៏ដោយ សិទ្ធិឆ្លងកាត់នេះត្រូវតែរៀបចំនៅកន្លែងណា ដែលមានការខូចខាតតិចបំផុត សម្រាប់កម្មសិទ្ធិករនៃដីដែលទទួលបន្ទុកឲ្យឆ្លងកាត់នោះ”។*

**៧.តើម្ចាស់ដីលើ មានសិទ្ធិធ្វើទំនប់ទប់ទឹកមិនឲ្យហូរទៅដីក្រោមដែរឬទេ?**

ម្ចាស់ដី ដែលនៅជាប់នឹងផ្លូវទឹកហូរ មិនអាចធ្វើទំនប់ទប់ទឹកនេះប្រើតែម្នាក់ឯងបានទេ។ គាត់មានករណីយកិច្ចទុកឲ្យទឹកហូរទៅដីអ្នកជិតខាងដែលនៅខាងក្រោម ទៅតាមតម្រូវការសម្រាប់ប្រកបរបរកសិកម្ម។ ហើយម្ចាស់ដីក្រោម ដែលនៅជាប់នេះ ក៏ត្រូវមានករណីយកិច្ចដូចគ្នាអ៊ីចឹងដែរ ចំពោះម្ចាស់ដី ដែលនៅបន្ទាប់ៗទៅទៀត។

ករណីមិនមានផ្លូវនាំទឹកពីប្រភពទឹកធម្មជាតិទៅដីក្រោម។ ឧទាហរណ៍ថា នៅខាងលើមានបឹងធម្មជាតិមួយ។ ម្ចាស់ដីនៅខាងក្រោមត្រូវការទឹក ដើម្បីធ្វើស្រែ ឬធ្វើចម្ការ ក៏ប៉ុន្តែ មិនមានប្រឡាយ ឬផ្លូវទឹកណាមួយនាំទឹកពីបឹងនោះ មកដីគាត់ទេ។ ហើយនៅចន្លោះពីបឹង មកដីរបស់គាត់ សុទ្ធតែជាដីរបស់ម្ចាស់ផ្សេង។ ក្នុងករណីនេះ ម្ចាស់ដីក្រោម អាចទាមទារសុំធ្វើប្រឡាយ ឬផ្លូវទឹកផ្សេងទៀត ឆ្លងកាត់ដីលើនេះបាន ដើម្បីយកទឹកពីបឹងមកប្រើប្រាស់ ប៉ុន្តែ ត្រូវបង់ប្រាក់សំណងខូចខាតដល់ម្ចាស់ដីលើ ដែលត្រូវឆ្លងកាត់។

*មាត្រា ១៤៧៖ “កម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់ផ្លូវទឹកហូរ មានករណីយកិច្ចទុកឲ្យទឹកហូរទៅលើដីអ្នកជិតខាងតាមតម្រូវការនៃកសិកម្ម ហើយកម្មសិទ្ធិករនៃដីជិតខាងក៏មានករណីយកិច្ចដូចគ្នាដែរ ដោយយោគយល់ចំពោះដីដែលនៅឆ្ងាយទៀត”។*

*មាត្រា ១៤៨៖ “កម្មសិទ្ធិករដែលចង់ឲ្យទឹកដែលខ្លួនមានសិទ្ធិប្រើប្រាស់ ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើ និងរក្សាទុកនូវផ្លូវទឹកឆ្លងកាត់ដីដែលស្ថិតនៅចន្លោះប្រភពទឹកនិង ដីរបស់ខ្លួនបាន ដោយបង់ប្រាក់សំណងនៃការខូចខាតដល់កម្មសិទ្ធិករនៃដីដែលត្រូវ ឆ្លងកាត់នោះ”។*

នៅក្នុងករណីមានទឹកពីធម្មជាតិច្រើនហួសពីតម្រូវការ (ដែលអាចបណ្តាលឲ្យជនលិចដី) ម្ចាស់ដីក្រោមមានករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិពីដីលើ ដោយមិនអាចធ្វើទំនប់ ឬក៏លើកភ្លឺ ទប់ទឹកមិនឲ្យហូរ បណ្តាលឲ្យទឹកចាល់ជន់

លិចដីលើបានទេ។ ម្ចាស់ដីលើក៏មិនអាចជីកប្រឡាយ ឬក៏ធ្វើអ្វីផ្សេងទៀតឲ្យលើសពីលក្ខណៈធម្មជាតិ ដើម្បីបណ្តោះទឹកពីដីរបស់ខ្លួនឲ្យហូរទៅជន់លិចដីខាងក្រោមបានដែរ គឺត្រូវទុកឲ្យទឹកហូរទៅតាមធម្មជាតិ។

*មាត្រា ១៤៥៖ "កម្មសិទ្ធិករនៃដីក្រោមមានករណីយកិច្ចទទួលទឹកដែលហូរតាមធម្មជាតិ ពីដីលើ។ កម្មសិទ្ធិករនៃដីក្រោមមិនអាចលើកទំនប់ ភ្លឺ របាំង ឬការផ្សេងទៀតទប់មិនឲ្យទឹកហូរបានឡើយ។ កម្មសិទ្ធិករនៃដីលើមិនអាចធ្វើអំពើអ្វីបន្ថែមបន្ទុករបស់ កម្មសិទ្ធិករនៃដីក្រោមបានឡើយ"*។

## ផ្នែកទី៤៥

## ឆ្លើយនឹងសំណួរអ្នកស្តាប់ជុំវិញកិច្ចសន្យាជួលអចលនវត្ថុ

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងអំពីច្បាប់របស់យើង នៅថ្ងៃនេះ សេង ឌីណា សូមឆ្លើយនឹងសំណួរមួយចំនួនរបស់អ្នកស្តាប់ជុំវិញកិច្ចសន្យាជួលផ្ទះ ឬដី ដែលវិទ្យុយើងបានលើកយកមកពន្យល់ កាលពីថ្ងៃព្រហស្បតិ៍មុន។

**១. ជាទូទៅអ្នកជួលតែងតែកក់លុយមួយចំនួនទៅម្ចាស់អចលនវត្ថុ នៅពេលចាប់ផ្តើមកិច្ចសន្យាជួល។ បើសិនជាកិច្ចសន្យានេះគឺជាកិច្ចសន្យាជួលដោយមានកំណត់ពេល ហើយភាគីអ្នកជួលស្នើសុំបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ដោយជូនដំណឹងដល់ម្ចាស់វត្ថុទៅតាមពេលកំណត់ដោយច្បាប់ តើអ្នកជួលអាចទទួលលុយកក់នេះមកវិញបានដែរ ឬទេ?**

ចំពោះការបញ្ចប់កិច្ចសន្យាជួលមុនកាលកំណត់នេះ ច្បាប់ចែងតែលក្ខខណ្ឌពីរប៉ុណ្ណោះ(មាត្រា ៦១៦ នៃក្រមរដ្ឋប្បវេណី) ៖

- ភាគីម្ខាង (អ្នកជួល ឬក៏ម្ចាស់វត្ថុ) អាចស្នើសុំបញ្ចប់កិច្ចសន្យាមុនផុតកំណត់បាន ប្រសិនបើនៅពេលចុះកិច្ចសន្យាគូភាគីបានកំណត់ជាមុនថារក្សាទុកសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់។
- ហើយការស្នើសុំបញ្ចប់កិច្ចសន្យានេះត្រូវមានការជូនដំណឹងទៅភាគីម្ខាងទៀត យ៉ាងតិច ៣ខែ (សម្រាប់ផ្ទះ ឬអគារផ្សេងទៀត) និង យ៉ាងតិច ១ឆ្នាំ សម្រាប់ដីធ្លី។

បើមើលទៅលើអ្វីដែលមានចែងក្នុងមាត្រានេះ យើងអាចសន្និដ្ឋានបានថា ឲ្យតែគូភាគីបានរក្សាសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ហើយការស្នើសុំបញ្ចប់កិច្ចសន្យាបានធ្វើឡើងដោយមានការជូនដំណឹងទៅភាគីម្ខាងទៀត ទៅតាមពេលវេលាដែលកំណត់ខាងលើនេះ អ្នកស្នើសុំបញ្ចប់កិច្ចសន្យានេះ មិនមានកាតព្វកិច្ចត្រូវបង់ថ្លៃអ្វីបន្ថែមទៀតទេ។ ដូច្នេះ ដើម្បីឆ្លើយនឹងសំណួរខាងលើ អ្នកជួលត្រូវមានសិទ្ធិទទួលលុយកក់មកវិញបាន។

ក៏ប៉ុន្តែ បើសិនជាអ្នកជួលបានបង្កការខូចខាតអ្វីមួយទៅលើវត្ថុជួល ម្ចាស់វត្ថុអាចកាត់លុយកក់នេះទុកជាសំណងទៅតាមទំហំនៃការខូចខាតនេះ។

ទាក់ទងនឹងការកាត់លុយកក់ ធ្វើជាសំណងខូចខាតលើវត្ថុជួលនេះ ដើម្បីចៀសវាងកុំឲ្យមានវិវាទ ម្ចាស់វត្ថុ និងអ្នកជួលគួរតែទៅពិនិត្យមើលស្ថានភាពវត្ថុទាំងអស់គ្នា ដើម្បីមើលឲ្យឃើញទាំងអស់គ្នាថា តើវត្ថុនេះមានស្ថានភាពដើមយ៉ាងដូចម្តេចនៅមុនពេលអ្នកជួលចូលប្រើប្រាស់ និងអាស្រ័យផល? របាយការណ៍អំពីស្ថានភាពវត្ថុជួលនេះ គួរតែធ្វើជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខាពីភាគីទាំងសងខាង។

ដល់ពេលបញ្ចប់កិច្ចសន្យាជួល ភាគីទាំងពីរត្រូវទៅពិនិត្យមើលស្ថានភាពវត្ថុជួលម្តងទៀត ដើម្បីប្រៀបធៀបមើលថាតើវត្ថុជួលនេះមានការខូចខាតអ្វីខុសពីស្ថានភាពដើមដែរឬទេ? បើសិនជាមានការខូចខាត សួរថា តើខូចខាតដោយសារអ្វី?

បើជាការខូចខាតដោយសារការប្រើប្រាស់ជាធម្មតា ឬខូចខាតទៅតាមអាយុកាលជាធម្មតារបស់វត្ថុជួល នេះមិនរាប់ថាជាកំហុសរបស់អ្នកជួលទេ។ ដូច្នេះ អ្នកជួលត្រូវមានសិទ្ធិទទួលលុយកក់មកវិញ។

ផ្ទុយទៅវិញ បើវាជាការខូចខាតដោយសារទង្វើរបស់អ្នកជួល ឬដោយសារតែអ្នកជួលប្រើប្រាស់មិនស្របតាមកិច្ចសន្យា ឬប្រើប្រាស់ដោយមិនបានថែទាំដិតដល់ ទៅតាមករណីយកិច្ចជាអ្នកជួល ក្នុងករណីនេះ អ្នកជួលគឺជាអ្នកត្រូវទទួលខុសត្រូវ ហើយម្ចាស់វត្ថុអាចកាត់លុយកក់ទុក ដើម្បីធ្វើជាសំណង (អាចកាត់ទុកទាំងអស់ ឬមួយផ្នែក ទៅតាមទំហំនៃការខូចខាត)។

**២.ក្នុងពេលដែលកិច្ចសន្យាជួលដោយមានពេលកំណត់ កំពុងមានសុពលភាពនៅឡើយ តើភាគីម្ចាស់អចលនវត្ថុអាចលក់ ឬផ្ទេរសិទ្ធិលើអចលនវត្ថុនោះ ដោយមិនជូនដំណឹងជាមុនដល់អ្នកជួលបានដែរ ឬទេ?**

ចំពោះរឿងនេះ យើងត្រូវបែងចែកជាពីរករណី៖

ករណីទី១ ប្រសិនបើម្ចាស់អចលនវត្ថុចង់លក់ ឬផ្ទេរសិទ្ធិលើអចលនវត្ថុ ដោយមិនចង់ឲ្យមានជាប់កិច្ចសន្យាជួលលើអចលនវត្ថុនេះ ផ្ទេរបន្តទៅអ្នកទិញទេ គាត់ត្រូវសុំរំលាយកិច្ចសន្យានេះជាមុនសិន។ ដើម្បីអាចរំលាយកិច្ចសន្យានេះមុនកាលកំណត់បាន ម្ចាស់អចលនវត្ថុត្រូវគោរពទៅតាមលក្ខខណ្ឌទាំងពីរខាងលើ ពោលគឺ៖

- នៅក្នុងកិច្ចសន្យា ត្រូវមានចែងអំពីការរក្សាសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់
- ត្រូវជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យានេះ ទៅភាគីអ្នកជួល យ៉ាងតិច ៣ខែ (សម្រាប់អគារ) ឬយ៉ាងតិច ១ឆ្នាំ (សម្រាប់ដីធ្លី)

ក្នុងករណីនេះ ម្ចាស់វត្ថុអាចចុះហត្ថលេខាលក់ ឬផ្ទេរសិទ្ធិភ្លាមៗបាន ក៏ប៉ុន្តែ ត្រូវរង់ចាំរហូតទាល់តែផុតរយៈពេលខាងលើនេះ ទើបកិច្ចសន្យាជួលត្រូវបញ្ចប់ ហើយម្ចាស់វត្ថុអាចផ្ទេរអចលនវត្ថុនេះទៅឲ្យអ្នកទិញបាន។

ករណីទី២ ប្រសិនបើម្ចាស់អចលនវត្ថុចង់លក់ ឬផ្ទេរសិទ្ធិលើអចលនវត្ថុជួល ដោយផ្ទេរទាំងកិច្ចសន្យាជួលទៅជាមួយ គាត់មិនចាំបាច់ជូនដំណឹងទៅអ្នកជួលក៏បានដែរ។ ក៏ប៉ុន្តែ គាត់ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីកិច្ចសន្យាជួលនេះ ជាមួយអ្នកទិញ ឬអ្នកទទួលសិទ្ធិបន្ត ពីព្រោះថា អ្នកទិញ ឬអ្នកទទួលសិទ្ធិបន្តពីម្ចាស់អចលនវត្ថុ ត្រូវបន្តគោរពកិច្ចសន្យាជួលនេះក្នុងលក្ខខណ្ឌដដែល (ថ្លៃឈ្នួល និងរយៈពេលជួលដដែល) ពោលគឺ អ្នកទិញ ឬអ្នកទទួលសិទ្ធិបន្តនេះ ត្រូវក្លាយទៅជាគូភាគីក្នុងកិច្ចសន្យាជួល៖

- គាត់ត្រូវជាប់កាតព្វកិច្ចក្នុងឋានៈជាភាគីអ្នកឲ្យជួល (ភាគីម្ចាស់វត្ថុ)។ បើសិនជាត្រូវមានការជួសជុល ដែលជាកាតព្វកិច្ចរបស់ម្ចាស់វត្ថុ គឺគាត់ត្រូវទទួលបន្ទុកជួសជុល
- គាត់ត្រូវមានសិទ្ធិជាអ្នកទទួលថ្លៃឈ្នួលដែលអ្នកជួលត្រូវបង់
- បើសិនជាគាត់ចង់រំលាយកិច្ចសន្យាជួលនេះ គាត់ត្រូវគោរពទៅតាមលក្ខខណ្ឌដែលច្បាប់កំណត់ដូចជាម្ចាស់អចលនវត្ថុពីមុនដែរ

**៣.ចំពោះភាគីអ្នកជួលវិញ តើគាត់អាចផ្ទេរសិទ្ធិជួល ឬជួលបន្តទៅអ្នកដទៃ ដោយគ្មានការយល់ព្រមពីម្ចាស់អចលនវត្ថុបានដែរ ឬទេ?**

ចំពោះកិច្ចសន្យាជួលទូទៅ អ្នកជួលមិនអាចផ្ទេរសិទ្ធិជួល ឬជួលបន្តទៅឲ្យអ្នកដទៃបានទេ បើមិនមានការយល់ព្រមពីម្ចាស់អចលនវត្ថុ។ មានន័យថា ចង់ជួលបន្តក៏ត្រូវមានការយល់ព្រមពីម្ចាស់អចលនវត្ថុ។ ចង់ផ្ទេរសិទ្ធិទៅឲ្យអ្នកដទៃប្រើប្រាស់ ឬអាស្រ័យផលលើអចលនវត្ថុជួល ក៏ចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់អចលនវត្ថុ។ បើមិនដូច្នោះទេ ម្ចាស់វត្ថុអាចរំលាយកិច្ចសន្យាជួលនេះចោលបាន។

លើកលែងតែក្នុងករណីជួលអចិន្ត្រៃយ៍ ពោលគឺ កិច្ចសន្យាជួលអចលនវត្ថុ ដែលមានរយៈពេលចាប់ពី ១៥ឆ្នាំឡើងទៅ (មាត្រា ២៤៤ ស្តីពីនិយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍)។ ក្នុងករណីជួលអចិន្ត្រៃយ៍ មាត្រា ២៥២ ចែងផ្តល់សិទ្ធិឲ្យអ្នកជួលអាចយកអចលនវត្ថុទៅជួលបន្តក៏បាន ឬក៏ផ្ទេរសិទ្ធិឲ្យអ្នកដទៃប្រើប្រាស់ ឬអាស្រ័យផលលើអចលនវត្ថុនេះ ដោយឥតយកថ្លៃក៏បាន ដោយមិនចាំបាច់ទៅសុំការយល់ព្រមពីម្ចាស់វត្ថុជាមុនទេ។

# ផ្នែកទី៤៦

# ការកាន់កាប់អចលនវត្ថុដោយគ្មានប័ណ្ណកម្មសិទ្ធិ

*បកស្រាយដោយបណ្ឌិត ហ៊ែល ចំរើន*

ដោយ សេង ឌីណា

បញ្ហាដីធ្លី នៅតែជារឿងចម្រូងចម្រាស់មួយនៅប្រទេសកម្ពុជា។ របបកម្មសិទ្ធិចាស់ មុនឆ្នាំ១៩៧៩ ត្រូវបានលុបចោល។ អ្នកដែលកាន់កាប់ដីធ្លី ក្រោយឆ្នាំ១៩៧៩ នៅតែមានច្រើន ដែលកាន់កាប់ដោយគ្មានប័ណ្ណសម្គាល់កម្មសិទ្ធិ។ វិវាទបានកើតឡើងជាញឹកញាប់ ជុំវិញបញ្ហាដីធ្លីនេះ។ ហេតុដូច្នេះហើយបានជា នៅក្នុងនាទីយល់ដឹងអំពីច្បាប់ វិទ្យុយើងលើកយកបញ្ហាដីធ្លីមកនិយាយមុនគេ ដោយចាប់ផ្តើមដំបូង អំពីការកាន់កាប់ដី ដោយមិនមានប័ណ្ណ ដោយមានការឆ្លើយបំភ្លឺពីបណ្ឌិត ហ៊ែល ចំរើន។

**១. ខ្ញុំកាន់កាប់ដីមួយកន្លែងតាំងពីឆ្នាំ ១៩៧៩មក។ ជាការកាន់កាប់ដោយស្របច្បាប់ ក៏ប៉ុន្តែ មិនមានប័ណ្ណកម្មសិទ្ធិ។ តើខ្ញុំមានសិទ្ធិជាអ្វីលើដីនេះ?**

អ្នកដែលបានកាន់កាប់ដី ឬអចលនវត្ថុផ្សេងទៀត ពីឆ្នាំ១៩៧៩មក បើសិនជាមិនទាន់មានប័ណ្ណកម្មសិទ្ធិចេញដោយអាជ្ញាធរមានសមត្ថកិច្ចទេ អ្នកនោះមិនមែនជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុនេះទេ គឺមានសិទ្ធិត្រឹមតែជាភោគី (អ្នកកាន់កាប់ស្របច្បាប់) ប៉ុណ្ណោះ។

**២.ក្នុងឋានៈជាភោគី តើខ្ញុំមានសិទ្ធិអ្វីខ្លះលើដីនេះ?**

ភោគី មានសិទ្ធិប្រហាក់ប្រហែលនឹងម្ចាស់កម្មសិទ្ធិដែរ ពោលគឺមានសិទ្ធិប្រើប្រាស់ អាស្រ័យនៅ ដាំដុះ ប្រវាស់ ជួល បញ្ចាំ លក់ ឬផ្ទេរទៅឲ្យកូនចៅ ។ល។

នៅក្នុងករណីមានការផ្ទេរកម្មសិទ្ធិនេះ អ្នកទទួលអចលនវត្ថុពីភោគី គឺទទួលបានត្រឹមតែសិទ្ធិជាភោគីដដែល មិនមែនជាម្ចាស់កម្មសិទ្ធិនោះទេ។

ភោគី និងកម្មសិទ្ធិករ មានទំហំសិទ្ធិដូចគ្នា។ អ្វីដែលខុសគ្នា គឺនៅត្រង់ថា សិទ្ធិជាកម្មសិទ្ធិករគឺជាសិទ្ធិស្ថាពរ ហើយអាចទទួលបានការគាំពារពីច្បាប់ ដោយពេញលេញ។ ចំណែកសិទ្ធិជាភោគីវិញ គឺជាសិទ្ធិ ដែលមានលក្ខណៈបណ្តោះអាសន្ន ដែលអាចមានការជំទាស់តវ៉ាបានទៅថ្ងៃក្រោយ។

**៣.តើភោគីអាចក្លាយជាកម្មសិទ្ធិករបានដែរ ឬទេ?**

បាន! ប្រសិនបើការកាន់កាប់នេះ ធ្វើឡើងដោយស្របច្បាប់ ដោយគោរពតាមលក្ខខណ្ឌ ៥៖

- កាន់កាប់ដោយពិតប្រាកដ ពោលគឺ មិនមែនជាការកាន់កាប់ ក្នុងឋានៈជាអ្នកចាំដី ចាំផ្ទះ ឬចាំចម្ការឲ្យគេ
- កាន់កាប់ដោយគ្មានហិង្សា ពោលគឺ មិនប្រើកម្លាំងចូលទៅដណ្តើមកាន់កាប់
- កាន់កាប់ដោយមានការដឹងឮជាសាធារណៈ ពោលគឺ មិនមែនចូលកាន់កាប់ដោយលួចលាក់ មិនឲ្យគេដឹង
- កាន់កាប់ដោយគ្មានការអាក់ខាន ពោលគឺ មិនបានបោះបង់អចលនវត្ថុនេះចោល ក្នុងគម្លាតមួយធំ
- កាន់កាប់ដោយសុចរិត ពោលគឺ ពេលចូលកាន់កាប់ភោគីមិនបានដឹងថា អចលនវត្ថុនេះមានម្ចាស់រួចទៅហើយនោះទេ។

ភោគី ដែលបំពេញតាមល័ក្ខខ័ណ្ឌទាំង ៥ ខាងលើនេះ អាចក្លាយជាម្ចាស់កម្មសិទ្ធិបាន ក្រោយពីបានកាន់កាប់អចលនវត្ថុ រយៈពេល ៥ឆ្នាំ ជាប់ៗគ្នាឥតដាច់។

**៤. ក្រោយពីបានកាន់កាប់តាមលក្ខខណ្ឌ និងគ្រប់រយៈពេល ដែលកំណត់ដោយច្បាប់ហើយ តើខ្ញុំអាចក្លាយជាម្ចាស់កម្មសិទ្ធិដោយស្វ័យប្រវត្តិ ឬទេ?**

សិទ្ធិ ជាកម្មសិទ្ធិករ មិនអាចទទួលបានដោយស្វ័យប្រវត្តិនោះទេ។ ភោគី អាចក្លាយជាម្ចាស់កម្មសិទ្ធិស្ថាពរ លុះត្រាតែអាជ្ញាធរមានសមត្ថកិច្ចចេញប័ណ្ណសម្គាល់កម្មសិទ្ធិឲ្យ ក្រោយមានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

**៥. ក្នុងពេលរង់ចាំ ការទទួលបានប័ណ្ណកម្មសិទ្ធិស្ថាពរ តើភោគីអាចទទួលបានប័ណ្ណអ្វី ដែលសម្គាល់ការកាន់កាប់អចលនវត្ថុនេះដែរ ឬទេ?**

បាន! អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ អចលនវត្ថុ ទៅឲ្យភោគី ដែលកាន់កាប់ស្រប់ច្បាប់។ ក៏ប៉ុន្តែ ប័ណ្ណនេះ គ្រាន់តែជាភស្តុតាងបញ្ជាក់អំពីសិទ្ធិកាន់កាប់ប៉ុណ្ណោះ មិនមែនជាប័ណ្ណកម្មសិទ្ធិ ដែលតវ៉ាមិនបាននោះទេ។

**៦.ប្រសិនបើខ្ញុំឃើញមានអចលនវត្ថុទំនេរគ្មានម្ចាស់ តើខ្ញុំអាចចូលកាន់កាប់ធ្វើជាភោគីបានគ្រប់ពេលឬ?**

ការកាន់កាប់អចលនវត្ថុក្នុងនាមជាភោគីដែលច្បាប់ទទួលស្គាល់ គឺមានតែការកាន់កាប់ មុនពេលច្បាប់ភូមិបាលចូលជាធរមានប៉ុណ្ណោះ ពោលគឺ មុនឆ្នាំ២០០១។ រាល់ការចូលកាន់កាប់អចលនវត្ថុ នៅក្រោយច្បាប់ភូមិបាលចូលជាធរមាន គឺជាការកាន់កាប់ខុសច្បាប់ ដែលអាចទទួលទោសព្រហ្មទណ្ឌ។

ប្រជាជនក្រីក្រ ដែលចង់បានដី ត្រូវតែធ្វើពាក្យសុំទៅអាជ្ញាធរ តាមរយៈយន្តការ “សម្បទានដីសង្គមកិច្ច”។

## ផ្នែកទី៤៧

# សម្បទានដីសង្គមកិច្ច

*<u>បកស្រាយដោយបណ្ឌិត ហ៊ែល ចំរើន</u>*

ដោយ <u>សេង ឌីណា</u>

នៅក្នុងនាទីយល់ដឹងអំពីច្បាប់ កាលពីលើកមុន យើងបានឃើញអំពីសិទ្ធិរបស់អ្នកដែលកាន់កាប់អចលនវត្ថុដោយស្របច្បាប់ ក៏ប៉ុន្តែ មិនទាន់មានប័ណ្ណកម្មសិទ្ធិ។ នៅថ្ងៃនេះ សេង ឌីណា នឹងលើកបញ្ហាថ្មីមួយទៀតគឺ “ការធ្វើសម្បទានដីសង្គមកិច្ច” មកបកស្រាយ តាមរយៈបទសម្ភាសន៍ជាមួយ បណ្ឌិត ហ៊ែល ចំរើន។

ដូចដែលលោក-អ្នកបានជ្រាបរួចមកហើយ កាលពីលើកមុនថា ភោគី (មានន័យថា អ្នកកាន់កាប់អចលនវត្ថុដោយស្របច្បាប់ ប៉ុន្តែ មិនទាន់មានប័ណ្ណកម្មសិទ្ធិ) ក៏មានសិទ្ធិប្រហាក់ប្រហែលនឹងកម្មសិទ្ធិករដែរ គឺមានសិទ្ធិប្រើប្រាស់ (ដូចជា សាងសង់លំនៅដ្ឋាន ដាំដុះ បង្កបង្កើនផល) សិទ្ធិអាស្រ័យផល (ដូចជា ជួល ប្រវាស់) និងមានសិទ្ធិផ្ទេរកម្មសិទ្ធិបន្ត (ដូចជា លក់ ឬចែកជាកេរមរតកទៅឲ្យកូនចៅ)។

ភោគី ដែលកាន់កាប់អចលនវត្ថុត្រឹមត្រូវតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ក្នុងរយៈពេល ៥ ឆ្នាំជាប់ៗគ្នា អាចក្លាយទៅជាម្ចាស់កម្មសិទ្ធិបាន។

ក៏ប៉ុន្តែ ច្បាប់ភូមិបាល ដែលចូលជាធរមាន កាលពីឆ្នាំ២០០១ បានបិទបញ្ចប់រាល់ការចូលកាន់កាប់ដីធ្លី ក្នុងឋានៈជាភោគី មានន័យថា ច្បាប់ទទួលស្គាល់តែអ្នកចូលកាន់កាប់ មុនឆ្នាំ២០០១ប៉ុណ្ណោះ។ អ្នកដែលចូលកាន់កាប់ ក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន ត្រូវចាត់ទុកថាជាការកាន់កាប់ ដោយខុសច្បាប់។

ក៏ប៉ុន្តែ ច្បាប់ភូមិបាលថ្មីនេះ ក៏បានបង្កើតយន្តកម្មមួយដែរ ដើម្បីជួយដល់ប្រជាពលរដ្ឋកម្ពុជាក្រីក្រដែលគ្មានដីនោះគឺ “ការធ្វើសម្បទានដីសង្គមកិច្ច”។

នៅថ្ងៃនេះ បណ្ឌិត ហ៊ែល ចំរើន នឹងត្រឡប់មកបកស្រាយបំភ្លឺ អំពីសម្បទានដីសង្គមកិច្ចនេះ។

**១.តើប្រជាពលរដ្ឋ ដែលអាចទទួលបានដីសម្បទានសង្គមកិច្ច ត្រូវមានលក្ខណៈសម្បត្តិអ្វីខ្លះ?**

ក- មានសញ្ជាតិខ្មែរ និងមានសមត្ថភាពតាមផ្លូវច្បាប់ ដើម្បីធ្វើជាម្ចាស់ដី

ខ- ជាមេគ្រួសារនៃគ្រួសារ ដែលមានសមាជិកពីរនាក់ ឬច្រើននាក់ ដែលជាប់សាច់សាលោហិតជាមួយគ្នា ឬមានចំណងអាពាហ៍ពិពាហ៍ និងរស់នៅជាមួយគ្នា ក្នុងលំនៅដ្ឋានតែមួយ។

គ- មានប្រាក់ចំណូលទាប (កម្រិតប្រាក់ចំណូលនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច និងការងារ)

ឃ-មិនមែនជាកម្មសិទ្ធិករ ឬជាភោគី លើដីផ្សេងទៀត

ង- មានឆន្ទៈ និងមានលទ្ធភាពអនុវត្តតាមកម្មវិធីសម្បទានដីសង្គមកិច្ច ដែលនឹងត្រូវប្រគល់ឲ្យ។

ក្រៅពីប្រជាពលរដ្ឋដែលមានលក្ខណៈសម្បត្តិខាងលើនេះ មានប្រភេទពលរដ្ឋមួយចំនួន ដែលមានសិទ្ធិជាស្វ័យប្រវត្តិក្នុងការទទួលបានសម្បទានដីសង្គមកិច្ច មានន័យថា អាជ្ញាធរមិនអាចបដិសេធសំណើរបស់ជនទាំងនេះបានទេ៖ មេគ្រួសារជាស្ត្រី មេគ្រួសារជាជនបាត់បង់សមត្ថភាព (ពិការ) មេគ្រួសារជាអតីតយុទ្ធដែលបាត់បង់សមត្ថភាព និងមេគ្រួសារជាយោធិនរំសាយ។

**២.តើសម្បទានដីសង្គមកិច្ច ត្រូវផ្តល់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ឬក៏មានបង់ថ្លៃឈ្នួល?**

ដីសម្បទានសង្គមកិច្ច ត្រូវផ្តល់ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ។

**៣.តើសម្បទានិក(មានន័យថា អ្នកដែលទទួលបានដីសម្បទានសង្គមកិច្ច)អាចកាន់កាប់ដីនេះបាន ក្នុងរយៈពេលប៉ុន្មានឆ្នាំ?**

គ្រប់សម្បទានដីទាំងអស់ មិនអាចផ្តល់ឲ្យលើសពីរយៈពេល ៩៩ឆ្នាំឡើយ។

ក៏ប៉ុន្តែ សម្បទានដីសង្គមកិច្ច មានលក្ខណៈពិសេសមួយ គឺ សម្បទានិកអាចស្នើសុំធ្វើជាម្ចាស់កម្មសិទ្ធិបាន ក្រោយពីបានកាន់កាប់ដីសម្បទានរយៈពេល៥ឆ្នាំជាប់ៗគ្នា។

**៤.បើដូច្នេះ តើសម្បទានដីសង្គមកិច្ច និងភោគៈ មានចំណុចខុសគ្នាត្រង់ណាខ្លះ?**

ទាំងភោគី និងសម្បទានិកដីសង្គមកិច្ច សុទ្ធតែអាចសុំធ្វើជាម្ចាស់កម្មសិទ្ធិលើដីដែលខ្លួនកាន់កាប់បាន ក្រោយពីបានកាន់កាប់ដី ក្នុងរយៈពេល ៥ឆ្នាំ ជាប់ៗគ្នា។

ចំណុចដែលខុសគ្នា គឺត្រង់ថា នៅក្នុងរយៈពេលកំពុងកាន់កាប់ ៥ឆ្នាំនេះ ភោគី អាចផ្ទេរសិទ្ធិរបស់ខ្លួនទៅឲ្យអ្នកដ៏ទៃបាន (ដូចជា លក់ ឬធ្វើជាអំណោយនូវដីរបស់ខ្លួនបាន)។

ចំណែកសម្បទានិកដី សង្គមកិច្ចវិញ ក្នុងពេលរង់ចាំបានក្លាយជាម្ចាស់កម្មសិទ្ធិ (៥ឆ្នាំ) មិនអាចធ្វើការផ្ទេរសិទ្ធិរបស់ខ្លួនបានទេ គឺអាចមានសិទ្ធិត្រឹមតែប្រើប្រាស់ (សាងសង់លំនៅដ្ឋាន ដាំដុះ បង្កបង្កើនផល) និងអាស្រ័យផល (ជួល ប្រវាស់) តែប៉ុណ្ណោះ។

**៥.ប្រសិន បើនៅក្នុងរយៈពេលកាន់កាប់ដី មិនទាន់គ្រប់ ៥ឆ្នាំ សម្បទានិកទទួលមរណភាព តើសម្បទានដីសង្គមកិច្ចត្រូវរលាយជាស្វ័យប្រវត្តិ ហើយដីសម្បទានត្រូវប្រគល់ទៅឲ្យរដ្ឋវិញ ឬក៏កូនចៅ ដែលជាទាយាទរបស់អ្នកស្លាប់នេះអាចកាន់កាប់បន្តបាន?**

សម្បទានដី សង្គមកិច្ច មិនអាចរលាយជាស្វ័យប្រវត្តិ ដោយមកពីហេតុតែសម្បទានិកទទួលមរណភាពនោះទេ។ កូនចៅ (ទាយាទ) របស់សព អាចបន្តកាន់កាប់ដីសម្បទាននេះតទៅទៀតបាន។

**៦.នៅក្នុងករណី ដែលសម្បទានដីសង្គមកិច្ចត្រូវផ្ទេរជាមរតកទៅឲ្យកូនចៅ តើរយៈពេល ៥ឆ្នាំ ដែលច្បាប់តម្រូវឲ្យកាន់កាប់ដើម្បីបានក្លាយជាម្ចាស់កម្មសិទ្ធិលើដីហ្នឹង ត្រូវចាប់ផ្តើមរាប់ឡើងវិញ ឬក៏អាចរាប់បន្តពីមុន?**

ចំណុចនេះ មិនមានចែងលម្អិតនៅក្នុងច្បាប់ភូមិបាល ឬអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចនោះទេ។ ក៏ប៉ុន្តែ តាមគោលការណ៍ទូទៅនៃច្បាប់រយៈពេល ៥ឆ្នាំ ត្រូវចាប់រាប់បន្ត មិនមែនរាប់ឡើងវិញនោះទេ។ មានន័យថា ប្រសិនបើសម្បទានិកកាន់កាប់បាន ៣ឆ្នាំ ហើយទទួលមរណភាព ទាយាទរបស់សពទទួលកាន់កាប់ដីសម្បទាននេះ រយៈពេល ២ឆ្នាំទៀត គ្រប់ ៥ឆ្នាំ ហើយអាចសុំធ្វើជាម្ចាស់កម្មសិទ្ធិបាន។

# ផ្នែកទី៤៨

# កិច្ចសន្យាសម្បទាន និងតំបន់សេដ្ឋកិច្ចពិសេស

**១. តើច្បាប់សម្បទានត្រូវបានអនុម័តនៅថ្ងៃខែឆ្នាំណា ? ហើយច្បាប់នេះមានគោលដៅអ្វី ?**

ច្បាប់សម្បទានអនុម័តថ្ងៃទី ១៩ ខែតុលា ឆ្នាំ១៩៩៧ មាន៦ជំពូក និង ៤៣មាត្រា ហើយមានគោលដៅដើម្បីជំរុញ និងសំរួលការអនុវត្តន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធដោយហិរញ្ញប្បទានឯកជននៅព្រះរាជាណាចក្រកម្ពុជា។

ច្បាប់នេះ ត្រូវការអនុក្រឹត្យមួយផ្សេងទៀតដើម្បីដាក់វាឲ្យអនុវត្ត(ប៉ុន្តែ មកដល់ពេលនេះមិនទាន់ត្រូវបានអនុម័តនៅឡើយទេ)

**២.តើគម្រោងវិនិយោគប្រភេទណាខ្លះដែលអាចធ្វើសម្បទានបាន?**

សំណង់ហេដ្ឋារចនាសម្ព័ន្ធទាំងឡាយណាដែលផ្តល់សេវាកម្មដោយផ្ទាល់ ឬមិនផ្ទាល់ដល់សាធារណៈជននៅក្នុងវិស័យដូចខាងក្រោមនេះដែលច្បាប់កម្ពុជាបើកអោយអាចធ្វើសម្បទានបាន ៖

- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី
- ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធដឹកជញ្ជូនមានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ កំពង់ផែ ផ្លូវដែក ព្រែកជីក
- ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ
- ហេដ្ឋារចនាសម្ព័ន្ធបំរើឲ្យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន
- ហេដ្ឋារចនាសម្ព័នមូលដ្ឋានសម្ភារៈបម្រើអោយគម្រោងផ្នែកទេសចរណ៍សារៈមន្ទី
- ហេដ្ឋារចនាសម្ព័នបម្រើអោយវិស័យឧស្ម័ន និងប្រេង មានជាអាទិ៍ បំពុងបង្ហូរប្រេង និងឧស្ម័ន
- ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ
- ប្រព្រឹត្តិកម្ម និង ការគ្រប់គ្រងសំណល់
- ហេដ្ឋារចនាសម្ព័នសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យកីឡា
- ហេដ្ឋារចនាសម្ព័នបំរើអោយតំបន់សេដ្ឋកិច្ចពិសេស និងលំនៅដ្ឋានសង្គម
- ហេដ្ឋារចនាសម្ព័នបម្រើអោយប្រព័ន្ធជារាសស្រ្ត និងការងារកសិកម្ម
- វិស័យផ្សេងៗទៀតដែលច្បាប់ដោយឡែកអនុញ្ញាតអោយមានការផ្តល់សម្បទាន។

**៣.តើអាជ្ញាធរដែលជាភាគីនៃកិច្ចសន្យាសម្បទានធ្វើការជ្រើសរើសសម្បទានិកតាមវិធីណា?**

តាមនីតិវិធីដេញថ្លៃ ជាលក្ខណៈជាតិ និងអន្តរជាតិ ឬតាមនីតិវិធីចរចារដោយផ្អែកទៅតាម កាលៈទេសៈ។

**៤.ចូរនិយាយពីនីតិវិធីជ្រើសរើសសម្បទានិក?**

នៅពេលដែលដំណើរការជ្រើសរើសសម្បទានិកត្រូវបានបំពេញសព្វគ្រប់ហើយអាជ្ញាធររដ្ឋ ជាភាគីនៃកិច្ចសន្យាសម្បទានត្រៀមក្នុងការទទួលពាក្យដេញថ្លៃចុងក្រោយ ឬការធ្វើស្នើរចរចារ បន្ទាប់ពីនោះអាជ្ញាធររដ្ឋដែលជាភាគីនៃកិច្ចសន្យាសម្បទាន ត្រូវមាននូវការអនុម័តជាគោល ការណ៍សំរាប់លក្ខខណ្ឌចុងក្រោយនៃកិច្ចសន្យាសម្បទាន។

បន្ទាប់ពីទទួលបានការអនុម័តយល់ព្រមជាគោលការសំរាប់កិច្ចសន្យាសម្បទាន អាជ្ញាធររដ្ឋដែលជា ភាគីនៃកិច្ចសន្យាសម្បទានត្រូវចេញសេចក្តីជូនដំណឹងពីការយល់ព្រមផ្តល់សម្បទានទៅបេក្ខជន ដែលបានជ្រើសរើសមុននឹងចុះកិច្ចសន្យាសម្បទាន។

# ផ្នែកទី៤៩

# នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍

*បកស្រាយដោយលោក ខាត់ ណារិទ្ធ ចៅសង្កាត់ទន្លេបាសាក់*

ដោយ សេង ឌីណា

នៅក្នុងបទសម្ភាសន៍ជាមួយ គួច គន្ធារ៉ា លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានជំរុញឲ្យប្រជាពលរដ្ឋទាំងអស់ទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីឲ្យចំណងអាពាហ៍ពិពាហ៍មានសុពលភាពត្រឹមត្រូវទៅតាមផ្លូវច្បាប់។ សេង ឌីណា សូមលើកយកនីតិវិធី នៃការចុះសំបុត្រអាពាហ៍ពិពាហ៍នេះ មកជម្រាបជូនលោក-អ្នកស្តាប់ ដោយមានការពន្យល់ពីសំណាក់លោក ខាត់ ណារិទ្ធ ចៅសង្កាត់ទន្លេបាសាក់។

លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារីធ្លាប់បានថ្លែងថា ការរៀបអាពាហ៍ពិពាហ៍ភាគច្រើននៅកម្ពុជា ជាពិសេសនៅតាមជនបទ បានធ្វើទៅដោយគ្រាន់តែមានរៀបចំពិធីតាមទំនៀមទម្លាប់ប្រពៃណីតែប៉ុណ្ណោះ ប៉ុន្តែ មិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ។

ចំណងអាពាហ៍ពិពាហ៍ ដែលមានត្រឹមតែពិធីរៀបការតាមប្រពៃណី ដោយគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះ មិនមានសុពលភាពតាមផ្លូវច្បាប់នោះទេ មានន័យថា បើទោះជាគូស្វាមីភរិយានេះ រស់នៅជាមួយគ្នា ដោយមានការទទួលស្គាល់ពីសង្គមថា ជាប្តី-ប្រពន្ធរៀបការពេញមុខពេញមាត់ហើយក៏ដោយ ក៏ប៉ុន្តែ តាមផ្លូវច្បាប់ អ្នកទាំងពីររស់នៅដោយគ្មានចំណងអាពាហ៍ពិពាហ៍នោះទេ។

ចំណងអាពាហ៍ពិពាហ៍បែបនេះ អាចនឹងបង្កជាបញ្ហាស្មុគស្មាញ ជាពិសេស នៅពេលមានការលែងលះ ឬនៅពេលដែលភាគីណាមួយ ទៅលបលួចមានប្តី ឬប្រពន្ធផ្សេង។ ហេតុដូច្នេះ ហើយបានជាលោកជំទាវ អ៊ឹង កន្ថាផាវី បានអំពាវនាវឲ្យគូស្វាមីភរិយា ត្រូវនាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់។

**១.តើការចុះសំបុត្រអាពាហ៍ពិពាហ៍ត្រូវធ្វើឡើង ដោយគោរពទៅតាមនីតិវិធីអ្វីខ្លះ?**

យោងតាមលោក ខាត់ ណារិទ្ធ ចៅសង្កាត់ទន្លេបាសាក់ នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ គឺមានជាលំដាប់លំដោយដូចតទៅ៖

អនាគត កូនកម្លោះ ត្រូវដាក់ពាក្យសុំទៅឃុំ-សង្កាត់ដែលខ្លួនរស់នៅដើម្បីឲ្យមេឃុំ-ចៅសង្កាត់ ចេញសេចក្តីបញ្ជាក់ថាខ្លួនពិតជាមិនមានជាប់ចំណងអាពាហ៍ពិពាហ៍ចាស់ណាមួយមែន (នៅលីវ ឬពោះម៉ាយ)។ ប្រសិនបើជាពោះម៉ាយដោយការលែងលះ ត្រូវមានដីកាតុលាការ អំពីការលែងលះ។ ប្រសិនបើជាពោះម៉ាយ ដោយប្រពន្ធស្លាប់ ត្រូវមានលិខិតមរណភាពរបស់សពប្រពន្ធ។

ក្រោយពីបានលិខិតបញ្ជាក់ ពីមេឃុំ-ចៅសង្កាត់រួចហើយ ភាគីខាងប្រុស ត្រូវយកលិខិតនេះ ព្រមទាំងសំណុំបែបបទមួយទៀត បំពេញដោយភាគីខាងស្រី ដាក់ជូនទៅសាលាឃុំ-សង្កាត់ខាងស្រី។ មន្ត្រីអត្រានុកូលដ្ឋាន នៅឃុំ-សង្កាត់ខាងស្រី ជាអ្នកចេញសេចក្តីប្រកាសជូនដំណឹងអាពាហ៍ពិពាហ៍ ដើម្បីយកទៅបិទ នៅផ្ទះខាងស្រី ហើយសេចក្តីចម្លងមួយទៀតយកទៅបិទនៅផ្ទះខាងប្រុស។

ក្នុងរយៈពេល ១០ថ្ងៃ ប្រសិនបើមិនមានការតវ៉ាជំទាស់ណាមួយទេ ការធ្វើពិធីអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ប្រពៃណីអាចរៀបចំធ្វើទៅបាន។

ក្រោយពិធីអាពាហ៍ពិពាហ៍នេះ (យ៉ាងយូរ ១ខែ) គូស្វាមី ភរិយាថ្មីថ្មោងនេះ ត្រូវត្រឡប់ទៅសាលាឃុំ-សង្កាត់ខាងស្រីវិញ ដើម្បីផ្តិតមេដៃក្នុងសៀវភៅអត្រានុកូលដ្ឋាន ហើយមេឃុំ-ចៅសង្កាត់ ចេញសំបុត្រអាពាហ៍ពិពាហ៍ជាផ្លូវការជូន។

គួរបញ្ជាក់ថា នៅក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍នេះ ភាគីទាំងពីរត្រូវមានសាក្សី យ៉ាងតិច ២រូប (ម្នាក់សម្រាប់ខាងស្រី និងម្នាក់សម្រាប់ខាងប្រុស)។ សាក្សីនេះ អាចជាឪពុកម្តាយក៏បាន ជាសាច់ញាតិ ឬមិត្តភក្តិណាមួយក៏បាន (មានវ័យគ្រប់ការ)។

ចំពោះគូស្វាមី ភរិយា ដែលបានរៀបការកន្លងមក ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ (ជាពិសេស អ្នករៀបការក្នុងរបបខ្មែរក្រហម) អាចទៅសុំលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ពីសាលាឃុំ-សង្កាត់ ដែលខ្លួនរស់នៅ។

ការដាក់ពាក្យសុំនេះ មិនទាមទារឲ្យមាននីតិវិធីប្រកាសផ្សាយជាសាធារណៈ ដូចការរៀបការថ្មីទេ ប៉ុន្តែ ត្រូវមានសាក្សី យ៉ាងតិច ២រូប ដែរ។

## ផ្នែកទី៥០

## នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋបរទេស

ដោយ សេង ឌីណា

ដើម្បីរៀបការជាមួយនារីខ្មែរ បុរសជាជនបរទេសមិនត្រូវមានអាយុលើសពី ៥០ឆ្នាំ ហើយត្រូវមានប្រាក់ចំណូលយ៉ាងតិច ២៥០០ដុល្លារអាមេរិក ក្នុងមួយខែ។

ដើម្បីឆ្លើយតបទៅនឹងសំណួររបស់អ្នកស្តាប់យើង នៅក្នុងនាទីយល់ដឹងពីច្បាប់នៅថ្ងៃនេះ សេង ឌីណា សូមធ្វើការពន្យល់អំពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋបរទេស។ តើសាមីខ្លួនទាំងខាងភាគីជាពលរដ្ឋខ្មែរ និងភាគីបរទេស ត្រូវបំពេញនូវលក្ខខណ្ឌអ្វីខ្លះ? តើការសុំរៀបអាពាហ៍ពិពាហ៍នេះត្រូវធ្វើឡើងដោយគោរពទៅតាម នីតិវិធីអ្វីខ្លះ ហើយធ្វើនៅកន្លែងណា?

**លក្ខខណ្ឌទាក់ទងនឹងសាមីខ្លួនដែលត្រូវរៀបអាពាហ៍ពិពាហ៍**

សាមីខ្លួនទាំងពីរ គឺទាំងភាគីជាពលរដ្ឋខ្មែរ ទាំងភាគីជាពលរដ្ឋបរទេស ចាំបាច់ត្រូវតែបំពេញនូវលក្ខខណ្ឌរួមមួយចំនួន ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរ ដូចជាករណីអាពាហ៍ពិពាហ៍ទូទៅ រវាងខ្មែរ និងខ្មែរដែរ គឺ៖

- អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងទៅតាមគោលការណ៍ស្ម័គ្រចិត្ត ដែលចេញពីឆន្ទៈផ្ទាល់របស់សាមីខ្លួនទាំងសងខាង ដោយគ្មានការបង្ខំ ឬការបន្លំបោកប្រាស់ (មាត្រា ៩៥៨)
- បុរស និងនារី ដែលត្រូវរៀបអាពាហ៍ពិពាហ៍មិនមានជាប់ជាសាច់ញាតិនឹងគ្នា ដែលច្បាប់ហាមឃាត់ (មាត្រា ៩៥១ និង ៩៥២)
- មិនមានជាប់ចំណងអាពាហ៍ពិពាហ៍ចាស់ ពីព្រោះក្រមរដ្ឋប្បវេណីខ្មែរចែងថា អ្នកដែលមានប្តី ឬប្រពន្ធរួចហើយ មិនអាចរៀបអាពាហ៍ពិពាហ៍ទៀតបានទេ (មាត្រា ៩៤៩)
- ត្រូវតែជានីតិជន មានន័យថា ត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើង (មាត្រា ៩៤៨)

ក្នុងករណីអាពាហ៍ពិពាហ៍ រវាងនារីខ្មែរ និងបុរសបរទេស បុរសបរទេសនេះត្រូវបំពេញទៅតាមលក្ខណ្ឌបន្ថែម ដែលកំណត់ដោយក្រសួងការបរទេសខ្មែរ តាមរយៈកំណត់ទូតចេញកាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ គឺ៖

- អាយុមិនត្រូវឲ្យលើសពី ៥០ឆ្នាំ
- ត្រូវមានប្រាក់ចំណូលយ៉ាងតិច ២៥០០ដុល្លារ ក្នុងមួយខែ

ម្យ៉ាងទៀត យោងតាមអនុក្រឹត្យ លេខ ១៨៣ ចុះថ្ងៃ៣ វិច្ឆិកា ២០០៨ ការរៀបអាពាហ៍ពិពាហ៍ ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម គឺត្រូវហាមឃាត់ដាច់ខាត។

**នីតិវិធី និងសំណុំបែបបទដែលត្រូវបំពេញ**

យោងតាមអនុក្រឹត្យ ១៨៣ ខាងលើនេះ ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវតែមានវត្តមាននៅក្នុងប្រទេសកម្ពុជា ដើម្បីរៀបចំបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នេះដោយខ្លួនឯង។

សំណុំបែបបទនៃការសុំរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ទៅក្រសួងការបរទេស ដោយត្រូវមានភ្ជាប់នូវ៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយត្រូវបំពេញទៅតាមទម្រង់ដែលមានស្រាប់ ចេញដោយអាជ្ញាធរខ្មែរ

- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជាជនបរទេស ដោយមានទិដ្ឋាការ (Visa) ចូលក្នុងប្រទេសកម្ពុជា ដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬម៉េម៉ាយ ចេញដោយសមត្ថកិច្ចប្រទេសរបស់សាមីខ្លួនជាជនបរទេស
- លិខិតបញ្ជាក់សុខភាព ចេញដោយសមត្ថកិច្ចកម្ពុជា
- លិខិតថ្កោលទោស ចេញដោយសមត្ថកិច្ចប្រទេសរបស់សាមីខ្លួនជាជនបរទេស
- លិខិតបញ្ជាក់ពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជាជនបរទេស ដោយមានបញ្ជាក់ពីចំនួនប្រាក់ចំណូលប្រចាំខែ ចេញដោយសមត្ថកិច្ចប្រទេសរបស់សាមីខ្លួនជាជនបរទេស

សំណុំឯកសារទាំងអស់នេះ (ក្រៅពីពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងលិខិតបញ្ជាក់សុខភាព) គឺត្រូវមានបោះត្រាបញ្ជាក់នីត្យានុកូលភាព ពីស្ថានទូត នៃប្រទេសរបស់សាមីខ្លួនជាជនបរទេស ដែលប្រចាំនៅក្នុងប្រទេសកម្ពុជា។

ម្យ៉ាងទៀត បើតាមកំណត់ទូតរបស់ក្រសួងការបរទេសខ្មែរ ចុះថ្ងៃទី២៣ មីនា ឆ្នាំ២០០៩ សាមីខ្លួនជាជនបរទេសមិនត្រូវទាក់ទង ដាក់សំណុំបែបបទសុំរៀបអាពាហ៍ពិពាហ៍នេះទៅក្រសួងការបរទេសដោយផ្ទាល់ទេ គឺត្រូវដាក់តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល នៃប្រទេសរបស់សាមីខ្លួនជាជនបរទេសដែលប្រចាំនៅកម្ពុជា។

ក្រោយពីទទួលបានសំណុំបែបបទនេះហើយ ក្រសួងការបរទេសមានរយៈពេលយ៉ាងយូរ ៥ថ្ងៃ (ថ្ងៃធ្វើការ) ដើម្បីពិនិត្យ និងសម្រេច។ ប្រសិនបើមើលទៅឃើញថា មានសំណុំឯកសារគ្រប់គ្រាន់ ហើយសាមីខ្លួនជាជនបរទេសបំពេញទៅតាមលក្ខខណ្ឌ ដែលបានកំណត់ហើយ ក្រសួងការបរទេសត្រូវបញ្ជូនសំណុំបែបបទនេះ បន្តទៅឲ្យក្រសួងមហាផ្ទៃ។

ក្រសួងមហាផ្ទៃក៏មានពេលយ៉ាងយូរ ៥ថ្ងៃ ដែរ ដើម្បីពិនិត្យ និងចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍នេះ។ ពិនិត្យ និងចុះបញ្ជីចប់សព្វគ្រប់ហើយ ក្រសួងមហាផ្ទៃត្រូវជូនដំណឹង អំពីការសុំរៀបអាពាហ៍ពិពាហ៍នេះ ទៅខាងមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនជាពលរដ្ឋខ្មែរ ហើយក៏ត្រូវជូនដំណឹងទៅសាមីខ្លួនជាជនបរទេសដែរ។

ទទួលបានចម្លើយពីក្រសួងមហាផ្ទៃ អំពីការចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍នេះហើយ សាមីខ្លួនទាំងពីរ គឺទាំងពលរដ្ឋខ្មែរ និងទាំងជនបរទេស ត្រូវរៀបចំដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ស្របពេលជាមួយគ្នា ទៅឃុំ ឬសង្កាត់ នៅខាងលំនៅរបស់សាមីខ្លួនជាពលរដ្ឋខ្មែរ ទៅតាមនីតិវិធីសុំអាពាហ៍ពិពាហ៍ធម្មតា។

សំណុំបែបបទរបស់សាមីខ្លួនជាពលរដ្ឋខ្មែរ គឺត្រូវមានភ្ជាប់៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- សេចក្ដីចម្លងសំបុត្រកំណើត
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬម៉េម៉ាយ ដែលចេញដោយមេឃុំ ឬចៅសង្កាត់
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាល

ក្រោយពីពិនិត្យមើលសំណុំឯកសាររបស់សាមីខ្លួនទាំងពីរ ឃើញថា ត្រឹមត្រូវតាមច្បាប់ហើយ មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដើម្បីយកទៅបិទផ្សាយ នៅផ្ទះរបស់សាមីខ្លួនជាពលរដ្ឋខ្មែរផង នៅសាលាឃុំ ឬសង្កាត់នេះផង និងនៅស្ថានទូត នៃប្រទេសរបស់សាមីខ្លួនជាជនបរទេសផង។ ១០ថ្ងៃ ក្រោយពីបិទប័ណ្ណប្រកាសនេះហើយ បើសិនជាមិនមានអ្នកណាប្ដឹងតវ៉ា ជំទាស់នឹងការរៀបអាពាហ៍ពិពាហ៍នេះទេ ទើបសាមីខ្លួនអាចរៀបចំពិធីអាពាហ៍ពិពាហ៍បាន។

នៅចុងបញ្ចប់នៃនីតិវិធី ដើម្បីឲ្យអាពាហ៍ពិពាហ៍ មានសុពលភាពពេញលក្ខណៈច្បាប់ សាមីខ្លួនទាំងពីរ ត្រូវទៅចុះបញ្ជីអាពាហ៍ពិពាហ៍ នៅសាលាឃុំ ឬសង្កាត់ គឺនៅកន្លែង ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។ ការចុះបញ្ជីអាពាហ៍ពិពាហ៍នេះ ត្រូវមានវត្តមានផ្ទាល់របស់សាមីខ្លួនទាំងពីរ បូករួមជាមួយនឹងសាក្សី ដែលមានអាយុគ្រប់ការ ចំនួន ២រូប។

# ផ្នែកទី៥១

## អំពីបែបបទនៃការសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត (សំបុត្រកំណើត)

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងអំពីច្បាប់របស់យើង នៅថ្ងៃនេះ សេង ឌីណា សូមធ្វើការពន្យល់ អំពីបែបបទនៃការចុះសៀវភៅកំណើតរបស់កូន។

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលពលរដ្ឋម្នាក់ៗមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និងដែលបង្កើតឲ្យជននោះ មានសិទ្ធិ និងករណីយកិច្ច។ ការចុះសៀវភៅអត្រានុកូលដ្ឋាន គឺជាកាតព្វកិច្ច ដែលពលរដ្ឋខ្មែរគ្រប់ត្រូវតែបំពេញ (មាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០)។

**១.នៅពេលដែលមានទារកទើបនឹងកើត តើឪពុកម្តាយត្រូវទៅចុះសំបុត្រកំណើតនៅកន្លែងណា ហើយត្រូវចុះនៅក្នុងរយៈពេលប៉ុន្មានថ្ងៃ?**

នៅពេលដែលមានទារកកើត ឪពុក ឬម្តាយរបស់ទារក (ជាទូទៅ គឺឪពុក) ត្រូវទៅរាយការណ៍ចុះសំបុត្រកំណើតនៅសាលាឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន។ ក្នុងករណីឪពុក និងម្តាយមានធុរៈទៅមិនបានត្រូវពឹងពាក់សាច់ញាតិ ឬក៏អ្នកជិតខាងឲ្យទៅជំនួសបាន ក៏ប៉ុន្តែ សាច់ញាតិ និងអ្នកជិតខាងនោះ ត្រូវតែជាអ្នក ដែលបានឃើញ និងបានដឹងឮផ្ទាល់ពីការកើតរបស់ទារកនេះ។

ការចុះសំបុត្រកំណើតនេះ ក្នុងរយៈពេលយ៉ាងយូរបំផុត ៣០ថ្ងៃ គិតចាប់ពីថ្ងៃ ដែលទារកកើត។

យោងតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ (ស.ណ.ន ១៨ ឧសភា ២០០៧) ការចុះសៀវភៅកំណើតត្រូវនាំទៅជាមួយនូវលិខិតស្នាមមួយចំនួន៖

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតរបស់ទារក ចេញដោយមន្ទីរពេទ្យ (ប្រសិនបើទារកកើតនៅមន្ទីរពេទ្យ) ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើត ចេញដោយមេភូមិ (បើទារកកើតនៅផ្ទះ)
- ប្រសិនបើមាន ត្រូវយកទៅជាមួយផងដែរ នូវឯកសារមួយចំនួនទៀត ដូចជា សៀវភៅគ្រួសារ ដែលមានឈ្មោះឪពុកម្តាយរបស់ទារក សេចក្តីចម្លងសំបុត្រកំណើតរបស់ឪពុកម្តាយ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកម្តាយ អត្តសញ្ញាណប័ណ្ណរបស់ឪពុកម្តាយ។
- ក្នុងករណីឪពុកម្តាយមិនបានទៅចុះសៀវភៅកំណើតដោយផ្ទាល់ខ្លួនឯង ហើយពឹងពាក់សាច់ញាតិ ឬអ្នកជិតខាងឲ្យទៅជំនួស ឪពុកម្តាយ ត្រូវធ្វើលិខិតបញ្ជាក់មួយទៀត ដោយមានបញ្ជាក់ច្បាស់លាស់ ពីនាមត្រកូល នាមខ្លួន និងថ្ងៃខែឆ្នាំកំណើតរបស់ទារក។

បើសិនជាបានមកចុះសំបុត្រកំណើតកូន ក្នុងរយៈពេលកំណត់ ៣០ថ្ងៃ ហើយមានឯកសារគ្រប់គ្រាន់ដូចខាងលើនេះ មេឃុំ ឬចៅសង្កាត់ ដែលជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញសំបុត្រកំណើតច្បាប់ដើមមួយសន្លឹកឲ្យទៅឪពុកម្តាយ។ សំបុត្រកំណើតច្បាប់ដើមនេះ ត្រូវចេញឲ្យដោយឥតគិតថ្លៃ។

**២.ក្នុងករណីខកខានមិនបានទៅចុះសំបុត្រកំណើត ក្នុងរយៈពេលកំណត់ ៣០ថ្ងៃ តើត្រូវធ្វើដូចម្តេច?**

បើសិនជាកូនកើតមក មិនទៅចុះសំបុត្រកំណើត ទុកឲ្យហួស ៣០ថ្ងៃ ការចុះសំបុត្រកំណើត នៅតែអាចធ្វើបាន ប៉ុន្តែត្រូវបានសំណុំបែបបទច្រើនជាងការទៅចុះសំបុត្រកំណើត ក្នុងរយៈពេលកំណត់ ហើយត្រូវមានការបង់ថ្លៃ។

ការសុំចុះសំបុត្រកំណើតហួសពី ៣០ថ្ងៃ ក្រោយពីទារកកើត គឺត្រូវធ្វើទៅតាមនីតិវិធីដែលគេហៅថា “ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋាន” ប៉ុន្តែ ធ្វើនៅសាលាឃុំសង្កាត់ដែលឪពុកម្តាយរស់នៅដដែល ដោយមិនចាំបាច់ត្រូវទៅដល់ស្រុកខណ្ឌ ឬក៏ខេត្តក្រុងទេ។

ក្នុងការប្តឹងសុំចុះសំបុត្រកំណើតនេះ ឪពុក ឬម្តាយរបស់ទារកត្រូវមានសំណុំឯកសារ ដូចករណីចុះសំបុត្រកំណើតក្នុងរយៈពេលកំណត់ ៣០ថ្ងៃដែរ ប៉ុន្តែ ត្រូវនាំទៅជាមួយនូវសាក្សី ២រូប ដែលជានីតិជន ហើយត្រូវបំពេញពាក្យប្តឹងសុំចុះសំបុត្រកំណើត។ ពាក្យប្តឹងសុំចុះសំបុត្រកំណើតនេះត្រូវបិទតែមប្រ៊ី ថ្លៃ១ពាន់រៀល សម្រាប់ប្រជាពលរដ្ឋដែលរស់នៅខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ព្រះវិហារ និងឧត្តរមានជ័យ។ សម្រាប់អ្នកនៅខេត្តផ្សេងក្រៅពីនេះ ត្រូវបិទតែមប្រ៊ី ថ្លៃ៤ពាន់រៀល។ ការទិញតែមប្រ៊ីនេះ គឺជំនួសឲ្យការបង់លុយផ្ទាល់ មានន័យថា អ្នកសុំមិនតម្រូវឲ្យបង់លុយអ្វីបន្ថែមពីលើនេះទៀតទេ។

និយាយសរុបជារួមមកវិញ ប្រសិនបើទៅចុះសំបុត្រកំណើតទាន់ពេល គឺមិនហួសពី ៣០ថ្ងៃ ក្រោយពីទារកកើត សំណុំបែបបទមានលក្ខណៈងាយស្រួលជាង ហើយសំបុត្រកំណើតត្រូវចេញឲ្យដោយឥតគិតថ្លៃ។ ប៉ុន្តែ បើទុកឲ្យហួស ៣០ថ្ងៃ បានទៅចុះ គឺត្រូវបំពេញសំណុំបែបបទច្រើនជាង ហើយត្រូវមានបង់ថ្លៃ តាមរយៈការទិញតែមប្រ៊ី។

**៣.ចំពោះអ្នកដែលបានកើតតាំងពីក្នុងសម័យខ្មែរក្រហម ឬក្រោយសម័យខ្មែរក្រហម ប៉ុន្តែ មិនទាន់មានការរៀបចំសៀវភៅអត្រានុកូលដ្ឋានឡើងវិញត្រឹមត្រូវ។ តើត្រូវធ្វើដូចម្តេច ដើម្បីអាចចុះសំបុត្រកំណើតបាន?**

អ្នកដែលបានកើតមុនសម័យខ្មែរក្រហមក៏ដោយ ក្នុងសម័យខ្មែរក្រហមក៏ដោយ ក្រោយសម័យខ្មែរក្រហមក៏ដោយ ឲ្យតែកើតមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន មានន័យថា កើតមុនថ្ងៃទី២៩ ធ្នូ ឆ្នាំ២០០០ អនុក្រឹត្យនេះទុកលទ្ធភាពឲ្យមានការចុះសំបុត្របញ្ជាក់កំណើត ដោយឥតគិតថ្លៃ ក៏ប៉ុន្តែ ត្រូវធ្វើឲ្យបានមុនថ្ងៃទី៣១ សីហា ឆ្នាំ២០០៥ មានន័យថា មកទល់នឹងពេលឥឡូវនេះ ការចុះសំបុត្របញ្ជាក់កំណើតដោយឥតគិតថ្លៃនេះ ត្រូវហួសពេលធ្វើហើយ។

អ្នកដែលមិនបានទៅសុំចុះសំបុត្របញ្ជាក់កំណើត មុនថ្ងៃទី៣១ សីហា ឆ្នាំ២០០៥ នៅតែអាចទៅសុំចុះសំបុត្រកំណើតបានដដែលនៅសាលាឃុំ-សង្កាត់ ដែលខ្លួនរស់នៅ ដោយត្រូវធ្វើទៅតាមនីតិវិធី “ប្តឹងសុំចុះសំបុត្រកំណើត” ដូចករណីចុះសំបុត្រកំណើតហួសរយៈពេល ៣០ថ្ងៃដែរ មានន័យថា ត្រូវមានសាក្សីជានីតិជន ២រូប ទៅជាមួយ ហើយត្រូវបង់លុយតាមរយៈការទិញតែមប្រ៊ី គឺ ១ពាន់រៀល សម្រាប់អ្នកនៅរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងឧត្តរមានជ័យ ហើយ ៤ពាន់រៀល សម្រាប់អ្នកនៅខេត្តក្រុងក្រៅពីនេះ។

**៤.ក្នុងករណីទារក ដែលកើតនៅឯបរទេស តើត្រូវទៅចុះសំបុត្រកំណើតនៅកន្លែងណា?**

ក្នុងករណីទារកកើតនៅបរទេស ពីឪពុក ឬម្តាយជាពលរដ្ឋខ្មែរ ហើយរស់នៅដោយស្របច្បាប់នៅបរទេស ឪពុក ម្តាយរបស់ទារកនេះ អាចទៅសុំចុះសំបុត្រកំណើតកូន នៅអាជ្ញាធរអត្រានុកូលដ្ឋានរបស់ប្រទេសដែលខ្លួនរស់នៅនោះបានទៅតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ។

បន្ទាប់មកទៀត គាត់អាចមានលទ្ធភាពពីរៈ

ឬមួយ គាត់ទៅសុំចុះសំបុត្រកំណើត នៅឯស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជា ដែលប្រចាំនៅក្នុងប្រទេស ដែលគាត់រស់នៅនោះ។ ក្នុងករណីនេះ ស្ថានទូត ឬស្ថានកុងស៊ុល នឹងចេញសំបុត្រកំណើតច្បាប់ដើម ដែលអាចយកមកប្រើប្រាស់ជាផ្លូវការបាន ដូចសំបុត្រកំណើត ដែលចេញដោយមេឃុំ ចៅសង្កាត់ នៅក្នុងប្រទេសកម្ពុជាដែរ។

ឬមួយទៀត ឪពុក ម្ដាយ មិនចាំបាច់ទៅសុំចុះសំបុត្រកំណើត នៅស្ថានទូត ឬស្ថានកុងស៊ុលកម្ពុជាក៏បានដែរ។ ក៏ប៉ុន្តែ នៅពេលគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញ គាត់ត្រូវយកសំបុត្រកំណើតដែលចេញដោយអាជ្ញាធរបរទេស ទៅបង្ហាញមេឃុំ ឬចៅសង្កាត់ នៃទីលំនៅថ្មីរបស់គាត់ ដើម្បីសុំសំបុត្រកំណើតថ្មី។

**៥.និយាយពីនាមត្រកូលរបស់ទារកវិញ។ តើច្បាប់មានចែងកំណត់ អំពីការជ្រើសរើសនាមត្រកូលរបស់កូនដែរ ឬក៏អាចដាក់ត្រកូលអ្វីក៏បាន តាមតែការកំណត់របស់ឪពុកម្ដាយ?**

យោងតាមអនុក្រឹត្យ ស្ដីពីអត្រានុកូលដ្ឋាន (មាត្រា ១៨) ការកំណត់នាមត្រកូលរបស់កូន អាចធ្វើឡើងបាន ៣យ៉ាង៖

- អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយក៏បាន
- អាចយកឈ្មោះជីតាខាងឪពុកមកដាក់ជានាមត្រកូលក៏បាន
- ឬក៏អាចយកឈ្មោះរបស់ឪពុក មកដាក់ជានាមត្រកូលក៏បាន

ចំពោះឈ្មោះរបស់ទារកវិញ (នាមខ្លួន) គឺឪពុក ម្ដាយ ឬអាណាព្យាបាលជាអ្នកដាក់ឲ្យ។ ការកំណត់ឈ្មោះ និងនាមត្រកូលរបស់ទារកនេះ គឺត្រូវធ្វើឡើងតាំងពីពេលចុះសំបុត្រកំណើត។ មែនទែនទៅ ឪពុកម្ដាយត្រូវរកឈ្មោះដាក់ឲ្យកូន តាំងពីមុនចុះសំបុត្រកំណើតម្ល៉េះ ព្រោះ បើកើតនៅមន្ទីរពេទ្យ លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យក៏ត្រូវមានកំណត់ នាមត្រកូល និងនាមខ្លួនទារក។ បើកើតនៅផ្ទះ លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារក ដែលចេញដោយមេភូមិក៏ត្រូវមានដាក់នាមត្រកូល និងនាមខ្លួនទារកដែរ។

## ផ្នែកទី៥២

# ក្នុងករណីឪពុកម្ដាយលែងលះគ្នា តើកូនត្រូវបានទៅខាងណាជាអ្នកគ្រប់គ្រង?

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា សូមធ្វើការពន្យល់ជុំវិញសិទ្ធិគ្រប់គ្រងកូន នៅក្នុងករណីឪពុកម្ដាយលែងលះគ្នា។ តើអំណាចមេបាត្រូវប្រគល់ទៅឲ្យឪពុក ឬម្ដាយ? តើអ្នកគ្មានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចអ្វីខ្លះ?

**១.នៅក្នុងករណី ដែលឪពុកម្ដាយលែងលះគ្នា តើកូនត្រូវបានទៅអ្នកណាជាអ្នកគ្រប់គ្រង?**

ជាបឋម គួរបញ្ជាក់ថា កាលណានិយាយអំពីការគ្រប់គ្រងកូន នៅក្នុងករណីលែងលះ គេត្រូវនិយាយពីចំណុចសំខាន់ ២ គឺ អំណាចមេបា (តើឪពុក ឬម្ដាយ ឬទាំងឪពុក និងម្ដាយ ដែលត្រូវមានអំណាចមេបាលើកូន?) និងទីកន្លែង ដែលកូនត្រូវរស់នៅ (កូនត្រូវរស់នៅជាមួយឪពុក ឬជាមួយម្ដាយ?)។

ជាធម្មតា កាលណាលែងលះគ្នា ឪពុកម្ដាយ នឹងត្រូវរស់នៅបែកគ្នា។ ដូច្នេះ កូនត្រូវទៅរស់នៅជាមួយខាងណាមួយ (ជាមួយឪពុក ឬជាមួយម្ដាយ?)។

បើគេនិយាយពីគោលការណ៍ច្បាប់ជាទូទៅ នៅក្រោយការលែងលះ ការកំណត់ពីអំណាចមេបា អាចធ្វើឡើងតាមពីររបៀប គឺ អំណាចមេបារួម និងអំណាចមេបាទោល។ អំណាចមេបារួម គឺមានន័យថា បើទោះបីជារស់នៅបែកគ្នាក៏ដោយ ឪពុក និងម្ដាយ ដែលលែងលះគ្នា នៅតែមានអំណាចមេបារួមគ្នាលើកូន ដូចជា កាលពីមិនទាន់លែងលះគ្នាដែរ។

ក៏ប៉ុន្តែ ច្បាប់ខ្មែរ គឺនៅក្នុងក្រមរដ្ឋប្បវេណី (មាត្រា ១០៣៧) ទទួលស្គាល់តែអំណាចមេបាទោលតែប៉ុណ្ណោះ ដោយមិនទទួលស្គាល់អំណាចមេបារួមទេនៅក្នុងករណីលែងលះ។ មានន័យថា អំណាចមេបាត្រូវប្រគល់ទៅឲ្យខាងណាមួយ។ ឬមួយត្រូវឲ្យទៅម្ដាយ។ ឬមួយត្រូវឲ្យទៅឪពុក។ តាមធម្មតា បើម្ដាយជាអ្នកទទួលអំណាចមេបា កូនត្រូវរស់នៅជាមួយម្ដាយ។ បើឪពុកជាអ្នកទទួលអំណាចមេបា កូនត្រូវរស់នៅជាមួយនឹងឪពុក។

**២.តើការសម្រេចប្រគល់កូនទៅឲ្យឪពុក ឬទៅឲ្យម្ដាយជាអ្នកគ្រប់គ្រង ត្រូវធ្វើឡើងដោយរបៀបណា? ហើយត្រូវធ្វើឡើងដោយយោងទៅលើកត្តាអ្វីខ្លះ?**

មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ផ្ដល់អាទិភាពទៅឲ្យឪពុកម្ដាយ ដែលចង់លែងលះគ្នា ជាអ្នកពិភាក្សាគ្នា កំណត់អំពីការគ្រប់គ្រងកូន។

ប្រសិនបើឪពុកម្ដាយមិនអាចស្វែងរកដំណោះស្រាយតាមរយៈការជជែកពិភាក្សាគ្នាបានទេ គឺតុលាការជាអ្នកសម្រេច ហើយតុលាការត្រូវសម្រេចយកផលប្រយោជន៍របស់កូនជាធំ។ ជាទូទៅ តុលាការតែងតែពិនិត្យមើលទៅលើចំណុចមួយចំនួនដូចជា៖

- ការងារ និងប្រាក់ចំណូល៖ តើខាងណា ដែលមានការងារ និងប្រាក់ចំណូលជាប់លាប់ជាង ដើម្បីជានាពីការចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូន?
- ផ្ទះសម្បែង៖ តើខាងណា ដែលមានលំនៅដ្ឋានជាប់លាប់ មានផ្ទះធំល្អ សម្រាប់ឲ្យកូនរស់នៅសមរម្យ? តើទីលំនៅខាងណា ដែលមានទីតាំងមានអំណោយផលជាង សម្រាប់ការរៀនសូត្ររបស់កូន?
- បុគ្គលិកលក្ខណ: អាកប្បកិរិយា និងមនោសញ្ចេតនាចំពោះកូន៖ រវាងឪពុក និងម្ដាយ តើមានខាងណាមួយដែលធ្លាប់ប្រើអំពើហិង្សាលើកូនដែរ ឬទេកន្លងមក? តើធ្លាប់បង្ហាញពីការយកចិត្តទុកដាក់លើកូនប៉ុណ្ណា?

ដូច្នេះ បើសិនជាតុលាការមើលទៅឃើញថា ឪពុក ឬម្តាយណាមួយ គិតតែពីដើរផឹកស៊ី ឬលេងល្បែងស៊ីសង គ្មានគិតគូរធ្វើការរកស៊ី គ្មានផ្ទះសម្បែងត្រឹមត្រូវ ឬក៏ធ្លាប់ប្រើអំពើហិង្សាលើកូន តុលាការនឹងមិនឲ្យឪពុក ឬម្តាយនោះ ជាអ្នកទទួលសិទ្ធិគ្រប់គ្រងកូនទេ គឺប្រាកដជាត្រូវឲ្យទៅម្ខាងទៀត ដែលមានការងារធ្វើជាប់លាប់ជាង មានផ្ទះសម្បែងត្រឹមត្រូវ មានអត្តចរឹកសមរម្យ មានការយកចិត្តទុកដាក់ក្នុងការបីបាច់ថែរក្សាកូន។

**៣.តើឪពុក ឬម្តាយ ដែលមិនមានអំណាចមេបា (មិនរស់នៅជាមួយកូន) ត្រូវមានសិទ្ធិអ្វីខ្លះ?**

ឪពុក ឬម្តាយ ដែលទទួលបានសិទ្ធិគ្រប់គ្រងកូន នៅតែមានចំណងញាតិស្របច្បាប់ជាមួយកូន ជាឪពុក ឬជាម្តាយដដែល។ ការប្រគល់សិទ្ធិឲ្យឪពុកជាអ្នកគ្រប់គ្រងកូន មិនមែនមានន័យថា ចំណងគតិយុត្តរវាងកូន និងម្តាយត្រូវកាត់ផ្តាច់នោះទេ ហើយការប្រគល់សិទ្ធិទៅឲ្យម្តាយគ្រប់គ្រងជាអ្នកគ្រប់គ្រងកូន ក៏មិនមែនមានន័យថា ចំណងគតិយុត្តជាឪពុកត្រូវកាត់ផ្តាច់នោះដែរ។

ឪពុក ឬម្តាយ ដែលមិនបានទទួលសិទ្ធិគ្រប់គ្រងកូន នៅតែមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយនឹងកូន ហើយក្នុងពេលជាមួយគ្នា នៅតែមានករណីយកិច្ចចូលរួមទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន។ ចំណែកឯឪពុក ឬម្តាយ ដែលទទួលសិទ្ធិគ្រប់គ្រងកូន ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ក្នុងការចូលជួប សួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយកូន។

របៀបនៃការចូលជួប ការប្រាស្រ័យទាក់ទងជាមួយកូន និងការចូលរួមចំណែក ក្នុងសោហ៊ុយចាំបាច់ ក្នុងការគ្រប់គ្រងថែរក្សាកូន (អាហារកិច្ច) គឺត្រូវកំណត់ តាមរយៈការជជែកពិភាក្សាគ្នា រវាងឪពុក និងម្តាយ។ ប្រសិនបើឪពុកម្តាយមិនមានការព្រមព្រៀងគ្នាទេ គឺតុលាការជាអ្នកសម្រេច ដោយយកផលប្រយោជន៍កូនជាធំ ហើយនៅក្នុងការកំណត់អំពីអាហារកិច្ច តុលាការក៏ត្រូវគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយដែរ។

ចំណុចសំខាន់មួយទៀត ឪពុក ឬម្តាយ ដែលមិនទទួលបានសិទ្ធិគ្រប់គ្រងកូន នៅតែមានសិទ្ធិទាមទារឲ្យភាគីម្ខាងទៀតរាយការណ៍អំពីស្ថានភាពរបស់កូននេះបាន។ ម្យ៉ាងទៀត ចំពោះកិច្ចការសំខាន់ៗ ដែលទាក់ទងនឹងអាយុជីវិតកូន ទាក់ទងនឹងអនាគតកូន ឪពុក ឬម្តាយ ដែលទទួលសិទ្ធិគ្រប់គ្រងកូន មានកាតព្វកិច្ចពិភាក្សាជាមួយនឹងភាគីម្ខាងទៀត មុននឹងធ្វើការសម្រេចអ្វីមួយ លើកលែងតែក្នុងករណីចាំបាច់បន្ទាន់ មិនអាចពិភាក្សាគ្នាបាន។

កិច្ចការចាំបាច់ ដែលច្បាប់តម្រូវឲ្យមានការពិភាក្សាគ្នានេះ មានចែងក្នុងមាត្រា ១០៤២ នៃក្រមរដ្ឋប្បវេណី គឺមាន៖

- ការអប់រំកូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំ ដែលកំណត់ដោយច្បាប់ ដូចជា ការបញ្ជូនកូនឲ្យទៅរៀននៅមហាវិទ្យាល័យ ឬបញ្ជូនកូនឲ្យទៅរៀននៅបរទេស ជាដើម
- ការផ្លាស់ប្តូរទីសំណាក់របស់កូន ពីខេត្តក្រុងមួយទៅខេត្តក្រុងមួយទៀត។ ការពិគ្រោះយោបល់គ្នាលើចំណុចនេះវាមានសារៈសំខាន់ ដើម្បីចៀសវាងកុំឲ្យប៉ះពាល់ទៅដល់សិទ្ធិ ក្នុងការជួបសួរសុខទុក្ខ និងការប្រាស្រ័យទាក់ទងជាមួយកូន
- សេចក្តីសម្រេចទាក់ទងនឹងវិជ្ជាជីវៈ ឬអាជីវកម្មរបស់កូន ដូចជា ការសម្រេចឲ្យកូនឈប់រៀន ហើយចាប់ផ្តើមប្រកបការងារអ្វីមួយ ឬក៏ឲ្យកូនផ្អាក ឬបញ្ឈប់ការសិក្សា ដើម្បីទៅបួស ជាដើម
- សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន
- ការចាត់ចែងទ្រព្យសម្បត្តិរបស់កូន

- ការសម្រេចសំខាន់ៗផ្សេងទៀត ដែលទាក់ទងនឹងការគ្រប់គ្រងថែរក្សាកូន និងទ្រព្យសម្បត្តិរបស់កូន។ ការដែលច្បាប់ចែងត្រង់ចំណុចចុងក្រោយនេះ គឺដើម្បីទុកលទ្ធភាពឲ្យឪពុកម្តាយ ធ្វើការពិចារណាដោយខ្លួនឯង អំពីចំណុចសំខាន់ៗផ្សេងៗទៀត ដែលមិនមានចែងនៅក្នុងប៉ុន្មានចំណុចខាងលើ ប៉ុន្តែ ខ្លួនយល់ថា ជាចំណុចសំខាន់ដែលចាំបាច់ត្រូវធ្វើការពិភាក្សាគ្នាមុននឹងសម្រេចចិត្ត។

**៤. ចុះបើនៅក្នុងការពិភាក្សាគ្នា ទៅលើចំណុចសំខាន់ៗទាំងនេះ ឪពុកម្តាយមិនឯកភាពគ្នា តើខាងណាជាអ្នកមានសិទ្ធិសម្រេចចុងក្រោយ?**

នៅត្រង់ចំណុចនេះ ច្បាប់មិនបានចែងបញ្ជាក់ច្បាស់លាស់ទេ ក៏ប៉ុន្តែ បើយើងពិនិត្យមើលជារួម ដោយសារតែឪពុក ឬម្តាយ ដែលទទួលសិទ្ធិគ្រប់គ្រងកូន គឺជាអ្នកមានអំណាចមេបា ដូច្នេះ គួរតែការសម្រេចរបស់អ្នកមានអំណាចមេបានេះដែលត្រូវមានអាទិភាព។ ប្រសិនបើភាគីម្ខាងទៀត គឺឪពុក ឬម្តាយ ដែលគ្មានអំណាចមេបាជំទាស់នឹងការសម្រេចនេះ ដោយយល់ថា ជាការសម្រេចដែលនាំឲ្យប៉ះពាល់ទៅដល់សុខមាលភាពរបស់កូន ទៅដល់ផលប្រយោជន៍របស់កូន គាត់អាចទាមទារទៅតុលាការ សុំឲ្យមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងកូនវិញបាន ដូចដែលមានចែងកំណត់ក្នុង មាត្រា ១០៣៩ នៃក្រមរដ្ឋប្បវេណី។

## ផ្នែកទី៥៣

## ឆ្លើយនឹងសំណួររបស់អ្នកស្ដាប់ជុំវិញការលែងលះ

ដោយ សេង ឌីណា

នៅថ្ងៃនេះ សេង ឌីណា សូមឆ្លើយនឹងសំណួររបស់អ្នកស្ដាប់របស់យើងមួយចំនួន ដែលបានផ្ញើជាសំណួរ មកចង់ដឹងអំពីរឿងខ្លះៗ ទាក់ទងនឹងបញ្ហាច្បាប់ (ការលែងលះ)។

**១. តើប្ដីដែលមិនគិតជីវភាពប្រពន្ធ-កូន ចុះចោលផ្ទះជាយូរខែហើយៗ បែរជាមកប្ដឹងលែងប្រពន្ធទៀត តើត្រូវមានទោសដែរ ឬទេ?**

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ មាត្រា ៣០ ចែងថា “*ប្ដី ប្រពន្ធ មានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និងជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល*”។

បើប្ដីមិនគិតគូរជីវភាពប្រពន្ធ-កូន ចុះចោលផ្ទះរាប់ខែ គឺគាត់រំលោភលើករណីយកិច្ចជាប្ដី ដែលមានចែងក្នុងមាត្រា ៣០នេះ។ ដូច្នេះ គាត់ជាអ្នកខុស។ គាត់មិនអាចមកប្ដឹងលែងប្រពន្ធបានទេ។ តាមត្រូវ គឺប្រពន្ធទៅវិញទេ ដែលអាចប្ដឹងលែងបាន។

ក៏ប៉ុន្តែ សួរថា ចុះបើប្ដីជាអ្នកប្ដឹងលែង តើគាត់ត្រូវមានទោសដែរឬទេ? បើឲ្យគាត់មានទោស ក៏មិនដឹងជាត្រូវឲ្យគាត់មានទោសអ្វីដែរ ពីព្រោះថា ច្បាប់មិនមានចែង។ មិនមានច្បាប់ណា ចែងថា គ្រាន់តែប្ដឹងលែងប្រពន្ធត្រូវមានទោសនោះទេ។ បើបណ្ដឹងរបស់គាត់មិនត្រឹមត្រូវ មិនមានអ្វីជាសំអាង យ៉ាងច្រើន គឺចៅក្រមមិនកាត់ឲ្យលែងលះតាមបណ្ដឹងនេះ។ ចំណែកអ្នកប្ដឹងមិនត្រូវជាប់ទោសអ្វីទៀតទេ។

**២. ក្នុងករណីនេះ ប្រសិនបើប្ដីប្ដឹងលែង ហើយប្រពន្ធមិនព្រមលែង តើតុលាការមានសិទ្ធិកាត់ឲ្យលែងដែរ ឬទេ?**

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារបានកំណត់ថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យា ដែលមានភាគី ២ គឺបុរសជាប្ដី និងស្ត្រីជាប្រពន្ធ។ ថ្វីដ្បិតតែជាកិច្ចសន្យា ដែលមានលក្ខណៈពិសេស ក៏ប៉ុន្តែ អាពាហ៍ពិពាហ៍នៅតែជាកិច្ចសន្យាមួយ។ ដូច្នេះ តុលាការមិនអាចលូកដៃចូលមករំលាយកិច្ចសន្យានេះបានទេ ប្រសិនបើមិនមានការស្ម័គ្រចិត្តទាំងសងខាង គឺទាំងខាងប្ដី និងខាងប្រពន្ធ។

ប្រសិនបើមានតែភាគីម្ខាងចង់លែង ឯភាគីមួយទៀតមិនព្រមលែង តុលាការអាចកាត់ឲ្យលែងបាន លុះត្រាតែ ភាគីដែលប្ដឹងសុំលែងបង្ហាញអំពីមូលហេតុច្បាស់លាស់។ មូលហេតុនេះ គឺមានចែងក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រង់មាត្រា ៣៩៖

- ការចុះចោលលំនៅសង្វាស ដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបំរុងកូនសោះ
- មានការវាយដំឃោរឃៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរ ចំពោះសហព័ទ្ធ ឬចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ (សហព័ទ្ធនេះ គឺចង់សំដៅលើប្ដី ឬប្រពន្ធ ឯបុព្វញាតិ គឺសំដៅញាតិនៅខ្សែខាងលើ ដូចជា ឪពុក-ម្ដាយ ឬក៏ជីដូន-ជីតា ជាដើម)
- មានចរិយាផ្ទុយពីសីលធម៌ ឬប្រព្រឹត្តអំពើអនាចារ (ដូចជា ទៅរំលោភគេ ទៅលបមានសាហាយស្មន់ ជាដើម)
- ខ្វះសមត្ថភាពខាងផ្លូវភេទ (មានន័យថា គាត់មិនអាចរួមភេទបាន)
- បើភាគីទាំងពីរបែកគ្នាអស់រយៈពេលលើសពី១ឆ្នាំ

ក្នុងករណីដែលប្តីជាអ្នកចុះចោលប្រពន្ធកូន អត់គិតគូរពីជីវភាពគ្រួសារ គឺអាចចូលក្នុងមូលហេតុទី១មែន ក៏ប៉ុន្តែតុលាការមិនអាចសម្រេចឲ្យលែងបានទេ ពីព្រោះថា ភាគីដែលប្តឹងលែង (ប្តី) គឺជាអ្នកមានកំហុស។ តុលាការអាចសម្រេចឲ្យលែងបាន ទាល់តែក្នុងករណីបញ្ច្រាសមកវិញ គឺភាគីចុងចម្លើយជាអ្នកខុស។

ក៏ប៉ុន្តែ បើសិនជាប្តី ដែលចុះចោលផ្ទះនេះ គឺគាត់ចុះទៅបាត់ លើសពីមួយឆ្នាំ មិនដែលវិលមករួមរស់ជាមួយប្រពន្ធវិញសោះ នេះអាចចូលក្នុងមូលហេតុទី ៥ ក្នុងមាត្រា ៣៩ ខាងលើ (ភាគីទាំងពីរបែកគ្នាអស់រយៈពេលមួយឆ្នាំ) ដែលជាមូលហេតុអាចឲ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចការលែងលះបាន។

គួរបញ្ជាក់ថា បើទោះជាក្នុងករណីមានការព្រមព្រៀងពីភាគីទាំងពីរ ក្នុងការលែងលះក៏ដោយ ក្នុងករណីមានមូលហេតុគ្រប់គ្រាន់ ដូចមានចែងក្នុងច្បាប់ក៏ដោយ ក៏ចៅក្រមមិនអាចចេះតែសម្រេចឲ្យលែងលះស្រួលៗដែរ។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារបានកំណត់ច្បាស់លាស់ អំពីនីតិវិធីមុននឹងឈានទៅជំនុំជម្រះសម្រេចសេចក្តីឲ្យលែងលះ ពោលគឺតុលាការចាំបាច់ត្រូវតែធ្វើការផ្សះផ្សាជាមុនសិន។ បើផ្សះផ្សាលើកទី១មិនបានសម្រេច ត្រូវផ្សះផ្សាលើកទី២ទៀត។ បើនៅតែផ្សះផ្សារមិនបានទៀត ទើបឈានទៅជំនុំជម្រះសម្រេចការលែងលះ។

## ផ្នែកទី៥៤

# តើច្បាប់ខ្មែរចែងពីលក្ខខណ្ឌអ្វីខ្លះស្តីពីការសុំកូនទៅចិញ្ចឹមនៅបរទេស?

ដោយ សេង ឌីណា

រដ្ឋាភិបាលកម្ពុជាទើបនឹងបានប្រកាសថា នឹងចាប់ផ្តើមបើកឲ្យមានការសុំកូនយកទៅចិញ្ចឹមនៅបរទេសឡើងវិញ នៅដើមឆ្នាំ២០១៣ ឆាប់ៗខាងមុខនេះ ក្រោយពីបានផ្អាកមួយរយៈ ចាប់តាំងពីឆ្នាំ២០០៩មក។ ការសុំកូនយកទៅចិញ្ចឹមឆ្លងប្រទេស គឺជាផ្នែកមួយនៃនីតិឯកជនអន្តរជាតិ ដែលចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអន្តរជាតិ និងមានបទដ្ឋាន ដែលស្របនឹងស្តង់ដារអន្តរជាតិ។

**១.តើការសុំកូនយកទៅចិញ្ចឹមនៅបរទេស អាចមានចោទជាបញ្ហាអ្វីខ្លះ?**

ការសុំកូនទៅចិញ្ចឹមឆ្លងប្រទេស គឺជាបញ្ហាស្មុគស្មាញ ដោយសារតែវាមិនអាស្រ័យលើច្បាប់ និងអាជ្ញាធរនៃប្រទេសតែមួយ។ ការរៀបចំបទដ្ឋានច្បាប់ និងនីតិវិធីថ្នាក់ជាតិឲ្យត្រូវតាមស្តង់ដារអន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសកំណើតរបស់កូនសុំ និងប្រទេសរបស់អ្នកសុំ គឺជារឿងចាំបាច់ ដើម្បីចៀសវាងបញ្ហា ដែលអាចបង្កផលប៉ះពាល់ដល់អនាគតរបស់កុមារ និងជាពិសេស ការជួញដូរកុមារ។

ប្រទេសកំណើតរបស់កូនសុំ និងប្រទេសរបស់អ្នកសុំ ចាំបាច់ត្រូវមានការទុកចិត្តគ្នាទៅវិញទៅមកថាមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបំពេញតាមកាតព្វកិច្ចរៀងៗខ្លួន។

ប្រទេសកំណើតរបស់កូនសុំត្រូវតែមានច្បាប់ នីតិវិធី និងស្ថាប័នគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌដែលទាក់ទងនឹងកូនសុំ ដើម្បីឲ្យដឹងប្រាកដច្បាស់ថា កុមារពិតជាក្មេងកំព្រា ឬជាក្មេងដែលស្ថិតក្នុងស្ថានភាពលំបាក ដែលគួរដាក់ជាកូនសុំ។

ចំណែកប្រទេសកំណើតរបស់អ្នកសុំវិញត្រូវតែមានច្បាប់ នីតិវិធី និងស្ថាប័នគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌ ដែលទាក់ទងនឹងអ្នកសុំ ដើម្បីឲ្យប្រាកដថា គ្រួសារថ្មីនេះអាចផ្តល់ការថែទាំសមស្របដល់កូនសុំ។

**២.រហូតមកទល់សព្វថ្ងៃនេះ តើកម្ពុជាមានក្របខ័ណ្ឌច្បាប់អ្វីខ្លះ ដែលគ្រប់គ្រងការសុំកូនយកទៅចិញ្ចឹមនៅបរទេស?**

កាលពីដំបូង គឺមានអនុក្រឹត្យឆ្នាំ២០០១ "ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាទៅចិញ្ចឹមនៅបរទេស"។ ក្រោយមកនៅឆ្នាំ២០០៧ កម្ពុជាបានផ្តល់សច្ចាប័ន លើ "អនុសញ្ញាស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស" (អនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៩៣) ហើយនៅឆ្នាំ២០០៩ រដ្ឋសភាកម្ពុជាក៏បានអនុម័តច្បាប់មួយទៀត គឺ "ច្បាប់ស្តីពីសុំកូនអន្តរប្រទេស" ដើម្បីរៀបចំបទដ្ឋានឲ្យត្រូវទៅតាមអនុសញ្ញាក្រុងឡាអេនេះ។

ក៏ប៉ុន្តែ តាំងពីត្រូវអនុម័តមក ច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩នេះ មិនទាន់ត្រូវបានរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមអនុវត្តនៅឡើយទេ ដោយសារតែត្រូវចាំរៀបចំនីតិវិធី បែបបទលម្អិតក្នុងការអនុវត្ត ហើយជាពិសេស គឺក្រសួងសង្គមកិច្ច ដែលជា "អាជ្ញាធរកណ្តាលសុំកូនអន្តរជាតិ" ត្រូវរៀបចំបង្កើតជារដ្ឋបាលសុំកូនអន្តរជាតិ ដែលត្រូវជាសេនាធិការទទួល និងពិនិត្យពាក្យសុំកូនអន្តរប្រទេស។

**៣.តើនៅក្នុងច្បាប់ ឆ្នាំ២០០៩នេះ មានចែងអំពីលក្ខខណ្ឌអ្វីខ្លះ ដើម្បីឲ្យជនជាតិបរទេសអាចសុំកូននៅកម្ពុជាយកទៅចិញ្ចឹមបាន?**

លក្ខខណ្ឌត្រូវចែកជាពីរផ្នែកៈ លក្ខខណ្ឌទាក់ទងនឹងកូនដែលត្រូវសុំយកទៅចិញ្ចឹម និងលក្ខខណ្ឌទាក់ទងនឹងអ្នកសុំ។

**លក្ខខណ្ឌទាក់ទងនឹងកូនសុំ**

ច្បាប់ចែងថា កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ៥៖

១-ត្រូវមានសញ្ជាតិខ្មែរ ហើយមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា

២-ត្រូវមានអាយុក្រោម ៨ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីពិសេសខ្លះ ដូចជា ករណីកុមារត្រូវការចាំបាច់នូវការថែទាំពិសេស គឺអាចអនុញ្ញាតឲ្យសុំទៅចិញ្ចឹមបាន ទោះបីជាមានអាយុលើសពី៨ឆ្នាំក៏ដោយ ក៏ប៉ុន្តែ មិនត្រូវឲ្យដល់អាយុ ១៨ឆ្នាំ។ ករណីមួយទៀត គឺកូនសុំមានច្រើនគ្នា ហើយជាបងប្អូនបង្កើតនឹងគ្នា បើមានកូនមួយណាអាយុក្រោម ៨ឆ្នាំ ហើយកូនផ្សេងទៀតអាយុលើសពី ៨ឆ្នាំ តែក្រោម ១៨ឆ្នាំ គឺអាចសុំយកទៅចិញ្ចឹមរួមគ្នាបាន។

៣-ត្រូវតែជាកុមារ ដែលកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬកន្លែងណាផ្សេងទៀត ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសង្គមកិច្ច។

៤-ត្រូវតែជាកុមារដែលស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬស្ថិតក្រោមអំណាចមេបា ដែលមានស្ថានភាពលំបាកបំផុត។

៥-ត្រូវតែជាកុមារ ដែលក្រសួងសង្គមកិច្ចបានខិតខំអស់ពីលទ្ធភាព រកដំណោះស្រាយក្នុងស្រុកជាមុនសិន។ មានន័យថា ដំបូងក្រសួងសង្គមកិច្ចត្រូវខិតខំឲ្យអស់ពីលទ្ធភាព ដើម្បីបញ្ជូនកុមារទៅគ្រួសារកំណើត បើមិនអាចធ្វើទៅបានទេត្រូវរកដំណោះស្រាយតាមរយៈការសុំកូនក្នុងប្រទេសកម្ពុជាជាមុនសិន។ ខិតខំអស់លទ្ធភាពហើយ នៅតែមិនអាចដោះស្រាយតាមវិធីទាំងពីរខាងលើនេះទេ ទើបអាចឲ្យសុំកុមារនេះយកទៅចិញ្ចឹមនៅបរទេសបាន។

**លក្ខខណ្ឌទាក់ទងនឹងអ្នកសុំ**

ជនបរទេស ដែលអាចសុំកូនខ្មែរយកទៅចិញ្ចឹមបាន ទាល់តែ៖

១-មានអាយុចាប់ពី៣០ឆ្នាំឡើងទៅ ប៉ុន្តែ មិនលើសពី ៤៥ឆ្នាំ ហើយអាយុត្រូវលើសកូនសុំ យ៉ាងតិច ២២ឆ្នាំ។

២-អ្នកសុំត្រូវតែជាប្តីប្រពន្ធ ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយការសុំកូនត្រូវតែធ្វើឡើងដោយប្តីប្រពន្ធទាំងពីរនាក់រួមគ្នា។

៣-អ្នកសុំត្រូវតែមានសញ្ជាតិ ឬមានលំនៅឋានអចិន្ត្រៃយ៍ នៅក្នុងប្រទេស ដែលមានទំនាក់ទំនងការទូតជាមួយកម្ពុជា ហើយច្បាប់ជាតិនៃប្រទេសរបស់អ្នកសុំនេះ ត្រូវតែទទួលស្គាល់ចំណងបុត្តភាពរបស់កូនសុំ ក្នុងលក្ខណៈជាកូនសុំពេញលេញ។

៥-អ្នកសុំត្រូវតែមានលក្ខណសម្បត្តិ និងលក្ខខណ្ឌចាំបាច់ ដែលច្បាប់ជាតិរបស់ខ្លួនតម្រូវសម្រាប់ការសុំកូន។ ត្រូវមានសមត្ថភាពផ្តល់ការថែទាំដល់កូនសុំ។ មិនធ្លាប់ត្រូវបានផ្តន្ទាទោស ឬកំពុងជាប់បណ្តឹងពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬកំហុសណាមួយផ្សេងទៀត ដែលទាក់ទងនឹងកិរិយាមារយាទ។

៦-អាចសុំកូនទៅចិញ្ចឹមបាន ទាល់តែអ្នកសុំអត់មានកូនសោះ ឬមានកូនតែម្នាក់ក្នុងបន្ទុក។ ហើយសម្រាប់ប្តីប្រពន្ធមួយគូ អាចសុំកូនពីកម្ពុជាទៅចិញ្ចឹមបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែករណីសុំកូន ដែលជាបងប្អូនបង្កើតនឹងគ្នា ទើបអាចសុំច្រើនគ្នាបាន។

ចុងក្រោយ ដំណើការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីសំណាក់ឳពុកម្តាយ ឬអាណាព្យាបាលរបស់កូនសុំជាមុនសិន។ ហើយការយល់ព្រមនេះត្រូវតែធ្វើឡើងដោយច្បាស់លាស់ និងដោយសេរី មិនត្រូវមានការបង្ខិតបង្ខំការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្តល់លាភសក្ការៈអ្វីមួយនោះទេ។

# ផ្នែកទី៥៥

# ការគ្រប់គ្រង ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ

ដោយ សេង ឌីណា

នៅក្នុងទំនាក់ទំនងប្តីប្រពន្ធ ការគ្រប់គ្រង ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិអាចនាំទៅរកវិវាទ ទាំងនៅក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ ក៏ដូចជា នៅពេលលែងលះ។ ដើម្បីបង្កា និងដោះស្រាយវិវាទទាំងនេះ ក្រមរដ្ឋប្បវេណីខ្មែរមានចែងអំពីប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ។ ខាងក្រោមនេះ គឺជាសំណួរ-ចម្លើយ ជុំវិញការគ្រប់គ្រង ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ។

**១. តាមច្បាប់ខ្មែរ ចំពោះប្តីប្រពន្ធដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ តើទ្រព្យសម្បត្តិណាខ្លះត្រូវចាត់ទុកជាទ្រព្យរួម ហើយទ្រព្យណាខ្លះជាទ្រព្យដោយឡែក?**

ការបែងចែកទ្រព្យរួម និងទ្រព្យដោយឡែក គឺវាអាស្រ័យនឹងប្រព័ន្ធទ្រព្យសម្បត្តិ ដែលប្តីប្រពន្ធទាំងពីរជ្រើសរើស។ ក្រមរដ្ឋប្បវេណីខ្មែរទុកលទ្ធភាពឲ្យប្តីប្រពន្ធធ្វើកិច្ចសន្យា ដើម្បីកំណត់ការបែងចែក និងការចាត់ចែងទ្រព្យសម្បត្តិ ដែលគេហៅថា ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ក្រមរដ្ឋប្បវេណីតម្រូវថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចាំបាច់ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយដើម្បីអាចយកទៅតតាំងជាមួយនឹងតតិយជនបាន កិច្ចសន្យានេះត្រូវតែចុះបញ្ជីត្រឹមត្រូវនៅក្រសួងយុត្តិធម៌។

បើសិនជាប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិទេ ការបែងចែក គ្រប់គ្រង និងចាត់ចែងទ្រព្យ គឺត្រូវធ្វើតាមច្បាប់ដែលបានកំណត់ ដែលគេហៅថា ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

**ក.ទ្រព្យសម្បត្តិដោយឡែក**

ច្បាប់ (មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី) កំណត់ថា ត្រូវចាត់ទុកជាទ្រព្យដោយឡែករបស់សហព័ទ្ធតែម្ខាង (របស់ប្តី ឬរបស់ប្រពន្ធ) គឺ៖

- ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ មានន័យថា មុនពេលរៀបការ ភាគីខាងណាមានទ្រព្យអ្វី ក្រោយពេលរៀបការ ទ្រព្យនោះ ត្រូវស្ថិតនៅជាកម្មសិទ្ធិដោយឡែករបស់ភាគីនោះដដែល មិនត្រូវរាប់ជាទ្រព្យរួមទេ។
- ទ្រព្យសម្បត្តិដែលសហព័ទ្ធណាមួយទទួលបានក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែ ទទួលជាកេរមរតក ឬដោយអំណោយ (ប្រទានកម្ម ឬអច្ច័យទាន)។ ឧបមាថា ក្រោយរៀបការហើយ ឪពុកម្តាយរបស់ភាគីខាងប្តីគាត់ស្លាប់ទៅហើយបន្សល់ទុកទ្រព្យជាកេរទៅឲ្យកូន ទ្រព្យនេះត្រូវជាទ្រព្យផ្ទាល់របស់ប្តី។ ក្នុងករណីអំណោយ បើម្ចាស់អំណោយឲ្យទៅអ្នកណា គឺជាទ្រព្យផ្ទាល់របស់អ្នកនោះ បើសិនជាម្ចាស់អំណោយបញ្ជាក់ច្បាស់ថាឲ្យទៅទាំងពីរនាក់ប្តីប្រពន្ធ គឺជាទ្រព្យរួម។
- ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិទាំងពីរប្រភេទខាងលើ។ ឧទាហរណ៍ថា ភាគីជាប្រពន្ធមានដីមួយកន្លែង ដែលជាទ្រព្យផ្ទាល់ ដែលគាត់មានតាំងពីមុនពេលរៀបការ។ ក្រោយមក ក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ គាត់លក់ដីនេះចេញ រួចហើយយកលុយដែលបានពីការលក់ដីនេះ ទៅទិញផ្ទះមួយល្វែង ផ្ទះនេះ នៅតែជាទ្រព្យសម្បត្តិផ្ទាល់របស់គាត់ ទោះបីជាទិញនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ក៏ដោយ។

**ខ.ទ្រព្យសម្បត្តិរួម**

ក្រមរដ្ឋប្បវេណីខ្មែរកំណត់ថា *"ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាង ទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍"* (មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី)។ និយាយជារួម លើកលែងតែទ្រព្យសម្បត្តិទាំងបីប្រភេទខាងលើ រាល់ទ្រព្យទាំងអស់ ដែលទទួលបានក្នុងពេលអាពាហ៍ពិពាហ៍ (ដូចជា ប្រាក់ខែ ប្រាក់ចំណូលពីការប្រកបអាជីវកម្ម ផ្ទះ ដី ឡាន ដែលទិញក្នុងពេលមានចំណងអាពាហ៍ពិពាហ៍) ត្រូវចាត់ទុកជាទ្រព្យរួមទាំងអស់ ទោះបីជាទ្រព្យនោះរកបានដោយសហព័ទ្ធណាមួយក៏ដោយ។

**២.យើងសង្កេតឃើញថា នៅក្នុងសង្គមខ្មែរយើង មានករណីច្រើន ដែលមានតែប្តីជាអ្នកធ្វើការរកស៊ី ឯប្រពន្ធ គឺជាមេផ្ទះ។ ក្នុងករណីនេះ តើប្រពន្ធដែលជាមេផ្ទះ មានសិទ្ធិទៅលើប្រាក់ខែ ឬប្រាក់ចំណូល ដែលបានពីការងាររបស់ប្តីដែរ ឬទេ?**

ក្នុងករណីនេះ ប្រាក់ខែ ឬប្រាក់ចំណូល ដែលបានពីការងាររបស់ប្តី គឺជាទ្រព្យដែលទទួលបានក្នុងចំណងអាពាហ៍ពិពាហ៍ ហើយតាមច្បាប់ គឺត្រូវចាត់ទុកជាទ្រព្យសម្បត្តិ។ ដូច្នេះ ប្រពន្ធត្រូវមានសិទ្ធិស្មើគ្នាលើទ្រព្យរួមនេះ បើទោះបីជាគាត់មិនធ្វើការក៏ដោយ។ តាមពិតទៅ ក្នុងក្រមរដ្ឋប្បវេណី ត្រង់មាត្រា ៩៨០ គឺមានចែងយ៉ាងច្បាស់ថា "គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ"។ មានន័យថា បើទោះបីជាស្ត្រីជាមេផ្ទះ មិនធ្វើការបានប្រាក់ខែមែន ក៏ប៉ុន្តែ គាត់គឺជាអ្នករ៉ាប់រងកិច្ចការក្នុងផ្ទះ ដែលត្រូវរាប់ជាការងារមួយដែលមានតម្លៃដូចជាការងារក្រៅផ្ទះដែរ។

**៣.ចំពោះការប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិវិញ តើត្រូវធ្វើដូចម្តេច?**

ចំពោះទ្រព្យសម្បត្តិរួម ច្បាប់កំណត់ថា ប្តីប្រពន្ធត្រូវមានសិទ្ធិស្មើគ្នា ក្នុងការប្រើប្រាស់ទទួលផលប្រយោជន៍ និងគ្រប់គ្រង (មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី) ដោយមិនបែងចែកថា អ្នកណាធ្វើការបានប្រាក់ខែច្រើនជាងអ្នកណាទេ។ ក៏ប៉ុន្តែ ការប្រើប្រាស់ទ្រព្យសម្បត្តិរួមនេះ ត្រូវតែធ្វើឡើងនៅក្នុងទំហំចាំបាច់ ដោយផ្អែកទៅលើភាពចាំបាច់នៅក្នុងជីវភាពរស់នៅ មិនមែនចេះតែចាយវាយតម្រូវទៅតាមចិត្តចង់ខ្លួនឯងទេ។

ចំពោះកិច្ចសំខាន់ៗ ដែលទាក់ទងនឹងការចាត់ចែងទ្រព្យរួម ដូចជា ការលក់ដូរ ឬការយកទៅធ្វើជាអំណោយជាដើម ត្រូវតែមានការព្រមព្រៀងពីប្តីប្រពន្ធទាំងសងខាង។

ចំពោះទ្រព្យផ្ទាល់វិញ ទ្រព្យរបស់អ្នកណា អ្នកនោះជាអ្នកគ្រប់គ្រង និងចាត់ចែង ដោយមិនចាំបាច់មានការព្រមព្រៀងពីសហព័ទ្ធម្ខាងទៀតទេ។

**៤.នៅក្នុងករណីលែងលះវិញ តើទ្រព្យសម្បត្តិទាំងអស់នេះត្រូវបែងចែកដូចម្តេច?**

ចំពោះការបែងចែកទ្រព្យ ក្នុងករណីមានការលែងលះ ច្បាប់ឲ្យអាទិភាពទៅលើការព្រមព្រៀងគ្នារវាងប្តីប្រពន្ធ។ បើសិនជាគ្មានការព្រមព្រៀងគ្នាទេ ទើបត្រូវបែងចែកតាមច្បាប់ គឺរបៀបបែងចែក ដែលមានចែងក្នុងមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី។ គោលការណ៍នៃការបែងចែកទ្រព្យតាមច្បាប់នេះ គឺទ្រព្យសម្បត្តិផ្ទាល់របស់សហព័ទ្ធមួយណា ត្រូវសហព័ទ្ធនោះជាអ្នកទទួលបានផ្តាច់មុខ ចំណែកទ្រព្យសម្បត្តិរួម គឺត្រូវបែងចែកគ្នាស្មើ (ពាក់កណ្តាលម្នាក់)។

គួរបញ្ជាក់ថា ទ្រព្យសម្បត្តិប្តីប្រពន្ធអាចមានទ្រព្យរួម និងទ្រព្យផ្ទាល់ខ្លួន ចំណែកកាតព្វកិច្ចលើបំណុលវិញ ក៏ត្រូវមានការបែងចែកជាបំណុលរួម និងបំណុលផ្ទាល់ខ្លួនដែរ។

បំណុលរួម ដែលប្តីប្រពន្ធត្រូវតែទទួលខុសត្រូវរួមគ្នា គឺបំណុលទាំងឡាយណា ដែលប្តីប្រពន្ធទាំងពីរជាអ្នកខ្ចីរួមគ្នា ឬក៏សហព័ទ្ធណាមួយជាអ្នកខ្ចី ប៉ុន្តែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀត។ មានប្រភេទបំណុលខ្លះ គឺមានបំណុល ដែលមានជាប់ពាក់ព័ន្ធនឹងការរក្សាជីវភាពរួមប្តីប្រពន្ធ ការអប់រំ ថែទាំ និងព្យាបាលកូន បំណុលដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរួម ត្រូវបានច្បាប់ចាត់ទុកថាជាបំណុលរួមដោយស្វ័យប្រវត្តិ ដែលប្តីប្រពន្ធចាំបាច់ត្រូវតែទទួលខុសត្រូវរួមគ្នា ទោះបីសហព័ទ្ធណាជាអ្នកខ្ចីក៏ដោយ ហើយគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀតក៏ដោយ។

## ផ្នែកទី៥៦

# ក្រមរដ្ឋប្បវេណី៖ អំពីរបៀបបែងចែកកេរមរតក

ដោយ សេង ឌីណា

បុគ្គលម្នាក់ៗ គឺជាម្ចាស់ ដែលមានសិទ្ធិផ្តាច់មុខ ទៅលើទ្រព្យសម្បត្តិដែលខ្លួនមាន។ ទោះបីជាក្រោយពីស្លាប់ទៅក៏គេមិនអាចដកហូតទ្រព្យសម្បត្តិនេះបានដែរ។ ទ្រព្យសម្បត្តិ ដែលជាកេរមរតករបស់បុគ្គលដែលស្លាប់ (មតកជន) គឺត្រូវផ្ទេរទៅឲ្យសាច់ញាតិរបស់គាត់ដែលនៅរស់។ ក៏ប៉ុន្តែ ការផ្ទេរមរតកនេះត្រូវគោរពទៅតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់។ ខាងក្រោមនេះ គឺជាសំណួរ-ចម្លើយ ស្តីពីរបៀបបែងចែកកេរមរតក ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧។

**១.នៅពេលដែលបុគ្គលម្នាក់ទទួលមរណភាព តើទ្រព្យសម្បត្តិ ដែលជាកេរមរតករបស់គាត់ត្រូវបែងចែកដោយរបៀបណា?**

ការបែងចែកកេរមរតក គឺមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចាប់ពីមាត្រា ១១៤៥ រហូតដល់ មាត្រា ១៣០៤ (សន្តតិកម្ម)។

ការផ្ទេរកេរមរតក ត្រូវធ្វើទៅតាមឆន្ទៈរបស់មតកជន (ជនដែលស្លាប់ ហើយដែលជាម្ចាស់កេរមរតក) ប្រសិនបើគាត់មានទុកបណ្តាំ។ គេឲ្យឈ្មោះថា សន្តតិកម្មតាមមានបណ្តាំ ឬសន្តតិកម្មតាមមតកសាសន៍។

ក្នុងករណីគ្មានបណ្តាំ ការផ្ទេរមរតក គឺត្រូវធ្វើឡើងទៅតាមការកំណត់ដោយបទប្បញ្ញត្តិ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។ គេឲ្យឈ្មោះថា សន្តតិកម្មតាមច្បាប់ (មាត្រា ១១៤៥)។

**២.នៅក្នុងបណ្តាំ តើម្ចាស់ទ្រព្យមានសិទ្ធិបែងចែកកេរមរតករបស់គាត់យ៉ាងម៉េចក៏បាន ឬក៏យ៉ាងណា?**

មតកជន មានសិទ្ធិធ្វើការបែងចែកកេរមរតករបស់គាត់យ៉ាងម៉េចក៏បានដែរ ក៏ប៉ុន្តែ ត្រូវគោរពលក្ខខណ្ឌមួយដែលចែងក្នុងច្បាប់ គឺ "ភាគបម្រុង"។ ច្បាប់កំណត់ថា មរតកមួយផ្នែក ត្រូវបម្រុងទុកឲ្យសន្តតិជន (ជនដែលត្រូវទទួលកេរមរតក) តាមច្បាប់កំណត់។

អ្នកមានសិទ្ធិលើភាគបម្រុង គឺកូន ឬឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជន (មាត្រា ១២៣០)។ ចំណែកនៃភាគបម្រុងត្រូវកំណត់ដូចខាងក្រោម៖

- ក្នុងករណីដែលមានសន្តតិជន ដែលជាឪពុកម្តាយ ឬជីដូន ជីតាប៉ុណ្ណោះ (មិនមានកូន និងមិនមានសហព័ទ្ធ) ភាគបម្រុង គឺត្រូវមាន ១ភាគ៣ នៃទ្រព្យសម្បត្តិរបស់មតកជន។
- ក្នុងករណីដែលមានសន្តតិជនជាកូន ឬជាសហព័ទ្ធ ភាគបម្រុង ត្រូវមានពាក់កណ្តាល នៃទ្រព្យសម្បត្តិរបស់មតកជន។

ភាគបម្រុង ត្រូវយកទៅបែងចែកជាចំណែកស្មើៗគ្នាឲ្យសន្តតិជនដែលមានសិទ្ធិទទួល ភាគបម្រុង ដែលច្បាប់កំណត់ក្នុងមាត្រាខាងលើ។ កេរមរតក ដែលនៅសេសសល់ពីភាគបម្រុង ទើបមតកជនអាចយកទៅបែងចែកតាមចិត្តចង់បាន។ ក្នុងករណីដែលគ្មានសន្តតិជនដែលត្រូវមានសិទ្ធិទទួលភាគបម្រុងទេ មតកជនអាចចាត់ចែងទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ទៅតាមបណ្តាំបាន ដោយមិនត្រូវទុកភាគបម្រុងនោះទេ។

**៣.ក្នុងករណីមិនមានបណ្តាំ តើច្បាប់កំណត់ដូចម្តេចខ្លះ អំពីការបែងចែកកេរមរតក?**

ក្នុងករណីគ្មានបណ្តាំមរតក ច្បាប់កំណត់ថា កេរមរតកត្រូវចែកទៅឲ្យសន្តតិជន ដែលមាន ៣ លំដាប់ ៖

- ប្រសិនបើមតកជនមានកូន មរតកត្រូវបានទៅកូន។ បើសិនជាមានកូនណាមួយស្លាប់ ចំណែកមរតកនោះត្រូវផ្ទេរទៅឲ្យកូនៗរបស់កូននោះ (ចៅរបស់មតកជន) ដែលគេឲ្យឈ្មោះថា សន្តតិកម្មជំនួស។

- ប្រសិនបើមតកជនមិនមានកូនសោះ (ចំណុចនេះខុសពីមានកូន តែកូនស្លាប់) កេរមរតកត្រូវបានទៅឪពុកម្តាយ។ ប្រសិនបើគ្មានទាំងកូន ហើយឪពុកម្តាយក៏ស្លាប់អស់ទៀត កេរមរតកត្រូវបានទៅបងប្អូនបង្កើត។
- ចំពោះសហព័ទ្ធ (ប្តី ឬប្រពន្ធ) របស់មតកជនវិញ គឺជាសន្តតិជន "អចិន្ត្រៃយ៍" មានន័យថា ទោះជាស្ថិតក្នុងលំដាប់ណាមួយ ក្នុងលំដាប់សន្តតិជនទាំង៣ខាងលើ ក៏សហព័ទ្ធត្រូវមានចំណែកក្នុងការទទួលកេរមរតកដែរ។

ក្នុងករណីសន្តតិជនជាកូន សហព័ទ្ធត្រូវទទួលបានចំណែកស្មើគ្នាជាមួយនឹងកូននីមួយៗ។ ក្នុងករណីមតកជនគ្មានកូន ហើយមរតកត្រូវផ្ទេរទៅសន្តតិជនជាឪពុកម្តាយ ទ្រព្យសម្បត្តិត្រូវចែកជាបីចំណែកស្មើគ្នា ដោយ១ចំណែកបានទៅឪពុក ១ចំណែកបានទៅម្តាយ និងចំណែកទី៣បានទៅសហព័ទ្ធ។ ប្រសិនបើមានតែឪពុក ឬមានតែម្តាយនៅរស់ សហព័ទ្ធត្រូវបានទ្រព្យពាក់កណ្តាល ហើយពាក់កណ្តាលទៀតបានទៅឪពុក ឬម្តាយ ដែលនៅរស់នោះ។

ក្នុងករណីមតកជនគ្មានកូន គ្មានឪពុកម្តាយនៅរស់ ហើយមរតកត្រូវធ្លាក់ទៅបងប្អូនបង្កើត ទ្រព្យសម្បត្តិពាក់កណ្តាលត្រូវបានទៅសហព័ទ្ធ ហើយនៅសល់ពាក់កណ្តាលទៀតត្រូវយកទៅចែកជាចំណែកស្មើៗគ្នាឲ្យទៅបងប្អូនបង្កើតនោះ។

**៤.តើកូនសុំ មានសិទ្ធិទទួលកេរមរតកដែរ ឬទេ?**

កូនសុំក៏មានសិទ្ធិទទួលកេរមរតកដូចជាកូនបង្កើតដែរ។ ម្យ៉ាងទៀត ទាំងកូនបង្កើត និងទាំងកូនសុំ ត្រូវមានចំណែកស្មើៗគ្នា (មាត្រា ១១៥៦)។

**៥.ក្នុងករណីកូនដែលត្រូវទទួលមរតកស្លាប់ទៅ ហើយត្រូវចែកបន្តទៅឲ្យចៅ តើចំណែកមរតកត្រូវចែកដូចម្តេច?**

នេះ គឺជាករណីសន្តតិកម្មជំនួស។ ចំណែកមរតកមិនត្រូវយកទៅគិតជាចំណែកស្មើៗគ្នាឲ្យចៅរបស់មតកជន តែម្តងនោះទេ។ គេត្រូវគិតជាពីរដំណាក់។ ទីមួយ ត្រូវបែងចែកជាចំណែកស្មើៗគ្នាទៅឲ្យកូនៗជាមុនសិន។ បន្ទាប់មក ទើបគេយកចំណែករបស់កូនដែលស្លាប់ទៅចែកបន្តជាចំណែកស្មើៗគ្នាឲ្យទៅកូនៗគាត់បន្តទៀត។

# ផ្នែកទី៥៧
# នីតិវិធីក្នុងការសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ




ដោយ <u>សេង ឌីណា</u>

នៅក្នុងនាទីយល់ដឹងអំពីច្បាប់ នៅថ្ងៃព្រហស្បតិ៍នេះ សេង ឌីណា នឹងពន្យល់អំពីនីតិវិធីនៃការសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយមានអន្តរាគមន៍ពីសំណាក់មន្ត្រីការិយាល័យអត្តសញ្ញាណប័ណ្ណ រាជធានីភ្នំពេញ។

អត្តសញ្ញាណប័ណ្ណ គឺជាលិខិតសម្គាល់ថាជាពលរដ្ឋខ្មែរ ហើយមានប្រយោជន៍ សម្រាប់ការប្រើប្រាស់ ក្នុងការបំពេញបែបបទផ្សេងៗទៅតាមការកំណត់នៃច្បាប់ ដូចជា៖ ចុះឈ្មោះបោះឆ្នោត ឈរឈ្មោះបោះឆ្នោត សុំរៀបអាពាហ៍ពិពាហ៍ សុំធ្វើសំបុត្រកំណើតកូន សុំធ្វើការងារ សុំប្រកបអាជីវកម្ម សុំធ្វើលិខិតឆ្លងដែន សុំធ្វើម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យ ...។

យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ចុះខែកក្កដា ២០០៧ ប្រជាពលរដ្ឋដែលអាចធ្វើអត្តសញ្ញាណប័ណ្ណបានត្រូវមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ហើយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាពរយៈពេល ១០ឆ្នាំ។ នៅពេលផុតសុពលភាព សាមីខ្លួនត្រូវស្នើសុំធ្វើសាជាថ្មីឡើងវិញ។

ប្រកាសរបស់ក្រសួងមហាផ្ទៃ បានសម្រេចបង្កើតនីតិវិធីពិសេសមួយក្នុងការរៀបចំចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដល់ប្រជាពលរដ្ឋទូទៅនៅទូទាំងប្រទេស។ ការចេញអត្តសញ្ញាណប័ណ្ណតាមនីតិវិធីពិសេសនេះ គឺធ្វើឡើងតាមគំនិតផ្ដួចផ្ដើមរបស់មន្ត្រីមានសមត្ថកិច្ច ហើយធ្វើឡើងដល់ប្រជាពលរដ្ឋជាក្រុមៗតាមរយៈស្ថានីយ៍ចល័ត នៅតាមឃុំ-សង្កាត់នីមួយៗ។

នៅក្នុងនីតិវិធីបែបនេះ ប្រជាពលរដ្ឋមិនចាំបាច់ដាក់ពាក្យសុំទៅអាជ្ញាធរនោះទេ។ គឺខាងអាជ្ញាធរទៅវិញទេ ដែលជាអ្នកចេញលិខិតអញ្ជើញឲ្យប្រជាពលរដ្ឋទៅកាន់ស្ថានីយ៍ចល័ត ដើម្បីរៀបចំសំណុំបែបបទធ្វើអត្តសញ្ញាណប័ណ្ណ។

ប្រជាពលរដ្ឋដែលមានឈ្មោះត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណ ត្រូវទៅកាន់កន្លែងធ្វើ ដោយផ្ទាល់ខ្លួន ដើម្បីបំពេញសំណុំបែបបទ ថតរូប និងផ្ដិតស្នាមក្រយៅដៃ ហើយត្រូវនាំទៅជាមួយនូវឯកសារសំខាន់ៗមួយចំនួន ដែលបញ្ជាក់អំពីសញ្ជាតិខ្មែរ។ ឯកសារទាំងនោះរួមមាន៖ សំបុត្រកំណើត និងសៀវភៅស្នាក់នៅ (ក២) ឬសៀវភៅគ្រួសារ (ក៤)។

ក្នុងករណីពិសេសខ្លះ សាមីអ្នកសុំអាចផ្ដល់នូវឯកសារផ្សេង ដើម្បីបញ្ជាក់ពីសញ្ជាតិខ្មែរ ដូចជា៖

- សេចក្តីសម្រេចទទួលស្គាល់តាមផ្លូវច្បាប់នៃការធ្វើសញ្ជាតូបនីយកម្ម ឬការទាមទារសញ្ជាតិ សម្រាប់ជនបរទេសដែលបានចូលសញ្ជាតិខ្មែរ។
- សាលក្រមតុលាការ ឬឯកសារផ្លូវការផ្សេងទៀត ដែលអាចបញ្ជាក់ថា សាមីជនពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរមែន ជាពិសេស សម្រាប់អ្នកដែលកើតនៅបរទេស ប៉ុន្តែ មានឪពុក ឬម្តាយ ជាសញ្ជាតិខ្មែរ។

យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃ អភិបាលខេត្ត-ក្រុង មានភារកិច្ចទទួលខុសត្រូវលើដំណើរការផលិតអត្តសញ្ញាណប័ណ្ណឲ្យបានទាន់ពេលវេលា ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃបំពេញបែបបទ រហូតដល់ថ្ងៃចែកជូនប្រជាពលរដ្ឋប្រើប្រាស់។

រហូតមកទល់ពេលនេះ ការធ្វើអត្តសញ្ញាណប័ណ្ណជាក្រុម នៅតែបន្តធ្វើវិលជុំ ពីឃុំ-សង្កាត់មួយ ទៅឃុំ-សង្កាត់មួយ ហើយធ្វើឡើងដោយឥតគិតថ្លៃ។ ប្រសិនបើការធ្វើអត្តសញ្ញាណប័ណ្ណជាក្រុម ត្រូវបានគេធ្វើហួសទៅសង្កាត់ផ្សេងទៅហើយ អ្នកដែលចង់បានអត្តសញ្ញាណប័ណ្ណអាចធ្វើការស្នើសុំដាច់ដោយឡែកតែឯងបាន។

គួរបញ្ជាក់បន្ថែមថា ដើម្បីសុំអត្តសញ្ញាណប័ណ្ណបាន គេត្រូវមានសំបុត្រកំណើតជាមុន។ ដូច្នេះ សម្រាប់អ្នកដែលកើតមុនពេល ឬក្នុងពេលស្រុកមានសង្គ្រាម ហើយមិនបានចុះសំបុត្រកំណើត ឬក៏បានចុះដែរ ក៏ប៉ុន្តែ សំបុត្រកំណើតត្រូវបាត់បង់អស់ អ្នកទាំងនោះត្រូវទៅសុំសំបុត្របញ្ជាក់កំណើតជាមុនសិន មុននឹងទៅសុំធ្វើអត្តសញ្ញាណប័ណ្ណ។

ការសុំសំបុត្របញ្ជាក់កំណើតត្រូវធ្វើនៅសាលាឃុំ-សង្កាត់ ដែលសាមីអ្នកសុំមានទីលំនៅជាប់លាប់បច្ចុប្បន្ន។ អ្នកសុំត្រូវមានសាក្សីចំនួន ២នាក់ ដែលជានីតិជន ហើយដែលបានស្គាល់ច្បាស់ពីប្រវត្តិរបស់អ្នកសុំ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើត។

## ផ្នែកទី៥៨

## អាណិកជនខ្មែរនៅបរទេសមានសិទ្ធិអ្វីខ្លះ?




ពលរដ្ឋខ្មែរមានសញ្ជាតិពីរកាន់លិខិតឆ្លងដែនពីរ

ដោយ <u>សេង ឌីណា</u>

នៅក្នុងនាទីយល់ដឹងអំពីច្បាប់ថ្ងៃនេះ សេង ឌីណា សូមលើកយកបញ្ហាជុំវិញពលរដ្ឋខ្មែរដែលមានសញ្ជាតិពីរមកជម្រាបជូនលោក អ្នកស្តាប់។ តើជនជាតិខ្មែរដែលទទួលបានសញ្ជាតិបរទេស នៅមានសិទ្ធិអ្វីខ្លះ?

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៣ ចែងថា *"ប្រជាពលរដ្ឋ ខ្មែរមិនអាចត្រូវដកសញ្ជាតិ និរទេស ឬចាប់ខ្លួនបញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក"*។ មានន័យថា ពលរដ្ឋខ្មែរមិនត្រូវបាត់បង់សញ្ជាតិជាខ្មែរនោះទេ បើទោះជាទទួលបានសញ្ជាតិបរទេសហើយក៏ដោយ ពោលគឺ ពលរដ្ឋខ្មែរអាចមានសញ្ជាតិបរទេសផង និងសញ្ជាតិខ្មែរផង ក្នុងពេលជាមួយគ្នា។

ដូច្នេះ អាណិកជនខ្មែរ នៅបរទេស នៅតែមានសិទ្ធិក្នុងឋានៈជាពលរដ្ឋខ្មែរដដែល។ នេះបើនិយាយជាគោលការណ៍ផ្លូវច្បាប់។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងវិញ ពលរដ្ឋខ្មែរ ដែលមានសញ្ជាតិបរទេស ហើយរស់នៅបរទេសមានការពិបាកក្នុងការទទួលបាននូវឯកសារផ្លូវការនានា ដូចជា សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនខ្មែរ ជាដើម ពីព្រោះថា ការសុំឯកសារទាំងនេះ ពលរដ្ឋខ្មែរចាំបាច់ត្រូវតែមានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងប្រទេសកម្ពុជា។

ទោះជាយ៉ាងណា ពលរដ្ឋខ្មែរ ដែលមានសញ្ជាតិបរទេស ហើយកាន់លិខិតឆ្លងដែនបរទេសអាចទទួលបានទិដ្ឋាការ (ដែលគេតែងតែហៅថា Visa K) ដើម្បីធ្វើដំណើរចេញចូលប្រទេសកម្ពុជាបានដោយងាយ។ ទិដ្ឋាការនេះ អាចសុំបាននៅតាមស្ថានទូតកម្ពុជា នៅបរទេស ដោយអ្នកសុំគ្រាន់តែបង្ហាញនូវឯកសារណាមួយក្នុងចំណោមឯកសារខាងក្រោម៖

- សេចក្តីចម្លងសំបុត្រកំណើតកម្ពុជា (ប្រសិនបើអ្នកសុំកើតនៅក្នុងប្រទេសកម្ពុជា)
- សេចក្តីចម្លងសំបុត្រកំណើតបរទេស ឬប័ណ្ណគ្រួសារដែលមានចែងបញ្ជាក់ថា អ្នកសុំកើតពីឪពុក ឬម្តាយដែលជាពលរដ្ឋខ្មែរ (ប្រសិនបើអ្នកសុំកើតនៅក្រៅប្រទេសកម្ពុជា)
- លិខិតឆ្លងដែនខ្មែរ (ប្រសិនបើអ្នកសុំធ្លាប់មានពីមុន បើទោះជាលិខិតឆ្លងដែននេះផុតសុពលភាពហើយក៏ដោយ)

- ប្រសិនបើគ្មានឯកសារណាមួយ ក្នុងចំណោមឯកសារខាងលើនេះទេ អ្នកសុំអាចធ្វើលិខិតបញ្ជាក់មួយ ដោយមានសាក្សីជាជនជាតិខ្មែរម្នាក់ផង បញ្ជាក់អំពីឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតរបស់អ្នកសុំ ព្រមទាំងឈ្មោះឪពុក-ម្តាយ ដែលមានសញ្ជាតិខ្មែរ។

គួរបញ្ជាក់ថា Visa K អាចផ្តល់ជូនតែចំពោះពលរដ្ឋខ្មែរ ដែលមានសញ្ជាតិបរទេសប៉ុណ្ណោះ ហើយផ្តល់ជូនដោយឥតគិតថ្លៃ។ នៅប្រទេសបារាំង ទិដ្ឋាការប្រភេទនេះអាចចេញជូនក្នុងរយៈពេលយ៉ាងយូរ ៤៨ម៉ោង (យោងតាមវែបសៃត៍ស្ថានទូតកម្ពុជាប្រចាំក្រុងប៉ារីស)។ អ្នកដែលទទួលបានទិដ្ឋាការនេះហើយ អាចធ្វើដំណើរចេញចូលប្រទេសកម្ពុជាប៉ុន្មានដងក៏បាន ស្នាក់នៅកម្ពុជារយៈពេលប៉ុន្មានក៏បាន ហើយទិដ្ឋាការនេះមានសុពលភាពជាអចិន្ត្រៃយ៍ (លើកលែងតែនៅពេលមានការផ្លាស់ប្តូរលិខិតឆ្លងដែនថ្មី)។

ក៏ប៉ុន្តែ Visa K គ្រាន់តែជាឯកសារដែលអនុញ្ញាតឲ្យធ្វើដំណើរចេញចូលប្រទេសកម្ពុជាតែប៉ុណ្ណោះ មិនមែនជាឯកសារបញ្ជាក់អំពីសញ្ជាតិខ្មែរនោះទេ។

ដើម្បីទទួលបានសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនខ្មែរ គេត្រូវដាក់ពាក្យសុំទៅអាជ្ញាធរមានសមត្ថកិច្ច នៅប្រទេសកម្ពុជា ដោយគោរពទៅតាមនីតិវិធីធម្មតា ដូចប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្នុងប្រទេសកម្ពុជាដែរ មានន័យថា អ្នកសុំត្រូវមានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងប្រទេសកម្ពុជា។

## ផ្នែកទី៥៩

## តើសញ្ជាតិខ្មែរត្រូវផ្តល់ឲ្យកូនលក្ខខណ្ឌណាខ្លះ?

ដោយ <u>សេង ឌីណា</u>

នៅក្នុងនាទីយល់ដឹងពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា សូមធ្វើការពន្យល់ អំពីលក្ខខណ្ឌក្នុងការទទួលបានសញ្ជាតិខ្មែរ។ ការកំណត់អំពីសញ្ជាតិខ្មែរ មានចែងនៅក្នុងច្បាប់ ស្តីពីសញ្ជាតិ ឆ្នាំ១៩៩៦។

យោងតាមច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៩៦ ការទទួលបានសញ្ជាតិខ្មែរអាចកើតឡើងនៅក្នុងករណី ៣ ធំៗ៖

- ការទទួលសញ្ជាតិខ្មែរពីកំណើត
- ការទទួលសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍
- ការទទួលសញ្ជាតិខ្មែរតាមរយៈការសុំចូលសញ្ជាតិ (សញ្ជាតូបនីយកម្ម)

**ក. សញ្ជាតិខ្មែរពីកំណើត**

ច្បាប់ខ្មែរ ក៏ដូចជា ច្បាប់នៅតាមប្រទេសភាគច្រើនផ្សេងទៀត នៅលើពិភពលោក ជាពិសេស ប្រទេសដែលមានប្រព័ន្ធច្បាប់ Romano-Germanique ការកំណត់សញ្ជាតិខ្មែរពីកំណើត គឺត្រូវយកសិទ្ធិដែលជាប់នឹងខ្សែលោហិតជាធំ។ មានន័យថា កូនដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើត ទោះបីជាកើតនៅទីណាក៏ដោយ (កើតនៅក្នុងទឹកដីកម្ពុជាក៏ដោយ ឬក៏កើតនៅបរទេសក៏ដោយ)។

គួរបញ្ជាក់បន្ថែមថា មិនចាំបាច់ទាល់តែទាំងសងខាង (ទាំងឪពុក ទាំងម្តាយ) មានសញ្ជាតិខ្មែរ ទើបកូនមានសិទ្ធិទទួលសញ្ជាតិខ្មែរពីកំណើតទេ។ ឲ្យតែមានម្ខាងណាមួយមានសញ្ជាតិខ្មែរ (ឪពុកបរទេស ម្តាយខ្មែរ ឬឪពុកខ្មែរ ម្តាយបរទេស) ក៏កូនអាចទទួលសញ្ជាតិខ្មែរពីកំណើតបានដែរ។

ម៉្យាងទៀត កូនឥតខាន់ស្លា (កូនដែលកើតក្រៅចំណងអាពាហ៍ពិពាហ៍ស្របច្បាប់) ដែលម្តាយ ឬឪពុកមានសញ្ជាតិខ្មែរ ក៏អាចទទួលបានសញ្ជាតិខ្មែរពីកំណើតបានដែរ ឲ្យតែឪពុក ឬម្តាយ ដែលមានសញ្ជាតិខ្មែរ ទទួលស្គាល់កូននេះថាជាកូនរបស់ខ្លួន។

*ឧទាហរណ៍៖ កូនកើតក្រៅចំណងអាពាហ៍ពិពាហ៍ ពីម្តាយជាជនបរទេស ហើយឪពុកមានសញ្ជាតិខ្មែរ។ បើសិនជាឪពុកដែលមានសញ្ជាតិខ្មែរនេះ ទទួលស្គាល់តាមផ្លូវច្បាប់ថា កូននេះ គឺជាកូនរបស់ខ្លួន កូននេះត្រូវមានសិទ្ធិទទួលបានសញ្ជាតិខ្មែរពីកំណើត។ ផ្ទុយទៅវិញ បើមានតែម្តាយ ដែលទទួលស្គាល់កូន ចំណែកឪពុកមិនទទួលស្គាល់ កូននេះមិនអាចទទួលបានសញ្ជាតិខ្មែរពីកំណើតបានទេ ព្រោះម្តាយមិនមានសញ្ជាតិខ្មែរ។*

ក្នុងករណីកូន ដែលឪពុកម្តាយមិនទទួលស្គាល់ ប៉ុន្តែ តុលាការចេញសាលក្រមកំណត់ថា កូននេះពិតជាកើតពីឪពុក ឬម្តាយ ដែលមានសញ្ជាតិខ្មែរ កូននេះក៏ត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើតដែរ។

និយាយពីកូនបរទេស ដែលកើតនៅលើទឹកដីកម្ពុជាវិញ។ ច្បាប់ខ្មែរមិនដូចជាច្បាប់ នៅប្រទេសមួយចំនួន ដូចជា អាមេរិក កាណាដា ឬក៏អូស្ត្រាលីទេ។ កូន ដែលកើតនៅលើទឹកដីខ្មែរ ក៏ប៉ុន្តែ មានទាំងឪពុក និងទាំងម្តាយជាជនបរទេស មិនអាចទទួលសញ្ជាតិខ្មែរពីកំណើតបានទេ លើកលែងតែឪពុកនិងម្តាយជាជនបរទេសនោះ កើតនៅក្នុងប្រទេសកម្ពុជាដែរ ហើយរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ទើបកូនរបស់គាត់អាចទទួលសញ្ជាតិខ្មែរពីកំណើតបាន។

សរុបមកវិញ កូនដែលកើតនៅលើទឹកដីកម្ពុជា ពីឪពុកម្តាយជាជនបរទេស ហើយឪពុកម្តាយបរទេសនេះ មិនបានកើតនៅក្នុងប្រទេសកម្ពុជាទេ កូននេះ មិនអាចទទួលសញ្ជាតិខ្មែរពីកំណើតបានទេ។ ក៏ប៉ុន្តែ បើសិនជាកូននេះកើតមក ធំដឹងក្តី

បន្តរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ហើយក្រោយមក មានកូនកើតនៅក្នុងប្រទេសកម្ពុជា កូនរបស់គាត់ ដែលជាកូនបរទេសជំនាន់ទី២នេះ ត្រូវមានសិទ្ធិទទួលសញ្ជាតិខ្មែរពីកំណើត។

**ខ. សញ្ជាតិខ្មែរតាមអាពាហ៍ពិពាហ៍**

ស្ត្រី ឬបុរសបរទេស ដែលយកប្ដី ឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់អាចទាមទារសញ្ជាតិខ្មែរបាន លុះត្រាតែប្ដីប្រពន្ធទាំងពីររស់នៅជាមួយគ្នា រយៈពេលយ៉ាងតិច ៣ឆ្នាំ ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍។

ការផ្ដល់សញ្ជាតិខ្មែរដល់ជនបរទេស ដែលរៀបការជាមួយជនជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ។

**គ. សញ្ជាតូបនីយកម្ម (ការសុំចូលសញ្ជាតិខ្មែរ)**

ក្រៅពីការទទួលបានសញ្ជាតិខ្មែរពីកំណើត និងតាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិខ្មែរ ជនបរទេសអាចទទួលបានសញ្ជាតិខ្មែរតាមរយៈសញ្ជាតូបនីយកម្ម (ការសុំសញ្ជាតិខ្មែរ)។

ដើម្បីទទួលបានសញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មនេះ ជនបរទេសត្រូវបំពេញលក្ខខណ្ឌមួយចំនួនជាចាំបាច់៖

- ត្រូវមានលិខិតបញ្ជាក់ថា ជននោះមានទីលំនៅនៅក្នុងប្រទេសកម្ពុជា បានស្នាក់នៅជាប់ជាប្រចាំដោយស្របច្បាប់ក្នុងរយៈពេលយ៉ាងតិច ៧ឆ្នាំ ហើយកំពុងបន្តមានទីលំនៅក្នុងប្រទេសកម្ពុជា នៅក្នុងពេលដាក់ពាក្យសុំសញ្ជាតិ។
- ត្រូវមានលិខិតបញ្ជាក់ថាជននោះមានគំនិតមារយាទ និងសីលធម៌ល្អ ដែលចេញដោយមេឃុំ ឬចៅសង្កាត់ នៃទីលំនៅរបស់ខ្លួន
- ត្រូវមានលិខិតថ្កោលទោស ដែលបញ្ជាក់ថា ពុំដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ
- ត្រូវចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងថា ខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលយកនូវទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ខ្មែរ
- ត្រូវមានបញ្ញា និងកាយសម្បទាល្អ ដែលមិននាំឲ្យមានគ្រោះថ្នាក់ ឬនាំជាបន្ទុកដល់ជាតិ។

លក្ខខណ្ឌទាំងប៉ុន្មានខាងលើនេះ គឺជាលក្ខខណ្ឌទូទៅ ដែលអាចមានករណីលើកលែងមួយចំនួន ជាពិសេសទាក់ទងនឹងរយៈពេលរស់នៅក្នុងប្រទេសកម្ពុជា។

ជនបរទេស ដែលកើតក្នុងប្រទេសកម្ពុជា លក្ខខណ្ឌតម្រូវឲ្យស្នាក់នៅជាប់ៗគ្នាក្នុងប្រទេសកម្ពុជា ចំនួន ៧ឆ្នាំ ត្រូវកាត់បន្ថយឲ្យមកនៅត្រឹម ៣ឆ្នាំវិញ។ ដូចដែលបានលើកឡើងខាងលើរួចហើយថា ជនបរទេស ដែលកើតនៅក្នុងទឹកដីកម្ពុជាមិនមានសិទ្ធិទទួលសញ្ជាតិខ្មែរពីកំណើតទេ។ ក៏ប៉ុន្តែ បើសិនជាគាត់ចង់បានសញ្ជាតិខ្មែរ គាត់អាចដាក់ពាក្យសុំសញ្ជាតូបនីយកម្មបាន ដោយច្បាប់ដាក់លក្ខខណ្ឌធូរជាងជនបរទេស ដែលមិនកើតក្នុងប្រទេសកម្ពុជា។

ចំពោះជនបរទេសណា ដែលបានធ្វើការវិនិយោគក្នុងប្រទេសកម្ពុជា ក្នុងទឹកប្រាក់ចាប់ពី ១៣ន់ ២រយ ៥០លានរៀលឡើងទៅ (ប្រហែលជាជាង ៣០ម៉ឺនដុល្លារ) ដែលជាគម្រោងវិនិយោគជាក់ស្ដែង ទទួលបានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ក៏ប៉ុន្តែ មិនមានលិខិតអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លក្ខខណ្ឌស្នាក់នៅជាប់គ្នាក្នុងប្រទេសកម្ពុជា ក៏ត្រូវកាត់បន្ថយ ពី ៧ឆ្នាំ មក ៣ឆ្នាំវិញ ដូចករណីជនបរទេសកើតក្នុងប្រទេសកម្ពុជាដែរ។

បើសិនជាការវិនិយោគនេះធ្វើឡើង ក្នុងទំហំទឹកប្រាក់ដូចគ្នា ក៏ប៉ុន្តែ មានលិខិតអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លក្ខខណ្ឌទាក់ទងនឹងរយៈពេលស្នាក់នៅក្នុងប្រទេសកម្ពុជាត្រូវលើកលែង ទាំងស្រុងតែម្ដង។ មានន័យថា ទោះបីជនបរទេសនោះ ទើបនឹងរស់នៅក្នុងប្រទេសកម្ពុជាបាន ១ឆ្នាំ កន្លះឆ្នាំ ឬ១ខែ ក៏អាចដាក់ពាក្យសុំសញ្ជាតិខ្មែរបានដែរ។

ដូចគ្នាដែរចំពោះជនបរទេសណា ដែលបានធ្វើអំណោយជាលុយដល់ថវិកាជាតិ ចាប់ពី ១ពាន់លានរៀលឡើងទៅ (ប្រហែលជា ២៥មុឺនដុល្លារ) សម្រាប់ជាផលប្រយោជន៍ដល់ការស្តារ និងកសាងសេដ្ឋកិច្ចរបស់កម្ពុជា។ ឬជនបរទេសណា ដែលបានបង្ហាញនូវភស្តុតាងបញ្ជាក់ថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយ ដែលជាប្រយោជន៍ដល់ប្រទេសកម្ពុជា។

ក៏ប៉ុន្តែ បើទោះជាក្នុងករណីណាមួយក៏ដោយ ច្បាប់ស្តីពីសញ្ជាតិចែងថា ការសុំសញ្ជាតិតាមរយៈសញ្ជាតូបនីយកម្ម មិនមែនជាសិទ្ធិរបស់អ្នកសុំទេ។ ប៉ុន្តែ វាជាការអនុគ្រោះរបស់កម្ពុជា។ ដូច្នេះ បើទោះបីជាអ្នកសុំបានបំពេញគ្រប់លក្ខខណ្ឌ ដែលកំណត់ដោយច្បាប់ក៏ដោយ ក៏ពាក្យសុំនេះអាចត្រូវបដិសេធចោលបានដែរ ហើយការបដិសេធពាក្យសុំសញ្ជាតូបនីយកម្មនេះ អាចធ្វើឡើង ទៅតាមអំណាចឆន្ទានុសិទ្ធិ មានន័យថា កម្ពុជាមិនចាំបាច់ត្រូវបកស្រាយពន្យល់ថា ហេតុអ្វីបានជាខ្លួនបដិសេធពាក្យសុំសញ្ជាតិនេះទេ។

ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ក៏ដូចជា ការផ្តល់សញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍ដែរ គឺត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ មានន័យថា ត្រូវឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។

# ផ្នែកទី៦០

# ច្បាប់ការងារៈ អំពីថិរវេលាការងារ និងការឈប់សម្រាក

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងអំពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា នឹងធ្វើ ការពន្យល់អំពីច្បាប់ការងារកម្ពុជា ដោយផ្តោតទៅលើថិរវេលាការងារ និង ការឈប់សម្រាក។

**១.តាមច្បាប់នៅប្រទេសកម្ពុជា តើនិយោជកអាចតម្រូវឲ្យបុគ្គលិកធ្វើការប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍?**

តាមច្បាប់ការងារខ្មែរ (ច្បាប់ឆ្នាំ១៩៩៧) ថិរវេលាធ្វើការងាររបស់និយោជិតទាំងពីរភេទ ទោះជាក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ គឺមិនឲ្យលើសពី ៨ម៉ោង ក្នុងមួយថ្ងៃ ឬ៤៨ម៉ោង ក្នុង មួយសប្តាហ៍។ ដូច្នេះបើគិតជាធម្មតាគឺមួយថ្ងៃធ្វើការ ៨ម៉ោងហើយមួយអាទិត្យធ្វើការ ៦ថ្ងៃ។

សហគ្រាសមានសេរីភាព ក្នុងការកំណត់របៀបចែកពេលធ្វើការ តាមប្រភេទសកម្មភាព និងរបៀបរៀបចំក្នុងសហគ្រាសនីមួយៗ កុំឲ្យតែបំពានថិរវេលា ដែលកំណត់ដោយច្បាប់ខាងលើ។ ដូចជា ចាប់ផ្តើមចូលធ្វើការ ម៉ោង ៨ព្រឹក ចេញម៉ោង ៥ល្ងាច ហើយឲ្យបុគ្គលិកឈប់សម្រាកបាយថ្ងៃត្រង់ ១ម៉ោង សរុបទៅ ៨ម៉ោង ក្នុងមួយថ្ងៃ។

រាល់ការរៀបចំបែងចែកម៉ោងធ្វើការនេះ សហគ្រាសត្រូវលៃលកយ៉ាងម៉េចឲ្យបុគ្គលិកមានថ្ងៃសម្រាកប្រចាំសប្តាហ៍យ៉ាងតិច ២៤ម៉ោងជាប់ៗគ្នា ពោលគឺមួយថ្ងៃពេញៗ។ ជាគោលការណ៍ ច្បាប់កំណត់យកថ្ងៃអាទិត្យ ជាថ្ងៃសម្រាកប្រចាំសប្តាហ៍។

**២.ចុះប្រសិនបើសហគ្រាសខ្លះ ដូចជា រោងចក្រ មន្ទីរពេទ្យ សណ្ឋាគារ ជាដើម ដែលមានតម្រូវការចាំបាច់ឲ្យមានសកម្មភាពជាប្រចាំ ២៤ម៉ោង ក្នុងមួយថ្ងៃ ៧ថ្ងៃ ក្នុងមួយសប្តាហ៍ តើត្រូវធ្វើយ៉ាងម៉េច?**

ក្នុងករណីនេះ សហគ្រាសអាចរៀបចំជាវេន ដើម្បីអាចដំណើរការ ២៤ម៉ោង លើ២៤ម៉ោង។ សហគ្រាសអាចចែកការងារជា ៣វេន ដោយ ១វេន មាន ៨ម៉ោង។ ដូច្នេះ បុគ្គលិក ១វេនៗ ធ្វើការតែ ៨ម៉ោងទេ ក្នុងមួយថ្ងៃ។ ការបែងចែកវេននេះត្រូវធ្វើយ៉ាងម៉េចឲ្យមានថ្ងៃសម្រាកប្រចាំសប្តាហ៍ទៅតាមច្បាប់កំណត់ គឺ ២៤ម៉ោងជាប់ៗគ្នា។

**៣.គ្រឹះស្ថានខ្លះ គេចង់ឲ្យបុគ្គលិកធ្វើការលើសពី ៨ម៉ោង ក្នុងមួយថ្ងៃ ប៉ុន្តែ ឲ្យសម្រាកប្រចាំសប្តាហ៍លើសពី ២៤ម៉ោង ដើម្បីសងម៉ោងលើសវិញ។ តើអាចធ្វើបានដែរ ឬទេ?**

ត្រង់ចំណុចនេះ គឺមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច និងការងារ តាមរយៈប្រកាស ចុះថ្ងៃទី១០ មិថុនា ២០០២ *ស្តីពីការបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍ ដើម្បីឲ្យឈប់សម្រាកបន្ថែមនារសៀលថ្ងៃសៅរ៍*។ ប្រកាសនេះអនុញ្ញាតឲ្យសហគ្រាសបង្កើនថិរវេលាធ្វើការរបស់កម្មករ លើសពី៨ម៉ោង ក្នុងមួយថ្ងៃ ប៉ុន្តែ មិនត្រូវឲ្យលើសពី ៩ម៉ោងទេ ហើយត្រូវឲ្យបុគ្គលិកសម្រាករសៀលថ្ងៃសៅរ៍ បន្ថែមពីលើថ្ងៃអាទិត្យ ១ថ្ងៃពេញ ដែលជាថ្ងៃសម្រាកធម្មតា។

ក៏ប៉ុន្តែ ការបែងចែកម៉ោងធ្វើការបែបនេះ នយោជកអាចធ្វើទៅបាន គឺទាល់តែមានការឯកភាពពីសំណាក់សហជីពតំណាងនិយោជិត និងប្រតិភូបុគ្គលិកជាមុនសិន។ ប្រសិនបើក្នុងសហគ្រាសមិនមានសហជីព និងប្រតិភូបុគ្គលិកទេ គឺត្រូវឲ្យមានការឯកភាពពីនិយោជិត យ៉ាងតិចពាក់កណ្តាល តាមរយៈការបោះឆ្នោតជាសម្ងាត់។

**៤.តើនិយោជកអាចតម្រូវឲ្យបុគ្គលិកធ្វើការថ្ងៃអាទិត្យ ដោយយកថ្ងៃផ្សេងជាថ្ងៃសម្រាកប្រចាំសប្តាហ៍បានដែរ ឬទេ?**

ច្បាប់ការងារខ្មែរកំណត់ឲ្យយកថ្ងៃអាទិត្យជាថ្ងៃសម្រាកប្រចាំសប្តាហ៍ (មាត្រា ១៤៧)។ ការកំណត់ផ្សេងក្រៅពីនេះ គឺទាល់តែមានករណីចាំបាច់ពិសេស ពោលគឺ បើសិនជាឲ្យបុគ្គលិកសម្រាកទាំងអស់នៅថ្ងៃអាទិត្យ ត្រូវនាំឲ្យខូចប្រយោជន៍ដល់សាធារណជន ឬក៏ធ្វើឲ្យខូចដលដំណើរការជាធម្មតារបស់សហគ្រាស។

ក្នុងករណីលើកលែងនេះ ច្បាប់ការងារ ត្រង់មាត្រា ១៤៨ ចែងថា ថ្ងៃសម្រាកប្រចាំសប្តាហ៍ត្រូវកំណត់ដូចតទៅ៖

- ឲ្យបុគ្គលិកទាំងអស់ឈប់សម្រាកនៅថ្ងៃណាមួយទៀត ក្រៅពីថ្ងៃអាទិត្យ
- សម្រាកពីថ្ងៃត្រង់ថ្ងៃអាទិត្យ រហូតដល់ថ្ងៃត្រង់ថ្ងៃចន្ទ
- សម្រាកផ្លាស់វេនគ្នាគ្រប់បុគ្គលិកទាំងអស់ គឺចែកវេនគ្នាធ្វើការថ្ងៃអាទិត្យម្តងម្នាក់។

ការរៀបចំថ្ងៃសម្រាក ក្រៅពីថ្ងៃអាទិត្យ ទៅតាមវិធីណាមួយក៏ដោយ ក្នុងចំណោមវិធីទាំងបីខាងលើ ចាំបាច់ត្រូវសុំការអនុញ្ញាតពីក្រសួងការងារជាមុនសិន លើកលែងតែចំពោះសហគ្រាសមួយចំនួន ដែលច្បាប់ចែងអនុញ្ញាតរួចជាស្រេចក្នុងមាត្រា ១៤៩ រួមមាន៖

- គ្រឹះស្ថានផលិតគ្រឿងបរិភោគសម្រាប់បរិភោគភ្លាមៗ
- សណ្ឋាគារ ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន
- ហាងលក់ផ្កាធម្មជាតិ
- មន្ទីរពេទ្យ កន្លែងសង្គ្រោះក្មេងកំព្រា មនុស្សពិការ មនុស្សចាស់ ជម្រកសម្រាប់អ្នកចូលនិវត្តន៍ និងអ្នកវិកលចរិត ឱសថស្ថាន និងគេហដ្ឋានសុខភាព
- គ្រឹះស្ថានងូតទឹក
- សហគ្រាសសារព័ត៌មាន ឃោសនាការ និងទស្សនីយភាព សារមន្ទីរ និងពិព័រណ៍
- សហគ្រាសយានជំនិះឈ្នួល
- សហគ្រាសផ្គត់ផ្គង់ចរន្តអគ្គិសនី ទឹក និងថាមពលសម្រាប់គ្រឿងចក្រ
- សហគ្រាសដឹកជញ្ជូនតាមផ្លូវគោក លើកលែងតែអយស្ម័យយាន
- រោងឧស្សាហកម្ម ដែលមានប្រើវត្ថុធាតុដែលឆាប់ខូច
- រោងឧស្សាហកម្ម ដែលការផ្អាកការងារអាចបណ្តាលឲ្យខូចបង់ ឬបន្ថយគុណភាពផលិតផល ដែលកំពុងធ្វើ
- រោងឧស្សាហកម្ម ដែលប្រកបការងារផ្តល់សន្តិសុខ ផាសុកភាព ឬប្រយោជន៍សាធារណៈ
- …. (សូមមើលមាត្រា ១៤៩ នៃច្បាប់ការងារ)

**៥.តើនិយោជកអាចឲ្យបុគ្គលិកធ្វើការបន្ថែមម៉ោងដែរ ឬទេ? បើបាន តើត្រូវគិតប្រាក់ឈ្នួលយ៉ាងម៉េច?**

ច្បាប់ការងារអនុញ្ញាតឲ្យមានការងារបន្ថែមម៉ោង ក៏ប៉ុន្តែ បានតែក្នុងករណីដែលមានកិច្ចការប្រញាប់ និងពិសេសខុសធម្មតាប៉ុណ្ណោះ ពោលគឺ សហគ្រាសមិនអាចឲ្យបុគ្គលិកធ្វើការបន្ថែមម៉ោង ដើម្បីបំពេញកិច្ចការអចិន្ត្រៃយ៍ធម្មតាបានទេ។

ការធ្វើការបន្ថែមម៉ោង គឺត្រូវធ្វើដោយស្ម័គ្រចិត្ត។ សហគ្រាសមិនអាចបង្ខិតបង្ខំនយោជិតកម្មករឲ្យធ្វើការបន្ថែមម៉ោងបានទេ។ បុគ្គលិកដែលបដិសេធមិនធ្វើការបន្ថែមម៉ោង មិនត្រូវទទួលទណ្ឌកម្មអ្វីទេ។

ច្បាប់ការងារ ត្រង់មាត្រា ១៣៩ កំណត់ថា ម៉ោងបន្ថែមត្រូវឲ្យប្រើឈ្នួលតាមអត្រាដំឡើង ៥០%។ មានន័យថា បើម៉ោងធម្មតាឲ្យប្រាក់ឈ្នួល ១ម៉ោង ២ពាន់រៀល ម៉ោងបន្ថែម ត្រូវឲ្យ៣ពាន់។ ប្រសិនបើការងារបន្ថែមម៉ោងនេះ ត្រូវធ្វើនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ឬធ្វើនៅពេលយប់ គឺប្រាក់ឈ្នួលត្រូវគិតលើសពីប្រាក់ឈ្នួលធម្មតាមួយទ្វេជាពីរ។

**៦.ក្រៅពីការឈប់សម្រាកប្រចាំសប្តាហ៍ និងថ្ងៃបុណ្យជាតិ តើក្នុងមួយឆ្នាំ បុគ្គលិកមានសិទ្ធិឈប់សម្រាកប៉ុន្មានថ្ងៃដោយមានប្រាក់ឈ្នួល?**

ច្បាប់កំណត់ថា កម្មករនិយោជិតទាំងអស់មានសិទ្ធិឈប់សម្រាក យ៉ាងតិច ១៨ថ្ងៃ ក្នុងមួយឆ្នាំ ដោយទទួលបានប្រាក់ឈ្នួលធម្មតា។ អនុសញ្ញារួមក្នុងសហគ្រាស ឬកិច្ចសន្យាការងារអាចកំណត់ឲ្យមានថ្ងៃសម្រាកលើសពី ១៨ថ្ងៃបាន ប៉ុន្តែមិនឲ្យតិចជាង ១៨ថ្ងៃក្នុងមួយឆ្នាំទេ។

ចំនួនថ្ងៃសម្រាកប្រចាំឆ្នាំនេះ ត្រូវបន្ថែមចំពោះបុគ្គលិកដែលមានអតីតភាពក្នុងសហគ្រាស គឺ ត្រូវបន្ថែម ១ថ្ងៃទៀត ពេលធ្វើការបានបីឆ្នាំក្នុងសហគ្រាស។

គួរបញ្ជាក់ថា ថ្ងៃឈប់សម្រាកប្រចាំឆ្នាំ ១៨ថ្ងៃនេះ គឺរាប់ជាថ្ងៃធ្វើការធម្មតា។ ការឈប់សម្រាកប្រចាំសប្ដាហ៍ និងការឈប់សម្រាកថ្ងៃបុណ្យ គឺមិនត្រូវរាប់បញ្ចូលជាថ្ងៃឈប់សម្រាកប្រចាំឆ្នាំទេ។

**៧.តើត្រូវធ្វើការបានរយៈពេលប៉ុន្មាន ទើបបុគ្គលិកមានសិទ្ធិសុំឈប់សម្រាកប្រចាំឆ្នាំ?**

ទាល់តែធ្វើការបានគ្រប់មួយឆ្នាំក្នុងសហគ្រាស ទើបអាចមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំបាន (មាត្រា ១៦៧)។

ក្នុងករណី មានផ្ដាច់ ឬចប់កិច្ចសន្យាមុនពេល ១ឆ្នាំនេះ សហគ្រាសត្រូវសងប្រាក់បំណាច់ទៅឲ្យបុគ្គលិកនោះ ដោយគិតជាសមាមាត្រទៅតាមពេលវេលាដែលគាត់បានធ្វើការក្នុងសហគ្រាស។

**៨.ក្នុងករណីមានធុរៈផ្ទាល់ខ្លួន តើនិយោជិតកម្មករអាចសុំឈប់សម្រាកបានដែរ ឬទេ? បើបាន តើត្រូវរាប់បញ្ចូលក្នុងថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែរ ឬទេ?**

ច្បាប់ការងារ ត្រង់មាត្រា ១៧១ អនុញ្ញាតឲ្យមានការឈប់សម្រាកពិសេស ក្នុងករណីនិយោជិតមានធុរៈផ្ទាល់ខ្លួន ឬក្នុងឱកាសមានព្រឹត្តិការណ៍ ដែលប៉ះពាល់ដល់គ្រួសាររបស់កម្មករនិយោជិត ដូចជា៖

- ត្រូវរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន
- ត្រូវរៀបអាពាហ៍ពិពាហ៍កូន
- ប្រពន្ធសម្រាលកូន
- ប្ដី ប្រពន្ធ កូន ឪពុក ឬម្ដាយ មានជម្ងឺ ឬទទួលមរណភាព

ក្នុងករណីមានធុរៈបែបនេះ បុគ្គលិកអាចសុំឈប់សម្រាកបាន ដោយនៅទទួលបានប្រាក់ឈ្នួលជាធម្មតា។ ក៏ប៉ុន្តែការឈប់សម្រាកពិសេសបែបនេះ ក្នុងមួយឆ្នាំ មិនឲ្យមានលើសពី ៧ ថ្ងៃទេ។

ការឈប់សម្រាកពិសេសនេះ អាចយកមកកាត់កងជាមួយថ្ងៃឈប់សម្រាកប្រចាំឆ្នាំបាន ប្រសិនបើនិយោជិតមិនទាន់អនុវត្តការឈប់សម្រាកប្រចាំឆ្នាំរបស់គាត់ អស់ទេ មានន័យថា និយោជិតមិនទាន់ឈប់សម្រាកអស់ទាំង ១៨ថ្ងៃ ដែលគាត់មាន។ បើសិនជាគាត់បានអនុវត្តអស់ហើយ នយោជកមិនអាចធ្វើការកាត់កងថ្ងៃឈប់សម្រាកពិសេសនេះ ពីការឈប់សម្រាកប្រចាំឆ្នាំ នៅឆ្នាំក្រោយៗទៀតបានទេ។

ចំពោះនិយោជិតជាស្ត្រី ដែលត្រូវសម្រាលកូន គាត់មានសិទ្ធិឈប់សម្រាក៩០ថ្ងៃ ដើម្បីសម្រាលកូន (មាត្រា ១៨២)។

បើសិនជាគាត់បានធ្វើការក្នុងសហគ្រាសរយៈពេលគ្រប់មួយឆ្នាំហើយ នៅក្នុងអំឡុងពេល ឈប់សម្រាក ដើម្បីសម្រាលកូន ៩០ថ្ងៃ គាត់មានសិទ្ធិទទួលប្រាក់ឈ្នួលពាក់កណ្ដាល។

បើសិនធ្វើការមិនទាន់គ្រប់ ១ឆ្នាំទេ គាត់មិនមានសិទ្ធិទទួលប្រាក់ឈ្នួលពាក់កណ្ដាលនេះទេ ប៉ុន្តែ គាត់នៅតែអាចឈប់៩០ថ្ងៃបាន ដោយនយោជកមិនមានសិទ្ធិបញ្ឈប់គាត់ពីការងារនោះទេ។ ក្រោយពេលផុតរយៈពេលឈប់សម្រាក ៩០ថ្ងៃ គាត់មានសិទ្ធិត្រឡប់ចូលមកធ្វើការវិញបាន។

# ផ្នែកទី៦១

# អំពីសិទ្ធិ និងនីតិវិធីនៃការធ្វើកូដកម្មរបស់កម្មករនិយោជិត

ដោយ សេង ឌីណា

សិទ្ធិរបស់កម្មករនិយោជិត ក្នុងការធ្វើកូដកម្ម គឺជាសិទ្ធិដែលទទួលបាននូវការពារដោយរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា។ ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញក៏បានបញ្ជាក់ផងដែរថា សិទ្ធិនេះត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌច្បាប់។ លក្ខខណ្ឌនៃការអនុវត្តសិទ្ធិធ្វើកូដកម្មមានចែងនៅក្នុង ច្បាប់ការងារ ឆ្នាំ១៩៩៧។

**១.តើច្បាប់កំណត់អំពីនីតិវិធីអ្វីខ្លះ ដែលកម្មករ និយោជិតត្រូវបំពេញ មុននឹងចាប់ផ្តើមធ្វើកូដកម្ម?**

នីតិវិធីនៃការធ្វើកូដកម្ម គឺមានចែងនៅក្នុងច្បាប់ការងារ មាត្រា ៣២៣ ដល់ មាត្រា ៣២៩។

ទីមួយ ដើម្បីធ្វើកូដកម្ម គឺត្រូវមានការសម្រេចពីកម្មករ និយោជិត។ របៀបរបបនៃការប្រជុំសម្រេចធ្វើកូដកម្មនេះ អាចរៀបចំធ្វើទៅតាមលក្ខន្តិកៈរបស់សហជីព នៅតាមសហគ្រាសនីមួយៗ ក៏ប៉ុន្តែ ច្បាប់ការងារបានកំណត់ថា ការសម្រេចធ្វើកូដកម្ម ឬមិនធ្វើ ត្រូវធ្វើតាមរយៈការបោះឆ្នោតជាសម្ងាត់។

បើសិនជាកម្មករ និយោជិត បោះឆ្នោតសម្រេចថាធ្វើកូដកម្ម នីតិវិធីបន្ទាប់ គឺត្រូវធ្វើការប្រកាសជូនដំណឹងទៅសហគ្រាស និយោជក អំពីការធ្វើកូដកម្ម។ ការជូនដំណឹងនេះត្រូវធ្វើឡើងយ៉ាងតិច ៧ថ្ងៃ មុនថ្ងៃធ្វើកូដកម្ម (៧ថ្ងៃ គិតតែថ្ងៃធ្វើការ ដោយមិនរាប់ថ្ងៃឈប់សម្រាក) ហើយក្នុងការជូនដំណឹងនេះ ត្រូវមានបញ្ជាក់ច្បាស់លាស់ អំពីការទាមទាររបស់កម្មករ និយោជិត ដែលជាមូលហេតុនៃការធ្វើកូដកម្ម។ ច្បាប់តម្រូវឲ្យធ្វើការជូនដំណឹងនេះទៅឲ្យក្រសួងការងារផងដែរ។

នៅក្នុងចន្លោះពេល ចាប់ពីថ្ងៃជូនដំណឹង រហូតដល់ថ្ងៃធ្វើកូដកម្ម ភាគីវិវាទមានកាតព្វកិច្ចចូលរួមប្រជុំផ្សះផ្សាទៅតាមការកោះអញ្ជើញ របស់រដ្ឋមន្ត្រីក្រសួងការងារ ដែលច្បាប់តម្រូវឲ្យទទួលបន្ទុករិះរកមធ្យោបាយផ្សះផ្សា ដើម្បីបញ្ចៀសកូដកម្ម។ បើសិនជាការចរចាអាចផ្សះផ្សាបាន កូដកម្មត្រូវលុបចោលវិញ។ បើសិនជាដល់ថ្ងៃកំណត់ធ្វើកូដកម្ម នៅតែមិនអាចចរចាត្រូវរ៉ូវគ្នាទៀត កម្មករ និយោជិត អាចចាប់ផ្តើមធ្វើកូដកម្មបាន។

**២.សហគ្រាស និយោជក អាចកាត់ប្រាក់ខែកម្មករ និយោជិត ដែលចូលរួមធ្វើកូដកម្មបានដែរ ឬទេ?**

ច្បាប់ការងារចែងថា កិច្ចសន្យាការងាររបស់កម្មករ និយោជិត ដែលសម្រេចចូលរួមធ្វើកូដកម្ម ត្រូវព្យួរជាបណ្តោះអាសន្ន នៅក្នុងអំឡុងពេលធ្វើកូដកម្ម (មាត្រា ៣៣២) មានន័យថា កម្មករ និយោជិតមិនជាប់កាតព្វកិច្ចបំពេញការងារ ហើយក៏មិនមានសិទ្ធិទទួលបានប្រាក់ឈ្នួលដែរ។ ដូច្នេះ សហគ្រាស និយោជក អាចកាត់ប្រាក់ខែកម្មករ និយោជិតណា ដែលចូលរួមធ្វើកូដកម្ម ប៉ុន្តែ កាត់ទៅតាមតែចំនួនថ្ងៃ ដែលធ្វើកូដកម្មប៉ុណ្ណោះ។

ក្រៅពីកាត់ប្រាក់ខែនេះ ច្បាប់ហាមឃាត់ដាច់ខាតមិនឲ្យសហគ្រាស និយោជក ដាក់ទណ្ឌកម្មអ្វីផ្សេងទៀត ទៅលើកម្មករ និយោជិត ដោយសារតែការចូលរួមធ្វើកូដកម្មនេះទេ។ ការបញ្ឈប់ការងារកម្មករ ដោយសារតែការចូលរួមធ្វើកូដកម្មនេះ ក៏កាន់តែមិនអាចធ្វើបានទៅទៀត។

**៣.ចុះបើគ្រាន់តែជ្រើសរើសកម្មករនិយោជិតផ្សេងឲ្យមកធ្វើការជាបណ្តោះអាសន្ន ក្នុងពេលមានកូដកម្ម ដើម្បីធ្វើការជំនួសនិយោជិត ដែលកំពុងធ្វើកូដកម្ម តើសហគ្រាស និយោជកអាចធ្វើបានដែរ ឬទេ?**

មាត្រា ៣៣៤ នៃច្បាប់ការងារ ចែងថា “*នៅក្នុងអំឡុងពេលធ្វើកូដកម្ម ត្រូវហាមឃាត់មិនឲ្យនិយោជកជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួស កូដករទាំងអស់ លើកលែងតែការជ្រើសរើសនេះធ្វើឡើង ដើម្បីធានាសេវាអប្បបរមា*”។

ក្នុងពេលមានកូដកម្ម ច្បាប់ការងារចែងអនុញ្ញាតឲ្យសហគ្រាស និយោជក កេណ្ឌកម្មករនិយោជិត ឲ្យបំពេញការងារ វ៉ាប់រងសេវាអប្បបរមា ដើម្បីធានាដល់ការពារទ្រព្យ ទំនិញ ឬគ្រឿងបរិក្ខារបស់សហគ្រាស (មាត្រា ៣២៦)។ បើសិនជានៅថ្ងៃធ្វើកូដកម្ម កម្មករនិយោជិត ដែលត្រូវកេណ្ឌឲ្យមកវ៉ាប់រងសេវាអប្បបរមា មិនមកធ្វើការ ហើយបែរជាទៅចូលរួមធ្វើកូដកម្មដែរ ក្នុងករណីនេះ សហគ្រាស និយោជក អាចជ្រើសរើសកម្មករនិយោជិតផ្សេងមកធ្វើការជំនួសបាន។ ចំណែកកម្មករនិយោជិត ដែលជាប់កាតព្វកិច្ចវ៉ាប់រងសេវាអប្បបរមា ហើយបែរជាមកមកធ្វើការបែបនេះ ត្រូវចាត់ទុកថាមានកំហុសធ្ងន់ ដែលអាចត្រូវទទួលទណ្ឌកម្ម។

**៤. ចុះបើសិនជាសហគ្រាស និយោជក ជ្រើសរើសនិយោជិតផ្សេងមកជំនួសកូដករ ក្រៅពីករណីសេវាអប្បបរមានេះ តើច្បាប់មានចែងអំពីទណ្ឌកម្មអ្វីដែរ?**

ក្នុងករណីដែលសហគ្រាស និយោជក ជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួសកូដករ ក្រៅពីករណីសេវាអប្បបរមា និយោជកមានកាតព្វកិច្ចបើកប្រាក់បៀវត្សឲ្យកម្មករនិយោជិតជាកូដករ ទាំងអស់ ក្នុងអំឡុងពេលធ្វើកូដកម្ម (តាមធម្មតា កម្មករនិយោជិតដែលចូលរួមធ្វើកូដកម្ម គឺមិនត្រូវទទួលប្រាក់ឈ្នួលទេសម្រាប់ថ្ងៃធ្វើកូដកម្ម)។

ដូច្នេះ មានន័យថា ក្នុងករណីមានការជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួសកូដករ ក្រៅពីករណីសេវាអប្បបរមា និយោជកត្រូវអស់លុយពីរជាន់៖ អស់លុយបង់ប្រាក់ឈ្នួលទៅឲ្យកម្មករនិយោជិតដែលរើសយកមកជំនួសកូដករ នោះផង ហើយត្រូវអស់លុយបង់ប្រាក់ឈ្នួលទៅឲ្យកូដករនោះមួយជាន់ទៀត។

**៥.ចុះបើសិនជាក្នុងករណីដែលកម្មករនិយោជិតធ្វើកូដកម្មដោយខុសច្បាប់វិញ តើអាចត្រូវទទួលទណ្ឌកម្មអ្វីខ្លះ?**

ទីមួយ ត្រូវបញ្ជាក់ថា ការកំណត់ថា កូដកម្មណាមួយជាកូដកម្មខុសច្បាប់ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ការងារ ឬតុលាការខេត្តក្រុងបើសិនជាគ្មានតុលាការការងារ (មាត្រា ៣៣៧)។ បើសិនជាសហគ្រាស និយោជក យល់ថា ការធ្វើកូដកម្មណាមួយ ត្រូវបានរៀបចំធ្វើដោយខុសច្បាប់ (មិនគោរពទៅតាមនីតិវិធី ដែលកំណត់ដោយច្បាប់ ឬធ្វើឡើងដោយមានអំពើហិង្សា) សហគ្រាស និយោជកនោះត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីស្នើសុំឲ្យតុលាការចេញដីកាសម្រេចរក្សាការពារ (នីតិវិធីបន្ទាន់)។

បើសិនជាតុលាការសម្រេចថា កូដកម្មនេះជាកូដកម្មខុសច្បាប់ កូដករត្រូវចូលធ្វើការវិញ ក្នុងរយៈពេល ៤៨ម៉ោង ចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ។ ផុតពេលកំណត់ ៤៨ម៉ោងនេះ បើសិនជាកម្មករនិយោជិតណាមិនចូលទៅធ្វើការវិញទេ គឺត្រូវចាត់ទុកថាមានកំហុសធ្ងន់ ដែលអាចត្រូវទទួលទណ្ឌកម្ម។

## ផ្នែកទី៦២

## អ្វីខ្លះជាគុណសម្បត្តិ និងគុណវិបត្តិនៃការងារមាននិងគ្មានកិច្ចសន្យាត្រឹមត្រូវ?

ដោយ គី សុខលីម

ដោយសារតែការងារតូចតាចនៅក្នុងប្រទេសកម្ពុជាពុំមាន កិច្ចសន្យាច្បាស់លាស់ កម្មករនិយោជិតមួយចំនួនជំតែងតែធ្វើការផ្លាស់ប្តូរការងារនៅក្រោយ បុណ្យប្រពៃណីខ្មែរម្តងៗ។ ជាក់ស្តែង ដូចជាករណីនៅក្រោយបុណ្យភ្ជុំបិណ្ឌឆ្នាំ២០១២នេះ។ តើការផ្លាស់ប្តូរការងាររបស់កម្មករក្រោយពិធីបុណ្យធំៗបង្កបញ្ហាអ្វីខ្លះ?

នៅក្នុងប្រទេសជឿនលឿនដែលមានក្របខណ្ឌគតិយុត្តិត្រឹមត្រូវនិង គ្រប់គ្រាន់ គ្រប់ពាណិជ្ជកម្មតូចធំ គ្រប់ការងារទាំងអស់ត្រូវតែមានច្បាប់ និងមានកិច្ចសន្យាត្រឹមត្រូវ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាវិញ អាជីវកម្មមួយចំនួននៅមិនទាន់បានចុះបញ្ជីត្រឹមត្រូវ រីឯការងារមួយចំនួនធំនៅមិនទាន់មានកិច្ចសន្យានៅឡើយទេ។

ហេតុផលមិនមានកិច្ចសន្យាការងារច្បាស់លាស់ ពេលខ្លះអាចបណ្តាលមកពីចេតនារបស់ម្ចាស់អាជីវកម្ម ពីព្រោះថាពួកគេមិនចង់អោយមានចំណងផ្លូវច្បាប់។ ប៉ុន្តែពេលខ្លះទៀត គឺកើតចេញពីចេតនារបស់កម្មករនិយោជិតទៅវិញទេ ពីព្រោះពួកគេចង់មានសេរីភាពក្នុងការផ្លាស់ប្តូរការងារនៅពេលណាដែលពួកគេចង់។

**១.តើការងារដែលមានកិច្ចសន្យាត្រឹមត្រូវនិងគ្មានកិច្ចសន្យាត្រឹមត្រូវមានគុណសម្បត្តិ និងគុណវិបត្តិយ៉ាងណាខ្លះ?**

សម្រាប់អ្នកវិភាគសង្គមសេដ្ឋកិច្ច វាមានទាំងគុណសម្បត្តិនិងគុណវិបត្តិ។ សម្រាប់ការងារដែលមានកិច្ចសន្យាត្រឹមត្រូវគុណសម្បត្តិរបស់វានៅត្រង់ថា កម្មករនិយោជិតទទួលបានការធានាការងារក្នុងរយៈពេលកំណត់ណាមួយពី ម្ចាស់អាជីវកម្ម។ រីឯចំពោះម្ចាស់អាជីវកម្មវិញ ពួកគេមានភាពងាយស្រួលក្នុងការពង្រីកគម្រោងអាជីកម្ម ឬប្រតិបត្តិការកិច្ចការអាជីវកម្មរបស់ខ្លួនពោលគឺ ពួកគេមិនមានការព្រួយបារម្ភថា នៅថ្ងៃស្អែក សប្តាហ៍ក្រោយ ឬខែក្រោយបុគ្គលិកនេះ ឬបុគ្គលិកនោះ សុំឈប់ពីការងារ។ ទាំងអស់នេះគឺជាគុណសម្បត្តិនៃការងារដែលមានកិច្ចសន្យា។

ប៉ុន្តែ ការងារដែលមានកិច្ចសន្យាត្រឹមត្រូវក៏បង្កប់នូវគុណវិបត្តិរបស់វាដែរ។ គុណវិបត្តិសម្រាប់កម្មករនិយោជិត គឺនៅត្រង់ថា ពួកគេមិនអាចផ្លាស់ប្តូរការងារបានតាមទំនើងចិត្ត។ រីឯគុណវិបត្តិសម្រាប់ម្ចាស់អាជីវកម្មវិញ ពួកគេមានកាតព្វកិច្ចផ្លូវច្បាប់មានន័យថា ពួកគេត្រូវគោរពម៉ោងធ្វើការងាររបស់កម្មករ ពួកគេត្រូវដំឡើងប្រាក់ខែជូនកម្មករទៅតាមគោលការណ៍កំណត់ ឬពួកគេមិនអាចដេញបុគ្គលិកចេញតាមអំណាចផ្លូវចិត្ត។ល។

**២.ងាកមកឆ្លើយទៅនឹងសំណួរដែលសួរថា តើការងារគ្មានកិច្ចសន្យាត្រឹមត្រូវផ្តល់គុណសម្បត្តិនិងគុណវិបត្តិយ៉ាងណានោះ?**

អ្នកវិភាគសង្គមសេដ្ឋកិច្ចដដែលបានអត្ថាធិប្បាយថា បញ្ហានេះផ្តល់ទាំងគុណសម្បត្តិនិងគុណវិបត្តិដល់កម្មករនិយោជិត និងម្ចាស់អាជីវកម្ម។ ការងារគ្មានកិច្ចសន្យាត្រឹមត្រូវមានគុណសម្បត្តិសម្រាប់កម្មករនិយោជិត នៅត្រង់ថា ពួកគេអាចផ្លាស់ប្តូរការងារបានយ៉ាងស្រួលដោយមិនមានចំណងអ្វីទាំងអស់។ ចំពោះថៅកែអាជីវកម្មវិញ ពួកគេគ្មានចំណងផ្លូវច្បាប់។ ប៉ុន្តែចំពោះគុណវិបត្តិវិញ កម្មករនិយោជិតប្រឈមនឹងការងារមិនទៀងទាត់ ប្រឈមនឹងការបណ្តេញចេញដោយគ្មានហេតុផល។

សរុបសេចក្តីមក បើទោះបីជាការងារគ្មានកិច្ចសន្យាផ្តល់អត្ថប្រយោជន៍ខ្លះដល់ថៅកែមែន ក៏ដោយក្តី ក៏ការងារប្រភេទនេះធ្វើអោយថៅកែឈឺក្បាលមិនតិចឡើយ។ ឈឺក្បាល ពីព្រោះថា ការផ្លាស់ប្តូរបុគ្គលិកញឹកញាប់រំខានដល់ចង្វាក់ផលិតកម្មឬគម្រោង ពង្រីកអាជីវកម្ម។

សូមបញ្ជាក់ថា នៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ ពេលវេលាដែលថៅកែឈឺក្បាលខ្លាំងរឿងកម្លាំងពលកម្មនោះគឺនៅពេលដែលមាន ពិធីបុណ្យប្រពៃណីធំៗរបស់ខ្មែរម្តងៗ ដូចជា រដូវបុណ្យចូលឆ្នាំខ្មែរ រដូវបុណ្យអំទូក និងពិធីបុណ្យភ្ជុំបិណ្ឌ ជាដើម។ នៅក្នុងឱកាសបុណ្យធំៗទាំងនេះ កម្មករនិយោជិតភាគច្រើនដែលធ្វើការគ្មានកិច្ចសន្យាត្រឹមត្រូវត្រូវផ្លាស់ប្តូរការងារ។

ការផ្លាស់ប្តូរការងាររបស់ពួកគេអាចបណ្តាលមកពីប្រាក់ខែតិច អាចបណ្តាលមកពីការមិនសប្បាយចិត្ត អាចបណ្តាលមកពីការចង់ផ្លាស់ប្តូរការងារជាដើម។ ប៉ុន្តែបើទោះជាក្នុងហេតុផលណាក៏ដោយ ក៏ថៅកែឈឺក្បាលដែរ។ ហើយនេះគឺជាបច្ច័យនៃការងារដែលគ្មានកិច្ចសន្យាច្បាស់លាស់។

# ផ្នែកទី៦៣
# អំពីការបញ្ឈប់ការងារកម្មករនិយោជិត

ដោយ សេង ឌីណា

ការបញ្ឈប់ការងារកម្មករនិយោជិត បើនិយាយតាមផ្លូវច្បាប់ គឺជាការរំលាយកិច្ចសន្យាការងារជាឯកតោភាគី ធ្វើឡើងដោយភាគីនិយោជក។ លក្ខខណ្ឌ នៃការរំលាយកិច្ចសន្យាការងារនេះ មានចែងនៅក្នុងច្បាប់ការងារខ្មែរ ឆ្នាំ១៩៩៧។

**១.តើក្នុងលក្ខខណ្ឌអ្វីខ្លះ ដែលនិយោជកអាចបញ្ឈប់ការងារកម្មករនិយោជិតបាន?**

ចំពោះករណីរំលាយកិច្ចសន្យាជាឯកតោភាគី ធ្វើឡើងដោយភាគីនិយោជក ដោយគ្មានការព្រមព្រៀងពីនិយោជិត គេត្រូវមើលថា តើកិច្ចសន្យានេះ ជាកិច្ចសន្យាមានកំណត់ថិរវេលា ឬមិនកំណត់ថិរវេលា?

ចំពោះករណីកិច្ចសន្យាមានកំណត់ថិរវេលា (មានន័យថា នៅពេលចុះកិច្ចសន្យាការងារ និយោជក និងនិយោជិត បានព្រមព្រៀងគ្នាជាមុនថា កិច្ចសន្យានេះ គឺធ្វើឡើងសម្រាប់រយៈពេលកំណត់ណាមួយ) និយោជកអាចបញ្ឈប់ការងាររបស់និយោជិតនៅមុនពេលកំណត់បានតែក្នុងករណីពីរប៉ុណ្ណោះ គឺករណីនិយោជិតមានកំហុសធ្ងន់ និងករណីប្រធានស័ក្តិ។

- **ករណីនិយោជិតមានកំហុសធ្ងន់៖** ដូចជា លួច ឬគេបំបាត់សហគ្រាស ផ្តល់សញ្ញាប័ត្រក្លែងក្លាយពេលសុំចូលធ្វើការ រំលោភលើការណ៍សម្ងាត់ខាងវិជ្ជាជីវៈ ជេរប្រមាថ ឬប្រព្រឹត្តអំពើហិង្សាទៅលើអ្នកធ្វើការជាមួយគ្នា ឬទៅលើនិយោជក ឬធ្វើបាតុកម្មនយោបាយ នៅក្នុងសហគ្រាស ។ល។ (មាត្រា ៨៣ នៃច្បាប់ការងារ)
- **ករណីប្រធានស័ក្តិ៖** ដូចជា សហគ្រាសត្រូវបិទទ្វារទៅតាមបទបញ្ជារបស់អាជ្ញាធរ ឬដោយសារមានគ្រោះមហន្តរាយធម្មជាតិ ។ល។ (មាត្រា ៨៥)

ក្រៅពីករណីពីរនេះ និយោជកមិនអាចបញ្ឈប់ការងារនិយោជិតមុនពេលកំណត់បានទេ គឺត្រូវតែចាំឲ្យកិច្ចសន្យាត្រូវផុតរលត់ជាធម្មតា នៅពេលដល់កាលកំណត់។

**២.ចុះបើសិនជាខាងនិយោជិតជាអ្នកសុំឈប់នៅមុនពេលដល់កាលកំណត់ តើអាចឈប់បានដែរទេ?**

និយោជិតអាចសុំឈប់បាន ប្រសិនបើមានការព្រមព្រៀងខាងនិយោជក ដែលត្រូវចូលក្នុងករណីរំលាយកិច្ចសន្យាទៅតាមការព្រមព្រៀងពីគូភាគីទាំងសងខាង។ ក្នុងករណីនេះ ច្បាប់ការងារខ្មែរ ចែងកំណត់ថា ការព្រមព្រៀងរំលាយកិច្ចសន្យាមុនកាលកំណត់នេះ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភាគីទាំងពីរ នៅចំពោះមុខអធិការការងារ (មាត្រា ៧៣)។

ប្រសិនបើភាគីនិយោជកមិនយល់ព្រមទេ និយោជិតមិនអាចឈប់បានទេ លើកលែងតែក្នុងករណីប្រធានស័ក្តិ (ដូចដែលរៀបរាប់ខាងលើ) ឬមានកំហុសធ្ងន់របស់និយោជក។ កំហុសធ្ងន់របស់និយោជក មានដូចជាការមិនព្រមបើកប្រាក់ឈ្នួល ឬបើកយឺតច្រើនលើកច្រើនសា ជេរប្រមាថ ឬប្រើអំពើហិង្សាទៅលើនិយោជិត ឬក៏មិនបានប្រតិបត្តិវិធានការសន្តិសុខ និងអនាម័យសម្រាប់និយោជិតទៅតាមបទប្បញ្ញត្តិជាធរមាន ។ល។ (មាត្រា ៨៣-ក)។

ដូច្នេះ បើនិយាយសរុបជារួមមកវិញ កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា អាចត្រូវរំលាយមុនកាលកំណត់បានលុះត្រាតែមានកំហុសធ្ងន់ពីខាងភាគីណាមួយ ឬក្នុងករណីប្រធានស័ក្តិ ឬមានការព្រមព្រៀងពីភាគីទាំងសងខាង។

ក្រៅពីករណីទាំងនេះ ប្រសិនបើនិយោជកជាអ្នករំលាយកិច្ចសន្យាជាឯកតោភាគី (មានន័យថា គាត់បញ្ឈប់ការងារបុគ្គលិកមុនពេលកំណត់នៃកិច្ចសន្យា) និយោជិតអាចទាមទារសំណងជំងឺចិត្តពីនិយោជកបាន។ ច្បាប់ការងារចែងថា សំណងជំងឺចិត្តនេះត្រូវមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួល ដែលនិយោជិតត្រូវទទួលបានរហូតដល់ពេលចប់កិច្ចសន្យា។

បើសិនជានិយោជិតជាអ្នកលាឈប់មុនកាលកំណត់វិញ (ដោយគ្មានការយល់ព្រមពីនិយោជក ដោយគ្មានចូលក្នុងករណីមានកំហុសធ្ងន់ ឬប្រធានស័ក្តិ) គឺខាងនិយោជកដែល មានសិទ្ធិទាមទារសំណងជំងឺចិត្ត ដើម្បីជួសជុលរាល់ការខូចខាត ដែលបង្កឡើងដោយនយោជិត ដែលលាឈប់នេះ។

**៣.ចុះចំពោះកិច្ចសន្យាដែលមានចិរវេលាមិនកំណត់វិញ តើក្នុងលក្ខខណ្ឌណាខ្លះ ដែលសហគ្រាស-និយោជក អាចបញ្ឈប់ការងារកម្មករនិយោជិតបាន?**

ក្នុងករណីកិច្ចសន្យាមានចិរវេលាមិនកំណត់ សហគ្រាស-និយោជកអាចបញ្ឈប់បុគ្គលិកបាន ដោយត្រូវគោរពតាមលក្ខខណ្ឌបី៖

– **ត្រូវតែមាន “ហេតុផលសមរម្យ”**

ច្បាប់ការងារ ត្រង់មាត្រា ៧៤ ចែងថា *“គ្មានការបញ្ឈប់ណាមួយអាចធ្វើ ទៅបានដោយគ្មានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមឡើយ”*។ ដូច្នេះ “សម្បទា ឬចរិយា” របស់កម្មករនិយោជិត ដែលនិយោជកអាចលើកយកមកធ្វើជាហេតុផលក្នុងការបញ្ឈប់ការងារបាន គឺទាល់តែមានជាប់ទាក់ទងនឹងដំណើរការរបស់សហគ្រាស។ បញ្ហាផ្ទាល់ខ្លួន ជាលក្ខណៈឯកជនដែលមិនពាក់ព័ន្ធនឹងដំណើរការរបស់សហគ្រាស (កម្មករនិយោជិតអត់ចេះគួរសម អត់ចេះយកចិត្ត អែបអប លើកដៃលើកជើងចៅហ្វាយនាយ) មិនអាចជាហេតុផល ក្នុងការបញ្ឈប់ការងារកម្មករនិយោជិតបានទេ!

ត្រង់កន្លែងនេះ ច្បាប់ចែងក្នុងគោលដៅការពារផលប្រយោជន៍កម្មករនិយោជិត ដើម្បីកុំឲ្យនិយោជកចេះតែអាចបញ្ឈប់ការងារអ្នកណាក៏បានស្រេចនឹង ចិត្ត ដោយគ្មានហេតុផលសមរម្យ។

– **ត្រូវឲ្យដំណឹងជាមុនជាលាយលក្ខណ៍អក្សរទៅកម្មករនិយោជិត អំពីការបញ្ឈប់ការងារ**

រយៈពេលនៃការជូនដំណឹងនេះ គឺវាអាស្រ័យទៅលើអតីតភាពរបស់កម្មករនិយោជិត ក្នុងសហគ្រាស (មាត្រា ៧៥)។

- អតីតភាពការងារ (រយៈពេលដែលកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាស) តិចជាង ៦ខែ ត្រូវជូនដំណឹងមុន យ៉ាងតិច ៧ថ្ងៃ
- អតីតភាពការងារលើសពី ៦ខែ ប៉ុន្តែ តិចជាង ២ឆ្នាំ ត្រូវជូនដំណឹងមុន យ៉ាងតិច ១៥ថ្ងៃ
- អតីតភាពការងារពី ២ឆ្នាំ ទៅ ៥ឆ្នាំ ត្រូវជូនដំណឹងមុន យ៉ាងតិច ១ខែ
- អតីតភាពការងារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ត្រូវជូនដំណឹងមុន យ៉ាងតិច ២ខែ
- អតីតភាពការងារលើសពី ១០ឆ្នាំ ត្រូវជូនដំណឹងមុន យ៉ាងតិច ៣ខែ

ច្បាប់ការងារក៏បានកំណត់ដែរថា នៅក្នុងរយៈពេលឲ្យដំណឹងមុននេះ កម្មករនិយោជិត ដែលត្រូវបញ្ឈប់ពីការងារមានសិទ្ធិឈប់សម្រាកពីការងារ ២ថ្ងៃ ក្នុងមួយសប្តាហ៍ ដើម្បីស្វែងរកការងារថ្មី។ ការឈប់សម្រាក ២ថ្ងៃនេះ គឺត្រូវទទួលបានប្រាក់ឈ្នួលពេញជាធម្មតា។

– **និយោជកត្រូវផ្តល់ទៅឲ្យកម្មករនិយោជិត នូវប្រាក់បំណាចបណ្តេញចេញពីការងារ**

ប្រាក់បំណាច់បណ្តេញចេញនេះ ក៏ត្រូវគិតទៅតាមអតីតភាពការងាររបស់និយោជិតដែរ (របៀបគណនាប្រាក់បំណាច់បណ្តេញចេញនេះ មានចែងក្នុងមាត្រា ៨៩) ៖

- ស្មើនឹងប្រាក់ឈ្នួល (បូកនឹងប្រាក់បន្ទាប់បន្សំផ្សេងទៀត) រយៈពេល ៧ថ្ងៃ ចំពោះកម្មករនិយោជិត ដែលមានអតីតភាពការងារក្នុងសហគ្រាស ចាប់ពី ៦ខែ ដល់ ១ឆ្នាំ។

- អតីតភាពការងារចាប់ពី ១ឆ្នាំឡើងទៅ ប្រាក់បំណាច់ត្រូវគណនាស្មើនឹង ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ១៥ថ្ងៃ ក្នុង ១ឆ្នាំការងារ ដោយធ្វើម៉េច បូកបញ្ចូលគ្នាទៅ ប្រាក់បំណាច់បណ្ដេញចេញនេះ មិនត្រូវឲ្យលើស ពី ៦ខែប្រាក់ឈ្នួល។

ប៉ុន្តែ បើសិនជាការបញ្ឈប់ការងារនេះ ធ្វើឡើងដោយសារតែករណីប្រធានស័ក្តិ ឬក៏ដោយសារតែកម្មករនិយោជិត មានកំហុសធ្ងន់ និយោជកមិនចាំបាច់ជូនដំណឹងជាមុនទេ ហើយក៏មិនមានកាតព្វកិច្ចត្រូវបើកប្រាក់បំណាច់បណ្ដេញចេញដែរ។

## ផ្នែកទី៦៤

## ការរក្សាសិទ្ធិ៖ តើអ្នកនិពន្ធស្នាដៃទទួលបានការការពារបែបណាខ្លះ?

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងអំពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា សូមធ្វើការបកស្រាយពន្យល់អំពីសិទ្ធិអ្នកនិពន្ធ។ តើអ្នកនិពន្ធស្នាដៃមួយទទួលបានការការពារបែបណាខ្លះ? តើសាធារណជនជាទូទៅ អាចប្រើប្រាស់ស្នាដៃមួយត្រឹមកម្រិតណា ដែលមិនចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធ?

**១.តើអ្វីទៅជា "សិទ្ធិអ្នកនិពន្ធ"?**

សិទ្ធិអ្នកនិពន្ធ (ការរក្សាសិទ្ធិ) គឺជាមែកជាងមួយ នៃកម្មសិទ្ធិបញ្ញា។

"កម្មសិទ្ធិបញ្ញា" (កម្មសិទ្ធិ + បញ្ញា) គឺជាសិទ្ធិរបស់បុគ្គលណាមួយ (ទោះជារូបវន្តបុគ្គលក៏ដោយ ឬជានីតិបុគ្គលក៏ដោយ) ជាម្ចាស់កម្មសិទ្ធិផ្ដាច់មុខទៅលើស្នាដៃ ឬក៏អ្វីផ្សេងទៀត ដែលជាផលផ្លែ កើតចេញពីគំនិត-បញ្ញារបស់ខ្លួន។ "កម្មសិទ្ធិបញ្ញា" ត្រូវចែកចេញជាពីរផ្នែកធំៗ៖

**-កម្មសិទ្ធិឧស្សាហកម្ម៖** ដូចជា រូបគំនូរឧស្សាហកម្ម សញ្ញាពាណិជ្ជកម្ម ការរកឃើញ ឬការច្នៃប្រឌិតអ្វីមួយ (តក្កកម្ម) ដូចជា ការរកឃើញផលិតផលអ្វីមួយ ឬក៏ដំណើការផលិតកម្មណាមួយ ។ល។ នៅកម្ពុជា សិទ្ធិទាំងនេះ ត្រូវបានការពារដោយច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលសភាអនុម័តកាលពីឆ្នាំ២០០២។

**-សិទ្ធិអ្នកនិពន្ធ៖** គឺសំដៅលើស្នាដៃខាងផ្នែកអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ តូរ្យតន្ត្រី ដែលកើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬដោយមនោសញ្ចេតនា។ ស្នាដៃទាំងអស់នេះទទួលបានការការពារពីច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលសភាអនុម័តកាលពីឆ្នាំ២០០៣។

**២.ដើម្បីឲ្យស្នាដៃមួយទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធ តើត្រូវគោរពតាមលក្ខខណ្ឌអ្វីខ្លះ?**

ដើម្បីឲ្យស្នាដៃមួយអាចទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធ ស្នាដៃនោះត្រូវតែមានទម្រង់ណាមួយជាក់លាក់ មិនមែននៅជាគំនិតអរូបិយ។ គំនិត ដែលស្ថិតនៅជាលក្ខណៈអរូបិយគេមិនអាចការពារបានទេ។ គេការពារបាន លុះត្រាតែគំនិតនោះ ត្រូវបញ្ចេញមកខាងក្រៅក្នុងទ្រង់ទ្រាយណាមួយជាក់លាក់ ដែលតាមច្បាប់ គេឲ្យឈ្មោះថា "ស្នាដៃ" ដូចជា៖

- ការនិពន្ធ៖ សៀវភៅ បទភ្លេង ចម្រៀង ប្រលោមលោក ភាពយន្ត
- ការសម្ដែង៖ ការសម្ដែងរបាំ ឬការប្រគំតន្ត្រី
- ការផ្សាយជាសំឡេង រូបភាព ឬឯកសារនានា តាមវិទ្យុ ឬ ទូរទស្សន៍ ។ល។

យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ គឺស្នាដៃទាំងនេះហើយ ដែលទទួលបានការការពារពីច្បាប់។

លក្ខខណ្ឌទី២ ស្នាដៃ ដែលទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធ ត្រូវតែជាស្នាដៃដើម ពោលគឺជាស្នាដៃដែលបង្កើតឡើងតាមគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធមិនមែនធ្វើតាមគេ។

**៣.ជាឧទាហរណ៍ជាក់ស្ដែង តើស្នាដៃអ្វីខ្លះ ដែលទទួលបានការការពារពីច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ?**

ចំណុចនេះ គឺមានចែងក្នុងមាត្រា ៣ នៃច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ៖

- សៀវភៅអានគ្រប់ប្រភេទ ឬក៏ឯកសារផ្សេងៗទៀត ស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ
- អត្ថបទបឋកថា សង្កថា ឬធម្មទេសនា

- ការតែងទំនុកច្រៀង បទភ្លេង
- ការសម្តែងរបាំ ការសម្តែងសៀក ឬការសម្តែងកាយវិការ
- ស្នាដៃជាផ្ទាំងគំនូរ រូបចម្លាក់ រូបថត ផែនទី ប្លង់ស្ថាបត្យកម្ម
- កម្មវិធីកុំព្យូទ័រ
- ផលិតផលសិប្បកម្ម ដូចជា តម្បាញ ឬក៏ម៉ូដសម្លៀកបំពាក់ ។ល។ និង។ល។

**៤.ស្នាដៃមួយ ដើម្បីទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធ តើគេត្រូវធ្វើការចុះបញ្ជីអ្វីដែរ ឬទេ?**

សិទ្ធិអ្នកនិពន្ធ មិនតម្រូវឲ្យមានការចុះបញ្ជីអ្វីទេ។ ឲ្យតែស្នាដៃនោះ កើតឡើងចេញជាទម្រង់ជាក់លាក់ណាមួយ ហើយជាស្នាដៃដើមរបស់អ្នកនិពន្ធ គឺអាចទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធ។

យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣ ចែងថា ស្នាដៃមួយ ទោះបីពុំទាន់ចប់សព្វគ្រប់ក្តី ឬពុំទាន់បានផ្សព្វផ្សាយជាសាធារណៈក្តី ស្នាដៃនោះ ត្រូវចាត់ទុកថាបានបង្កើតឡើងដោយចំណេះដឹងពិតប្រាកដតែមួយគត់ពីគំនិត ប្រាជ្ញាអ្នកនិពន្ធដែរ ពោលគឺ ត្រូវទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធដែរ។

ដូច្នេះ ចំពោះសិទ្ធិអ្នកនិពន្ធ ច្បាប់មិនតម្រូវឲ្យមានការចុះបញ្ជីអ្វីទេ។ ក៏ប៉ុន្តែ ការយកស្នាដៃទៅចុះបញ្ជី នៅស្ថាប័នមានសមត្ថកិច្ច គឺវាមានប្រយោជន៍ដល់ម្ចាស់ស្នាដៃ ព្រោះថា ការចុះបញ្ជី គឺជាភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិលើស្នាដៃ។

**៥.តើសិទ្ធិអ្វីខ្លះ ដែលត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ?**

យោងតាមច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ ត្រង់មាត្រា ១៨៖ អ្នកនិពន្ធស្នាដៃ គឺជាម្ចាស់កម្មសិទ្ធិផ្តាច់មុខលើស្នាដៃនោះ ហើយជាសិទ្ធិ ដែលជនគ្រប់រូបត្រូវតែទទួលស្គាល់។ សិទ្ធិនេះបែងចែកចេញជាពីរ៖

***សិទ្ធិសីលធម៌***

- សិទ្ធិសម្រេចអំពីទម្រង់ និងពេលវេលានៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ
- សិទ្ធិតម្រូវឲ្យគេដាក់ឈ្មោះ និងឋានៈ សម្រាប់ទាក់ទងជាមួយសាធារណជន
- សិទ្ធិធ្វើការជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកែប្រែខ្លឹមសារ ក្នុងស្នាដៃរបស់ខ្លួន ដែលជាហេតុធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ អ្នកនិពន្ធ

***សិទ្ធិបេតិកភណ្ឌ*** គឺសិទ្ធិប្រកបអាជីវកម្មលើទ្រព្យ ដែលជាស្នាដៃរបស់ខ្លួន តាមរយៈការបោះផ្សាយជាសាធារណៈ ឬក៏តាមរយៈការបង្កើតស្នាដៃបន្ត។ យោងតាមមាត្រា ២១ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខ ធ្វើដោយខ្លួនឯង ឬក៏អនុញ្ញាតឲ្យគេធ្វើបន្ត នូវកិច្ចការដូចតទៅ៖

- ចែកចាយជាសាធារណៈ តាមការលក់ ការជួល ឬតាមមធ្យោបាយផ្សេងទៀតនូវច្បាប់ដើម ឬច្បាប់ចម្លង
- ការបកប្រែជាភាសាបរទេស
- ការយកលំនាំតាម ឬការកែសម្រួលផ្សេងៗទៀត ដូចជា ការយករឿងប្រលោមលោក និពន្ធជាសៀវភៅ ទៅធ្វើជាខ្សែភាពយន្ត
- ការផលិតស្នាដៃឡើងវិញ ដូចជា ការយកសៀវភៅទៅបោះពុម្ពឡើងវិញ ឬក៏យកខ្លឹមសារទៅផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធ័រណិត ។ល។ និង។ល។

សូមបញ្ជាក់ថា ទាំងនេះ គឺជាសិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធ មានន័យថា មានតែអ្នកនិពន្ធទេ ដែលអាចធ្វើការទាំងអស់នេះបាន។ គ្មានអ្នកណាផ្សេងអាចធ្វើបានទេ លុះត្រាតែមានការអនុញ្ញាតពីអ្នកនិពន្ធ។

**៦.តើសិទ្ធិអ្នកនិពន្ធ ទទួលបាននូវការការពារពីច្បាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំ?**

បើនិយាយអំពីសិទ្ធិសីលធម៌ គឺមានលក្ខណៈអចិន្ត្រៃយ៍ (មាត្រា ១៩ ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ)។ បើនិយាយអំពីសិទ្ធិបេតិកភណ្ឌវិញ មានន័យថា សិទ្ធិផ្ដាច់មុខក្នុងការប្រកបអាជីវកម្មលើស្នាដៃ គឺទទួលបានការការពារពេញមួយជីវិតរបស់អ្នកនិពន្ធ បូកថែម ៥០ឆ្នាំ ក្រោយពីអ្នកនិពន្ធទទួលមរណភាពទៀត (មាត្រា ៣០ ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ)។

ផុតពីរយៈពេលនេះទៅ ស្នាដៃត្រូវក្លាយជាសម្បត្តិសាធារណៈ ដែលសាធារណជនទូទៅអាចយកទៅប្រើប្រាស់បាន។

**៧.តើស្នាដៃ ចាំបាច់ត្រូវតែមានដាក់សញ្ញា “©រក្សាសិទ្ធិ” ទើបទទួលបានការការពារសិទ្ធិអ្នកនិពន្ធ ឬយ៉ាងណា?**

តាមច្បាប់នៅប្រទេសខ្លះ គេតម្រូវឲ្យដាក់សញ្ញា “©រក្សាសិទ្ធិ” លើស្នាដៃណាមួយ ទើបអាចទទួលបានការការពារសិទ្ធិអ្នកនិពន្ធ។

ក៏ប៉ុន្តែ តាមច្បាប់ នៅកម្ពុជា ក៏ដូចជា ប្រទេសផ្សេងទៀត ដែលជាហត្ថលេខី នៃអនុសញ្ញាក្រុងប៊ែន (Berne) គេមិនតម្រូវឲ្យមានដាក់សញ្ញា “©រក្សាសិទ្ធិ”ទេ។ បើទោះជាស្នាដៃ ដែលគ្មានដាក់សញ្ញា “©រក្សាសិទ្ធិ” ក៏ទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធដែរ។

ក៏ប៉ុន្តែ សញ្ញា “©រក្សាសិទ្ធ” មានប្រយោជន៍ ក្នុងការជូនដំណឹងដល់សាធារណជនថា ស្នាដៃនេះ ស្ថិតក្រោមការរក្សាសិទ្ធិ។ ប្រសិនបើគ្មានសញ្ញា “©រក្សាសិទ្ធិ” វាអាចចោទជាបញ្ហា នៅពេលមានក្ដីក្ដាំ។ ចុងចោទគេអាចដោះសារថា គេមិនបានដឹង ដោយស្មានថា ស្នាដៃនេះមិនមានរក្សាសិទ្ធិ។ ប្រសិនបើមានដាក់សញ្ញា “©រក្សាសិទ្ធិ” គេមិនអាចដោះសារថាមិនបានដឹងនោះទេ។

**៨.ការចម្លងឡើងវិញនូវស្នាដៃនិពន្ធមួយ ដើម្បីទុកប្រើប្រាស់ផ្ទាល់ខ្លួន ដោយមិនយកទៅធ្វើអាជីវកម្ម តើជាការរំលោភសិទ្ធិអ្នកនិពន្ធដែរ ឬទេ?**

បើតាមច្បាប់ នៅប្រទេសខ្លះ (ដូចជា បារាំង ជាដើម) ការចម្លងស្នាដៃមួយ ដូចជា ចម្លងសៀវភៅជាដើម អាចធ្វើទៅបាន ទាល់តែការចម្លងនេះធ្វើឡើងតែមួយផ្នែកតូចមួយ។ ក៏ប៉ុន្តែ នៅកម្ពុជាវិញ ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ ត្រង់មាត្រា ២៤ ចែងថា ការផលិតឡើងវិញចំនួនមួយច្បាប់ ជាលក្ខណៈឯកជននូវស្នាដៃ ដែលបានបោះពុម្ពរួចហើយ ដើម្បីយកមកប្រើប្រាស់ផ្ទាល់ខ្លួន គឺអាចធ្វើទៅបាន ដោយមិនចាំបាច់មានការអនុញ្ញាតពីអ្នកនិពន្ធឡើយ។

ក៏ប៉ុន្តែ ការចម្លងយកទៅប្រើប្រាស់ផ្ទាល់ខ្លួននេះ មិនអាចធ្វើទៅបានទៅបានទេ ក្នុងករណីមួយចំនួន ដូចជា៖

- ការចម្លងកម្មវិធីកុំព្យូទ័រ
- ការចម្លងប្លង់ស្ថាបត្យកម្ម
- ការចម្លងចេញពីប្រព័ន្ធអ៊ីនធ័រណិត
- ឬការចម្លង ឬការផលិតឡើងវិញ នូវស្នាដៃណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់ការធ្វើអាជីវកម្មជាប្រក្រតីនៃស្នាដៃនោះ ឬធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់អ្នកនិពន្ធ។

**៩.ការដកស្រង់ខ្លឹមសារមួយផ្នែកនៃស្នាដៃមួយ ដើម្បីយកមកផ្សព្វផ្សាយ តើចាំបាច់ត្រូវសុំការអនុញ្ញាតពីអ្នកនិពន្ធដែរ ឬទេ?**

ការដកស្រង់ខ្លឹមសារនេះ អាចធ្វើទៅបាន ដោយមិនចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធទេ យោងទៅតាមមាត្រា ២៥ នៃច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ។ ក៏ប៉ុន្តែ ត្រូវមានលក្ខខណ្ឌពីរ៖

- ជាការដកស្រង់តែមួយផ្នែកខ្លីៗ មិនមែនដកស្រង់ទាំងស្រុង
- ត្រូវមានការបញ្ជាក់យ៉ាងច្បាស់លាស់នូវឈ្មោះរបស់អ្នកនិពន្ធ និងប្រភពនៃស្នាដៃ។

## ផ្នែកទី៦៥

# ដើម្បីទទួលបាននូវការរក្សាសិទ្ធិ តើចាំបាច់ត្រូវដាក់និមិត្តសញ្ញា "©រក្សាសិទ្ធិ" ឬទេ?

ដោយ សេង ឌីណា

នៅក្នុងនាទីយល់ដឹងពីច្បាប់ នៅថ្ងៃនេះ សេង ឌីណា សូមឆ្លើយនឹងសំណួររបស់អ្នកស្តាប់ ជុំវិញនិមិត្តសញ្ញា "©រក្សាសិទ្ធិ"។ តើការដាក់និមិត្តសញ្ញា "©រក្សាសិទ្ធ" ជាលក្ខខណ្ឌចាំបាច់ ដើម្បីទទួលបានការរក្សាសិទ្ធិឬទេ? ហេតុអ្វី?

ជាបឋម គួរបញ្ជាក់ថា នៅក្នុងច្បាប់ខ្មែរ ការរក្សាសិទ្ធិមានចែងនៅក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលអនុម័តឆ្នាំ២០០៣ ហើយច្បាប់នេះមិនបានចែងហាមមិនឲ្យដាក់និមិត្តសញ្ញា "©រក្សាសិទ្ធិ" ទេ ក៏ប៉ុន្តែ ក៏មិនមានចែងតម្រូវថា ចាំបាច់ត្រូវតែដាក់និមិត្តសញ្ញា "©រក្សាសិទ្ធិ" នេះ ទើបទទួលបាននូវការការពារស្របច្បាប់ដែរ។ និយាយសរុបមកវិញ ឲ្យតែស្នាដៃនិពន្ធណាមួយបំពេញទៅតាមលក្ខខណ្ឌដែលច្បាប់តម្រូវ ទោះបីជាមាននិមិត្តសញ្ញា "©រក្សាសិទ្ធិ" ឬគ្មាន ក៏នៅតែទទួលបាននូវការការពារពីច្បាប់រក្សាសិទ្ធិដូចគ្នាទាំងអស់។

ហេតុអ្វីបានជាច្បាប់ចែងថា មិនបាច់ដាក់និមិត្តសញ្ញា "©រក្សាសិទ្ធិ" ក៏បានបែបនេះ? ការចែងបែបនេះ គឺដើម្បីកំណត់ឲ្យបានច្បាស់ថា ការរក្សាសិទ្ធិ គឺជាសិទ្ធិស្វ័យប្រវត្តិ មានន័យថា រាល់ស្នាដៃទាំងអស់ត្រូវតែទទួលបាននូវការការពារពីច្បាប់ ដោយមិនចាំបាច់ត្រូវបំពេញបែបបទអ្វី ឬត្រូវចុះបញ្ជីអ្វីទាំងអស់ (មាត្រា ៣៨ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល)។

តាមពិតកាលពីមុនច្បាប់នៅប្រទេសមួយចំនួន ជាពិសេស សហរដ្ឋអាមេរិក មានចែងតម្រូវជាចាំបាច់ថា ទាល់តែមានដាក់និមិត្តសញ្ញា "©រក្សាសិទ្ធិ" ហើយមានការចុះបញ្ជីត្រឹមត្រូវ ទើបស្នាដៃមួយអាចទទួលបាននូវការការរក្សាសិទ្ធិបាន។ ក៏ប៉ុន្តែ ក្រោយមកអនុសញ្ញាអន្តរជាតិសំខាន់ៗមួយចំនួន ដូចជា អនុសញ្ញាក្រុងប៊ែន (Berne Convention 1886) និងក្នុងកិច្ចព្រមព្រៀងស្តីពីកម្មសិទ្ធិបញ្ញារបស់អង្គការពាណិជ្ជកម្មពិភពលោក (Agreement on Trade Related Aspects of Intellectual Property Rights 1994 ហៅកាត់ថា TRIPS) បានកំណត់ថា ការរក្សាសិទ្ធិត្រូវតែជាសិទ្ធិស្វ័យប្រវត្តិ ហើយប្រទេសជាហត្ថលេខីទាំងអស់ ត្រូវតែសម្របច្បាប់ជាតិរបស់ខ្លួន ឲ្យត្រូវនឹងគោលការណ៍នេះ ដោយមិនត្រូវចែងតម្រូវថា ទាល់តែបំពេញបែបបទចុះបញ្ជី ឬត្រូវដាក់និមិត្តសញ្ញា ទើបទទួលបានការរក្សាសិទ្ធិទេ។

កម្ពុជា គឺជាប្រទេសហត្ថលេខី នៃកិច្ចព្រមព្រៀងស្តីពីកម្មសិទ្ធិបញ្ញារបស់អង្គការពាណិជ្ជកម្មពិភពលោក ដូច្នេះ ហើយបានជាច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ចែងថា *"រាល់ស្នាដៃទាំងអស់ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ជាស្វ័យប្រវត្តិ"* ដោយគ្រាន់តែត្រូវបំពេញតាមលក្ខខណ្ឌចាំបាច់តែ ២ប៉ុណ្ណោះ។

លក្ខខណ្ឌទីមួយ ស្នាដៃនោះត្រូវតែមានទម្រង់ណាមួយជាក់លាក់ មិនមែនគ្រាន់តែជាគំនិតអរូបិយ ឬគ្រាន់តែជាការស្រមើស្រមៃ។ តាមមាត្រា ៣ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ទម្រង់ជាក់លាក់នៃស្នាដៃ ដែលត្រូវទទួលបាននូវការការពារពីច្បាប់ គឺអាចជា ៖

- ការនិពន្ធ៖ សៀវភៅ បទភ្លេង ចម្រៀង ប្រលោមលោក ភាពយន្ត
- ការសម្តែង៖ ការសម្តែងរបាំ ឬការប្រគំតន្ត្រី
- ការផ្សាយជាសំឡេង រូបភាព ឬឯកសារនានា តាមវិទ្យុ ឬ ទូរទស្សន៍ ។ល។

លក្ខខណ្ឌទី២ ស្នាដៃ ដែលទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធ ត្រូវតែជាស្នាដៃដើម ពោលគឺជាស្នាដៃដែលបង្កើតឡើងតាមគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធមិនមែនធ្វើតាមគេ (មាត្រា ៤ នៃច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល)។

សរុបមកវិញ រាល់ស្នាដៃទាំងឡាយណាដែលមានទម្រង់ជាក់លាក់ ហើយជាស្នាដៃដើម ដោយមិនចម្លងពីគេត្រូវទទួលបាននូវការការរក្សាសិទ្ធិដោយស្វ័យប្រវត្តិ ដោយមិនតម្រូវឲ្យមានការចុះបញ្ជី ឬដាក់និមិត្តសញ្ញា “©រក្សាសិទ្ធិ” នោះទេ។

អ្នកនិពន្ធ ឬក៏ម្ចាស់សិទ្ធិ បើសិនជាចង់ធ្វើអាចសុំចុះបញ្ជី ដើម្បីតម្កល់ស្នាដៃរបស់ខ្លួនទុកនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬដាក់និមិត្តសញ្ញា “©រក្សាសិទ្ធិ” សម្គាល់ស្នាដៃរបស់ខ្លួនឯងបាន។ ប៉ុន្តែ នេះជាសិទ្ធិ មិនមែនជាកាតព្វកិច្ចត្រូវតែបំពេញនោះទេ។

គួរបញ្ជាក់បន្ថែមថា អ្វីដែលបានរៀបរាប់ខាងលើនេះ (សិទ្ធិស្វ័យប្រវត្តិ) ទាក់ទងតែនឹងការរក្សាសិទ្ធិ (សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល) ប៉ុណ្ណោះ។ ចំពោះកម្មសិទ្ធិឧស្សាហកម្មវិញ ដូចជា ការរកឃើញ ឬការច្នៃប្រឌិត ដែលតាមភាសាច្បាប់ហៅថា “តក្កកម្ម” (ជាភាសាបារាំង Brevet), រូបគំនូរឧស្សាហកម្ម និងសញ្ញាពាណិជ្ជកម្ម ជាដើម ចាំបាច់ត្រូវតែមានការចុះបញ្ជី ដើម្បីទទួលបាននូវវិញ្ញាបនបត្រសម្គាល់ ទើបអាចទទួលបាននូវការការពារពីច្បាប់ដោយពេញលេញបាន។

តាមច្បាប់ ស្ដីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម (អនុម័តឆ្នាំ ២០០២) ការចុះបញ្ជីសុំប្រកាសនីយបត្រតក្កកម្ម (ឬ Brevet) ត្រូវធ្វើនៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ដែលស្ថិតនៅក្រោមក្រសួងឧស្សាហកម្ម។ ប្រកាសនីយបត្រនេះមានសុពលភាព ២០ឆ្នាំ គិតពីថ្ងៃចុះបញ្ជី ហើយដើម្បីរក្សាសុពលភាពនេះ ម្ចាស់តក្កកម្មត្រូវបង់កម្រៃប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំ។

ចំពោះការរក្សាសិទ្ធិ បើទោះបីជាច្បាប់មិនតម្រូវឲ្យដាក់និមិត្តសញ្ញា “©រក្សាសិទ្ធិ” ក៏ដោយ ក៏ប៉ុន្តែ សម្រាប់ម្ចាស់ស្នាដៃ ការដាក់និមិត្តសញ្ញា “©រក្សាសិទ្ធិ” មានប្រយោជន៍ ក្នុងការជូនដំណឹងដល់សាធារណជនថា ស្នាដៃនេះ ស្ថិតក្រោមការរក្សាសិទ្ធិ ពីព្រោះ មានស្នាដៃខ្លះមិនស្ថិតក្រោមការរក្សាសិទ្ធិ ឬក៏ផុតរយៈពេលរក្សាសិទ្ធិ។ ដូច្នេះ ប្រសិនបើមិនមានដាក់និមិត្តសញ្ញា “©រក្សាសិទ្ធិ” នៅពេលមានវិវាទ ចុងចោទអាចយកចំណុចនេះមកឆ្លើយដោះសារការពារខ្លួនថា ដោយសារមិនឃើញមាននិមិត្តសញ្ញា “©រក្សាសិទ្ធិ” គេក៏ស្មានថា ស្នាដៃនេះមិនមានរក្សាសិទ្ធិ ឬក៏ផុតរយៈពេលរក្សាសិទ្ធិ។ ដូច្នេះ បើសិនជាមានដាក់និមិត្តសញ្ញា “©រក្សាសិទ្ធិ” ច្បាស់លាស់ គេមិនអាចដោះសារថាមិនបានដឹងបានទេ។

ចំពោះការចុះបញ្ជីវិញក៏ដូចគ្នាដែរ បើទោះជាច្បាប់មិនតម្រូវឲ្យធ្វើក៏ដោយ ការយកស្នាដៃទៅចុះបញ្ជីតម្កល់នៅស្ថាប័នមានសមត្ថកិច្ច វាមានប្រយោជន៍សម្រាប់ទុកជាភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិលើស្នាដៃ។

ដើម្បីស្វែងយល់បន្ថែមពីកម្មសិទ្ធបញ្ញា សូមអានឯកសារដែលចុះផ្សាយនៅលើវិបសៃត៍របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។

# ផ្នែកទី៦៦

# វិសាលភាពនៃដែនអនុវត្តក្រមព្រហ្មទណ្ឌខ្មែរ

ដោយ សេង ឌីណា

ក្រមព្រហ្មទណ្ឌខ្មែរ ត្រូវបានចាប់ផ្តើមអនុវត្តនៅទូទាំងប្រទេសកាលពីថ្ងៃខែធ្នូ ២០១០។ តើក្រមព្រហ្មទណ្ឌថ្មីនេះអាចត្រូវអនុវត្តចំពោះអំពើល្មើស ដែលបានប្រព្រឹត្តចាប់ពីពេលណា? តើមានវិសាលភាពនៃដែនអនុវត្តក្រមនេះគ្របដណ្តប់ចំពោះអំពើល្មើស ដែលប្រព្រឹត្តឡើងនៅកន្លែងណាខ្លះ? ខាងក្រោមនេះ គឺជាសំណួរ-ចម្លើយទាក់ទងនឹងដែនអនុវត្តនៃក្រមព្រហ្មទណ្ឌថ្មីរបស់ព្រះរាជាណាចក្រកម្ពុជា។

**១.ក្រមព្រហ្មទណ្ឌត្រូវបានព្រះមហាក្សត្រឡាយ ព្រះហស្តលេខាប្រកាសឲ្យប្រើតាំងពីថ្ងៃទី៣០ វិច្ឆិកា ២០០៩ម្ល៉េះ។ ហេតុអ្វីទើបនឹងចាប់ផ្តើមអនុវត្តនៅពេលនេះ?**

ក្រមព្រហ្មទណ្ឌថ្មីរបស់កម្ពុជា បានចូលជាធរមានតាំងពីមួយឆ្នាំកន្លងទៅហើយ ក៏ប៉ុន្តែ ក្រមនេះនៅមិនទាន់អាចយកទៅអនុវត្តបាន ដោយហេតុថា នៅមាត្រាចុងក្រោយ (មាត្រា ៦៧២) ចែងថា “*លើកលែងតែបទប្បញ្ញត្តិទូទៅ ដែលត្រូវយកមកអនុវត្តភ្លាម បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ*”។

ក្រោយពីបានចុះផ្សាយនៅក្នុងរាជកិច្ច ក្រមព្រហ្មទណ្ឌថ្មីត្រូវចូលជាធរមាន នៅភ្នំពេញ នៅថ្ងៃទី១១ ធ្នូ ២០០៩ និងនៅតាមបណ្តាខេត្ត-ក្រុងផ្សេងទៀត នៅថ្ងៃទី២១ ធ្នូ ២០០៩ (១០ថ្ងៃក្រោយពីចូលជាធរមាននៅភ្នំពេញ)។ ១ឆ្នាំក្រោយពីចូលជាធរមាន ទើបក្រមថ្មីនេះចាប់ផ្តើមអនុវត្ត នៅខែធ្នូ ២០១០នេះ។

**២.តើក្រមព្រហ្មទណ្ឌថ្មីនេះអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តចាប់ពីពេលណា?**

ក្រមព្រហ្មទណ្ឌថ្មីអាចអនុវត្តបានតែចំពោះបទល្មើសណា ដែលប្រព្រឹត្តក្រោយក្រមនេះចាប់ផ្តើមអនុវត្តតែប៉ុណ្ណោះ (១១ ធ្នូ ២០១០ នៅភ្នំពេញ និង ២១ ធ្នូ ២០១០ នៅតាមបណ្តាខេត្ត-ក្រុងផ្សេងទៀត) ។ នេះគឺជាគោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌ ដែលជាគោលការណ៍មានតម្លៃជាសកល។

នៅក្នុងក្រមព្រហ្មទណ្ឌខ្មែរ នៅត្រង់មាត្រា ៣ ចែងថា “*មានតែអំពើ ដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន*”។

ដូច្នេះ អំពើដែលប្រព្រឹត្តនៅមុនពេលក្រមព្រហ្មទណ្ឌត្រូវចាប់អនុវត្ត មិនត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌទេ។ ជនល្មើសក៏មិនអាចត្រូវយកមកផ្តន្ទាទោសព្រហ្មទណ្ឌបានដែរ លើកលែងតែក្នុងករណីអំពើល្មើសមានចែងនៅក្នុងច្បាប់ចាស់រួចហើយ ដូចជា បទមនុស្សឃាត បទលួច ប្លន់ ឆបោក ជាដើម ដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល (ច្បាប់អ៊ុនតាក់)។ ក្នុងករណីនេះ ជនល្មើសអាចត្រូវយកមកផ្តន្ទាទោសបាន តាមអំណាចច្បាប់ចាស់។

**៣.តើក្រមព្រហ្មទណ្ឌថ្មីនេះអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅកន្លែងណាខ្លះ?**

ចម្លើយ៖ មាត្រា ១២ នៃក្រមព្រហ្មទណ្ឌថ្មីចែងថា៖ “*ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ*”។

ដូច្នេះ ឲ្យតែអំពើល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីខ្មែរ ទោះបីជាជនល្មើសនោះមានសញ្ជាតិអ្វីក៏ដោយ ក៏ត្រូវយកក្រមព្រហ្មទណ្ឌខ្មែរទៅអនុវត្តបានដែរ។

អំពើល្មើស ដែលប្រព្រឹត្តនៅលើនាវា ឬយន្តហោះ ដែលចុះបញ្ជីនៅកម្ពុជា គឺត្រូវចាត់ទុកថាបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីនាវា ឬយន្តហោះនោះ ស្ថិតនៅក្រៅទឹកដីកម្ពុជាក៏ដោយ (មាត្រា ១៤ និង មាត្រា ១៦)។

**៤. ចុះបើអំពើល្មើសត្រូវបានប្រព្រឹត្តនៅក្រៅទឹកដីកម្ពុជា ក្រៅនាវាកម្ពុជា ហើយក្រៅយន្តហោះកម្ពុជាទៀត តើក្រមព្រហ្មទណ្ឌខ្មែរអាចអនុវត្តបានដែរ ឬទេ?**

ក្រមព្រហ្មទណ្ឌខ្មែរអាចអនុវត្តបាន ចំពោះបទល្មើស ដែលប្រព្រឹត្តនៅបរទេស ប្រសិនបើជនល្មើស ឬជនរងគ្រោះមានសញ្ជាតិខ្មែរ។

- **បទល្មើសដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ (មាត្រា ១៩)**

បទល្មើសដែលប្រព្រឹត្តនៅបរទេសដោយពលរដ្ឋខ្មែរ អាចយកច្បាប់ព្រហ្មទណ្ឌខ្មែរទៅអនុវត្តបាន តែចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមប៉ុណ្ណោះ។ ចំពោះបទលហុ គឺមិនអាចយកទៅអនុវត្តបានទេ។ ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម បទប្បញ្ញត្តិត្រូវបែងចែកជាពីរករណី៖

១. បើសិនជាបទល្មើសនោះ ជាបទឧក្រិដ្ឋ ក្រមព្រហ្មទណ្ឌខ្មែរត្រូវយកទៅអនុវត្ត ទោះជាបទឧក្រិដ្ឋនោះមានចែង ឬគ្មានចែង ក្នុងច្បាប់របស់ប្រទេស ដែលជាទីកន្លែងប្រព្រឹត្តបទល្មើសក៏ដោយ។

២. ផ្ទុយទៅវិញ ប្រសិនបើបទល្មើសនោះ ជាបទមជ្ឈិម ទាល់តែបទមជ្ឈិមនោះ មានចែងនៅក្នុងច្បាប់របស់ប្រទេស ដែលជាកន្លែងប្រព្រឹត្តបទល្មើស ទើបគេអាចយកក្រមព្រហ្មទណ្ឌខ្មែរទៅអនុវត្តបាន។

បទល្មើសខ្លះ ដូចជា "បទស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ" ជាដើម គឺជាបទមជ្ឈិម ក្នុងក្រមព្រហ្មទណ្ឌខ្មែរ ត្រង់មាត្រា ៥០៨។ ក៏ប៉ុន្តែ ក្នុងប្រទេសខ្លះទៀត ដែលមិនកាន់ពុទ្ធសាសនា បទល្មើសបែបនេះមិនមានចែងក្នុងច្បាប់ទេ។ ដូច្នេះ ច្បាប់ព្រហ្មទណ្ឌខ្មែរមិនអាចយកទៅអនុវត្តបានទេ ចំពោះបទល្មើស ដែលប្រព្រឹត្តក្នុងប្រទេសនោះ បើទោះជាជនល្មើសមានសញ្ជាតិខ្មែរក៏ដោយ។

គួរបញ្ជាក់បន្ថែមថា ចំពោះករណីទាំងពីរខាងលើ (បទឧក្រិដ្ឋ និងបទមជ្ឈិម) ច្បាប់ព្រហ្មទណ្ឌខ្មែរនៅតែអាចយកទៅអនុវត្តបាន ទោះបីជាជនល្មើសទទួលបានសញ្ជាតិខ្មែរ ក្រោយពេលប្រព្រឹត្តបទល្មើសក៏ដោយ។ ឧបមាថា ជនបរទេសម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋ នៅក្រៅទឹកដីកម្ពុជា។ ក្រោយមកជនល្មើសនេះ ទទួលបានសញ្ជាតិខ្មែរ។ ក្នុងករណីនេះ ជនល្មើស អាចត្រូវតុលាការកម្ពុជាយកមកកាត់ទោសតាមច្បាប់ព្រហ្មទណ្ឌខ្មែរ បាន។

- **បទល្មើសដែលប្រព្រឹត្តទៅលើពលរដ្ឋខ្មែរ (មាត្រា ២០)**

ច្បាប់ព្រហ្មទណ្ឌខ្មែរអាចអនុវត្តបានទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តនៅបរទេស បើសិនជាជនរងគ្រោះមានសញ្ជាតិខ្មែរ បើទោះជាជនល្មើសជាពលរដ្ឋខ្មែរ ឬក៏ជាពលរដ្ឋបរទេសក៏ដោយ។

តាមរយៈមាត្រានេះ យើងអាចសន្និដ្ឋានបានថា ចំពោះបទល្មើស ដែលប្រព្រឹត្តទៅលើពលរដ្ឋខ្មែរ ច្បាប់ព្រហ្មទណ្ឌខ្មែរអាចយកទៅអនុវត្តបាន តែចំពោះបទឧក្រិដ្ឋប៉ុណ្ណោះ មិនអាចយកទៅអនុវត្តចំពោះបទមជ្ឈិមបានទេ (ខុសពីច្បាប់បារាំងដែលក្រមព្រហ្មទណ្ឌអាចយកទៅអនុវត្តបានចំពោះបទមជ្ឈិម ប្រព្រឹត្តនៅបរទេស ទៅលើពលរដ្ឋបារាំង)។

- **សមត្ថកិច្ចដោយឡែក ចំពោះបទឧក្រិដ្ឋដោយឡែក (មាត្រា ២២)**

ក្រៅពីបទល្មើសពាក់ព័ន្ធនឹងពលរដ្ឋខ្មែរ ច្បាប់ព្រហ្មទណ្ឌខ្មែរអាចយកទៅអនុវត្តបាន ចំពោះបទល្មើសផ្សេងទៀតដែលប្រព្រឹត្តនៅបរទេស បើទោះជាជនល្មើស ឬជនរងគ្រោះមិនមែនជាពលរដ្ឋខ្មែរក៏ដោយ។ បទល្មើសពិសេសទាំងនេះរួមមាន៖

- បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅកម្ពុជា
- បទល្មើសប្រឆាំងនឹងទីតាំង ឬភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

**៥.តើបទឧក្រិដ្ឋ និងបទមជ្ឈិមខុសគ្នាត្រង់ណាខ្លះ?**

ក្រមព្រហ្មទណ្ឌថ្មី បែងចែកបទល្មើសជា ៣ប្រភេទ ទៅតាមកម្រិតទោស ៖

– **បទឧក្រិដ្ឋ (មាត្រា ៤៦)**

បទល្មើសមួយ ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ប្រសិនបើបទល្មើសនោះអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី៥ឆ្នាំ ឬដាក់ពន្ធនាគារអស់មួយជីវិត។ ឧទាហរណ៍៖ បទឃាតកម្មគិតទុកជាមុន បទឃាតកម្មដោយចេតនា បទរំលោភសេពសន្ថវៈ បទលួចដោយហិង្សា (ប្លន់) ។ល។

– **បទមជ្ឈិម (មាត្រា ៤៧)**

បទល្មើសមួយ ត្រូវចាត់ទុកជាបទមជ្ឈិម ប្រសិនបើកម្រិតទោសជាប់ពន្ធនាគារអតិបរមាមានលើសពី៦ថ្ងៃ រហូតដល់៥ឆ្នាំ។ ឧទាហរណ៍៖ បទមនុស្សឃាតដោយអចេតនា, បទលួច, បទឆបោក, បទបង្ករបួសស្នាមដោយអចេតនា ។ល។

– **បទលហុ (មាត្រា ៤៨)**

បទល្មើសមួយ ត្រូវចាត់ទុកជាបទលហុ ប្រសិនបើកម្រិតទោសជាប់ពន្ធនាគារអតិបរមា រយៈពេលស្មើ ឬតិចជាង ៦ថ្ងៃ ឬក៏ជាបទល្មើស ដែលមិនមានទោសជាប់ពន្ធនាគារសោះ គឺមានតែទោសពិន័យជាប្រាក់។ ឧទាហរណ៍៖ បទបរិហារកេរ្តិ៍ បទជេរប្រមាថជាសាធារណៈ បទស្រវឹងជាក់ស្តែងនៅទីសាធារណៈ ។ល។

# ផ្នែកទី៦៧

## ក្រមព្រហ្មទណ្ឌខ្មែរ៖ ប្រភេទនៃទោសព្រហ្មទណ្ឌ និងការអនុវត្ត

ដោយ សេង ឌីណា

តាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើសព្រហ្មទណ្ឌ អំពើណាមួយដែលអាចជាបទល្មើស លុះត្រាតែអំពើនោះមានចែងក្នុងច្បាប់ជាធរមាន។ ទោស ដែលអាចប្រកាសបាន ក៏ទាល់តែមានចែងក្នុងច្បាប់ដែរ។ ហេតុដូច្នេះហើយបានជានៅក្នុងក្រមព្រហ្មទណ្ឌខ្មែរ (២០០៩) សម្រាប់រាល់បទល្មើសទាំងអស់ គឺតែងតែមានចែងអំពីនិយមន័យ និងធាតុផ្សំនៃបទល្មើស និងអំពីទោស ដែលត្រូវអនុវត្តចំពោះអំពើល្មើសនោះ។ ខាងក្រោមនេះ គឺជាសំណួរ-ចម្លើយ ស្តីអំពីប្រភេទនៃទោស និងការអនុវត្តទោសនៅក្នុងក្រមព្រហ្មទណ្ឌខ្មែរ។

**១.តើប្រភេទទោសអ្វីខ្លះ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌខ្មែរ?**

បើយើងនិយាយដោយសង្ខេប ទោសព្រហ្មទណ្ឌ ត្រូវបានបែងចែកជាពីរប្រភេទធំៗ៖ មូលទោស និងទោសបន្ថែម។

មូលទោស (មាត្រា ៤៣) គឺរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ នៅក្នុងបទល្មើសខ្លះ ជាពិសេស បទឧក្រិដ្ឋភាគច្រើន គឺមានតែទោសដាក់ពន្ធនាគារប៉ុណ្ណោះ ដោយមិនមានទោសពិន័យជាប្រាក់ទេ។ បទល្មើសខ្លះទៀត ជាពិសេស បទលហុភាគច្រើន គឺមានតែទោសពិន័យជាប្រាក់ ហើយមិនមានទោសដាក់ពន្ធនាគារទេ។ ចំណែកបទល្មើសខ្លះទៀត ជាពិសេស គឺបទមជ្ឈិម គឺមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

**២.តើទោសពិន័យជាប្រាក់ និងសំណងជំងឺចិត្តខុសគ្នាយ៉ាងដូចម្តេច?**

ទោសពិន័យជាប្រាក់ គឺជាទោសព្រហ្មទណ្ឌ។ ដូច្នេះ ទាល់តែមានច្បាប់ចែងថា បទល្មើសណា ដែលត្រូវពិន័យជាប្រាក់ទើបចៅក្រមអាចប្រកាសទោសពិន័យជាប្រាក់បាន។ ប្រាក់ដែលពិន័យ គឺត្រូវបង់ទៅឲ្យរដ្ឋ។

ចំណែកសំណងជំងឺចិត្តវិញ គឺជាទោសរដ្ឋប្បវេណី ហើយមិនចាំបាច់ត្រូវតែមានចែងក្នុងក្រមព្រហ្មទណ្ឌទេ។ ចៅក្រមអាចប្រកាសទោសសំណងជំងឺចិត្តបាន គឺទាល់តែមានការទាមទារពីដើមបណ្តឹងរដ្ឋប្បវេណី ហើយទាល់តែដើមបណ្តឹងរដ្ឋប្បវេណីនេះពិតជាបានទទួលរងព្យសនកម្ម (ការខូចខាត) បង្កឡើងដោយទង្វើរបស់ជនល្មើសមែន។ សំណងជំងឺចិត្ត គឺត្រូវបង់ទៅឲ្យជនរងគ្រោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ហើយចំនួនទឹកប្រាក់ គឺត្រូវសមាមាត្រទៅនឹងព្យសនកម្ម។

ឧទាហរណ៍៖ក្នុងករណី បង្ករបួសស្នាមដោយចេតនា (ក្នុងក្រមព្រហ្មទណ្ឌថ្មី ត្រង់មាត្រា ២១៧ គេឲ្យឈ្មោះថា "បទហិង្សាដោយចេតនា") បើសិនជាចៅក្រមរកឃើញថាមានទោសមែន ជនល្មើសអាចត្រូវទទួលទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ ពី២លាន ទៅ៦លានរៀល។ ២លាន ទៅ៦លានរៀលនេះ គឺជាទោសព្រហ្មទណ្ឌ ដែលត្រូវបង់ទៅឲ្យរដ្ឋ។ ទោះបីមាន ឬក៏គ្មានដើមបណ្តឹងរដ្ឋប្បវេណី ក៏ជនល្មើសត្រូវតែបង់ដែរ។

ក៏ប៉ុន្តែ ការបង្ករបួសស្នាម គឺបង្កទៅលើអ្នកដទៃ។ ដូច្នេះ តែងតែមានជនរងគ្រោះ។ បើសិនជាជនរងគ្រោះទាមទារសំណងជម្ងឺចិត្ត ចៅក្រមអាចសម្រេចឲ្យជនល្មើសបង់សំណងជំងឺចិត្តទៅជនរងគ្រោះ បន្ថែមពីលើលុយពិន័យ ដែលត្រូវបង់ទៅឲ្យរដ្ឋ។

**៣.នៅក្នុងបទល្មើសខ្លះ យើងឃើញមានចែងកំណត់ទោសថា ត្រូវដាក់ពន្ធនាគារពីប៉ុណ្ណោះឆ្នាំ ដល់ប៉ុណ្ណោះឆ្នាំ ឬត្រូវពិន័យជាប្រាក់ពីប៉ុណ្ណោះរៀល ទៅប៉ុណ្ណោះរៀល។ តើនេះមានន័យដូចម្តេច?**

មានន័យថា ច្បាប់កំណត់តែកម្រិតអប្បរមា និងអតិបរមានៃទោសប៉ុណ្ណោះ។ ចំណែកឯការប្រកាសទោសជាក់ស្តែង គឺត្រូវទុកឲ្យចៅក្រមជាអ្នកសម្រេច ដោយយោងទៅលើករណីជាក់ស្តែងនីមួយៗ ដែលអាចខុសគ្នា អាស្រ័យទៅតាមបុគ្គលិក

លក្ខណៈរបស់ជនល្មើស និងកាលៈទេសៈនៃការប្រព្រឹត្តអំពើល្មើស។ ក៏ប៉ុន្តែ ទោស ដែលប្រកាសដោយចៅក្រម មិនអាចទាបជាងកម្រិតអប្បបរមា ឬខ្ពស់ជាងកម្រិតអតិបរមា ដែលកំណត់ដោយក្រមព្រហ្មទណ្ឌនោះទេ លើកលែងតែក្នុងករណីពិសេស ដែលមានស្ថានសម្រាលទោស ឬស្ថានទម្ងន់ទោស ដែលមានចែងច្បាស់លាស់ក្នុងក្រមព្រហ្មទណ្ឌនេះស្រាប់។ ឧទាហរណ៍ ដូចជា ក្នុងករណីជនល្មើសជាអនីតិជនជាដើម ដែលច្បាប់តម្រូវឲ្យបន្ថយទោសពាក់កណ្ដាល។

**៤.តើទោសបន្ថែមមានអ្វីខ្លះ? តើក្នុងករណីណាខ្លះ ដែលចៅក្រមអាចប្រកាសទោសបន្ថែមបាន?**

ទោសបន្ថែមអាចមានច្រើនប្រភេទ ដែលមានចែងក្នុងមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ។ បទប្បញ្ញត្តិដោយឡែកផ្សេងទៀត ក៏អាចបង្កើតទោសបន្ថែមផ្សេងៗទៀតបានដែរ។

និយាយដោយត្រួសៗ ទោសបន្ថែម គឺអាចជា៖

- ការដកសិទ្ធិពលរដ្ឋខ្លះ ដូចជា ការដកសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត សិទ្ធិបំពេញការងារជាមន្ត្រីរាជការជាដើម
- ការរឹបអូសឧបករណ៍ ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬការរឹបអូសទ្រព្យសម្បត្តិ ដែលបានមកពីការប្រព្រឹត្តបទល្មើស
- ការហាមឃាត់មិនឲ្យចាកចេញពីប្រទេសកម្ពុជា ឬការហាមឃាត់មិនឲ្យចូលមកក្នុងប្រទេសកម្ពុជា (បើជនល្មើសជាជនបរទេស)
- ការផ្សាយសេចក្តីសម្រេចទោស នៅតាមបណ្តាញសារព័ត៌មាន ។ល។

ទោសបន្ថែម គឺជាទោស ដែលចៅក្រមអាចប្រកាសដាក់បន្ថែមពីលើមូលទោស (ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់)។ ចៅក្រមអាចប្រកាសទោសបន្ថែមបាន លុះត្រាតែទោសនោះត្រូវបានចែងច្បាស់លាស់ក្នុងច្បាប់ ចំពោះបទល្មើស ដែលត្រូវចោទប្រកាន់។

ទោសបន្ថែម ចៅក្រមអាចប្រកាសក៏បាន មិនប្រកាសក៏បានដែរ លើកលែងតែក្នុងករណីខ្លះ ដែលច្បាប់ចែងច្បាស់លាស់ថា ត្រូវតែប្រកាសទោសបន្ថែម ទើបចៅក្រមមានកាតព្វកិច្ចត្រូវតែប្រកាសទោសបន្ថែម។

**៥.ក្នុងករណីខ្លះ តុលាការសម្រេចព្យួរទោស។ តើការព្យួរទោសមានន័យដូចម្តេច?**

ការព្យួរទោស (មាត្រា ១០៤ ដល់ ១៣៥) មានន័យថា ជនល្មើស គឺពិតជាមានពិរុទ្ធភាព ហើយចៅក្រមបានប្រកាសផ្តន្ទាទោស ក៏ប៉ុន្តែ ទោសនេះមិនត្រូវយកទៅអនុវត្តទេ។

ឧទាហរណ៍៖ ក្នុងករណីបទហិង្សាដោយចេតនា ចៅក្រមប្រកាសថា ជនល្មើសពិតជាមានទោស ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល១ឆ្នាំ និងពិន័យជាប្រាក់ ២លានរៀល។ ប្រសិនបើចៅក្រមសម្រេចព្យួរទោសនេះ មានន័យថា ពិរុទ្ធជនមិនត្រូវជាប់ពន្ធនាគារទេ គឺអាចមានសេរីភាពធម្មតា។ លុយពិន័យក៏អាចត្រូវព្យួរដោយមិនបាច់បង់ដែរ។ ក៏ប៉ុន្តែ ការព្យួរទោស គឺមានសុពលភាពតែទៅលើទោសព្រហ្មទណ្ឌប៉ុណ្ណោះ។ បើសិនជាត្រូវមានសំណងជំងឺចិត្ត ដែលត្រូវបង់ទៅឲ្យជនរងគ្រោះ ជនល្មើសត្រូវតែបង់ ទោះបីជាត្រូវព្យួរទោសក៏ដោយ។

ក្នុងពេលព្យួរទោស បើសិនជាទណ្ឌិតមានប្រព្រឹត្តបទល្មើសអ្វីណាមួយផ្សេងទៀត ការព្យួរទោសនឹងត្រូវបញ្ចប់ ហើយទោសនឹងត្រូវចាប់អនុវត្តទាំងស្រុង។ ម្យ៉ាងទៀត ទោសដែលត្រូវព្យួរ ក្នុងបទល្មើសមុន មិនត្រូវយកមកលាយឡំគ្នា ជាមួយទោសបទល្មើសក្រោយនេះទេ ព្រោះជាបទល្មើសពីរដាច់ពីគ្នា ដូច្នេះ ជាទោសពីរដាច់ពីគ្នា។ ទោសបទល្មើសមុន ចៅក្រម

សម្រេចរួចហើយ គ្រាន់តែមិនទាន់អនុវត្ត ដូច្នេះ ត្រូវយកមកអនុវត្ត។ ចំណែកបទល្មើសក្រោយ គឺអាចមានទោសផ្សេងទៅតាមការសម្រេចរបស់ចៅក្រម។

ការព្យួរទោសអាចជាការព្យួរទោសទាំងអស់ ឬក៏ព្យួរមួយផ្នែក។ ឧទាហរណ៍ ត្រូវជាប់ពន្ធនាគារ ១ឆ្នាំ ប៉ុន្តែ ព្យួរ ៩ខែ ហើយ ៣ខែទៀតត្រូវអនុវត្តជម្មតា។

អាចជាការព្យួរទោសធម្មតា ឬក៏ជាការព្យួរទោសសាកល្បង។ បើជាការព្យួរទោសធម្មតា ពិរុទ្ធជន គឺអាចរស់នៅក្រៅឃុំ ដោយមានសេរីភាពធម្មតា។ បើសិនជាការព្យួទោសសាកល្បង ជនល្មើសអាចស្ថិតនៅក្រៅពន្ធនាគារដែរ ប៉ុន្តែ ត្រូវស្ថិតក្រោមវិធានការត្រួតពិនិត្យ និងត្រូវគោរពនូវកាតព្វកិច្ចដោយឡែកណាមួយ ទៅតាមការកំណត់របស់ចៅក្រម នៅក្នុងរយៈពេលសាកល្បង ដូចជា៖

- ត្រូវមកបង្ហាញខ្លួន នៅពេលដែលមានដីកាកោះរបស់ព្រះរាជអាជ្ញា
- ត្រូវជូនដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋាន ឬផ្លាស់ប្តូរមុខរបរ
- ត្រូវសុំការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុន មុននឹងធ្វើដំណើរចេញទៅបរទេស ។ល។ (មាត្រា ១១៩ និងមាត្រា ១២០ នៃក្រមព្រហ្មទណ្ឌ)

ម្យ៉ាងទៀត កាតព្វកិច្ច គឺអាចជាកិច្ច ដែលជនល្មើសត្រូវតែធ្វើ ឬអាចជាបម្រាម ដែលជនល្មើសមិនត្រូវបំពាន។

**៦.តើក្នុងករណីណាខ្លះ ដែលចៅក្រមអាចប្រកាសព្យួរទោសបាន?**

ការព្យួរទោសធម្មតា អាចប្រកាសទៅបាន គឺត្រូវគោរពទៅតាមលក្ខខណ្ឌពីរ៖

**លក្ខខណ្ឌទាក់ទងនឹងជនល្មើស (មាត្រា ១០៦)** ចៅក្រមអាចប្រកាសព្យួរទោសបាន លុះត្រាតែ ក្នុងរយៈពេល ៥ឆ្នាំ មុនអំពើល្មើសនេះ ជនល្មើសមិនធ្លាប់មានការផ្តន្ទាទោសពីបទល្មើសណាមួយផ្សេងទៀត។

ឧបមាថា កាលពី ៤ឆ្នាំមុន ជនល្មើសធ្លាប់ប្រព្រឹត្តបទល្មើសអ្វីមួយ ហើយត្រូវបានតុលាការកាត់ទោសជាស្ថាពររួចហើយ ស្រាប់តែ ៤ឆ្នាំក្រោយ ប្រព្រឹត្តបទល្មើសណាមួយទៀត។ សម្រាប់បទល្មើសលើកក្រោយនេះ ចៅក្រមមិនអាចប្រកាសព្យួរទោសបានទេ។

**លក្ខខណ្ឌទាក់ទងនឹងប្រភេទទោស (មាត្រា ១០៧)** ចៅក្រមអាចប្រកាសព្យួរទោសបាន លុះត្រាតែទោសជាប់ពន្ធនាគារមានរយៈពេលមិនលើសពី ៥ឆ្នាំ។

## ផ្នែកទី៦៨

## ចំណាត់ថ្នាក់បទល្មើស អាជ្ញាយុកាល និងអាជ្ញាអស់ជំនុំ នៅក្នុងច្បាប់ព្រហ្មទណ្ឌខ្មែរ




ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១០

ដោយ សេង ឌីណា

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័ត និងប្រកាសឲ្យប្រើ កាលពីឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌត្រូវបែងចែកជា បី ថ្នាក់ គឺ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ខាងក្រោមនេះ គឺជាសំណួរចម្លើយជុំវិញបទល្មើសទាំងបីថ្នាក់នេះ។

**១.តើបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុខុសគ្នាត្រង់ចំណុចណាខ្លះ?**

បទល្មើសទាំងបីថ្នាក់នេះខុសគ្នាទៅតាមទម្ងន់ទោស។

បទឧក្រិដ្ឋ គឺជាប្រភេទបទល្មើសដែលកម្រិតទោសអតិបរមា ជាទោសជាប់ពន្ធនាគារ ចាប់ពី ៥ឆ្នាំ រហូតដល់មួយជីវិត។ *ឧទាហរណ៍៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឃាតកម្ម បទរំលោភសេពសន្ថវៈ បទលួចដោយមានអំពើហិង្សា (ប្លន់) ។ល។*

បទមជ្ឈិម គឺជាប្រភេទបទល្មើសដែលកម្រិតទោសអតិបរមាជាទោសជាប់ពន្ធនាគារ ចាប់ពី ៦ថ្ងៃ ដល់ ៥ឆ្នាំ។ *ឧទាហរណ៍៖ បទមនុស្សឃាតដោយអចេតនា លួច បង្ករបួសស្នាម (ហិង្សាដោយចេតនា) បទឆបោក រំលោភលើសេចក្ដីទុកចិត្ត ។ល។*

បទលហុ គឺជាប្រភេទបទល្មើស ដែលកម្រិតទោសអតិបរមា ជាទោសជាប់ពន្ធនាគារ តិចជាង ៦ថ្ងៃ ឬជាបទល្មើសដែលត្រូវផ្ដន្ទាទោសត្រឹមតែជាប្រាក់ពិន័យសុទ្ធសាធ ដោយគ្មានទោសពន្ធនាគារ។ *ឧទាហរណ៍៖ ការបើកបរដោយមិនគោរពច្បាប់ចរាចរណ៍ ការជេរប្រមាថមន្ត្រីរាជការសាធារណៈ ការបរិហាកេរ្តិ៍ ឬជេរប្រមាថជាសាធារណៈ ការបង្ហាញនូវភាពស្រវឹងនៅទីសាធារណៈ ។ល។*

**២.តើអ្វីទៅជាអាជ្ញាយុកាល? ហើយបើសិនជាក្នុងករណីផុតអាជ្ញាយុកាល តើនឹងមានអ្វីកើតឡើង?**

អាជ្ញាយុកាល ត្រូវចែកជាពីរ៖ អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា និងអាជ្ញាយុកាលនៃទោស។

**អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា**

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា គឺជារយៈពេលកំណត់មួយ ដែលបណ្តឹងអាជ្ញាអាចធ្វើឡើងបាន។ បើផុតរយៈពេលកំណត់នេះ គេលែងអាចធ្វើការចោទប្រកាន់ និងកាត់ទោសជនល្មើសបានទៀតហើយ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ (មាត្រា ១០) អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា គឺមានៈ

- ១៥ឆ្នាំ សម្រាប់បទឧក្រិដ្ឋ
- ៥ឆ្នាំ សម្រាប់បទមជ្ឈិម
- ១ឆ្នាំ សម្រាប់បទលហុ

គួរកត់សម្គាល់ថា អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានេះ ត្រូវគិតចាប់ពីពេលដែលអំពើល្មើសត្រូវបានប្រព្រឹត្ត។

*ឧទាហរណ៍ៈ បុគ្គលឈ្មោះ “ក” បានលួចទ្រព្យគេ ដែលជាបទមជ្ឈិម ក៏ប៉ុន្តែ គ្មានបណ្តឹង គ្មានការស៊ើបអង្កេត គ្មានការចោទប្រកាន់អ្វីទាំងអស់។ ៥ឆ្នាំ ក្រោយថ្ងៃដែល “ក” បានប្រព្រឹត្តអំពើល្មើស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាត្រូវផុត ដូច្នេះ តុលាការលែងអាចយកជនល្មើស “ក” នេះ មកជំនុំជម្រះបានទៀតហើយ។*

មានប្រភេទបទល្មើសធំៗមួយចំនួន រួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាប្រភេទបទឧក្រិដ្ឋដែលគ្មានអាជ្ញាយុកាលទេ។ មានន័យថា បើទោះបីជានៅក្រោយពេលប្រព្រឹត្តអំពើល្មើសប៉ុន្មានឆ្នាំក៏ដោយ ក៏តុលាការអាចយកជនល្មើសមកកាត់ទោសបានដែរ។

**អាជ្ញាយុកាលនៃទោស**

អាជ្ញាយុកាលនៃទោស គឺទាក់ទងនឹងរយៈពេលដែលត្រូវអនុវត្តទោស មានន័យថា ក្នុងករណី ដែលជនល្មើសត្រូវបានតុលាការកាត់ឲ្យជាប់ទោសរួចហើយ ប៉ុន្តែ គេមិនអាចចាប់ពិរុទ្ធជននេះឲ្យមកអនុវត្តទោសបាន។ ដល់ផុតអាជ្ញាយុកាលទោសនេះលែងអាចអនុវត្តទៀតបានហើយ ពោលគឺ ពិរុទ្ធជនត្រូវរួចខ្លួន។

អាជ្ញាយុកាលនៃទោស ក៏ត្រូវបែងចែកទៅតាមចំណាត់ថ្នាក់បទល្មើសដែរ គឺៈ

- ទោសដែលប្រកាសចំពោះបទឧក្រិដ្ឋ មានអាជ្ញាយុកាល ២០ឆ្នាំ
- ទោសដែលប្រកាសចំពោះបទមជ្ឈិម មានអាជ្ញាយុកាល ៥ឆ្នាំ
- ទោសដែលប្រកាសចំពោះបទលហុ មានអាជ្ញាយុកាល ១ឆ្នាំ

ចំណុចចាប់ផ្តើមនៃអាជ្ញាយុកាល (២០ឆ្នាំ ៥ឆ្នាំ និង ១ឆ្នាំ ខាងលើនេះ) គឺត្រូវចាប់ផ្តើមរាប់ ពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសចូលជាស្ថាពរ។

*ឧទាហរណ៍ៈ បុគ្គលឈ្មោះ “ក” បានប្រព្រឹត្តអំពើឃាតកម្ម ដែលជាបទឧក្រិដ្ឋ ហើយត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ ក៏ប៉ុន្តែ ជាការកាត់ទោសដោយកំបាំងមុខ ដោយសារតែ "ក" បានរត់គេចខ្លួនបាត់ ហើយគេមិនអាចចាប់ "ក" យកមកដាក់ក្នុងពន្ធនាគារបាន។ ២០ឆ្នាំ ក្រោយពីថ្ងៃប្រកាសសាលក្រមស្ថាពរ ទោសដែលដាក់លើ “ក” នេះ នឹងត្រូវផុតអាជ្ញាយុកាល។ បើទោះបីជា “ក” វិលត្រឡប់មកវិញ ក៏គេមិនអាចចាប់ "ក" ដាក់ពន្ធនាគារបានដែរ។*

**៣.ទាក់ទងនឹងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា។ ឧបមាថា នៅសល់តែ ពីរ-បីថ្ងៃ មុនពេលផុតអាជ្ញាយុកាល ទើបគេចាប់ផ្តើមមានតម្រុយ អំពីជនសង្ស័យ ហើយចាប់ផ្តើមបើកការស៊ើបអង្កេត។ ក៏ប៉ុន្តែ ការស៊ើបអង្កេតត្រូវចំណាយពេលជាច្រើនខែ។ ទម្រាំតែស៊ើបអង្កេតចប់ អាជ្ញាយុកាលក៏ត្រូវផុត។ ក្នុងករណីនេះ តើតុលាការនៅតែអាចយកជនល្មើសមកកាត់ទោសបាន ឬក៏ត្រូវបិទបញ្ចប់បណ្តឹងអាជ្ញា?**

ក្នុងករណីនេះ តុលាការនៅតែអាចយកជនល្មើសមកកាត់ទោសបានដដែល ពីព្រោះថា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១១ ចែងថា "*អាជ្ញាយុកាលត្រូវផ្ដាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ*"។ មានន័យថា ឲ្យតែមានការចោទប្រកាន់ ឬការបើកការស៊ើបអង្កេតលើបទល្មើសណាមួយហើយ អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាលើបទល្មើសនោះ នឹងត្រូវផ្ដាច់លែងរាប់តទៅទៀតហើយ។

ដូច្នេះ សរុបមកវិញ ទោះបីជានៅសល់ត្រឹមតែ១ថ្ងៃទៀតត្រូវផុតអាជ្ញាយុកាលក៏ដោយ ឲ្យតែមានការបើកការស៊ើបអង្កេត អាជ្ញាយុកាលនឹងត្រូវផ្ដាច់លែងរាប់តទៅទៀត ហើយទោះបីការស៊ើបអង្កេតនេះត្រូវចំណាយពេលរាប់ខែក៏ដោយ បើសិនជាមានសំណុំរឿងគ្រប់គ្រាន់ តុលាការនៅតែអាចធ្វើការចោទប្រកាន់ និងជំនុំជម្រះជនល្មើស ដោយបទល្មើសនេះមិនត្រូវផុតអាជ្ញាយុកាលនោះទេ។

**ក-តើអ្វីទៅជា "អាជ្ញាអស់ជំនុំ"?**

អាជ្ញាអស់ជំនុំ គឺមានន័យថា ជនណាក៏ដោយ ដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ គេមិនអាចយកជននោះមកកាត់ទោសចំពោះអំពើដដែលនោះទៀតបានទេ បើទោះជាការកាត់ទោសនោះធ្វើឡើងក្រោមការកំណត់ឈ្មោះបទល្មើសថ្មី ផ្សេងក៏ដោយ ឬកាត់ទោសដោយតុលាការណាមួយផ្សេងទៀតក៏ដោយ។

## ផ្នែកទី៦៩

## នីតិព្រហ្មទណ្ឌ៖ តើអ្វីទៅជាការព្យួរទោស? អ្វីទៅជារបបពាក់កណ្ដាលសេរីភាព?

ដោយ សេង ឌីណា

តាមក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា នៅពេលដែលតុលាការប្រកាសផ្ដន្ទាទោសជនល្មើសណាមួយ តុលាការអាចបង្គាប់ឲ្យព្យួរទោស ឬក៏អាចបង្គាប់ឲ្យអនុវត្តរបបពាក់កណ្ដាលសេរីភាពបាន។ តើអ្វីទៅជាការព្យួរទោស? ហើយអ្វីទៅជារបបពាក់កណ្ដាលសេរីភាព?

– **ការព្យួរទោស**

ការព្យួរទោស គឺការអនុញ្ញាតឲ្យជនជាប់ពិរុទ្ធ ដែលត្រូវតុលាការផ្ដន្ទាទោស អាចមិនអនុវត្តទោសនេះបាន ប្រសិនបើមិនប្រព្រឹត្តល្មើសថ្មីទៀត ក្នុងរយៈពេលដែលបានកំណត់ណាមួយ។ នៅក្នុងក្រមព្រហ្មទណ្ឌខ្មែរ ទោសដែលអាចព្យួរបាន គឺមានទាំងទោសពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយការព្យួរទោសត្រូវចែកជាពីរប្រភេទ គឺការព្យួរទោសធម្មតា (Sursis simple) និងការព្យួរទោសសាកល្បង (Sursis avec mise à l'épruve)។

– **ការព្យួរទោសធម្មតា**

ប្រសិនបើជនល្មើសត្រូវតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារ ដោយត្រូវព្យួរទោស ជនល្មើសនេះមិនត្រូវជាប់ក្នុងពន្ធនាគារទេ។ ក៏ប៉ុន្តែ ប្រសិនបើក្នុងរយៈពេល៥ឆ្នាំ ចាប់ពីថ្ងៃប្រកាសទោស ជនល្មើសនេះបានប្រព្រឹត្តបទល្មើសណាមួយថ្មីទៀត ការព្យួរទោសនឹងត្រូវលើកចេញវិញ ហើយជនល្មើសនឹងត្រូវអនុវត្តទោសទាំងពីរ គឺទាំងទោសទី១ ដែលបានព្យួរ និងទោសទី២ សម្រាប់បទល្មើសដែលប្រព្រឹត្តថ្មីក្រោយ។

ដូចគ្នាចំពោះទោសពិន័យជាប្រាក់។ ប្រសិនបើតុលាការប្រកាសព្យួរទោស ជនល្មើសមិនត្រូវបង់ប្រាក់ពិន័យទេ ប្រសិនបើមិនមានប្រព្រឹត្តបទល្មើសថ្មីទៀត ក្នុងរយៈពេល ៥ឆ្នាំ។

គួរបញ្ជាក់ថា ការប្រកាសព្យួរទោស ឬមិនព្យួរ គឺជាសិទ្ធិអំណាចរបស់តុលាការ ក៏ប៉ុន្តែ ទោសពន្ធនាគារ ដែលតុលាការអាចប្រកាសព្យួរបាន ទាល់តែទោសពន្ធនាគារនោះ មានរយៈពេលយ៉ាងច្រើនបំផុត ៥ឆ្នាំ។ ប្រសិនបើជនល្មើសត្រូវតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារ លើសពី៥ឆ្នាំ តុលាការមិនអាចប្រកាសព្យួរទោសនេះបានទេ។

ម្យ៉ាងទៀត បើទោះបីជាទោសពន្ធនាគារនេះមានរយៈពេលត្រឹម ៥ឆ្នាំ ឬតិចជាង ៥ឆ្នាំក៏ដោយ តុលាការអាចប្រកាសព្យួរទោសបាន លុះត្រាតែជនល្មើសមិនធ្លាប់ត្រូវបានផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារ ម្ដងសោះ នៅក្នុងរយៈពេល ៥ឆ្នាំមុនអំពើល្មើស។

*ឧទាហរណ៍៖ នៅឆ្នាំ២០០៨ ជនល្មើស "ក" ធ្លាប់ត្រូវបានតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារម្ដងរួចមកហើយ ស្រាប់តែ ៤ឆ្នាំក្រោយមក នៅឆ្នាំ២០១២ "ក" បានប្រព្រឹត្តបទល្មើសថ្មីទៀត ហើយត្រូវតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារ ៣ឆ្នាំ។ ទោស ៣ឆ្នាំក្រោយនេះមិនអាចត្រូវព្យួរបានទេ។*

– **ការព្យួរទោសសាកល្បង**

ការព្យួរទោសសាកល្បង គឺប្រហាក់ប្រហែលនឹងការព្យួរទោសធម្មតាដែរ គ្រាន់តែមានរយៈពេលសាកល្បងមួយ ដែលមានរយៈពេល ពី ១ឆ្នាំ ទៅ ៣ឆ្នាំ។ ក្នុងរយៈពេលសាកល្បងនេះ ទណ្ឌិតត្រូវគោរពទៅតាមវិធានការត្រួតពិនិត្យ ដែលកំណត់ដោយតុលាការ៖

- ត្រូវចូលខ្លួនទៅតាមដីកាកោះពីព្រះរាជអាជ្ញា (ឬតំណាងព្រះរាជអាជ្ញា)

- ត្រូវទទួលការមកត្រួតពិនិត្យមើលរបស់ព្រះរាជអាជ្ញា
- ត្រូវផ្តល់ឯកសារ ទៅតាមការបង្គាប់របស់ព្រះរាជអាជ្ញា
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋាន ឬការផ្លាស់ប្តូរមុខរបរ
- ត្រូវសុំការអនុញ្ញាតពីព្រះរាជអាជ្ញាមុននឹងធ្វើដំណើរទៅបរទេស

ក្រៅពីវិធានការទាំងអស់នេះ តុលាការអាចកំណត់ឲ្យទណ្ឌិតគោរពទៅតាមកាតព្វកិច្ចមួយចំនួនផ្សេងទៀត នៅក្នុងរយៈពេលសាកល្បង ដូចជា ៖

- ត្រូវបំពេញសកម្មភាពខាងវិជ្ជាជីវៈ
- ត្រូវទៅរៀន ឬទទួលការបណ្តុះបណ្តាលខាងវិជ្ជាជីវៈ
- ត្រូវរស់នៅក្នុងកន្លែងណាមួយជាកំណត់
- ត្រូវទទួលឲ្យពេទ្យធ្វើការពិនិត្យ និងព្យាបាល
- មិនត្រូវមានវត្តមាន នៅទីកន្លែងណាមួយ ដែលកំណត់ដោយតុលាការ
- មិនត្រូវធ្វើសកម្មភាពមួយចំនួន ដូចជា សេពគប់បនល្បែង គ្រឿងស្រវឹង កាន់កាប់ ឬយកអាវុធតាមខ្លួន ឬប្រកបអាជីវកម្មណាមួយ ដែលកំណត់ដោយតុលាការ
- មិនត្រូវទៅក្បែរ ឬទៅជួបជាមួយបុគ្គលខ្លះ ដូចជា អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ជាដើម។

នៅក្នុងរយៈពេលសាកល្បង (១ឆ្នាំទៅ៣ឆ្នាំ) ប្រសិនបើជនល្មើសមិនគោរពតាមវិធានការត្រួតពិនិត្យ ឬតាមកាតព្វកិច្ច ដែលកំណត់ដោយតុលាការទេ ការព្យួរទោសនឹងត្រូវលើកចេញវិញ ហើយជនល្មើសត្រូវតែអនុវត្តទោស។ ប្រសិនបើជនល្មើសប្រព្រឹត្តបទល្មើសថ្មីណាមួយទៀត ក្នុងរយៈពេលសាកល្បងនេះ ការព្យួរទោសក៏ត្រូវលើកចេញវិញដូចគ្នាដែរ ហើយជនល្មើសត្រូវអនុវត្តទោស សម្រាប់បទល្មើសទាំងពីរ ដូចករណីព្យួរទោសធម្មតាដែរ។

គួរបញ្ជាក់ថា តុលាការអាចប្រកាសព្យួរទោសសាកល្បងបាន តែចំពោះទោសពន្ធនាគារប៉ុណ្ណោះ ហើយបានតែចំពោះទោសពន្ធនាគារ ដែលមានរយៈពេល ក្នុងចន្លោះពី ៦ខែ ទៅ ៥ឆ្នាំប៉ុណ្ណោះ។ ទោសពិន័យជាប្រាក់ និងទោសពន្ធនាគារតិចជាង ៦ខែ ឬច្រើនជាង ៥ឆ្នាំ មិនអាចព្យួរដោយមានរយៈពេលសាកល្បងនេះបានទេ។

ចំណុចដែលគួរកត់សម្គាល់ចុងក្រោយ ការប្រកាសព្យួរទោសអាចធ្វើចំពោះទោសទាំងមូល ឬក៏ធ្វើមួយផ្នែកក៏បាន។

*ឧទាហរណ៍៖ ជនល្មើស “ក” ប្រព្រឹត្តបទល្មើសឆបោក ហើយត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ៤ឆ្នាំ ប៉ុន្តែ ២ឆ្នាំត្រូវព្យួរ។ ក្នុងករណីនេះ ជនល្មើសត្រូវជាប់ពន្ធនាគារតែ ២ឆ្នាំប៉ុណ្ណោះ ដោយត្រូវព្យួរទោស ២ឆ្នាំ* ។

– **របបពាក់កណ្តាលសេរីភាព**

របបពាក់កណ្តាលសេរីភាពអាចអនុវត្តបានតែចំពោះទោសពន្ធនាគារ ដែលមានរយៈពេល ៦ខែ ឬតិចជាង ៦ខែប៉ុណ្ណោះ។ តុលាការអាចប្រកាសរបបពាក់កណ្តាលសេរីភាព គឺដើម្បីឲ្យទណ្ឌិតអាចបំពេញសកម្មភាពខាងវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្តុះបណ្តាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្តីត្រូវការរបស់ក្រុមគ្រួសារ។

ទណ្ឌិតដែលស្ថិតក្នុងរបបពាក់កណ្តាលសេរីភាព ត្រូវអនុញ្ញាតឲ្យចាកចេញពីពន្ធនាគារ ក្នុងរយៈពេលជាកំណត់ណាមួយ។ នៅពេលប្រកាសពីរបបពាក់កណ្តាលសេរីភាព តុលាការត្រូវកំណត់នៅក្នុងសេចក្តីសម្រេច អំពីថ្ងៃ និងម៉ោង ដែលទណ្ឌិតអាចចេញពីពន្ធនាគារបាន។

*ឧទាហរណ៍៖ ឈ្មោះ "ក" ជានិស្សិត ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ៦ខែ ពីបទលួច។ តុលាការពិនិត្យពិចារណាមើលទៅ មិនចង់ឲ្យទណ្ឌិត "ក" ខាតការរៀនសូត្រ ក៏សម្រេចឲ្យអនុវត្តរបបពាក់កណ្តាលសេរីភាព ដើម្បីឲ្យទណ្ឌិត "ក" អាចបន្តការរៀនសូត្របាន។ ដូច្នេះ ទណ្ឌិត "ក" អាចចេញពីពន្ធនាគារបាន ដើម្បីទៅរៀន ទៅតាមថ្ងៃ និងម៉ោងពេលដែលបានកំណត់ដោយតុលាការ ដូចជា ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ អាចចេញពីពន្ធនាគារ ទៅសាលារៀនបាន នៅម៉ោង ៨ព្រឹក ហើយត្រូវត្រឡប់ចូលមកក្នុងពន្ធនាគារវិញ នៅម៉ោង ៥ល្ងាច។*

## ផ្នែកទី៧០

## លក្ខណៈខុសគ្នារវាងបទឃាតកម្ម ឃាតកម្មគិតទុកជាមុន និងមនុស្សឃាតដោយអចេតនា

ដោយ សេង ឌីណា

នៅក្នុងក្រមព្រហ្មទណ្ឌខ្មែរ ដែលទើបនឹងចូលជាធរមាន កាលពីខែធ្នូ ២០១០កន្លងទៅនេះ ទាក់ទងនឹងមនុស្សឃាត គេឃើញមានបទល្មើសបី ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា៖ បទឃាតកម្ម ឃាតកម្មគិតទុកជាមុន និងមនុស្សឃាតដោយអចេតនា។ ខាងក្រោមនេះ គឺជាសំណួរ-ចម្លើយ អំពីភាពខុសគ្នារវាងបទល្មើសទាំងបីនេះ។

**១.តើ "បទឃាតកម្ម" "បទឃាតកម្មគិតទុកជាមុន" និង "បទមនុស្សឃាតដោយអចេតនា" ខុសគ្នាត្រង់ណាខ្លះ?**

ចំណុចខុសគ្នាទី១ គឺរវាងចេតនា និងអចេតនា។

បទឃាតកម្ម និងឃាតកម្មគិតទុកជាមុន គឺសុទ្ធសឹងជាឃាតកម្មដោយចេតនា មានន័យថា ជនល្មើសមានចេតនាចង់សម្លាប់ជនរងគ្រោះ។ ចំណែកបទមនុស្សឃាតដោយ អចេតនាវិញ ជនល្មើសមិនមានចេតនាសម្លាប់ទេ ក៏ប៉ុន្តែ ទង្វើរបស់គាត់បានបណ្តាលឲ្យជនរងគ្រោះស្លាប់។

ចំណុចខុសគ្នាទី២ គឺ ទាក់ទងនឹងការគិតទុកជាមុន ពោលគឺ រវាង "បទឃាតកម្ម" និង "បទឃាតកម្មគិតទុកជាមុន"។ ក្នុងបទល្មើសពីរនេះ ជនល្មើសសុទ្ធសឹងតែមានចេតនាសម្លាប់ជនរងគ្រោះ ដូចគ្នា ក៏ប៉ុន្តែ ក្នុងបទឃាតកម្ម ជនល្មើសមិនមានការគិតទុកជាមុនថានឹងសម្លាប់ជនរងគ្រោះទេ។ ចំណែកឃាតកម្មគិតទុកជាមុន ជនល្មើសបានគិតទុកជាមុន ឬបានប្រុងប្រៀបរៀបចំទុកជាមុន។

**២."មានចេតនាសម្លាប់" ឬ "មានការគិតទុកជាមុន" ជនល្មើសសុទ្ធតែមានគោលដៅចង់សម្លាប់ជនរងគ្រោះដូចគ្នា។ តើគេមើលទៅលើចំណុចណាខ្លះ ដើម្បីឲ្យដឹងថា មួយណាជា "បទឃាតកម្ម" ហើយមួយណា "បទឃាតកម្មគិតទុកជាមុន"?**

ក្នុងបទល្មើសទាំងពីរនេះ ជនល្មើសចេតនាសម្លាប់គឺមានដូចគ្នា ក៏ប៉ុន្តែ មួយ(បទឃាតកម្ម)គំនិតចង់សម្លាប់ជនរងគ្រោះ គឺកើតឡើងភ្លាមៗ នៅពេលមានសកម្មភាពសម្លាប់។ ចំណែកមួយទៀត (ឃាតកម្មគិតទុកជាមុន) គំនិតចង់សម្លាប់ គឺកើតឡើងនៅមុនពេលសកម្មភាពសម្លាប់។

យោងតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ឃាតកម្មគិតទុកជាមុន គឺជាអំពើសម្លាប់មនុស្ស ៖

- ដោយមានគម្រោងទុកជាមុន៖ គម្រោងបង្កើតឡើងមុនអំពើបៀតបៀនទៅលើជនរងគ្រោះ
- ឬដោយមានការពួនស្ទាក់៖ ជនល្មើសបានឃ្លាំចាំជនរងគ្រោះ ក្នុងរយៈពេលណាមួយ ដើម្បីចាំសម្លាប់ជនរងគ្រោះ។

ជាទូទៅ គេកំណត់ថា អំពើឃាតកម្មមួយមានការគិតទុកជាមុន គេច្រើនមើលទៅលើចំណុចសំខាន់៣៖

**១-ផ្លូវចិត្ត**

គេមើលថាតើ នៅពេលធ្វើសកម្មភាពសម្លាប់ មានកម្លាំងផ្លូវចិត្តណាមួយ ដូចជា កំហឹងជាដើម ដែលជំរុញឲ្យជនល្មើសសម្លាប់ជនរងគ្រោះដែរឬទេ? បើសិនជាអំពើសម្លាប់ កើតឡើងភ្លាមៗដោយសារកំហឹង គឺមិនមែនជាឃាតកម្មគិតទុកជាមុនទេ។

**ឧទាហរណ៍៖** ជនល្មើសជាប្តីចេញពីធ្វើការ មកដល់ផ្ទះ សម្រាប់តែឃើញទាន់ប្រពន្ធកំពុងតែមានសាហាយស្មន់។ ដោយខឹងខ្លាំងពេក បុរសជាប្តីក៏ទាញកាំភ្លើងបាញ់សម្លាប់បុរសជាសហាយ។ ករណីនេះ មិនមែនជាបទឃាតកម្មគិតទុកជា

មុនទេ ព្រោះថា ការសម្លាប់ដោយកំហឹង គេអាចសន្និដ្ឋានថា គំនិតចង់សម្លាប់ និងអំពើគឺកើតឡើងក្នុងពេលប្រហាក់ប្រហែលគ្នា ដោយជនល្មើសមិនមានពេលគិតពិចារណាទេ។

**២-ពេលវេលា**

គេអាចចាត់បញ្ចូលជាឃាតកម្មគិតទុកជាមុន ប្រសិនមានគម្លាតវែង រវាងពេលដែលជនល្មើសគិតចង់សម្លាប់ជនរងគ្រោះ និងពេលដែលគាត់ធ្វើសកម្មភាពសម្លាប់។

**ឧទាហរណ៍៖** ដូចក្នុងឧទាហរណ៍ខាងលើ បុរសជាប្តីមកដល់ទាន់ឃើញប្រពន្ធកំពុងមានសាហាយស្មន់ ក៏ប៉ុន្តែ បុរសជាសហាយរត់គេចខ្លួនបាត់។ ១ខែក្រោយមក ទើបបុរសជាប្តីទៅសម្លាប់បុរសជាសាហាយ។ ក្នុងករណីនេះ មុននឹងប្រព្រឹត្តសកម្មភាពសម្លាប់ ជនល្មើសមានពេលគិតពិចារណា។ ដូច្នេះ វាមិនមែនជាការសម្លាប់ដោយកំហឹងភ្លាមៗទេ ប៉ុន្តែ ជាការសម្លាប់ដោយគំនុំទៅវិញ ដោយត្រូវចូលជាឃាតកម្មគិតទុកជាមុន។

**៣-សម្ភារៈ**

គេមើលថា មុននឹងធ្វើសកម្មភាព តើជនល្មើសមានប្រុងប្រៀបឧបករណ៍ ឬរៀបចំផែនការទុកជាមុនដែរឬទេ? ជាទូទៅការសម្លាប់មនុស្ស ដោយមិនមានការគិតជាមុន ជនល្មើសច្រើនតែប្រើឧបករណ៍ដែលខ្លួនរកបាននៅនឹងកន្លែងកើតហេតុ។ បើសិនជាមានការរៀបចំប្រុងប្រៀបជាមុន ដូចជា សំលៀងកាំបិត ឬទៅរកទិញកាំភ្លើង ដើម្បីទុកសម្លាប់ជនរងគ្រោះ ឬមានការតាមដាន ឃ្លាំមើលជនរងគ្រោះ ឬមានការប្រើល្បិចបញ្ឆោតជនរងគ្រោះឲ្យចូលអន្ទាក់ ឬពួនស្ទាក់ចាំសម្លាប់ជនរងគ្រោះ ជាដើម គេចាត់ទុកថាជាឃាតកម្មគិតទុកជាមុន។

**៣.រវាងបទឃាតកម្ម និងឃាតកម្មគិតទុកជាមុន តើការផ្តន្ទាទោសមានការខុសគ្នាបែបណាដែរ?**

ចំពោះឃាតកម្មគិតទុកជាមុន ច្បាប់កំណត់ផ្តន្ទាទោសធ្ងន់ជាងបទឃាតកម្ម ដោយគ្មានការគិតទុកជាមុន។

បទឃាតកម្ម គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ។ ចំណែកឃាតកម្មគិតទុកជាមុនវិញ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

**៤.តើអ្វីទៅជា "បទមនុស្សឃាតដោយអចេតនា"?**

ក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ២០៧ ចែងថា៖

*"បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឲ្យស្លាប់អ្នកដទៃដោយ៖*

*១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា។*

*២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។*

ដូច្នេះ នៅក្នុងបទមនុស្សឃាតដោយអចេតនា ជនរងគ្រោះស្លាប់ដោយសារតែទង្វើរបស់ជនល្មើស ក៏ប៉ុន្តែ ជនល្មើសមិនមានចេតនាចង់ឲ្យជនរងគ្រោះស្លាប់ទេ។ ទង្វើដែលនាំឲ្យជនរងគ្រោះស្លាប់ ច្រើនតែកើតចេញពីជាកំហុសណាមួយរបស់ជនល្មើស។

**ឧទាហរណ៍១៖** នៅលើផ្លូវនេះ តាមច្បាប់ចរាចរណ៍ គេហាមមិនឲ្យបើកជែងគ្នាទេ ប៉ុន្តែជនល្មើសបានបើកជែងគេទាំងរំលោភលើបម្រាម ហើយទៅបុកគេស្លាប់។ នេះ គឺជាបទមនុស្សឃាតដោយអចេតនា។ ថ្វីដ្បិតតែជនល្មើសមិនមានចេតនាបុកសម្លាប់ជនរងគ្រោះ ក៏ប៉ុន្តែ ជនល្មើសបានបើកបរល្មើសនឹងច្បាប់ចរាចរណ៍ ធ្វើឲ្យស្លាប់អ្នកដទៃ។

**ឧទាហរណ៍២៖** ផ្ទះជនល្មើសនៅជាន់ទី៣។ នៅពីក្រោមសំយាបផ្ទះ គឺជាផ្លូវមនុស្សដើរ។ ជនល្មើសបានយកផើងផ្កាទៅដាក់នៅចុងសំយាបផ្ទះ ដោយមិនមានចង ឬដាក់អ្វីទប់ឲ្យជាប់ត្រឹមត្រូវ។ ផើងផ្កាក៏ធ្លាក់ត្រូវគេស្លាប់។ ក្នុងករណីនេះ ជនល្មើសនឹងត្រូវជាប់ទោសអំពីបទមនុស្សឃាតដោយអចេតនា។

**ឧទាហរណ៍៣៖** រោងចក្រមួយដំណើរការដោយមានជាតិគីមី ដែលអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស ក៏ប៉ុន្តែប្រើបុគ្គលិក ដោយមិនមានគោរពទៅតាមបែបបទសុវត្ថិភាពត្រឹមត្រូវ ដូចជា ឲ្យបុគ្គលិកធ្វើការដោយប៉ះពាល់ជាតិគីមីពុល (គ្មានស្រោមដៃ ឬពាក់របាំងមុខ) ឬក៏នៅកន្លែងការងារ មិនមានរៀបចំប្រព័ន្ធបង្ហុយខ្យល់ត្រឹមត្រូវ ធ្វើឲ្យជាតិគីមីពុល នៅវិលវល់ក្នុងកន្លែងការងារ។ បើសិនជាមានបុគ្គលិកណាម្នាក់ស្លាប់ដោយពុលជាតិគីមីនេះ ក្រុមហ៊ុននឹងត្រូវទទួលខុសត្រូវ ក្នុងបទមនុស្សឃាតដោយអចេតនា។

បទមនុស្សឃាតដោយអចេតនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ ពី ២លានរៀល ទៅ ៦លានរៀល។

បើសិនជាជនល្មើសជានីតិបុគ្គល (ដូចជា រោងចក្រ ក្នុងឧទាហរណ៍ខាងលើ) នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពី១០លានរៀល ទៅ ៥០លានរៀល។ ក្នុងករណីនេះ ជនល្មើសជានីតិបុគ្គល មិនមានជាប់ទោសដាក់ពន្ធនាគារទេ ប៉ុន្តែ អាចមានទោសបន្ថែម ដូចជា ការបិទរោងចក្រ ជាដើម។

## ផ្នែកទី៧១

# តើក្នុងករណីណាខ្លះដែលអ្នកប្រព្រឹត្តអំពើល្មើសអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ?

ដោយ សេង ឌីណា

ក្រមព្រហ្មទណ្ឌខ្មែរ ត្រូវបានចាប់ផ្ដើមអនុវត្តនៅទូទាំងប្រទេស កាលពីខែធ្នូ ឆ្នាំ២០១០កន្លងទៅនេះ។ ខាងក្រោមនេះគឺជាសំណួរ-ចម្លើយទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ។

**១.តើអនីតិជនអាចមានការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ឬទេ?**

មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ចែងថា “*នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ*”។

ដូច្នេះ ទាល់តែជនល្មើសមានអាយុចាប់ពី ១៨ឆ្នាំទៅ ទើបតុលាការអាចផ្ដន្ទាទោសផ្នែកព្រហ្មទណ្ឌបាន។ ទោសព្រហ្មទណ្ឌ គឺសម្ដៅលើទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

ជនល្មើស ដែលជាអនីតិជន ក្រោម ១៨ឆ្នាំ មិនត្រូវទទួលទោសព្រហ្មទណ្ឌទេ ប៉ុន្តែ តុលាការអាចចាត់វិធានការមួយចំនួន ដើម្បីអប់រំ កែប្រែជនល្មើស។ វិធានការទាំងនេះ អាចជា ៖

- ការប្រគល់ជនអនីតិជនទៅឲ្យឪពុកម្ដាយ ឬអាណាព្យាបាល ដើម្បីអប់រំ
- ការហាមឃាត់មិនឲ្យទៅកន្លែងណាមួយ ឬជួបបុគ្គលណាមួយ ដូចជា មិនឲ្យជួបជនរងគ្រោះនៃបទល្មើស ឬក៏មិនឲ្យជួបអ្នកសមគំនិតផ្សេងទៀត
- ការបញ្ជូនទៅអនីតិជនទៅដាក់ក្នុងមណ្ឌលកែប្រែ

ទោះជាយ៉ាងណា វិធានការទាំងនេះ មិនមែនជាទណ្ឌកម្មព្រហ្មទណ្ឌនោះទេ ពីព្រោះថា ជាគោលការណ៍អនីតិជនមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ក៏ប៉ុន្តែ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌចែងថា “*តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ*”។

នេះមានន័យថា ច្បាប់ទុកលទ្ធភាពឲ្យចៅក្រមជាអ្នកពិនិត្យ និងវាយតម្លៃ លើករណីជាក់ស្ដែង ថា តើបទល្មើសត្រូវបានប្រព្រឹត្តក្នុងកាលៈទេសៈបែបណា? តើជនល្មើស ជាអនីតិជននោះ (អនីតិជនចន្លោះពី ១៤ ទៅ ១៨ឆ្នាំ) មានបុគ្គលិកលក្ខណៈបែបណា ដែលចាំបាច់ត្រូវតែប្រកាសដាក់ទោសព្រហ្មទណ្ឌដែរឬទេ?

ក៏ប៉ុន្តែ ក្នុងករណីចៅក្រមសម្រេចដាក់ទោសព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌបានកំណត់ថា ទោសនោះ ត្រូវតែកាត់បន្ថយពាក់កណ្ដាល ពីទោសធម្មតា (មាត្រា ១៦០)។

ឧទាហរណ៍ ក្នុងករណីបទឃាតកម្ម ធម្មតាត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ។ ក៏ប៉ុន្តែចំពោះជនល្មើសជាអនីតិជន អាយុចន្លោះពី ១៤ឆ្នាំ ទៅ១៨ឆ្នាំ ទោស គឺត្រូវកាត់បន្ថយពាក់កណ្ដាល គឺមកត្រឹម ពី ៥ឆ្នាំ ទៅ ៧ឆ្នាំកន្លះវិញ។

ក្នុងករណីបទល្មើស ដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត គឺត្រូវកាត់បន្ថយមកនៅត្រឹម ២០ឆ្នាំវិញ។ ទោសពិន័យជាប្រាក់ ក៏ត្រូវកាត់បន្ថយពាក់កណ្ដាលដូចគ្នាដែរ។

**២.តើក្នុងករណីណាខ្លះ ដែលនីតិជន (អាយុចាប់ពី ១៨ឆ្នាំឡើងទៅ) អាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ?**

ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ អាចកើតមានក្នុង ៥ករណី ដែលមានចែងក្នុង មាត្រា ៣១ ដល់មាត្រា ៣៧ នៃក្រមព្រហ្មទណ្ឌ៖

**-ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី**

មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ ចែងថា *"កាលបើជនណាម្នាក់ប្រព្រឹត្ត បទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ"*។ ដូចជា ជនវិកលចរិត ជាដើម មិនមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ។

**-ការអនុញ្ញាតដោយច្បាប់ ឬដោយអាជ្ញាធរស្របច្បាប់**

អ្នកប្រព្រឹត្តអំពើល្មើស ដោយមានការអនុញ្ញាតពីច្បាប់ ឬដោយមានបញ្ជាពីអាជ្ញាធរស្របច្បាប់ មិនមានការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍៖ ទាហាន ដែលសម្លាប់គូសត្រូវ ក្នុងសមរភូមិ មិនត្រូវជាប់ទោសពីបទឃាតកម្មទេ។ ប៉ូលិស ដែលទម្លុះទម្លាយទ្វារ ចូលទៅឆែកឆេរលំនៅដ្ឋានឯកជន ទៅតាមសាលក្រមតុលាការ ក៏មិនត្រូវជាប់ទោសពីបទរំលោភលើលំនៅដ្ឋានដែរ។

**-ការការពារស្របច្បាប់**

ក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីការពារខ្លួនឯង ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិពីការរំលោភឈ្លានពានណាមួយ អ្នកប្រព្រឹត្តល្មើស ត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

**-ស្ថានភាពចាំបាច់**

ករណីនេះស្រដៀងគ្នានឹងការការពារស្របច្បាប់ដែរ ប៉ុន្តែ ខុសត្រង់ មិនមានអំពើឈ្លានពានណាមួយនោះទេ។ អ្នកប្រព្រឹត្តល្មើស ត្រូវប្រឈមមុខនឹងស្ថានភាពចាំបាច់ ដែលកើតចេញពីលក្ខខណ្ឌធម្មជាតិ ឬហេតុការណ៍ណាមួយ ដូចជាក្នុងករណី៖

- មិនមានអ្វីទទួលទាន ឃ្លានខ្លាំងជិតដាច់ពោះស្លាប់ ហើយចាំបាច់ត្រូវលួចចំណីអាហារមកទទួលទាន។
- គ្រូពេទ្យ ក្នុងពេលជួយសម្រាលកូន ដើម្បីជួយជីវិតម្ដាយ ចាំបាច់ត្រូវតែសម្លាប់ទារក ដែលរៀបនឹងកើត។
- អ្នកបើកឡានដាច់ហ្វ្រាំងចុះជម្រាល ហើយបង្ខំចិត្ត បើកចេញពីផ្លូវ ទៅបុកផ្ទះអ្នកស្រុក ដើម្បីចៀសវាងកុំឲ្យបុកមនុស្សនៅខាងមុខ ។ល។

ការលួច ការសម្លាប់ទារក ឬការបំផ្លាញផ្ទះអ្នកស្រុក សុទ្ធសឹងជាបទល្មើសព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ ដោយសារតែអំពើល្មើសនេះត្រូវបានប្រព្រឹត្តក្នុងស្ថានភាពចាំបាច់ ដើម្បីជួយសង្គ្រោះខ្លួនឯង ឬជួយសង្គ្រោះអ្នកដទៃ អ្នកប្រព្រឹត្តអំពើល្មើសត្រូវរួចផុតពីការទទួលខុសត្រូវ។

**-អនុភាពនៃកម្លាំង ឬការបង្ខំ**

ជនល្មើស ដែលប្រព្រឹត្តទង្វើល្មើស ក្រោមអានុភាពនៃកម្លាំងណាមួយ ឬក្រោមការបង្ខំពីអ្នកដទៃ ដូចជា ក្នុងករណីមានគេចាប់កូនភ្ជង់នឹងចុងកាំភ្លើង ហើយបង្ខំឲ្យឪពុកចូលទៅលួចលុយគេជាដើម មិនមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើល្មើសនេះទេ។

**៣.តើក្នុងលក្ខខណ្ឌណាខ្លះ ដែលជនវិកលចរិតអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន?**

ដើម្បីរួចផុតពីការទទួលខុសត្រូវទាំងស្រុង គឺត្រូវមានលក្ខខណ្ឌចាំបាច់ពីរ (មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ)៖

**-វិបល្លាសស្មារតីចាំបាច់ត្រូវតែកើតឡើងនៅក្នុងពេលប្រព្រឹត្តបទល្មើស**

ឧទាហរណ៍ ករណីជនវិកលចរិតមិនអចិន្ត្រៃយ៍ មានន័យថា មានពេលខ្លះឆ្កួត ហើយពេលខ្លះទៀត ដឹងខុសត្រូវធម្មតា។ ក្នុងករណីនេះ បើសិនបើគាត់ប្រព្រឹត្តបទល្មើស ក្នុងពេលគាត់ជា ដឹងខុសត្រូវធម្មតា គាត់នឹងទទួលខុសត្រូវព្រហ្មទណ្ឌធម្មតា។ លុះត្រាតែបទល្មើសត្រូវបានប្រព្រឹត្ត ក្នុងពេលដែលគាត់ឆ្កួត មិនដឹងខុសត្រូវ ទើបអាចរួចផុតពីការទទួលខុសត្រូវ។

**-លក្ខណៈវិបល្លាសស្មារតី ត្រូវតែមានលក្ខណៈធ្ងន់ធ្ងរ ធ្វើឲ្យជនល្មើសបាត់បង់ការដឹងខុសត្រូវទាំងស្រុង**

ប្រសិនបើមានវិបល្លាសស្មារតីដែរ ប៉ុន្តែ អាចនៅដឹងខុសត្រូវខ្លះៗ ជនល្មើសត្រូវតែមានការទទួលខុសត្រូវព្រហ្មទណ្ឌ គ្រាន់តែ អាចមានមានការសម្រាលទោស។

ម្យ៉ាងទៀត មាត្រា ៣១ បានកំណត់ថា ការវង្វេងស្មារតី ដែលកើតមកពីការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិ ដែលច្បាប់ហាមឃាត់ មិនអាចជាមូលហេតុ ដែលអាចឲ្យជនល្មើសរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ។

**៥. តើការការពារខ្លួន ត្រូវគោរពទៅតាមលក្ខខណ្ឌអ្វីខ្លះ ទើបអាចចាត់ទុកថាជាការការពារស្របច្បាប់ ហើយដែលអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន?**

មាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌ កំណត់ថា ដើម្បីឲ្យអំពើល្មើសមួយ អាចចាត់ទុកថាជាការពារស្របច្បាប់ ត្រូវគោរពទៅតាមលក្ខខណ្ឌ ដូចខាងក្រោមៈ

- អំពើល្មើសនោះ ត្រូវតែធ្វើឡើង ប្រឈមនឹងទង្វើមួយទៀត (ការឈ្លានពាន) ដែលជាអំពើល្មើសច្បាប់។ ឧទាហរណ៍ ក្នុងករណីប៉ូលិសចូលមកឆែកឆេរផ្ទះ ដោយមានដីកាពីតុលាការត្រឹមត្រូវ ស្រាប់តែម្ចាស់ផ្ទះទាញកាំបិតមកកាប់ប៉ូលិស នេះមិនមែនជាការការពារស្របច្បាប់ទេ ព្រោះទង្វើរបស់ប៉ូលិសជាទង្វើស្របច្បាប់។
- ក្នុងស្ថានភាពចាំបាច់ដោយចៀសមិនរួច មានន័យថា គាត់មិនអាចរត់គេចចេញទៅណាបានទេ គឺមានតែវាយតបតវិញ ដើម្បីការពារខ្លួន។
- បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើង ក្នុងពេលជាមួយគ្នា។ ប្រសិនបើមានគេបាញ់សម្លាប់កូន ស្អែកឡើងឪពុកទៅបាញ់សម្លាប់គេវិញ នេះមិនត្រូវចាត់ទុកថាជាការការពារស្របច្បាប់ទេ។
- មធ្យោបាយនៃការការពារខ្លួន ត្រូវតែសមាមាត្រទៅនឹងទម្ងន់នៃការឈ្លានពាន។ ឧបមាថា មានគេកាន់អង្កត់អុសតូចមួយចូលមករករឿង ស្រាប់តែទៅទាញកាំភ្លើងបាញ់គេស្លាប់ នេះមិនត្រូវចាត់ទុកថាជាការការពារស្របច្បាប់ទេ។

## ផ្នែកទី៧២

## តើបុគ្គលឯកជនអាចប្ដឹងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិក្រុងឡាអេបានដែរឬទេ?

ដោយ សេង ឌីណា

តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានទីតាំងនៅក្នុងទីក្រុងឡាអេ ប្រទេសហូឡង់ ពេលខ្លះត្រូវបានគេហៅថា "តុលាការក្រុងឡាអេ" ដែលអាចបណ្ដាលឲ្យមានការច្រឡំគ្នាជាមួយនឹងតុលាការអន្តរជាតិមួយទៀត គឺតុលាការយុត្តិធម៌អន្តរជាតិ ដែលមានទីតាំងនៅទីក្រុងឡាអេ ហើយត្រូវគេហៅថា "តុលាការក្រុងឡាអេ" ដែរ។ តើតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចជំនុំជម្រះលើសំណុំរឿង អ្វីខ្លះ? តើអ្នកណាខ្លះដែលអាចប្ដឹងទៅតុលាការនេះបាន?

**១.តើតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការយុត្តិធម៌អន្តរជាតិខុសគ្នាត្រង់ណា?**

តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការយុត្តិធម៌អន្តរជាតិ មានទីតាំងនៅទីក្រុងឡាអេដូចគ្នា ហើយជាទូទៅត្រូវគេហៅថា "តុលាការក្រុងឡាអេ" ដូចគ្នា ក៏ប៉ុន្តែ គឺជាស្ថាប័នពីរដាច់ពីគ្នាស្រឡះ។

តុលាការយុត្តិធម៌អន្តរជាតិ គឺជាស្ថាប័នតុលាការរបស់ អ.ស.ប. បង្កើតឡើងតាំងពីឆ្នាំ១៩៤៥ ពោលគឺ បង្កើតព្រមពេលជាមួយនឹងការបង្កើតអ.ស.ប. ហើយមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ។ តុលាការព្រហ្មទណ្ឌអន្តរជាតិវិញ ទើបនឹងត្រូវបានបង្កើតឡើងដោយអនុសញ្ញាក្រុងរ៉ូម ដែលចុះហត្ថលេខានៅឆ្នាំ១៩៩៨ ហើយចូលជាធរមាននៅឆ្នាំ២០០២។

តុលាការយុត្តិធម៌អន្តរជាតិមានសមត្ថកិច្ចជំនុំជម្រះតែទៅលើវិវាទ រវាងរដ្ឋ និងរដ្ឋជាសមាជិកអ.ស.ប.ប៉ុណ្ណោះ មិនអាចជំនុំជម្រះលើបុគ្គល ហើយមិនមានសមត្ថកិច្ចខាងផ្នែកព្រហ្មទណ្ឌទេ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាតុលាការព្រហ្មទណ្ឌ មានសមត្ថកិច្ចស៊ើបអង្កេតលើបទល្មើសព្រហ្មទណ្ឌ ហើយអាចជំនុំជម្រះលើជនជាប់ចោទជាបុគ្គល។

**២.តើតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចជំនុំជម្រះលើបទល្មើសអ្វីខ្លះ?**

យោងតាមអនុសញ្ញាក្រុងរ៉ូម (មាត្រា ៥) តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចជំនុំជម្រះលើបទឧក្រិដ្ឋធំៗ ចំនួន ៤ ៖

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
- ឧក្រិដ្ឋកម្មសង្គ្រាម
- ឧក្រិដ្ឋកម្មឈ្លានពាន

ក៏ប៉ុន្តែ តុលាការនៅមិនទាន់អាចអនុវត្តសមត្ថកិច្ចចំពោះឧក្រិដ្ឋកម្មឈ្លានពាន បាននៅឡើយទេ ដោយសារតែនៅពេលចុះហត្ថលេខាលើអនុសញ្ញាក្រុងរ៉ូម គេមិនទាន់បានកំណត់និយមន័យបទល្មើសនេះនៅឡើយ។ និយមន័យនៃឧក្រិដ្ឋកម្មឈ្លានពាននេះ ទើបនឹងត្រូវបានគេកំណត់ដាក់បញ្ចូលទៅក្នុងអនុសញ្ញាក្រុងរ៉ូម កាលពីខែមិថុនា ឆ្នាំ២០១០ កន្លងទៅថ្មីៗនេះ។ គេត្រូវរង់ចាំរហូតដល់ក្រោយថ្ងៃ១ មករា ឆ្នាំ២០១៧ ហើយត្រូវមានសេចក្ដីសម្រេចរបស់ប្រទេសជាសមាជិកអនុសញ្ញាក្រុងរ៉ូមមួយទៀត ទើបតុលាការព្រហ្មទណ្ឌអន្តរជាតិអាចចាប់ផ្ដើមធ្វើការជំនុំជម្រះលើឧក្រិដ្ឋកម្មឈ្លានពានបាន។

ដូច្នេះ រហូតមកទល់ពេលនេះ (ហើយទៅដល់ឆ្នាំ២០១៧) តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចជំនុំជម្រះលើបទល្មើសតែ ៣ប៉ុណ្ណោះ គឺ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។

**៣.ចំពោះបទឧក្រិដ្ឋទាំង៣នេះ តើតុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចជាស្វ័យប្រវត្តិ ឬក៏ទាល់តែមានការព្រមព្រៀងពីរដ្ឋជាសមាជិកទទួលស្គាល់សមត្ថកិច្ច តុលាការជាមុនសិន ទើបអាចជំនុំជម្រះបាន?**

ឲ្យតែជាបទឧក្រិដ្ឋ ដែលចូលក្នុងដែនយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការអាចធ្វើការជំនុំជម្រះបាន ដោយមិនចាំបាច់ត្រូវឲ្យការការព្រមព្រៀងពីរដ្ឋជាសមាជិក ដូចជាករណីនៅតុលាការយុត្តិធម៌អន្តរជាតិទេ។

ក៏ប៉ុន្តែ តុលាការអាចអនុវត្តសមត្ថកិច្ចជំនុំជម្រះលើបទឧក្រិដ្ឋទាំង៣នេះបាន តែក្នុងករណី ៣ ប៉ុណ្ណោះ គឺ៖

- ករណីទី១ បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅលើទឹកដីរដ្ឋ ដែលជាសមាជិក (បានចុះហត្ថលេខា និងបានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងរ៉ូម) ឬរដ្ឋមិនមែនជាសមាជិក តែបានប្រកាសទទួលស្គាល់សមត្ថកិច្ចតុលាការ ទោះបីជាជនប្រព្រឹត្តល្មើសជាពលរដ្ឋរបស់ប្រទេសណាក៏ដោយ។
- ករណីទី២ ជនដែលប្រព្រឹត្តបទល្មើស គឺជាពលរដ្ឋរបស់រដ្ឋជាសមាជិក ឬរដ្ឋមិនមែនជាសមាជិក តែបានប្រកាសទទួលស្គាល់សមត្ថកិច្ចតុលាការ ទោះបីជាបទល្មើសនោះប្រព្រឹត្តនៅក្នុងប្រទេសណាក៏ដោយ។
- ករណីទី៣ មានសេចក្តីសម្រេចពីក្រុមប្រឹក្សាសន្តិសុខអ.ស.ប. ទោះបីជនល្មើសជាពលរដ្ឋប្រទេសណាក៏ដោយ ហើយបទល្មើសត្រូវប្រព្រឹត្តនៅក្នុងប្រទេសណាក៏ដោយ។

ម្យ៉ាងទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចជំនុំជម្រះតែទៅលើបទល្មើស ដែលប្រព្រឹត្តក្រោយពេលអនុសញ្ញាក្រុងរ៉ូមចូលជាធរមានប៉ុណ្ណោះ មានន័យថា ក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២។

**៤.តើរហូតមកទល់ពេលនេះ មានប្រទេសប៉ុន្មានដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងរ៉ូម?**

គិតត្រឹមខែមេសា ឆ្នាំ២០១២ ប្រទេសដែលបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងរ៉ូម មានចំនួន ១២១ប្រទេស។ នៅក្នុងតំបន់អាស៊ាន មានតែប្រទេស ២ ប៉ុណ្ណោះ ដែលបានផ្តល់សច្ចាប័ន គឺ កម្ពុជា និងហ្វីលីពីន។ កម្ពុជាបានចុះហត្ថលេខា នៅថ្ងៃទី២៣ តុលា ឆ្នាំ២០០០ ហើយផ្តល់សច្ចាប័ន នៅថ្ងៃទី៧ មករាឆ្នាំ២០០២។

**៥.តើបុគ្គលឯកជនអាចប្តឹងទៅតុលាការព្រហ្មទណ្ឌអន្តរជាតិបានដែរ ឬទេ?**

បើយើងនិយាយពីបណ្តឹង ដែលមានអានុភាពឲ្យតុលាការបើកការស៊ើបអង្កេត គឺមានតែរដ្ឋជាសមាជិក និងក្រុមប្រឹក្សាសន្តិសុខអ.ស.ប.ប៉ុណ្ណោះ ដែលមានសិទ្ធិប្តឹងបាន (មាត្រា ១៣ នៃអនុសញ្ញាក្រុងរ៉ូម)។ បុគ្គលឯកជន (ជារូបវន្តបុគ្គលក៏ដោយ ឬជានីតិបុគ្គលក៏ដោយ) មិនអាចប្តឹងបានទេ។

ក៏ប៉ុន្តែ បើនិយាយពី "ប្តឹង" ក្នុងន័យជូនដំណឹងអំពីបទឧក្រិដ្ឋ អ្នកណាក៏អាចធ្វើបានដែរ (ទោះបីជាសមាគម ជាអង្គការក្រៅរដ្ឋាភិបាល ជាអង្គការអន្តរជាតិ ឬជារូបវន្តបុគ្គលឯកជនណាមួយក៏ដោយ) ពីព្រោះថា តុលាការព្រហ្មទណ្ឌអន្តរជាតិមានចំណុចពិសេសមួយ ដែលខុសពីតុលាការអន្តរជាតិផ្សេងទៀត គឺនៅត្រង់ថា រដ្ឋអាជ្ញាតុលាការអាចផ្តួចផ្តើមគំនិតបើកការស៊ើបអង្កេតដោយ ខ្លួនឯងបាន ទោះបីគ្មានបណ្តឹងពីរដ្ឋជាសមាជិក ឬពីក្រុមប្រឹក្សាសន្តិសុខក៏ដោយ។

នៅក្នុងករណីនេះ ក្រោយពីទទួលព័ត៌មានអំពីបទឧក្រិដ្ឋណាមួយ រដ្ឋអាជ្ញាត្រូវពិនិត្យមើលថា តើប្រភពព័ត៌មាននោះគួរឲ្យទុកចិត្តបានដែរឬទេ? តើព័ត៌មាននោះគ្រប់គ្រាន់អាចបើកការស៊ើបអង្កេតបាន ឬត្រូវស្វែងរកព័ត៌មានបន្ថែមពីប្រភពផ្សេង? ប្រសិនបើរដ្ឋអាជ្ញាមើលទៅឃើញថា អាចមានព័ត៌មានគួរឲ្យទុកចិត្ត និងជាមូលដ្ឋានគ្រប់គ្រាន់ គួរត្រូវបើកធ្វើការស៊ើបអង្កេត រដ្ឋអាជ្ញាបញ្ជូនសំណុំរឿងនេះទៅឲ្យអង្គបុរេជំនុំជម្រះជាអ្នកសម្រេច។ ប្រសិនបើអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចអនុញ្ញាតឲ្យបើកការ ស៊ើបអង្កេត ទើបរដ្ឋអាជ្ញាអាចបើកការស៊ើបអង្កេតបាន។

**៦. ប្រសិនបើជនសង្ស័យ គឺជាមេដឹកនាំកំពុងកាន់អំណាច ហើយមានអភ័យឯកសិទ្ធិជាប្រមុខរដ្ឋ តើតុលាការព្រហ្មទណ្ឌអន្តរជាតិអាចយកមកកាត់ទោសបានដែរ ឬទេ?**

អនុសញ្ញាក្រុងរ៉ូម ត្រង់មាត្រា ២៧ មានចែងច្បាស់ថា អភ័យឯកសិទ្ធិជាប្រមុខរដ្ឋ ឬអភ័យឯកសិទ្ធិណាមួយផ្សេងទៀត ដែលមានចែងក្នុងច្បាប់ផ្ទៃក្នុងរបស់ប្រទេសនីមួយៗ មិនអាចជាឧបសគ្គរាំងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនឲ្យអនុវត្តសមត្ថកិច្ចរបស់ខ្លួនបាននោះទេ។ ដូច្នេះ មានន័យថា ទោះបីជាជនសង្ស័យជាមេដឹកនាំកំពុងកាន់អំណាច ក៏តុលាការអាចនាំខ្លួនយកមកកាត់ទោសបានដែរ។ ក៏ប៉ុន្តែ នេះគ្រាន់តែជាគោលការណ៍ដែលចែងក្នុងច្បាប់ប៉ុណ្ណោះ។ រីឯក្នុងការអនុវត្តជាក់ស្តែងវិញ បើសិនជាប្រទេសណាមួយបដិសេធមិនព្រមប្រគល់ខ្លួនជនសង្ស័យ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចធ្វើបានដែរ ព្រោះតុលាការមិនមានកម្លាំងប៉ូលិសផ្ទាល់ខ្លួន ដើម្បីទៅចាប់ខ្លួនជនសង្ស័យបានទេ គឺរំពឹងតែទៅលើសុឆន្ទៈរបស់រដ្ឋជាសមាជិកប៉ុណ្ណោះ។ ករណីឧក្រិដ្ឋកម្មនៅ Darfour ប្រទេសស៊ូដង់ គឺជាភស្តុតាងស្រាប់។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការចោទប្រកាន់ និងចេញដីកាចាប់ខ្លួនប្រធានាធិបតីស៊ូដង់ តាំងពីឆ្នាំ២០០៩ ក៏ប៉ុន្តែ រហូតមកទល់ពេលនេះ តុលាការនៅតែមិនអាចនាំខ្លួន អូម៉ា អាល់បាស្សៀរ (Omar al-Bashir) មកកាត់ទោសបាន ហើយ អូម៉ា អាល់បាស្សៀរ នៅតែបន្តកាន់តំណែងជាប្រធានាធិបតីស៊ូដង់ដដែល។

**ចប់សូមអរគុណ!**

## ឯកសារយោង

១.គេហទំព័រកាសែតភ្នំពេញប៉ុស្ដិ៍ www.postkhmer.com

២.គេហទំព័រវិទ្យុបារាំងអន្តរជាតិ www.khmer.rfi.fi

បណ្ដាអត្ថបទ និងគេហទំព័រដទៃទៀតដែលខ្ញុំពុំបានរៀបរាប់អស់!

# កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់

***Researching and Understanding on Legal Law Program***

Website: www.lorkremlaw.wordpress.com

Tel: **012855668 / 069255525**